ចាប - ពិន

# អានិសង្ស៣០



សម្រាប់

ជាជំនួយយុវធម្មកថិក

អ្នកទេសនា

និង

នាយកនាយិកាអ្នកធ្វើ

បុណ្យទានផ្សេងៗ

អានិសង្ស ៣០ អានិសង្ស ៣០ អានិសង្ស ៣០

www.elibraryofcambodia.org

# សព្វទានំ ធម្មទានំ ជិនាតិ

## ធម្មទានឈ្នះអស់ទានទាំងពួង

សៀវភៅដែលលោកអ្នកកំពុងអាននេះ កើតឡើងដោយសទ្ធាជ្រះថ្លារបស់ឧបាសក **ចៅ ធឹង** នៅភូមិភ្នំពីរ ឃុំចូវឡាំង ស្រុកស្វាយទង ខេត្តអាងយ៉ាង, បានជាវសៀវភៅអានិសង្ស ៣០ ចំនួន ២៥០ ក្បាល សម្រាប់ជាធម្មទាន ក្នុងវិធីបុណ្យឆ្លងសាលាសំណាក់ នៅថ្ងៃ ១១ កើត ខែចែត្រ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស ២៥៥៧ ។

**ឥទំ នោ ធម្មទានំ មាតា បិតូនំ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ** រីបុណ្យនៃធម្មទាន (ដែលយើងខ្ញុំទាំងឡាយ បានធ្វើហើយក្នុងពេល) នេះ ចូរមានដល់មាតា និងបិតា ព្រមទាំងញាតិទាំងឡាយ (ក្នុងសង្សារវដ្តនេះ) សូមអស់លោកទាំងឡាយនោះ បានដល់នូវសេចក្តីសុខចុះ ។

ទទួលអំណោយពីលោក ខ្មៅ ឃុន តំរង ដល់ការុណាខ្មែរ
ដើម្បីទុកដាក់ក្នុង elibrary of Cambodia
ខុលា ២០១៥

www.elibraryofcambodia.org

# នាមសប្បុរសជនចូលបោះពុម្ពសៀវភៅអានិសង្ស ៣០ ជាតធម្មទាន

១. ឧបាសកចៅ ធឹង (ភូមិភ្នំពីរ) ................................ ១.០០០.០០០ ដុង
២. ភិក្ខុចក្ខុវរត្ថោ ចៅ ហាក់ (វត្តទឹកផុស់) ................................ ៣០០.០០០ ដុង
៣. ឧបាសកចៅ ម៉ុះ (ភូមិជីក្អេង) ................................ ២០០.០០០ ដុង
៤. ឧបាសិកានាង មី (សៀមរៀប) ................................ ២០០.០០០ ដុង
៥. ឧបាសកចៅ ហ៊ីម (ភូមិស្រទឡូង) ................................ ៣០០.០០០ ដុង
៦. ឧបាសិកានាង លីន (ភូមិក្រាំងក្រូច) ................................ ៥០០.០០០ ដុង
៧. លោកចៅ សេត អ្នកស្រីនាង ចាន់ថេន (ភូមិក្រាំងក្រូច) ..... ៥០០.០០០ ដុង
៨. ឧបាសិកានាង ហ៊ីម (ភូមិរលាំង) ................................ ៣០០.០០០ ដុង
៩. ឧបាសកចៅ កែវ ឧបាសិកា នាង ជុន (ភូមិកោះអណ្ដែត) ២០០.០០០ ដុង
១០. លោកចៅ ធីម អ្នកស្រីនាង យុង (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១១. ឧបាសកចៅ ចាន់ ឧបាសិកានាង ញ៉ី (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១២. ឧបាសកចៅ ស៊ុន ឧបាសិកានាង ជ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១៣. លោកចៅ ធី អ្នកស្រីនាង យ៉ីម (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១៤. អ្នកស្រីនាង ធា និងគ្រួសារ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១៥. លោកចៅ ភា អ្នកស្រីនាង ផាំ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១៦. លោកចៅ ជែន អ្នកស្រីនាង ធូ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១៧. លោកចៅ ជឿន និងគ្រួសារ (ភ្នំពេញ) ................................ ១០០.០០០ ដុង
១៨. លោកចៅ ជីន និងគ្រួសារ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
១៩. លោកចៅ ឯក អ្នកស្រីនាង មៅ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
២០. លោកចៅ ប៉ែង អ្នកស្រីនាង ថា-នី (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
២១. កញ្ញានាង ថាយ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
២២. កញ្ញានាង ភីន (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
២៣. យុវជនចៅ សេង (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
២៤. យុវជនចៅ សល់ (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
២៥. យុវជនចៅ សួង (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង
២៦. ចៅ សាន (ភូមិភ្នំពីរ) ................................ ១០០.០០០ ដុង

www.elibraryofcambodia.org

# អានិសង្ស ៣០

រៀបរៀងដោយ

ឧត្តមប្រាជ្ញ ចាប ពិន និពន្ធបណ្ឌិត
អតីតអធិបតីក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ
នៅពុទ្ធសាសនបណ្ឌិត្យ
ក្រសួងធម្មការ

ផ្សាយចេញពី
"បណ្ណាគារត្រៃរតន៍" ផ្ទះលេខ ១៣៦អ៊ី០
វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

បោះពុម្ពលើកទីពីរ

រក្សាសិទ្ធិ

www.elibraryofcambodia.org

# បញ្ជីរឿងអានិសង្ស


រឿង ................................................ ទំព័រ

បើម៉ាដើម ........................................

នមស្សការព្រះរតនត្រ័យ ---------------------------

១- អានិសង្សសាធារណៈ --------------------------- ១

២- អានិសង្សចីវរទាន ----------------------------- ២

*រឿងនាងឧម្មាទន្តី* ------------------------------- ៤

*រឿងព្រះបាទអសោក និងព្រះនាងអសន្ធិមិត្តា* ------------- ៩

៣- អានិសង្សបិណ្ឌបាតទាន -------------------------- ១៤

*រឿងព្រះបាទចណ្ឌបជោត* --------------------------- ១៧

*រឿងសុខសាមណេរ* -------------------------------- ១៨

៤- អានិសង្សសេនាសនទាន --------------------------- ២៤

*រឿងឧត្តិយឧបាសក* ------------------------------- ២៧

៥- អានិសង្សភេសជ្ជទាន ---------------------------- ២៨

*រឿងនាងវិសាខា* --------------------------------- ៣០

៦- អានិសង្សបរិក្ខារ -------------------------------- ៣២

*រឿងនាងវិហារិកប្រេត* ----------------------------- ៣៣

*រឿងព្រាហ្មណ៍ដែលសែនទៅឲ្យខ្មោចកូន* ---------------- ៣៥

៧- អានិសង្សវិហារ ---------------------------- ៣៦

រឿងរាជបុត្តកោសម្ពី ---------------------------- ៣៧

រឿងធម្មិកឧបាសក ---------------------------- ៣៨

៨- អានិសង្សកុដិសាលា ---------------------------- ៤៥

រឿងព្រះបាទអសោករាជ និងព្រះនាងអសន្ធមិត្តា ---------------------------- ៤៧

៩- អានិសង្សបង្គន់ ---------------------------- ៥០

រឿងព្រះពាក្កុលត្ថេរ ---------------------------- ៥១

១០- អានិសង្សពិតានរនាំងវាំងនន ---------------------------- ៥៣

រឿងចុល្លេកសាដកព្រាហ្មណ៍ ---------------------------- ៥៣

១១- អានិសង្សផ្លូវថ្នល់ ---------------------------- ៥៥

រឿងមាឃមាណព ---------------------------- ៥៧

១២- អានិសង្សស្ពាន ---------------------------- ៦១

រឿងសុមេធតាបស ---------------------------- ៦២

១៣- អានិសង្សអណ្តូងស្រះ ---------------------------- ៦៥

រឿងនាងសុចិត្រា ---------------------------- ៦៧

១៤- អានិសង្សពោសជ្រះ ---------------------------- ៦៧

រឿងព្រះនាគសេននិងក្រុងមិលិន្ទ ---------------------------- ៦៨

រឿងសុសិមមាណព ---------------------------- ៧១

១៥- អានិសង្សកឋិន ---------------------------- ៧២

www.elibraryofcambodia.org

រឿងភិក្ខុ ៣០ រូប ---------------------------------- ៧៥

១៦- អានិសង្សផ្កា -------------------------------- ៧៦

រឿងព្រះបុទមត្ថេរ ---------------------------------- ៧៧

រឿងសុមនមាលាការ ---------------------------------- ៧៩

រឿងនាងទេវធីតាផ្កាននោង ---------------------------- ៨០

១៧- អានិសង្សផ្លែ ---------------------------------- ៨១

រឿងព្រះមហាមហាន្ទត្ថេរ ------------------------------ ៨៣

១៨- អានិសង្សសំដែងធម៌ ------------------------------ ៨៦

១៩- អានិសង្សស្តាប់ធម៌ ------------------------------ ៨៩

រឿងព្រះអានន្ទ ------------------------------------ ៩០

រឿងមហាកបិនត្ថេរ ---------------------------------- ៩៣

២០- អានិសង្សប្រេញ ---------------------------------- ៩៤

រឿងកោរបកោណព ---------------------------------- ៩៥

រឿងដរិទាឡាគិរី ---------------------------------- ៩៦

រឿងអរកតសី ------------------------------------ ៩៧

២១- អានិសង្សកាយវិការ ------------------------------ ១០១

រឿងព្រះបាទបណ្តុបជោត ---------------------------- ១០២

រឿងព្រះនាងអសន្ធិមិត្តា ---------------------------- ១០៣

២២- អានិសង្សវចីវិការ ------------------------------ ១០៦

រឿងឃោសកសេដ្ឋី ---------------------------------- ១០៧

*រឿងកុមារសម្មាទិដ្ឋិ* ---------------------------------------- ១១៣

២៣- អានិសង្សមនោវិការ ---------------------------------------- ១១៤

*រឿងមដ្ឋកុណ្ឌលីមាណព* ---------------------------------------- ១១៥

២៤- អានិសង្សសច្ចំ ---------------------------------------- ១១៨

*រឿងមេគោ កូនគោ និងខ្លា* ---------------------------------------- ១២០

២៥- អានិសង្សខន្តី ---------------------------------------- ១២១

*រឿងនាងឧត្តរា* ---------------------------------------- ១២៥

*រឿងទីឃាវុកុមារ* ---------------------------------------- ១២៧

២៦- អានិសង្សកតញ្ញូ ---------------------------------------- ១២៩

*រឿងព្រះសារីបុត្ត* ---------------------------------------- ១៣៤

*រឿងភិក្ខុចិញ្ចឹមមាតា* ---------------------------------------- ១៣៥

*រឿងព្រះសុវណ្ណសាម* ---------------------------------------- ១៣៧

២៧- អានិសង្សសីល ---------------------------------------- ១៤២

*រឿងព្រះនាគសេនថ្វាយព្រះពរក្រុងមិលិន្ទ* ---------------------------------------- ១៤៦

*រឿងនាងសុជាតា* ---------------------------------------- ១៥២

២៨- អានិសង្សការនៅក្នុងទីស្ងាត់ ---------------------------------------- ១៥៤

*រឿងព្រះមេឃិយត្ថេរ* ---------------------------------------- ១៦១

២៩- អានិសង្សខ្មោច ---------------------------------------- ១៦៣

*រឿងព្រះចូឡបន្ថកត្ថេរ* ---------------------------------------- ១៦៦

៣០- អានិសង្សបង្សុកូល ---------------------------------------- ១៦៩

*រឿងនាងបុណ្ណទាសី* ---------------------------------------- ១៧១

## នមស្សការព្រះរតនត្រ័យ

### នមត្ថុ រតនត្តយស្ស

ខ្ញុំព្រះករុណា សូមបង្អោនកាយវាចាចិត្ត ថ្វាយបង្គំចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយគោរព ។

ហើយសូមពណ៌នាអំពីអានិសង្សសាមសិបយ៉ាងឱ្យមានសេចក្ដីពិស្ដារ ដោយមានរឿងនិទានប្រកបុជាសំអាងផង ដូចខាងមុខ :

# លំនាំដើម

សេចក្ដីសប្បាយរបស់បុព្ជិតពុទ្ធសាសនា មាន ៤ យ៉ាង គឺ :

១- **អាហារសប្បាយ** សប្បាយដោយអាហារគ្រឿងបរិភោគ.

២- **សេនាសនសប្បាយ** សប្បាយដោយសេនាសនៈទីលំនៅ.

៣- **បុគ្គលសប្បាយ** សប្បាយដោយបុគ្គលព្រមព្រៀងគ្នា

៤- **ធម្មសប្បាយ** សប្បាយដោយការប្រព្រឹត្តធម៌ត្រូវគ្នា ។

សេចក្ដីសប្បាយ ៤ យ៉ាងនេះ កើតមកពីភិក្ខុសាមណេរក្នុងវត្តនីមួយៗ បានសិក្សានូវអត្ថបទស្ដីពីផលានិសង្សនៃបុញ្ញកម្មផ្សេងៗ ចេះស្ទាត់ជំនាញ ហើយសំដែងពន្យល់ឧបាសកជើងវត្តរបស់ខ្លួន ឱ្យកើតសទ្ធាជ្រះថ្លាក្នុងការធ្វើបុណ្យទាន មានប្រគេនបច្ច័យ ៤ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ ចំពោះព្រះសង្ឃជាដើម ។

អត្ថបទដែលសំដែងរឿងផលានិសង្សនៃបុញ្ញកម្មផ្សេងៗ នោះ ព្រះគន្ថរចនាចារ្យរៀបរៀងទុកក្នុងគម្ពីរនានាជាភាសាបាលី អ្នកត្រូវការចេះដឹងរឿងអានិសង្សនានា មិនងាយរកមើលបាន ដោយនៅរាត់រាយពីគ្នា ។

ព្រោះហេតុនេះ ទើបខ្ញុំប្រមូលអត្ថបទទាំងនោះអំពីគម្ពីរនានា មករៀបរៀងឱ្យមូលគ្នាជាសៀវភៅមួយនេះ បោះពុម្ពឡើងសម្រាប់យុវធម្មកថិកអ្នកទេសនា ជ្រើសយកទៅសំដែងពន្យល់ពុទ្ធបរិស័ទឱ្យជ្រះថ្លា ហើយគេនឹងស្ថាបនាសេចក្ដីសប្បាយទាំង៤យ៉ាង ដូចពោលខាងដើមនោះឱ្យកើតមានដល់វត្តអារាមក្នុងពុទ្ធសាសនមណ្ឌលនាំឱ្យពុទ្ធសាសនារុងរឿង ជាអភិវឌ្ឍភាព ដើម្បីញុំាងប្រទេសកម្ពុជា ជាប្រទេសនិយមព្រះពុទ្ធសាសនា ឱ្យបានសុខសម្ពិភាពជានិរន្តរតទៅ ។

មករា ២៥១៣ / ១៩៦៩

ចាប-ពិន

www.elibraryofcambodia.org

# អានិសង្សសាមសិបយ៉ាង

## គឺ

### ១- អានិសង្សសាធារណៈ

ធម្មតាមនុស្សក្នុងលោក តែងស្រឡាញ់អាយុជីវិតរបស់ខ្លួនជាទីបំផុតចង់ឱ្យរស់នៅបានយូរ បានសុខចម្រើនតែរៀង១ខ្លួន ។ ការញ៉ាំងអាយុជីវិតឱ្យរស់នៅបានយូរ បានសុខចម្រើ នោះ មានសេចក្តីលំបាកច្រើនបែប ច្រើនយ៉ាងណាស់ គឺលំបាកដោយកិច្ចការពារសេចក្តីអន្តរាយកិច្ចការពារជម្ងឺដម្កាត់ កិច្ចស្វែងរកបច្ច័យគ្រឿងអាស្រ័យ កិច្ចស្វែងរកគ្រឿងឧបករណ៍សំរាប់ប្រើប្រាស់ ប្រាក់កាសសំរាប់ចាយវាយជាដើមដែលជាការចាំបាច់ ខានពុំបាន ។

ពោលដោយសារុប ក្នុងមនុស្សម្នាក់១ លុះតែប្រកបដោយឋានៈ ៥ យ៉ាងគ្រប់គ្រាន់ ទើបសមតាមបំណង គឺ:

១- អាយុ សេចក្តីរស់នៅ.

២- វណ្ណៈ សរីរវណ្ណល្អស្រស់.

៣- សុខៈ សេចក្តីសុខកាយស្រួលចិត្ត.

៤- ពលៈ កម្លាំងកាយកម្លាំងចិត្ត.

៥- បដិភាណៈ សេចក្តីឈ្លាសវៃ ។

www.elibraryofcambodia.org

# អានិសង្សសាមសិបយ៉ាង

## គឺ៖

### ១_ អានិសង្សសាធារណៈ

ធម្មតាមនុស្សក្នុងលោក តែងស្រឡាញ់អាយុជីវិតរបស់ខ្លួនជាទីបំផុតចង់ឱ្យរស់នៅបានយូរ បានសុខចម្រើនតែរៀង១ខ្លួន ។ ការញ៉ាំងអាយុជីវិតឱ្យរស់នៅបានយូរ បានសុខចម្រើ នោះ មានសេចក្ដីលំបាកច្រើនបែប ច្រើនយ៉ាងណាស់ គឺលំបាកដោយកិច្ចការពារសេចក្ដីរន្ធភាយ កិច្ចការពារជម្ងឺដម្កាត់ កិច្ចស្វែងរកបច្ច័យគ្រឿងអាស្រ័យ កិច្ចស្វែងរកគ្រឿងឧបករណ៍សំរាប់ប្រើប្រាស់ ប្រាក់កាសសំរាប់ចាយវាយជាដើម ដែលជាការចាំបាច់ ខានពុំបាន ។

ពោលដោយសារុប ក្នុងមនុស្សម្នាក់១ លុះតែប្រកបដោយឋានៈ ៥ យ៉ាងគ្រប់គ្រាន់ ទើបសមតាមបំណង គឺ:

១_ អាយុ សេចក្ដីរស់នៅ.

២_ វណ្ណៈ សរីរវណ្ណល្អស្រស់.

៣_ សុខៈ សេចក្ដីសុខកាយស្រួលចិត្ត.

៤_ ពលៈ កម្លាំងកាយកម្លាំងចិត្ត.

៥_ បដិភាណៈ សេចក្ដីឈ្លាសវៃ ។

www.elibraryofcambodia.org

ឋានៈ ៥ យ៉ាងនោះ និងឋិតនៅបាន ក៏ដោយសារបច្ច័យគ្រឿង
អាស្រ័យ ៤ យ៉ាងគឺ :

១- ចីវរប្បច្ច័យ គ្រឿងស្លៀកដណ្តប់.

២- បិណ្ឌបាតប្បច្ច័យ គ្រឿងបរិភោគ.

៣- សេនាសនប្បច្ច័យ គ្រឿងដេកអង្គុយ.

៤- គិលានភេសជ្ជប្បច្ច័យ គ្រឿងកែរោគ ។

ដែលសុទ្ធតែជាគ្រឿងរកបានដោយលំបាក ។

ព្រោះហេតុនេះ បានជាការដែលទាយកចិត្តសប្បុរសបានឱ្យបច្ច័យ ៤ ឬបច្ច័យណាមួយ ដោយសង្គ្រោះ ឬដោយបូជាគុណដល់បដិគ្គាហកៈដែលចាត់ជាការបំពេញសេចក្តីខ្វះខាត សេចក្តីត្រូវការរបស់អ្នកត្រូវការនោះ ជាទានមានផលានិសង្សច្រើនជាអនេក ។

អានិសង្សនោះ បើពោលដោយពិស្តារក៏ពិស្តារណាស់ តែបើពោលដោយសង្ខេប ក៏មានសេចក្តីខ្លី ល្មមរវានល្មមស្តាប់ឆាប់យល់បាន ដូចពុទ្ធភាសិត ១ បទថា:

"អ្នកដែលបានឱ្យបច្ច័យគ្រឿងអាស្រ័យ ៤ យ៉ាង គឺ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ ដល់ជនដែលគួរឱ្យ រមែងបានឈ្មោះថាជាអ្នកឱ្យឋានៈ ៥ យ៉ាងគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ ដល់អ្នកទទួលក្នុងពេលដែលគេទទួលនាបច្ចុប្បន្ន ហើយឋានៈ ៥ យ៉ាងនោះ រមែងផ្តល់

www.elibraryofcambodia.org

ដល់អ្នកឱ្យវិញក្នុងកាលជាអនាគត ។

គឺថា បដិគ្គាហកៈ ដែលបានទទួលបច្ច័យ ៤ គឺចីវរ (គ្រឿងស្លៀកដណ្តប់) បិណ្ឌបាតៈ(គ្រឿងបរិភោគ) សេនាសនៈ(គ្រឿងដេកអង្គុយ) និងគិលានភេសជ្ជៈ (គ្រឿងថ្នាំកែរោគ) ឬបច្ច័យណាមួយ អំពីទាយកហើយរមែងត្រូវបានឋានៈ៥ យ៉ាងនេះ គឺអាយុ (សេចក្តីរស់នៅ) វណ្ណៈ (សម្បុរល្អ ស្រស់) សុខៈ (សេចក្តីសុខកាយស្រួលចិត្ត) ពលៈ (កម្លាំងកាយកម្លាំងចិត្ត) បដិភាណៈ(សេចក្តីឈ្លាសវៃ) ទទួលវេលាទទួលក្នុងជាតិជាបច្ចុប្បន្ន ។

ឯទាយកត្រូវបានវិញ នូវឋានៈ ៥ យ៉ាង គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈនោះ ជារបស់មនុស្សក្នុងមនុស្សលោក ឬជារបស់ទិព្វក្នុងទេវលោក ក្នុងជាតិជាអនាគតជាពិតប្រាកដពុំខាន ដែលហៅថាបានផលានិសង្សនោះឯង ដូចមានសំដែងពិស្តារ ក្នុងអានិសង្សផ្សេងៗ ខាងមុខ

## ២-អានិសង្សចីវរទាន

គ្រឿងស្លៀកពាក់គ្រប់បែប ដែលដេរភ្ជាប់ដោយម្ជុល តាមព្យញ្ជនៈ[១] ក្នុងភាសាបាលីហៅថា ចីវរ ។ ពាក្យថា ចីវរ ស្តាប់ទៅដូចជាបានតែខាងស្បង់ចីវរជាបរិក្ខាររបស់បព្វជិតមួយមុខប៉ុណ្ណោះ ប៉ុន្តែតាមអត្ថ[២] ដែលសំដែងពីចីវរបច្ច័យនោះ លោកថា សូម្បីតែគ្រឿងស្លៀកពាក់ របស់គ្រហស្ថទូទៅដែលជារបស់ដេរភ្ជាប់ដោយម្ជុលដូចគ្នា ក៏រាប់ចូលក្នុងចីវរបច្ច័យដែរ ។

១- តួអក្សរ ។ ២- សេចក្តី ។

ធម្មតាមនុស្សក្នុងសកលលោក ទោះជាគ្រហស្ថក្តី បព្វជិតក្តី សុទ្ធតែត្រូវអាស្រ័យដោយជីវរប្បច្ច័យដូចគ្នា បើគ្មានជីវរប្បច្ច័យជាគ្រឿងអាស្រ័យទេ មិនអាចរស់នៅជាសុខបាន ព្រោះមានសេចក្តីអន្តរាយច្រើនចំពូកណាស់ មានក្តៅត្រជាក់ជាដើម ទោះបីរស់នៅបានក៏បានដោយវេទនា ដូចមនុស្សព្រៃនិងស្វាដែលគ្មានសំពត់អាវស្លៀកពាក់ វាការពារក្តៅត្រជាក់ដោយសារតែរោមប៉ុណ្ណោះ ទើបវាមានសាច់គគ្រាតគគ្រើមសម្បុរអាក្រក់ ដោយគ្មានគ្រឿងការពារអាកាសក្តៅត្រជាក់ ។

ព្រោះហេតុជីវរប្បច្ច័យ ជាគ្រឿងការពារក្តៅត្រជាក់របស់មនុស្ស ឱ្យមនុស្សបានរស់នៅជាសុខស្រួល ដូចពោលមកនេះ បានជាទានដែលទាយកបានឱ្យជីវរប្បច្ច័យ គឺឱ្យសំពត់អាវដល់បដិគ្គាហកៈជាគ្រហស្ថដោយសង្គ្រោះ ឬបានជូនសំពត់អាវដល់មាតាបិតាដោយបូជាគុណលោក ឬ បានប្រគេនត្រៃដល់បដិគ្គាហកៈ ជាបព្វជិត ដោយបូជាគុណធម៌របស់លោកនោះ ជាទានមានផលានិសង្សច្រើនទាំងបច្ចុប្បន្នទាំងអនាគត គឺអាចឱ្យបដិគ្គាហកៈ (អ្នកទទួលទាន) បានសម្បុរល្អ សម្បូរគ្រឿងស្លៀកពាក់ក្នុងកាលជាអនាគត ។

គម្ពីរសំយុត្តនិកាយ ទ្រង់ទេវតាសំយុត្ត ថែងថា កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានទេវតាចូលទូលសួរព្រះអង្គថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថាឱ្យពពោះសម្បុរ ?

www.elibraryofcambodia.org

ព្រះអង្គត្រាស់ថា វត្ថទោ ហោតិ វណ្ណទោ ការឱ្យសំពត់ជាទានបានឈ្មោះថា ឱ្យពណ៌សម្បុរជាទាន គឺបានឈ្មោះថាឱ្យវណ្ណទាន ដល់អ្នកទទួលទានក្នុងជាតិបច្ចុប្បន្ន ហើយអ្នកម្ចាស់ទាននោះតែងបានជាអ្នកមានសម្បុរល្អ សម្បូណ៌គ្រឿងស្លៀកពាក់ និងទ្រព្យសម្បត្តិ ក្នុងជាតិជាអនាគត ។

## រឿងនាងខ្ទុម្ពរានន្ទី

ក្នុងកាលដ៏កន្លងទៅហើយ មាននាងកញ្ញាម្នាក់ ជាកូនអ្នកទ័លក្រនៅនគរពារាណសី ។ ថ្ងៃមួយនៅរដូវចូលឆ្នាំ នាងបានឃើញពួកកញ្ញាកូនអ្នកមាន គេស្លៀកពាក់សំពត់ពណ៌ក្រហមល្អៗ ដើរលេងកំសាន្តតាមប្រពៃណីស្រុក ។ នាងចង់ល្អដូចគេបានសុំលាមាតាបិតាទៅរកស៊ីឈ្នួលគេ នៅភូមិមួយដើម្បីយកសំពត់ពណ៌ក្រហម ១ ត្បូង(១) ។

នាងទៅរកស៊ីឈ្នួលនៅផ្ទះគហបតីម្នាក់ គេថា លុះតែធ្វើការឱ្យគេគ្រប់ ៣ ឆ្នាំ ទើបគេឱ្យសំពត់ពណ៌ក្រហម ១ ត្បូង ។ នាងកញ្ញានោះក៏សុខចិត្តស៊ីឈ្នួលគេតាមកាលបរិច្ឆេទនោះ តែដោយនាងយកចិត្តទុកដាក់ធ្វើការឱ្យគេល្អពេញចិត្តគេ នាងធ្វើការត្រឹមតែមួយឆ្នាំក៏គេឱ្យសំពត់ក្រហម ១ ត្បូងព្រមទាំងសំពត់ដទៃខ្លះផង ហើយនាងក៏ត្រឡប់មកផ្ទះវិញ ដល់ពាក់កណ្ដាលផ្លូវនាងឃើញព្រះអរហន្តមួយអង្គ ជាសាវ័កនៃព្រះពុទ្ធកស្សប

១- ពាក្យថា ១ ត្បូង គឺ ២ អាវ ស្លៀកផង ដណ្ដប់បានផង ។

www.elibraryofcambodia.org

ដែលចោរដណ្ដើមយកស្បង់ចីពរអស់ លោកខ្ចាស់ស្លឹកឈើស្លៀកដណ្ដប់ និមន្តដើរមកជិតនាង ។ នាងអាណិតលោកបានប្រគេនសំពត់ ១ អាវដល់លោក ។ កាលលោកយកទៅស្លៀកហើយនាងឃើញពណ៌ល្អ ក៏ប្រគេន ១ អាវឱ្យលោកដណ្ដប់ហើយនាងឃើញលោកមានរស្មីល្អ ដូចព្រះអាទិត្យ ទើបរះក៏ធ្វើសេចក្ដីប្រាថ្នាថា ដោយអំណាចផលវត្ថុទាននេះ នាងខ្ញុំទៅកើតជាតិខាងមុខ សូមឱ្យមានរូបល្អអស្ចារ្យ បុរសណាបានឃើញឱ្យភ័ន្តស្មារតីកុំឱ្យទប់ចិត្តបាន ។ ព្រះថេរៈធ្វើអនុមោទនាហើយនិមន្តចៀសចេញទៅ ។

ដោយផលានិសង្សនោះ លុះនាងអស់អាយុទៅ បានទៅកើតជាទេពធីតាក្នុងទេវលោក អស់អាយុពីទេវលោក បានមកកើតជាកូនសេដ្ឋីអ្នកមានទ្រព្យ ៨០ កោដិ ឈ្មោះតិរីដវច្ឆសេដ្ឋី នៅអរិដ្ឋបុរៈក្នុងសីវរដ្ឋ នាងមានរូបល្អណាស់ អ្នកស្រុកហៅថាស្រីកែវ ។ លុះនាងពេញរូបរាងឡើង ជនណាបានឃើញក៏ភ័ន្តស្មារតីរកគិតអ្វីមិនឃើញ ហាក់ដូចឆ្កួត ។ ហេតុនេះ បានអ្នកស្រុកហៅថា នាងឧម្មាទន្តី ( ស្រីឱ្យគេឆ្កួត) ។

សេដ្ឋីជាបិតាបានថ្វាយដំណឹងដំកេះព្រះរាជា ។ ទ្រង់ព្រះសណ្ដាប់ក៏ទ្រង់សព្វព្រះរាជហឫទ័យ ទ្រង់ចាត់ឱ្យពួកព្រាហ្មណ៍ទៅពិនិត្យលក្ខណៈ បើឃើញល្អត្រឹមត្រូវមែន ទ្រង់នឹងឱ្យដណ្ដឹងយកធ្វើជាព្រះទេពី ។

លុះព្រាហ្មណ៍ទាំងនោះដល់ផ្ទះនាង សេដ្ឋីជាបិតាបានរៀបភោជ-នាហារឱ្យបរិភោគ ។ ពេលពួកព្រាហ្មណ៍កំពុងបរិភោគ សេដ្ឋីឱ្យនាងជាកូន-

www.elibraryofcambodia.org

តែងខ្លួនចេញមកបង្ហាញខ្លួនឱ្យព្រាហ្មណ៍ពិនិត្យមើល ។ លំអរបស់នាងនោះចោលស្រមោលសម្ផស្សទៅប៉ះនឹងចក្ខុរបស់ពួកព្រាហ្មណ៍ ធ្វើឱ្យពួកព្រាហ្មណ៍ទាំងនោះភាន់ស្មារតី ដោយកិលេសគ្របសង្កត់ ព្រាហ្មណ៍ខ្លះដាក់ះបាយលើក្បាល ខ្លះញាត់ទៅក្នុងត្រចៀក ខ្លះទះជញ្ជាំង ដូចមនុស្សឆ្កួត ។

នាងឧម្មាទន្តីឃើញអាការដូច្នោះ ក៏បណ្ដេញព្រាហ្មណ៍ទាំងនោះឱ្យចេញទៅ ។

ដោយខ្មាស់គេខ្លាំងពេក ព្រាហ្មណ៍ទាំងនោះ ទៅទូលព្រះរាជាថានាងនោះជាស្រីកាឡកណ្ណីឆ្កួត មិនល្អទេ ។ ព្រះរាជាក៏ឈប់ត្រូវការ ។

ក្រោយពីនោះមកមិនយូរប៉ុន្មាន នាងបានជាភរិយារបស់អភិ-បារកៈអាមាត្យ ជាមនុស្សសំណប់ព្រះរាជា ។

ថ្ងៃមួយជាថ្ងៃនក្ខត្តឫក្ស ព្រះរាជាទ្រង់គង់ព្រះរាជយានដើរប្រទក្សិណព្រះនគរ ។ នាងឧម្មាទន្តីឈរនៅបង្អួចផ្ទះមើលក្បួនហែព្រះរាជា ។ ព្រះរាជាទតឃើញនាង ទ្រង់ជ្រាបថា នាងហ្នឹងហើយជាស្រីកែវ ដែលទ្រង់ឱ្យព្រា-ហ្មណ៍ទៅពិនិត្យនោះ ក៏ទ្រង់ព្រះវិតក្កជាខ្លាំងផ្ទុំមិនលក់សោយមិនបាន ស្គមព្រះអង្គព្រោះចង់បាននាងជាព្រះទេពី នាងបានជាភរិយាមហាអមាត្យទៅហើយក៏ទ្រង់លាក់ សេចក្ដីស្នេហានោះទុកក្នុងព្រះទ័យ ពុំឱ្យនរណាដឹងឡើយ ។

មហាអាមាត្យដឹងរឿងនោះ ក៏ចាត់មនុស្សម្នាក់ឱ្យទៅជ្រកសម្ងំក្នុងព្រៃក្រោយខ្នងទេព្រក្សមួយ ហើយខ្លួនមហាអាមាត្យធ្វើជាទៅបន់

ទេព្រក្សនោះ សួរពីរឿងព្រះអាការរោគរបស់ព្រះរាជា ។ មហាអមាត្យទៅដល់ខ្ទមទេព្រក្សសួរថា

"លោកតា ព្រះរាជាទ្រង់ប្រឈួនដោយព្រះអាការរោគអ្វីបានជាទ្រង់ជុំពុំលក់ សោយពុំបាន" ? ។

អ្នកដែលនៅក្រោយទេព្រក្សឆ្លើយថា "ព្រះរាជាទ្រង់ព្រះឈួនព្រោះរោគស្នេហា ដោយស្រឡាញ់នាងស្រីកែវ ជាភរិយារបស់លោកហ្នឹងឯង" ។

មហាអមាត្យទូលព្រះរាជាតាមដំណើរនោះ ។ ព្រះរាជាទ្រង់ពិចារណាថា "ឱសេចក្តីស្នេហារបស់អញ១ លាក់ទុកតែក្នុងចិត្តមិនឱ្យនរណាដឹងទេ ម្តេចក៏ទេព្រក្សដឹងនូវលាមកភាពរបស់អញបាន" ហើយទ្រង់កាត់សេចក្តីស្នេហានេះ ចោលចេញទៅ ។

ឯនាងឧម្មាទន្តី ដែលមានរូបល្អត្រកូលខ្ពស់ បានជាភរិយាមហាអមាត្យមានទ្រព្យសម្បត្តិច្រើន ដោយផលវត្ថទានជាវណ្ណទានដែលនាងបានប្រគេនសំពត់ជាចីវរ ដល់ព្រះអរហន្តពីជាតិមុននោះឯង ។

ការឱ្យវត្ថទាននេះ កុំថាឡើយដល់ឱ្យសំពត់ធ្វើចីវរធំដុំ សូម្បីតែឱ្យសំពត់បិទបូស បិតដំបៅជាបរិក្ខារតូចតាចដែលរាប់បូលក្នុងចីវរប្បច្ច័យដែរនោះ ក៏បានផលានិសង្សច្រើនណាស់ ព្រោះថាសំពត់បិទបូសបាំងដំបៅនោះឈ្មោះថាវត្ថទានផង គិលានទានផង ដូចរឿងនិទានតទៅនេះ :

## រឿងព្រះបាទអសោក និងព្រះនាងអសន្ធិមិត្តា

មុនពុទ្ធកាលនៃព្រះសក្យមុនីគោតមបរមគ្រូរបស់យើងនេះ មាន ព្រះបច្ចេកពុទ្ធច្រើនព្រះអង្គគង់នៅភ្នំគន្ធមាទន៍ ។ ក្នុងក្រុំព្រះបច្ចេកពុទ្ធ ទាំងនោះ មាន ១ ព្រះអង្គកើតជំងឺ ហើយព្រះបច្ចេកពុទ្ធ ១ ព្រះអង្គ និមន្តទៅស្វែងរកទឹកឃ្មុំមកលាយថ្នាំព្យាបាល ។ ព្រះបច្ចេកពុទ្ធអង្គនោះ ហោះទៅចុះត្រង់មាត់កំពង់ទឹក ១ ឃើញនាងកុម្ភទាសីម្នាក់ចុះមកដងទឹក បានសួរថា នៅទីនេះ មានឯណាមានទឹកឃ្មុំ អាត្មាអឹងសុំគេយកទៅលាយ ថ្នាំព្យាបាលជំងឺព្រះបច្ចេកពុទ្ធ ១ អង្គនៅឯភ្នំគន្ធមាទន៍ឯណោះ ។

នាងកុម្ភទាសីនោះ បានលើកដៃចង្អុលបង្ហាញថា "ផ្ទះពុំ ផ្ទះ មធុពាណិជ្ជអ្នកលក់ទឹកឃ្មុំ សូមនិមន្តទៅសុំគេចុះ ទោះបានក្តី មិនបានក្តី សូមនិមន្តមកប្រាប់ខ្ញុំព្រះករុណាផង" ។

កាលព្រះបច្ចេកពុទ្ធនិមន្តទៅដល់ផ្ទះមធុពាណិជ្ជសុំបិណ្ឌបាតគេៗ ជ្រះថ្លាបានយកទឹកឃ្មុំមកដាក់បាត្រហើយ ឃើញទឹកឃ្មុំហៀរហូរចេញពី មាត់បាត្រ ចុះទៅក្រោមដោកដីមានក្លិនផ្សាយទៅលើអាកាស ក៏សូម ប្រាថ្នាថា "ដោយផលទឹកឃ្មុំច្រើនហៀរហូរទៅក្រោមដោកដី ទៅលើកចុំ ក្លិនពេញអាកាសនេះ ក្នុងជាតិខាងមុខ សូមឱ្យខ្ញុំបានជាស្តេចចក្រ មាន អំណាចធំផ្សាយទៅក្នុងដី ១ យោជន៍ លើអាកាស ១ យោជន៍" ។

ព្រះបច្ចេកពុទ្ធធ្វើអនុមោទនាហើយ ក៏និមន្តត្រឡប់មកប្រាប់នាង

www.elibraryofcambodia.org

កុម្ភទាសីវិញ ។ នាងកុម្ភទាសីសួរថា "កាលមធុពាណិជ្ជប្រគេនទឹកឃ្មុំនោះ គេប្រាថ្នាថាម្ដេចខ្លះ?" ។ ព្រះបច្ចេកពុទ្ធប្រាប់ថា "គេប្រាថ្នា ឱ្យបានជាស្ដេចចក្រ មានអំណាចទៅក្នុងដី ១ យោជន៍ លើអាកាស ១ យោជន៍" ។ នាងនោះនិមន្តលោកឱ្យរង់ចាំខ្លួន ទៅយកសំពត់សាដកថ្មីមកប្រគេនលោក ដើម្បីឱ្យលោកយកទៅរុំដំបៅ ហើយនាងសុំប្រាថ្នាថា "ខ្ញុំសូមឱ្យបានជាទេពីមធុពាណិជ្ជ នៅពេលដែលគេបានជាស្ដេចចក្រនោះ" ។

ដោយអំណាចផលានិសង្សនៃមធុទាន និងវត្ថទាននោះ អ្នកទាំងពីរក៏បានដូចសេចក្ដីប្រាថ្នា គឺ

-មធុពាណិជ្ជ ក្នុងជាតិខាងមុខ បានជាព្រះបាទធម្មាសោក នៅនគរបាតលីបុត្រមជ្ឈិមប្រទេស (ឥណ្ឌា) ក្រោយវេលាពុទ្ធនិព្វានប្រមាណ ២០០ ឆ្នាំ ជាស្ដេចចុល្លចក្រក្នុងជម្ពូទ្វីប មានអំណាចធំផ្សាយទៅក្នុងផែនដី និងលើអាកាស ១ យោជន៍ៗមែន. ពួកនាគនៅក្នុងសមុទ្រនិងពួកទេវតានៅលើអាកាស បាននាំបណ្ណាការផ្សេងៗ មកថ្វាយព្រះអង្គ ទ្រង់ជាអគ្គពុទ្ធសាសនូបត្ថម្ភក៏ ។ល។

-នាងកុម្ភទាសីបានជាព្រះនាងអសន្ធិមិត្តា ព្រះទេពីព្រះបាទធម្មាសោក ។ ដោយអំណាចផល កាលដែលនាងបានលើកដៃចង្អុលបង្ហាញផ្លូវព្រះបច្ចេកពុទ្ធទៅរកទឹកឃ្មុំនោះ ព្រះនាងមានរូបឆោមល្អណាស់ បាងព្រះហស្តស្រលូត ឥតសន្លាក់ឡើយ ។ ដោយហេតុព្រះនាងមានព្រះហស្ត

www.elibraryofcambodia.org

ស្រលូតឥតសន្លាក់នោះឯង បានជាមានព្រះនាមថា ព្រះនាងអសន្ធិមិត្តា ។

រឿងនេះ មានសេចក្ដីពិស្ដារពិរោះពិសារណាស់ តែសូមពណ៌នាសង្ខេប ដូចតទៅនេះ :

កាលដែលព្រះបាទអសោកមហារាជ បានសោយរាជ្យ ហើយពុំទាន់លើកនាងស្នំណាមួយ ឱ្យជាព្រះអគ្គមហេសីពេញទីនៅឡើយ ថ្ងៃមួយព្រះនាងអសន្ធិមិត្តា ទតតាមព្រះសីហបញ្ជរ(១) ទៅ ឃើញទេវតាយកអំពៅ១ដើមពីព្រៃហេមពាន្តមកថ្វាយ ។ ព្រះនាងកំពុងតែសោយអំពៅនោះ ព្រះបាទចក្រពត្រាសោក ស្ដេចមកទូលនៅក្នុងបន្ទប់នាង ទ្រង់ទតឃើញព្រះនាងសោយអំពៅទ្រង់សួរថា "ម្ដេចក៏នាងសោយអំពៅបានសាច់រាងដូច្នេះ?" ។ ព្រះនាងក្រាបទូលថា "ខ្ញុំម្ចាស់ទទួលព្រះរាជទានល មើលព្រោះអំពៅនេះ កើតដោយបុណ្យរបស់ខ្ញុំម្ចាស់" ។ ព្រះរាជាឮថាអំពៅកើតឡើងដោយបុណ្យព្រះនាង ក៏ទ្រង់ពិរោធខ្លាំងណាស់ត្រាស់ថា "បើដូច្នេះព្រឹកស្អែកឡើង យើងនឹងនិមន្តព្រះសង្ឃ ៥០០ អង្គមកឆាន់ក្នុងព្រះរាជវាំង ហើយយើងនឹងប្រគេនចីវរ១ត្រៃៗ មួយអង្គ តែឱ្យនាងឯងរកចីវរដែលកើតអំពីបុណ្យខ្លួនប្រគេនលោក មិនឱ្យយកព្រះរាជទ្រព្យក្នុងឃ្លាំងមកចំណាយធ្វើចីវរនោះទេ បើរកមិនបានគ្រប់៥០០ត្រៃ សម្រាប់ប្រគេនលោក ១ ត្រៃ ១ អង្គ ក្នុងថ្ងៃស្អែកនេះ យើងនឹងសម្លាប់នាងឯងពុំខាន ។

---

១. បង្អួច ។

កាលបានទ្រង់ព្រះសណ្ដាប់ដូច្នោះ យប់នោះព្រះនាងផ្ទុំពុំលក់សោះ ទ្រង់គង់នៅមាត់ព្រះសីហបញ្ជរ សម្បុងសង្រួងរកព្រេងវាសនា ពីបុព្វជាតិ ។

គ្រានោះ ដោយអំណាចផលវត្តទាន ដែលព្រះនាងបានថ្វាយសំពត់សាដក ដល់ព្រះបច្ចេកពុទ្ធ ដើម្បីឱ្យលោកយកទៅរុំដំបៅ ពីជាតិមុននោះ ក៏ក្ដៅដល់អាសនាព្រះឥន្ទ្រ បានឱ្យទេវបុត្រ ១ អង្គ យកប្រអប់ទិព្វតូច ១ ពេញដោយត្រៃចីវរមកថ្វាយព្រះនាង ហើយទេវបុត្រនោះ បើកមាត់ប្រអប់បន្តិចឡើង ហូតយកជាយចីវរបន្តិចបង្ហាញព្រះនាង ថា "នេះជាប្រអប់ដាក់ត្រៃចីវរ ដែលកើតពីផលវត្តទានរបស់ព្រះនាង កាលដែលនៅជានាងកុម្ភទាសី បានថ្វាយសំពត់សាកដដល់ព្រះបច្ចេកពុទ្ធ ឱ្យលោកយកទៅរុំដំបៅនោះ សូមព្រះនាងហូតយកចីវរ ១ ត្រៃម្ដងៗ ប្រគេនព្រះសង្ឃ ១ អង្គ ១ ត្រៃ គ្រប់ ៥០០ អង្គចុះ. ហើយបើទ្រង់ចង់ហូតយកក្រៅពីនេះទៀត ក៏បានតាមព្រះទ័យ" ។

ព្រះនាងទទួលយកប្រអប់នោះ ដោយសេចក្ដីរីករាយ ឥតឧបមា ។

ព្រឹកស្អែកឡើង ព្រះរាជាទ្រង់ព្រះរាជបញ្ជាឱ្យសេវកាមាត្យ រៀបចំនិមន្តព្រះសង្ឃ ៥០០ អង្គមកឆាន់ ។ កាលព្រះសង្ឃឆាន់ហើយ ទ្រង់ហៅព្រះនាងអសទ្ធិមិត្តា ឱ្យយកត្រៃចីវរមកប្រគេនលោក ។ ព្រះនាងក៏កាន់ប្រអប់ទិព្វនោះ ហូតយកចីវរ ១ ត្រៃៗ ថ្វាយព្រះរាជាៗ ទ្រង់ប្រគេនព្រះសង្ឃ ១ អង្គ ១ ត្រៃៗ គ្រប់ ៥០០ អង្គ ។

www.elibraryofcambodia.org

ហើយព្រះនាងហូតយកសំពត់ ១ អាវ១ ថ្វាយព្រះរាជវង្សានុវង្ស គ្រប់អង្គ និងមន្ត្រីគ្រប់រូប ដែលមកក្នុងមហាសន្និបាតនោះ ថែមទៀត ។

ព្រះមហាក្សត្រ ទ្រង់ឃើញនូវអព្ភូតហេតុដ៏អស្ចារ្យដូច្នោះ លំដាប់នោះ ទ្រង់លើព្រះនាងអសន្និមិត្តា ជាព្រះអគ្គមហេសីពេញទី ។

ថ្ងៃ ក្រោយ ទ្រង់ជ្រាបថា នាងស្នំឯទៀតប្រណែនខ្លាំង ក៏ទ្រង់ព្រះបញ្ជាឱ្យនាយពិសេសធ្វើនំបំពូនស្ករ (នំផ្លែអាយ) គ្រប់តាមចំនួននាងស្នំដែលមានប៉ុន្មាន ទ្រង់ដាក់នំនោះក្នុងភាជន៍ធំរួចឱ្យបង្កប់ព្រះទម្រង់ដ៏មានតម្លៃ ជាឈ្នួលក្នុងនំ ១ ដាក់លើគេបង្អស់ មិនឱ្យនាងណាដឹងឡើយ ហើយឱ្យនាងស្នំទាំងអស់ចូលចាប់យកនំមួយ១ ម្នាក់ ផ្សងតាមវាសនារបស់ខ្លួន។ ទ្រង់ឱ្យនាងស្នំឯទៀតចាប់មុន នៅសល់តែនំមួយ ទើបទ្រង់ឱ្យព្រះនាងអសន្និមិត្តាចូលចាប់ក្រោយគេបំផុត ហើយទ្រង់ឱ្យនាងស្នំទាំងអស់ចាប់បើកនំដំណាលគ្នា កណ្តាលជំនុំ ។ នាងស្នំឯទៀត១បើកនំឡើងមិនឃើញព្រះទម្រង់សោះ។ ឯព្រះនាងអសន្និមិត្តា ទ្រង់បើកឡើងឃើញព្រះទម្រង់ភ្លឺផ្លេក១ នៅក្នុងនោះ ជាមហាស្ចារ្យ ។

កាលទ្រង់ពិសោធរកព្រេងវាសនា របស់ព្រះនាងអសន្និមិត្តាឃើញច្បាស់ហើយ ក៏ទ្រង់ប្រកាសកណ្តាលមហាសន្និបាតថា "នេះហើយជាភ័ព្វវាសនារបស់នាងអសន្និមិត្តា ដែលគេបានសាងពីបុព្វជាតិមក ត្រូវបានជាអគ្គមហេសីឯករបស់យើង ចូរនាងស្នំឯទៀត១ជឿវាសនារបស់គេចុះ កុំ

ប្រណែននឹងគេឡើយ ។

លុះបានជាព្រះអគ្គមហេសីពេញទីហើយ ព្រះនាងអសន្ធិមិត្តា ក៏ទ្រង់សោយព្រះបរមសុខមាលសុខក្នុងព្រះសិរីរាជសម្បត្តិ ក្រោមម្លប់ព្រះសម្ភារបារមី នៃព្រះបាទធម្មាសោកមហារាជាធិរាជ ជាស្ដេចចុល្លចក្រ នៅជម្ពូទ្វីប ដរាបដល់អស់ព្រះជន្មបានទៅកើតក្នុងទេវលោក ។

វត្ថុទាន ក៏លាយដោយភេសជ្ជទាន គឺការថ្វាយសំពត់សាដក ជាគ្រឿងរុំដណ្ដប់ ចំពោះព្រះបច្ចេកពុទ្ធ ជាបដិគ្គាហកបុគ្គល មានព្រះគុណវិសេសប្រសើរ មានផលានិសង្សអស្ចារ្យ ដូចពណ៌នាមកនេះ ។

## ៣_ អានិសង្សបិណ្ឌបាតទាន

ដុំនៃអាមិស គឺអាហារមានបាយបបរនំចំណីជាដើម ដែលដាក់ចូលក្នុងមាត់ ទំពាររលេបចូលទៅបាន តាមព្យញ្ជនៈ(១) ក្នុងភាសាបាលី ហៅថាបិណ្ឌបាត ដែលយើងអ្នកកាន់ពុទ្ធសាសនា ធ្លាប់សំគាល់ពាក្យនេះថា ជាចង្ហាន់របស់ព្រះសង្ឃតែតាមអត្ថ(២) ដែលថ្លែងពីបិណ្ឌបាតបច្ច័យនោះលោកថា សូម្បីតែអាហាររបស់គ្រហស្ថឬរបស់សត្វទូទៅ ដែលជាគ្រឿងលេបចូលទៅតាមផ្លូវមាត់ដូចគ្នា ក៏លោករាប់ចូលក្នុងពួកបិណ្ឌបាតបច្ច័យដែរ ។

ធម្មតាមនុស្សសត្វក្នុងសកលលោក សុទ្ធតែត្រូវអាស្រ័យដោយបិណ្ឌបាតបច្ច័យដូចគ្នាទាំងអស់ បើគ្មានបិណ្ឌបាតបច្ច័យជាគ្រឿងអាស្រ័យ

១- តួអក្សរ ។ ២- សេចក្ដី ។

ខេ មិនអាចរស់នៅបានជាដាច់ខាត ។

រឿងនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់ថា សព្វេ សត្តា អាហារដ្ឋិតិកា សត្វទាំងឡាយទាំងពួង តាំងជីវិតរស់នៅបានដោយអាហារ ។ ពាក្យថា អាហារ មិនសំដៅតែបាយបបរនិងនំចំណី ជាគ្រឿងបរិភោគរបស់មនុស្សទេ សូម្បីតែស្មៅនិងស្លឹកឈើជាដើម ជាគ្រឿងបរិភោគរបស់សត្វតូចធំ ក៏ហៅថា អាហារដូចគ្នា មានសេចក្តីអធិប្បាយសង្ខេប ដូចតទៅនេះ :

មនុស្សសត្វក្នុងពិភពលោក សុទ្ធតែរស់នៅដោយអាហារទាំងអស់ បើគ្មានអាហារបរិភោគ ឬមានដែរ តែបរិភោគពុំកើត ព្រោះឈឺថ្កាត់ ក៏ដល់នូវសេចក្តីស្លាប់ ទោះបីមិនស្លាប់ ក៏គ្មានកម្លាំង ។

ព្រោះហេតុនេះ បានជាអាហារដែលទាយកបានឱ្យដល់គ្រហស្ថដោយសង្គ្រោះ ឬដោយបូជាគុណ មានបូជាដល់មាតាបិតាជាដើម ឬដល់បព្វជិតជាទានមានផលានិសង្សច្រើនជាអនេក ទាំងពីរខាង គឺអាចឱ្យខាងអ្នកទទួលទានមានកម្លាំងក្នុងពេលទទួលនាបច្ចុប្បន្ន ហើយឱ្យអ្នកម្ចាស់ទានបានជាអ្នកមានរូបល្អ មានកម្លាំងពលំ និងទ្រព្យសម្បត្តិច្រើនក្នុងកាលជា អនាគត ។

វិន័យបិដក មហាវគ្គ ទុតិយភាគ សំដែងថា ការឱ្យទានបបរមានអានិសង្ស ១០ យ៉ាងគឺ :

**១. យាគុំ ទេន្តោ អាយុំ ទេតិ** បុគ្គលកាលឱ្យបបរឈ្មោះថា

ឱ្យអាយុ.

២- វណ្ណំ ទេតិ ឈ្មោះថា ឱ្យពណ៌សម្បុរ.

៣- សុខំ ទេតិ ឈ្មោះថា ឱ្យសេចក្ដីសុខ.

៤- ពលំ ទេតិ ឈ្មោះថា ឱ្យកម្លាំងកាយ.

៥- បដិភាណំ ទេតិ ឈ្មោះថា ឱ្យប្រាជ្ញា.

៦- ឃាគុ បីតា ខុទំ បដិហនតិ បបរដែលហុតទៅហើយ រមែងឃាត់ នូវសេចក្ដីឃ្លាន.

៧- បិបាសំ វិនោទេតិ បន្ទោរបង់សេចក្ដីស្រេក.

៨- វាតំ អនុលោមេតិ ញ៉ាំងខ្យល់ឱ្យដើរស្រួល.

៩- វត្ថិំ សោធេតិ ញ៉ាំងសរសៃឱ្យស្អាត.

១០- អាមាវសេសំ បាចេតិ ញ៉ាំងអាហារថ្មីដ៏សេសសល់ ឱ្យរលួយ ។

គម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្ត សំដែងថា កាលព្រះបរមសាស្ដាគង់ព្រះជន្មនៅឡើយ មានទេវតាចូលទៅទូលសួរព្រះអង្គថា:

កឹ ទទោ ពលទោ ហោតិ បពិត្រព្រះដ៏មានបុណ្យដ៏ចម្រើន! ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថា ឱ្យកម្លាំង?

ព្រះអង្គឆ្លើយថា អន្នទោ ពលទោ ហោតិ ឱ្យបាយជាទាន បានឈ្មោះថា ឱ្យពលទាន គឺឱ្យកម្លាំងដល់អ្នកទទួលទានក្នុងជាតិជាបច្ចុប្បន្ន

ហើយអ្នកម្ចាស់ទានតែងបានសម្បូណ៌ទ្រព្យសម្បត្តិក្នុងជាតិជាអនាគត ។

## រឿងព្រះធានចង្ហាន់

ចំពោះអានិសង្សនៃពលទាន អដ្ឋកថាធម្មបទ បាននិទានរឿងមួយថា ក្នុងសម័យមុនពុទ្ធកាលនៃព្រះសក្យមុនីគោតមបរមគ្រូជាម្ចាស់នៃយើងនេះ មានមន្ត្រីម្នាក់ចេញពីគាល់ព្រះរាជាក្នុងព្រះរាជវាំង មកដល់ជិតផ្ទះរបស់ខ្លួន បានឃើញព្រះបច្ចេកពុទ្ធ ១ ព្រះអង្គ ឈរបិណ្ឌបាតចង្ហាន់នៅទីនោះ ។ មន្ត្រីនោះ បានឃើញលោកឈរស្ងៀម ក៏បួលទៅបើកគ្របបាត្រលោកឃើញបាតទទេ ពុំទាន់មានចង្ហាន់សោះ ហើយថែមទាំងពេលនោះថ្ងៃជិតត្រង់ផង ក៏ស្ទុះប្រញាល់ចូលទៅក្នុងផ្ទះ យកអាហារដែលអ្នកផ្ទះរៀបទុកបម្រុងខ្លួន ប្រើឱ្យកម្មករម្នាក់យកទៅដាក់បាត្រលោក ដោយពោលថា "ចូរអ្នកយកចង្ហាន់នេះទៅដាក់បាត្រលោកចុះ យើងចែកផលបុណ្យស្មើគ្នា" ។ បុរសជាកម្មករបានឮដូច្នោះ ក៏ស្ទុះរត់យកចង្ហាន់ទៅដាក់បាត្រព្រះបច្ចេក-ពុទ្ធដោយសេចក្តីត្រេកអរ ។ លុះដាក់បាត្រហើយ បុរសនោះសូមប្រាថ្នាថា "ដោយផលនៃចង្ហាន់ដែលខ្ញុំរត់ទាំងកណ្តាលថ្ងៃត្រង់ យកមកដាក់បាត្រព្រះអង្គនេះ សូមឱ្យខ្ញុំកើតក្នុងជាតិខាងមុខមានកម្លាំងច្រើន មានយានជំនិះសុទ្ធតែលឿនៗនិងមានអំណាចរុងរឿងដូចព្រះអាទិត្យឋិតកណ្តាលនភាល័យ" ។

ដោយអានិសង្សនោះ លុះបុរសនោះស្លាប់ពីមនុស្សទៅបានសោយសុខក្នុងឋានសួគ៌អស់ ១ ពុទ្ធន្តរ ( បន្លោះព្រះពុទ្ធ ១ ព្រះអង្គ) លុះដល់មក

ពុទ្ធកាលនៃព្រះសក្យមុនីគោតមបរមគ្រូនៃយើងនេះ ទើបចុះមកកើតក្នុងមនុស្សលោកជាស្ដេចព្រះនាមចណ្ឌបជោត នៅក្នុងជម្ពូទ្វីប ទ្រង់មានយានជំនិះ សេះ ដំរី សុទ្ធតែលឿនៗ រត់បាន ១២០ យោជន៍ ក្នុង ថ្ងៃ១ និងទ្រង់មានអំណាចរុងរឿងដូចព្រះអាទិត្យចែងចាំងកណ្ដាលអម្ពរ ។

## រឿងសុខសោមនស្ស

ចំពោះអានិសង្សនៃបិណ្ឌបាតទាន អដ្ឋកថាធម្មបទ បាននិទានរឿងមួយថា:

ក្នុងសម័យមុនពុទ្ធកាលនៃព្រះសក្យមុនីគោតមបរមគ្រូនៃយើងនេះ មានបុរស ២ នាក់ ម្នាក់នៅក្នុងក្រុង ម្នាក់នៅស្រុកក្រៅ ជាសំឡាញ់នឹងគ្នា ។ ថ្ងៃមួយបុរសនៅស្រុកក្រៅមកក្នុងក្រុង បុរសនៅក្នុងក្រុងនាំទៅមើលការបរិភោគអាហារនៃសេដ្ឋីម្នាក់ ដែលរៀងរាល់ល្ងាចពេញបូណ៌មីនៃខែនីមួយៗ បានតាក់តែងភោជនាហារដ៏ឈ្ងុយឆ្ងាញ់អស្ចារ្យ ដាក់ក្នុងភាជន៍មាស និងគ្រឿងប្រដាប់ល្អៗ ដ៏កល់លើតុថាសមាស មានតម្លៃដល់សែនតម្លឹង ។ វេលាបរិភោគម្ដងៗ សេដ្ឋីឱ្យទូងស្គរប្រកាសផ្សាយដំណឹងដល់មហាជនឱ្យទៅមើលគាត់បរិភោគជនានុជនបានទៅមើលយ៉ាងកុះករ ។វេលាសេដ្ឋីបើកភាជន៍ទាំងអស់ឡើងនឹងបរិភោគក្លិនអាហារនោះធុំឈ្ងុយផ្សាយទៅគ្របលើទីប្រជុំជនានុជនដែលទស្សនា នាំឱ្យនឹកចង់បរិភោគ គ្រប់គ្នា ។

ឯបុរសអ្នកស្រុកក្រៅ ជាអ្នកមិនធ្លាប់បានឃើញ បានធុំក្លិនអាហារដ៏ឈ្ងុយឆ្ងាញ់ដូច្នេះសោះ ក៏នឹកចង់បរិភោគក្រៃពេក គិតថាបើគេឱ្យបរិភោគ

អាហារបែបនេះម្តង ទោះបីគេឱ្យធ្វើការបម្រើគេយ៉ាងណាក៏ស៊ូទ្រាំធ្វើដែរ ។

លុះបុរសនោះត្រឡប់ពីទីប្រជុំនោះមក និយាយប្រាប់បុរសជាសម្លាញ់តាមគំនិតដែលគិតនោះ ។ បុរសជាសម្លាញ់ក៏ឱ្យបុរសនោះចូលទៅសួរសេដ្ឋី១ ប្រាប់ថា "លុះតែអ្នកមកនៅធ្វើការបម្រើយើង ៣ ឆ្នាំ ទើបយើងឱ្យបរិភោគអាហារនេះមួយឆ្អែតម្តង" ។ បុរសនោះក៏សុខចិត្តនៅធ្វើការឱ្យគេទៅ ។ បុរសនោះ មានឈ្មោះថា ភត្តភតិកបុរស (អ្នកស៊ីឈ្នួលយកបាយស៊ី) តាំងពីថ្ងៃនោះមក ។

លុះគ្រប់កំណត់ ៣ ឆ្នាំមហាសេដ្ឋីបានរៀបចំភោជនាហារឱ្យបុរសនោះបរិភោគនៅវេលាព្រឹក នៃថ្ងៃពេញបូណ៌មី ។ ពិធីរៀបចំនោះមានភត្តាហារ ព្រមទាំងប្រដាប់ប្រដារគ្រប់មុខ ដូចមហាសេដ្ឋីបរិភោគផ្ទាល់ខ្លួន ។ គ្រានោះ មហាជនមករង់ចាំមើលការបរិភោគនៃភត្តភតិកបុរសច្រើនជាងថ្ងៃដែលមហាសេដ្ឋីបរិភោគសព្វដង ។

វេលាភត្តភតិកបុរសរៀបនឹងបរិភោគ ស្រាប់តែមានព្រះបច្ចេកពុទ្ធ ១ ព្រះអង្គដែលទើបនឹងចេញពីនិរោធសមាបត្តិថ្មី ៗ អស់បង្ហាន់ ៧ ថ្ងៃ ហើយមកឈរបិណ្ឌបាតពីមុខ បុរសឃើញលោកក៏គិតថា "ហេតុតែអាត្មាអញមិនបានធ្វើទានពីជាតិមុខបានជាអញកំសត់ដូច្នេះ ជាភ័ព្វល្អណាស់ដែលលោកមកប្រោសអញ ត្រូវអញយកភត្តនេះដាក់បាត្រលោកចុះ" ។ គិតហើយក៏ឱ្យគេជួយយកភត្តនោះទៅដាក់បាត្រព្រះបច្ចេកពុទ្ធ ។ វេលាដាក់

បាត្រនោះ ទោះបីព្រះបច្ចេកពុទ្ធទទួលពាក់កណ្ដាលហើយ លោកបិទគ្រប បាត្រមិនឱ្យដាក់ទៀត ក៏ភត្តកម្មករបុរសចេះតែដាក់ទាល់តែអស់ ហើយសុំប្រាថ្នាថា "ព្រះអង្គបានសម្រេចធម៌យ៉ាងណាក្នុងអត្តភាពជាបច្ចុប្បន្ននេះ សូមឱ្យខ្ញុំព្រះអង្គបានសម្រេចធម៌យ៉ាងនោះក្នុងជាតិជាអនាគត" ។ បុរសប្រាថ្នាហើយ ព្រះបច្ចេកពុទ្ធធ្វើភត្តានុមោទនាថា "អ្នកប្រាថ្នាយ៉ាងណា សូមឱ្យសម្រេចយ៉ាងនោះរួសរាន់ទាន់ចិត្ត" ។

ពួកមហាជនឃើញដូច្នោះ ក៏ស្រែកកងរំពងឡើងឮសូរដល់មហាសេដ្ឋីជាម្ចាស់ភត្ត ។ សេដ្ឋីមកមើល ឃើញអស្ចារ្យដូច្នោះ ក៏សូមចែកផលបុណ្យនោះពាក់កណ្ដាល ហើយចែកទ្រព្យសម្បត្តិរបស់ខ្លួន ពាក់កណ្ដាលឱ្យភត្តកម្មករបុរស ។ ក៏បានឡើងឋានៈជាភត្តកម្មករបុរសសេដ្ឋី តាំងពីពេលនោះតទៅ ។

ភត្តទានដែលភត្តកម្មករបុរសដាក់បាត្រព្រះបច្ចេកពុទ្ធនោះបានជាមានផលជាទិដ្ឋធម្មវេទនី (ឃើញទាន់ភ្នែក) ដូច្នោះព្រោះជាទានប្រកបដោយសម្បទា ៤ យ៉ាងគឺ:

១- វត្ថុសម្បទា បរិបូណ៌ដោយវត្ថុ គឺតួអង្គព្រះបច្ចេកពុទ្ធជាព្រះអរហន្តបរិសុទ្ធផុតចាកកិលេស.

២- គុណាតិរេកសម្បទា បរិបូណ៌ដោយគុណច្រើន គឺព្រះបច្ចេកពុទ្ធទើបនឹងចេញពីនិរោធសមាបត្តិថ្មី.

www.elibraryofcambodia.org

ចង្ហាន់ ៧ ថ្ងៃមកហើយ.

៣-បច្ចយសម្បទា បរិបូណ៌ដោយបច្ច័យ គឺភត្តនោះបានដោយកម្លាំងស៊ីឈ្នួលគេ ៣ ឆ្នាំមកហើយ.

៤- ចេតនាសម្បទា បរិបូណ៌ដោយចេតនា គឺមានចិត្តជ្រះថ្លាក្នុងពេលមុនធ្វើ ពេលកំពុងធ្វើ និងពេលក្រោយធ្វើ ។

កាលភត្តភត្តិកសេដ្ឋីនោះ អស់អាយុពីមនុស្សលោកនេះបានទៅកើតជាទេវបុត្រក្នុងឋានត្រៃត្រិង្សទេវលោក សោយទិព្វសម្បត្តិជាសុខ អស់រយៈកាល ១ ពុទ្ធន្តរ ។ លុះដល់មកពុទ្ធកាលនៃព្រះសក្យមុនីគោតមបរមគ្រូជាម្ចាស់នៃយើងនេះ ទេវបុត្រនោះច្យុតមកកើត ក្នុងត្រកូលអ្នកមានទ្រព្យសម្បត្តិស្តួកស្តម្ភមួយ នៅក្រុងសាវត្ថី ។

ពេលដែលទារកនោះ នៅក្នុងឧទរមាតា គ្រួសារនោះ តាំងពីកម្មករឡើងទៅ រហូតដល់សត្វពាហនៈសត្វចិញ្ចឹមបានសុខសប្បាយណាស់ ឥតមានមោះមៃភ័យសត្រូវឬជម្ងឺដម្កាត់អ្វីឡើយ ។ ព្រោះហេតុមានសេចក្តីសុខក្នុងគ្រួសារនោះ បានជាទារកនោះប្រសូតចាកគភ៌មក ពួកញាតិកាមានមាតាបិតាជាដើមដាក់នាមថា សុខកុមារ ។

ដោយត្រកូលនោះ មានព្រះមហាសារីបុត្តត្ថេរជាជីតុន (១) ព្រះមហាសារីបុត្តក៏បាននិមន្តមកជាអធិបតីក្នុងពិធីដាក់នាមកុមារនោះដោយមេត្រីភាព ។

---

១-ពាក្យបុរាណ ៈ ភិក្ខុជាអ្នកឧបត្ថម្ភត្រកូល ថា ជីតុន ។

www.elibraryofcambodia.org

វេលាធ្វើពិធីនោះ មាតាបិតាបានគ្របសំពត់ផាហ៊ុំល្អ ១ ពីលើកុមារនោះៗ ចេះតែកាន់ផាហ៊ុំនោះហុចទៅចំពោះលោក ។ មាតាបិតាមានសេចក្តីត្រេកអរ ក៏យកផាហ៊ុំនោះប្រគេនព្រះមហាថេរ ។

លុះសុខកុមារបានអាយុ ៧ ឆ្នាំ មាតាបិតាបានបំបួសជាសាមណេរក្នុងសំណាក់ព្រះសារីបុត្រ ។ បួសហើយ ព្រឹកមួយព្រះសារីបុត្រនាំសុខសាមណេរត្រាច់តាមភ្លឺស្រែ ទៅបិណ្ឌបាតនៅភូមិជិតវត្ត ។ សុខសាមណេរបានឃើញអ្នកស្រែបង្ហូរទឹកតាមប្រឡាយ បញ្ចូលស្រែ បានពិចារណាថា ទឹកជាធម្មជាតិឥតចិត្តឥតជីវិតទេ តែគេអាចប្រើទៅតាមទីដៅរបស់គេតាមចិត្តគេបាន ឯខ្លួនអញដែលជាមនុស្សមានជីវិតមានវិញ្ញាណ ត្រូវតែពត់ចិត្តឱ្យត្រង់ទៅទីដៅ នៃពុទ្ធសាសនាគឺវិបស្សនាញាណទើបគួរ ។ លុះត្រាច់ទៅមុខទៀត បានឃើញជាងពត់ឈើធ្វើព្រួញ ក៏ពិចារណាថា ឈើឬឫស្សីជាវត្ថុឥតជីវិតឥតវិញ្ញាណទេ តែជាងគេអាចពត់ឱ្យកើតជាព្រួញយកទៅបាញ់ឱ្យត្រូវវត្ថុដែលគេត្រូវការតាមចិត្តគេបាន ឯចិត្តរបស់អញដែលជាមនុស្សមានជីវិតមានវិញ្ញាណគួរតែពត់ឱ្យត្រង់តម្រង់ទៅរកវិបស្សនាឱ្យសម្រេចល្អទាល់តែបានទើបគួរ ។

ត្រេចទៅមុខទៀតបានឃើញជាងក្រឡឹងដុំរទេះក៏ពិចារណាទៀតថា ឈើជាវត្ថុឥតជីវិតឥតវិញ្ញាណសោះ ហើយមានជ្រុងផង តែជាងគេអាចក្រឡឹងឱ្យមូលជាដុំកង់រទេះ ប្រើការបានដោយប្រពៃ ឯចិត្តរបស់

អញដែលជាមនុស្សមានជីវិតមានវិញ្ញាណ គួរតែដម្កល់ឱ្យមូលជាឯកគ្គតា-សមាធិមានអារម្មណ៍មូលតែមួយឱ្យទាល់តែបាន ទើបសមជាសមណៈអ្នកបួសក្នុងព្រះពុទ្ធសាសនា ។

លុះពិចារណាឃើញ ដូចពោលមកនេះហើយ សុខសាមណេរក៏ទូលព្រះសារីបុត្រជាព្រះឧបជ្ឈាយ៍ថា "ខ្ញុំករុណា សូមលាព្រះករុណាម្ចាស់ត្រឡប់ទៅចម្រើនធម៌ឯវត្តវិញ" ។ ព្រះសារីបុត្តថា "ទៅចុះ តែត្រូវចាក់សោទ្វារចូលទៅអង្គុយចម្រើនក្នុងកុដិ ខ្ទាស់គន្លឹះទ្វារពីខាងក្នុងឱ្យខ្ជាប់ហើយសឹមអង្គុយភាវនា" ។ មានថេរដីកាហើយព្រះសារីបុត្រក៏ប្រគល់កូនសោទ្វារឱ្យសាមណេរៗ ទូលថា "សូមព្រះករុណាមេត្តានិមន្តទៅឯផ្ទះញាតិញោម ខ្ញុំព្រះករុណា រកចង្ហាន់ប្រកបដោយរស ៧ យ៉ាងមកឱ្យខ្ញុំព្រះករុណាផង" ។ ព្រះសារីបុត្រថា "មិនដឹងជាទៅរកឯណាបាន" ។ សាមណេរទូលថា "បើមិនបានដោយបុណ្យព្រះករុណាម្ចាស់ គង់តែបានដោយបុណ្យ ខ្ញុំព្រះករុណាពុំខានឡើយ" ។ ទូលហើយក៏សុខសាមណេរថ្វាយបង្គំលាព្រះឧបជ្ឈាយ៍ទៅដល់វត្តចូលទៅអង្គុយភាវនានៅក្នុងកុដិ ដោយស្ងប់ស្ងាត់តែម្នាក់ឯងៗ ។

ដោយផលបុណ្យពីជាតិមុន ព្រះសារីបុត្រនិមន្តទៅផ្ទះត្រកូលសាមណេរ ក៏បានចង្ហាន់ប្រកបដោយរស ៧ យ៉ាង ហើយប្រញាប់ប្រញាល់ត្រឡប់ទៅវត្តវិញដើម្បីយកចង្ហាន់ទៅឱ្យសាមណេរឆាន់ទាន់ពេល ។ វេលាព្រះថេរៈនិមន្តទៅដល់វត្ត សុខសាមណេរ បានសម្រេចមគ្គផលខ្លះ

www.elibraryofcambodia.org

ហើយ តែមិនទាន់ដល់ថ្នាក់អរហត្តផល ។ ព្រះសម្មាសម្ពុទ្ធទ្រង់ពិចារណាឃើញថា "បើបណ្តោយឱ្យព្រះសារីបុត្រ ទៅគោះទ្វារហៅសាមណេរ។ សុះចេញមកទទួលព្រះឧបជ្ឈាយ៍ នឹងដាច់ធម៌មិនបានសម្រេចអរហត្ត ទើបព្រះអង្គប្រថាប់ឈរនៅត្រង់ទ្វារវត្តជេតពនទ្រង់សួរប្រស្នាផ្សេង។ ចំពោះព្រះសារីបុត្រ ។ លុះទ្រង់ជ្រាបថា សុខសាមណេរបានសម្រេចអរហត្តផល ហើយទើបទ្រង់បើកឱ្យទៅ ។ កាលព្រះថេរៈនិមន្តទៅដល់កុដិ សាមណេរ បើកទ្វារកុដិចេញមកឈរចាំទទួលដោយគោរព ហើយព្រះថេរៈបានរៀបចង្ហាន់ដោយស្រួល ។ល។

សុខសាមណេរនេះដែលបានកើតក្នុងត្រកូលខ្ពស់ បាន សុខបានសំរេចអរហត្តក្នុងជន្មាយុ ៧ ឆ្នាំ ហើយបានភោជនាហារដ៏មានរសឆ្ងាញ់ពិសារបរិភោគ តាំងពីនៅជាទារក រហូតដល់បានសម្រេចមគ្គផល ជាអវសានកិច្ចក្នុងព្រះពុទ្ធសាសនាដោយសារផលានិសង្សនៃបិណ្ឌបាតទាន កាលនៅជាបុរសកំសត់ជាតិមុននោះឯង ។

នេះហើយជាអានិសង្សនៃបិណ្ឌបាតទាន ដូចបានពណ៌នាមក ។

## ៤-អានិសង្សសេនាសនទាន

ទីជ្រក ទីដេក ទីអង្គុយ ទីនៅ តាមពាក្យព្យញ្ជនៈ[១] ក្នុងភាសាបាលីថា សេនាសនៈ ដែលយើងជាពុទ្ធបរិស័ទធ្លាប់សំគាល់ពាក្យនេះ ថាជាឈ្មោះទីនៅរបស់ព្រះសង្ឃ មានកុដិ សាលា វិហារឬបង្កន់ តុ៉ាំងកៅអីពូក កន្ទេល ខ្នើយ ជាដើម តែតាមអត្ថ[១] ដែលលោកអធិប្បាយពីសេនា-

---

១- តួអក្សរ ។

សនប្បច្ច័យ ក្នុងបច្ច័យ ៤ នោះថា សេនាសនៈមិនមែនសំដៅតែត្រឹមកុដិ សាលា វិហារ ឬគ្រែ គៅអី ពូក គ្រែ កន្ទេល ខ្នើយ របស់ព្រះសង្ឃទេ សូម្បី ផ្ទះសម្បែង ខ្ទម លំហារ គ្រែ គៅអី ពូក គ្រែ ជាទីនៅ ទីដេក ទីអង្គុយ របស់ គ្រហស្ថ ក៏រាប់បូលក្នុងពូកសេនាសនប្បច្ច័យដែរ ។

ទាំងមនុស្សទាំងសត្វ ដែលកើតមកក្នុងសាកលលោក តែងអាស្រ័យ ដោយសេនាសនប្បច្ច័យ ជាទីដេកពូនកោនជ្រកដូចគ្នា គ្មាននរណាចៀស រួចបាន បើគ្មានសេនាសនប្បច្ច័យជាទីអាស្រ័យទេ មនុស្សនិងសត្វមិនអាច រស់នៅជាសុខបានឡើយ សូម្បីសត្វទឹកសត្វគោក មានជើងក្តីឥតជើងក្តី ក៏ត្រូវតែមានដីមានរូបមានរន្ធ ជាទីសេនាសនៈស្នាក់អាស្រ័យទៅតាមភាព របស់វាដែរ ទើបវារស់នៅជាសុខបាន ។

ព្រោះហេតុនេះ បានជាទីសេនាសនៈ ដែលទាយកបានឱ្យដល់ គ្រហស្ថអ្នកកំសត់ទុគ៌ត ឬបព្វជិតអ្នកមានសីលបរិសុទ្ធមានផលានិសង្ស ច្រើនទាំងពីរខាង គឺទាំងខាងអ្នកទទួលទាន បានជ្រកនៅជាសុខស្រួលក្នុង បច្ចុប្បន្ន ទាំងខាងអ្នកម្ចាស់ទាននឹងបានជាអ្នកមានទ្រព្យសម្បត្តិផ្ទះសម្បែង ប្រាសាទវិមាន នៅជាសុខក្នុងកាលជាអនាគត ។

គម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្ត សំដែងថា កាលព្រះដ៏មាន បុណ្យគង់ព្រះជន្មនៅឡើយ មានទេវតាបូលទៅទូលសួរថា :

**យោ ច សព្វទទោ ហោតិ** បពិត្រព្រះអង្គដ៏ចំរើន! អ្នកឱ្យ

របស់អ្វីទើបបានឈ្មោះថា ឱ្យគ្រប់មុខ ។

ព្រះអង្គត្រាស់ថា សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ អ្នកណាបានឱ្យទីលំនៅជាទាន អ្នកនោះបានឈ្មោះថាឱ្យគ្រប់មុខ ។

មួយទៀតគម្ពីរសំយុត្តនិកាយ ជាមួយគ្នានោះ ថែងថា មានទេវតាចូលទៅទូលសួរព្រះសម្មាសម្ពុទ្ធថាៈ

កេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ បពិត្រព្រះអង្គដ៏ចម្រើន បុណ្យតែងចម្រើនទាំងយប់ទាំងថ្ងៃសព្វកាលទាំងពួងដល់ពួកជនណា ?

ព្រះអង្គត្រាស់ថាៈ

អារាមរោបា វនរោបា យេ ជនា សេតុការកា

បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ

តេសំ ទិវា ច រត្តោច សទា បុញ្ញំ បវឌ្ឍតិ

ម្នាលទេវតា! ជនទាំងឡាយណា បានដាំសួនឈើផ្កា ដាំសួនឈើស្លឹកជាម្លប់ សង់ស្ពាន សង់រោងដាក់ទានទឹក សាងអណ្តូងទឹកនឹងសាងទីលំនៅជាទាន បុណ្យរបស់ជនអម្បាលនោះ តែងចម្រើនទាំងថ្ងៃទាំងយប់សព្វកាលទាំងពួង ។

មួយទៀត ផលបុណ្យនានា ដែលជនទាំងឡាយបានធ្វើហើយ រមែងរង់ចាំទទួលពួកជនដែលធ្វើបុណ្យនោះ ក្នុងលោកខាងនាយ ដូចញាតិមិត្តដែលស្រឡាញ់គ្នា ទន្ទឹងរង់ចាំទទួលគ្នាដូច្នោះ ។

www.elibraryofcambodia.org

# រឿងនន្ទិយឧបាសក

ចំពោះផលបុណ្យដែលទន្ទឹងរង់ចាំអ្នកធ្វើបុណ្យនោះ ក្នុងអដ្ឋកថាធម្មបទ មាននិទានរឿង ១ ថា :

សម័យមួយ ព្រះបរមសាស្តាជាម្ចាស់ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី គ្រានោះមានមាណពម្នាក់ឈ្មោះនន្ទិយៈជាអ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា បានបម្រើព្រះសង្ឃតាមវង្សត្រកូលជាអ្នកមានសទ្ធាចំពោះព្រះរតនត្រ័យ ។ លុះមាតាបិតាក្ស័យជីវិតទៅនន្ទិយមាណព ក៏បានជាមហាទានាធិបតី បានថ្វាយទានចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន នឹងឱ្យទានដល់មនុស្សកំសត់ទុគ៌ត អនាថា បាន សាងសាលា ៤ ល្វែង ១ ខ្នងមានមុខ ៤ ព្រមទាំងគ្រឿងសេនាសនៈ ជាប្រដាប់សម្រាប់សាលានោះ នៅព្រៃឥសិបតនមិគទាយវ័ន ត្រង់កន្លែងដែលព្រះពុទ្ធអង្គទ្រង់សម្តែងព្រះធម្មចក្របឋមទេសនា ។ លុះសាងស្រេចហើយបានវេរសាលានោះថ្វាយចំពោះព្រះសង្ឃ មានព្រះពុទ្ធអង្គជាប្រធាន ។ ក្នុងពេលដែលនន្ទិយៈវេរសាលា បានច្រូចទឹកទក្ខិណោទកៈ លើបាតព្រះហស្តព្រះតថាគតនោះ ប្រាសាទទិព្វប្រកបដោយកែវ៧ប្រការ ទំហំ១២យោជន៍ កំពស់១៧យោជន៍ ផុះឡើងក្នុងឋានតាវត្តិង្សព្រមទាំងនាងទេពអប្សរចាំទទួលគាត់ ។

ថ្ងៃបន្ទាប់នោះ ព្រះមហាមោគ្គល្លានត្ថេរនិមន្តទៅកាន់ទេវចារិកបានឃើញប្រាសាទទិព្វនោះ ក៏សួរទេពធីតាទាំងឡាយដែលរង់ចាំនៅទីនោះថា ប្រាសាទនេះជារបស់នរណា? ។ នាងទេពធីតាពិតថេរវាចាថា ជារបស់នន្ទិយ

www.elibraryofcambodia.org

ឧបាសក. ហើយនាងផ្ដាំលោកថា សូមមេត្តាប្រាប់នន្ទិយឧបាសកផង ឱ្យគាត់ប្រញាប់ទៅកើតក្នុងទីនោះ ។ លុះព្រះមោគ្គល្លានត្ថេរត្រឡប់មកកាន់មនុស្សលោកវិញ បានទូលព្រះបរមសាស្ដាតាមដំណើរនោះ ព្រះអង្គទ្រង់សំដែងថា:

ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតិ មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ
តថេវ កតបុញ្ញម្បិ អស្មា លោកា បរំគតំ
បុញ្ញានិ បដិគ្គណ្ហន្តិ បិយំ ញាតីវ អាគតំ

សេចក្ដីថា: ពួកជនជាញាតិមិត្ត ឬក្មេរម្រាក់ ដែលរាប់អានគ្នាគេ រមែងមានចិត្តត្រេកអរនឹងបុរសជាញាតិសន្ដានដែលព្រាត់ប្រាសគ្នា អស់កាលជាយូរហើយ ដែលគេជាពាណិជ្ជឬនាហ្មឺន ដ៏មានសិរីសួស្ដី មកពីចម្ងាយចាំទទួលគ្នារាក់ទាក់យ៉ាងណាមិញ បុណ្យទាំងឡាយរមែងរង់ចាំទទួលជនអ្នកធ្វើបុណ្យក្នុងលោកខាងនាយ ដូចគេទទួលញាតិដែលស្រឡាញ់គ្នាយ៉ាងនោះដែរ ។

ឯនន្ទិយឧបាសក កាលបើអស់អាយុពីមនុស្សលោកនេះទៅ ក៏បានទៅកើតជាទេវបុត្រសោយសម្បត្តិទិព្វ ១០ ប្រការ គឺអាយុ វណ្ណៈ សុខៈ យសសក្ដិ អធិបតេយ្យ រូប សម្លេង ក្លិន រស សម្ផស្ស ក្នុងប្រាសាទកែវដែលដុះឡើងចាំទទួលគាត់ តាំងពីពេលដែលគាត់វេរសាលាថ្វាយព្រះសម្មាសម្ពុទ្ធនោះឯង ។

## ៥_អានិសង្សភេសជ្ជទាន

ថ្នាំសម្រាប់ព្យាបាលរោគគ្រប់ចំពូក ភាសាបាលី ហៅថាគិលានភេសជ្ជៈដែលក្នុងបច្ច័យ ៤ លោកហៅថា ភេសជ្ជបច្ច័យ ជាគ្រឿងអាស្រ័យព្យាបាលជម្ងឺបានទាំងគ្រហស្ថ ទាំងបព្វជិត ហើយទូទៅទាំងសត្វផង ។

www.elibraryofcambodia.org

មនុស្សសត្វក្នុងលោក តែងមានជម្ងឺដម្កាត់គ្រប់គ្នា បើមិនច្រើនក៏តិច ជាធម្មតា ស្ទើរតែរាល់ថ្ងៃ ហើយត្រូវតែអាស្រ័យដោយថ្នាំកែរោគនោះៗជារាល់ពេលដែលឈឺ ទើបជម្ងឺនោះៗ ជាសះស្បើយបាន ។

ក្នុងវិនយបិដក មហាវគ្គ ត្រង់ភេសជ្ជក្ខន្ធក: ថែងថា:

កាលព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ជ្រាបថាពួកភិក្ខុមានរោគាពាធគ្រុនស្រេវស្រាញក្នុងសរទរដូវ ។មុនដំបូងទ្រង់អនុញ្ញាតឱ្យភិក្ខុទទួលក្នុងកាលគួរក៏បាន កាលមិនគួរក៏បាន នូវគោរស ៥ យ៉ាង គឺទឹកដោះស្រស់ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ដែលជាភេសជ្ជៈផង ជាអាហាររបស់មនុស្សលោកផង ។

លំដាប់តៗមក ទ្រង់អនុញ្ញាតនូវភេសជ្ជៈច្រើនបំពួកទៀតគឺ:

-ពួកខ្លាញ់ មានខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រីជាដើម

-ពួកឫស មើម មានមើមរមៀត មើមខ្ញីជាដើម

-ពួកទឹកបត់ មានទឹកបត់កើតពីស្លឹកស្ដៅជាដើម

-ពួកស្លឹក មានស្លឹកស្ដៅជាដើម

-ពួកផ្លែ មានផ្លែដីប្លី ម្រេចជាដើម

-ពួកជ័រ មានជ័រហិង្គុជាដើម

ទ្រង់ឱ្យឆាន់ក្នុងវេលាវិកាល នូវទឹកបាន ៨យ៉ាង គឺទឹកផ្លែស្វាយ ព្រីង ចេកមានគ្រាប់-ចេកឥតគ្រាប់-ស្រគំ-បន្ទី-ក្រអៅឈូក-មាក់ប្រាង ។

ទ្រង់ឱ្យឆាន់ក្នុងវេលាវិកាល នូវទឹកខុទ្ទកផល (ផ្លែតូចៗ) គ្រប់យ៉ាង មានផ្លែថ្កៅ អម្ពិល-ក្រូច-ពង្រ-សង្ស៊ីរជាដើម វៀរតែផ្លែដែលអនុលោមតាមធញ្ញជាតិគឺ ស្រូវ និងសណ្ដែក-ល្ងចេញ ។

www.elibraryofcambodia.org

ឯមហាផល (ផ្លែធំ១) ៩ យ៉ាង គឺផ្លែត្នោត-ដូង-ខ្នុរ-សាកេ-ឃ្លោក-ត្រឡាច-ត្រសក់-ឪឡឹក-ល្ពៅ ទ្រង់បញ្ញត្តមិនឱ្យភិក្ខុឆាន់ក្នុងវេលាវិកាលទេ។

ទឹកត្នោត ទ្រង់អនុញ្ញាតឱ្យភិក្ខុឆាន់ក្នុងវេលាវិកាលបាន. តែទឹកដូងមិនទ្រង់អនុញ្ញាតឱ្យឆាន់ក្នុងវេលាវិកាលទេ ។

( ឯស្ករ-ជាវិ-ទឹកតែ-កាហ្វេ-ទឹកកក-ទឹកក្រូច-ស្ករស-ស្ករ-ត្នោត-ស្ករក្រាម-ស្ករគ៉ាំងស៊ុន លោករាប់ចូលក្នុងអនុលោមភេសជ្ជៈភិក្ខុឆាន់បានក្នុងកាលទាំងពីរ) ។

ទាយកអ្នកមានសទ្ធាបានឱ្យ ឬប្រគេនភេសជ្ជៈដូចពោលហើយនេះក្ដីថ្នាំពេទ្យគ្រប់យ៉ាងក្ដី ដល់ព្រះសង្ឃ ឬដល់គ្រហស្ថដែលមានជម្ងឺហៅថា ធ្វើភេសជ្ជទាន ។

ភេសជ្ជៈ ដែលអ្នកមានសទ្ធា បានប្រគេនដល់ព្រះសង្ឃឬបានឱ្យដល់គ្រហស្ថអ្នកមានជម្ងឺ ដោយសង្គ្រោះ ឬដោយបូជាគុណនោះជាទានមានផលា-និស័ង្សទាំងខាងអ្នកទទួល ទាំងខាងអ្នកប្រគេន-អ្នកឱ្យ គឺខាងបដិគ្គាហកៈ (អ្នកទទួល) បានជាជម្ងឺមានអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ ក្នុងវេលាដែលទទួលនាបច្ចុប្បន្នកាល ខាងទាយក (អ្នកឱ្យ) ក៏បានជាមនុស្សគ្មានរោគមានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខកាយសប្បាយចិត្ត មានកម្លាំងកាយកម្លាំងចិត្តនិងមានបដិភាណប្រាជ្ញាឈ្លាសវៃ ក្នុងអនាគតកាល ។

## រឿងនាងវិសាខា

អដ្ឋកថាធម្មបទ និទានរឿងនាងវិសាខា ពិស្ដារណាស់តែទីនេះ សូមពណ៌នាតែសង្ខេបខ្លី មានសេចក្ដីដូចតទៅ:

នាងវិសាខា ជាបុត្រីនៃធនញ្ជយសេដ្ឋី នៅក្រុងសាវត្ថី ជាអ្នកមានទ្រព្យ

www.elibraryofcambodia.org

សម្បត្តិច្រើន នាងបានស្តាប់ធម៌ព្រះសម្មាសម្ពុទ្ធបានសម្រេចស្រោតាបត្តិ អាយុ ៧ ឆ្នាំ ។ នាងមានស្វាមីឈ្មោះបុណ្ណវឌ្ឍន៍ ជាបុត្រមិគារសេដ្ឋីមានទ្រព្យសម្បត្តិច្រើនដូចគ្នា នាងបានសាងវត្តមួយ នៅខាងមុខទីក្រុងសាវត្ថី ហៅវត្តបុព្វារាម អស់ប្រាក់ ២៧ កោដិ (២៧០លាន) នាងមានកូន ២០ នាក់ ប្រុស ១០ ស្រី ១០ ។ ក្នុងកូន២០នាក់នោះ ម្នាក់ៗមានកូនប្រុស ១០ ស្រី ១០ ជា ២០ៗ នាក់ដូចគ្នា ។ នាងគ្មានរោគាព្យាធិអ្វីឡើយ ហើយមានអាយុ១២០ឆ្នាំ ។

តាមដំណាលថា នាងមានរូបឆោមលោមពណ៌ស្អាតបាតណាស់ មានកម្លាំងខ្លាំងណាស់ វេលានាងមានអាយុ១២០ ឆ្នាំហើយ នាងអង្គុយកណ្តាលហ្វូងកូនចៅ អ្នកផងមើលទៅឃើញចំណាស់ប្រហែលកូនចៅទាំងនោះ លុះតែក្រោកឈរឡើងយកដៃប្រត់ជង្គង់ ទើបគេដឹងថានាងចាស់ ។

លោកសំដែងថា សុខភាពទាំងនេះបានមកពីអានិសង្សដែលពីជាតិមុន នាងបានថ្វាយភេសជ្ជទាន មានទឹកដោះគោជាដើម ចំពោះព្រះពុទ្ធ និងព្រះអរហន្តពុទ្ធសាវ័ក ហើយវេលាដែលថ្វាយទឹកដោះគោម្តងៗ ព្រះសង្ឃឆាន់ហើយ នាងចេះតែថែមៗ ទៀតថាសូមនិមន្តឆាន់ឱ្យឆ្អែតបរិបូណ៌ ។

ដោយអានិសង្សនៃការថែមទឹកដោះគោ ជាភេសជ្ជទាននោះបានជានៅពេលដែលនាងមានស្វាមី ត្រូវទៅនៅខាងផ្ទះស្វាមី ហើយដែលសេដ្ឋីជាបិតាបង្កើត ចែកទ្រព្យមតិកនានាមានគោជាដើម ឱ្យនាង ។ ដោយគោដែលត្រូវចែកនោះច្រើនពេក មិនចាប់រាប់ថាប៉ុណ្ណេះប៉ុណ្ណោះ សេដ្ឋីឱ្យធ្វើក្រោល១យ៉ាងធំ រាល់គោពេញ១ក្រោលនោះឱ្យនាង ។ ពេលដែលគោខ្លះចូលពេញក្រោលហើយ នាយគោបាលបិទទ្វារក្រោល គោខ្លះដែលនៅក្រៅក្រោល ចេះតែលោតចុះផែរទៀត ឃាត់មិនឈ្នះឡើយ ។

(បើចង់ជ្រាបរឿងអានិសង្សកេសជូទាន ឱ្យពិស្តារជាងនេះទៅទៀត សូមមើលក្នុងរឿងព្រះបាទអសោក និងព្រះនាងអសន្ធិមិត្តាដែលពីជាតិមុន ទ្រង់ជាមធុពាណិជ្ជបានថ្វាយទឹកឃ្មុំ. ព្រះនាងអសន្ធិមិត្តា ជានាងកុម្ភទាសី បានថ្វាយសំពត់សាដកដល់ព្រះបច្ចេកពុទ្ធដែលកើតដំបៅ ដែលមាននៅក្នុង អានិសង្សចីវរទាន ត្រង់ទំព័រ២១៦ណោះ និងបានជ្រាបសព្វគ្រប់) ។

## ៦_អានិសង្សបិណ្ឌ

ចង្ហាន់ដែលពុទ្ធបរិស័ទប្រគេនព្រះសង្ឃឆាន់ក្នុងពិធីបុណ្យឧទ្ទិសផល បញ្ជូនទៅញាតិសន្តាន មាតាបិតាជាដើម ដែលចែកឋានទៅកាន់បរលោក ហើយនោះ លោកហៅថា បិណ្ឌ ថាធ្វើបុណ្យដាក់បិណ្ឌ ថាបុណ្យភ្ជុំបិណ្ឌ ។

របៀបបុណ្យដាក់បិណ្ឌនោះ ខាងប្រជារាស្ត្រគេយកចង្ហាន់ទៅប្រគេន លោកនៅឯវត្តរាល់ព្រឹកចំនួន ១៥ ថ្ងៃគឺតាំងពី ១ រោចខែភទ្របទទៅដល់១៥ រោចខែដដែល ត្រង់ថ្ងៃ ១ រោចដល់ថ្ងៃ ១៤ រោច ហៅថាថ្ងៃដាក់បិណ្ឌ ១៥ រោចហៅថាថ្ងៃភ្ជុំ វេលាព្រឹកថ្ងៃនោះ គេដាក់បិណ្ឌដូចថ្ងៃធម្មតា ប្លែកតែច្រើន គ្នាជាងថ្ងៃមុនៗ ព្រោះជាថ្ងៃជួបជុំធំក្នុង ១ ឆ្នាំម្តង ។

វេលាយប់ថ្ងៃភ្ជុំ ខាងប្រជារាស្ត្រគេរៀបសែនដូនតា តាមរបៀបសែន ខ្មោច មានរៀបកន្ទេល ខ្នើយ ក្រាលសំពត់សពីលើកន្ទេល ដាក់បំអាប១ចាស បង្អែម១ចាសឆ្អេង ស្លា ហើយគេជួបជុំគ្នាបៅប្រូចទឹកទៅលើសំណែននោះ និយាយប្រគិស្នអធិដ្ឋានជូនទៅដូនតាមានមាតាបិតាជាដើម ។ ខាងព្រះរាជា ដែលទ្រង់ដាក់បិណ្ឌតែ៥ថ្ងៃ គឺពីថ្ងៃ១១រោចដល់១៥រោចខែភទ្របទនោះត្រង់ យប់ថ្ងៃ១៥ រោចជាថ្ងៃភ្ជុំ ទ្រង់រៀបធ្វើព្រះរាជពិធីថ្វាយព្រះបិតរ(ដូនតា) ដោយជួបជុំព្រះរាជវង្សានុវង្សក្សត្រាក្សត្រី នាហ្មឺនសព្វមុខមន្ត្រីគ្រប់ក្រសួង

www.elibraryofcambodia.org

ក្នុងព្រះរាជធានី ចាក់ទឹកដូងប្រួចថ្វាយដូចប្រជារាស្ត្រប្រួចទឹកសែន នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យដោយមានរៀបតុ ២ ដម្កល់គ្រឿងធំនែកល្អៗ មានក្បាលជ្រូកនិងមាន់ស្ងោរជាដើម ។ តុទាំង ២ នោះ តុ១ធំ ដាក់ដង្វាយព្រះមហាក្សត្រទ្រង់រាជ្យតុ១តូចដាក់ដង្វាយព្រះរាជវង្សានុវង្ស ។ វេលាព្រឹកថ្ងៃមួយកើតខែអស្សុជ ខាងប្រជារាស្ត្រគេធ្វើទូកស្រទបចេក ដាក់នំចំណី អុជទៀនធូបបណ្ដែតលើខ្នងទន្លេ ស្ទឹង ព្រែក ឬអូរតាមទេសភាពស្រុកគេមានយ៉ាងណា បញ្ជូនដូនតាទៅស្រុកវិញ ។ ខាងព្រះរាជានៅវេលាព្រឹកជាមួយគ្នានោះ ទ្រង់បណ្ដែតប្រាសាទតូច ១ ធ្វើពីឈើ ដាក់លើក្បូនដើមចេក ១ បណ្ដែតលើខ្នងទឹកទន្លេ ៤មុខដាក់នំចំណីល្អៗ បញ្ជូនព្រះបិតរ ទៅស្រុកវិញ ។

ការបញ្ជូនផលទៅដូនតា ដោយពិធីប្រគេនចង្ហាន់ព្រះសង្ឃ និងពិធីសែនដូចពោកមកខាងលើនេះ ហៅថាធ្វើតាមព្រះពុទ្ធសាសនាផង តាមសាសនាព្រាហ្មណ៍ផង គឺលទ្ធិព្រះពុទ្ធសាសនាឱ្យធ្វើដោយពិធីប្រគេនទេយ្យទានបំពោះព្រះសង្ឃឬឱ្យដល់គ្រហស្ថអ្នកមានសីលហើយឧទ្ទិសផលបញ្ជូនទៅ លទ្ធិព្រាហ្មណ៍ឱ្យធ្វើដោយពិធីសែនផ្ទាល់នៅឯផ្នូរខ្មោច ឬនៅផ្ទះ ហើយឧទ្ទិសបញ្ជូនទៅ ។

សូមបញ្ជាក់រឿងឱ្យដោយសែនផ្ទាល់ និងឱ្យដោយបញ្ជូនផលតាមរយៈអ្នកមានសីល ដូចខាងមុខ:

អដ្ឋកថាបេតវត្ថុ សំដែងបញ្ជាក់រឿងឱ្យវត្ថុផ្ទាល់ និងឱ្យដោយបញ្ជូនផលតាមរយៈអ្នកកាន់សីល ដូចតទៅនេះ :

## រឿងនាងវិមានិកប្រេត

កាលព្រះសម្មាសម្ពុទ្ធបរមគ្រូគង់ព្រះធរមាននៅវេឡុវ័ន មានពាណិជ្ជ

ម្នាក់បើកសំពៅទៅតាមមហាផ្ទៃសមុទ្រ ជាមួយនិងពួកកម្មករ ។ កាលសំពៅទៅដល់កណ្ដាលសមុទ្រ បានឃើញនាងទេពធីតាសក់វែងអន្លាយ តែកាយអាក្រាតឋិតនៅក្នុងវិមានទិព្វកណ្ដាលសមុទ្រ ។ លុះបានឃើញហើយពាណិជ្ជក៏ចូលទៅជិត ។ នាងវិមានិកប្រេត ចេញមកបង្ហាញខ្លួនឱ្យឃើញតែមុខមិនឱ្យឃើញខ្លួន ពាណិជ្ជឃើញដូច្នោះសួរថា "ម្ដេចក៏នាងមិនឱ្យឃើញខ្លួន ?" ។ នាងវិមានិកប្រេតឆ្លើយថា "ព្រោះអាក្រាតកាយ" ។ ពាណិជ្ជសួរទៀតថា "នាងមានរូបល្អ មានប្រាសាទពិមាននៅដូចទេពធីតា តែហេតុដូចម្ដេចបានជានាងអាក្រាតកាយ?" ។ នាងវិមានិកប្រេតឆ្លើយថា "ដែលខ្ញុំមានប្រាសាទពិមានមានរូបល្អ មានអាហារទិព្វព្រោះផលដែលខ្ញុំបានប្រគេនចង្ហាន់ដល់ភិក្ខុ ១ រូប ដែលខ្ញុំមានរូបកាយអាក្រាត ព្រោះទោសដែលខ្ញុំបានលួចសម្រាតយកសំពត់មនុស្សម្នាក់ដែលដេកសំណាក់នៅក្រៅផ្ទះពីជាតិមុន" ។

បានឮដូច្នោះ ពាណិជ្ជមានចិត្តមេត្តា បានហុចសំពត់ស្លៀកដណ្ដប់ ១ ប្រដាប់ទៅឱ្យផ្ទាល់ តែសំពត់នោះរលាយបាត់មួយរំពេចទៅ ។

នាងវិមានិកប្រេតប្រាប់ថា "បើអ្នកមេត្តាខ្ញុំសូមឱ្យទានសំពត់ដល់ជនអ្នកមានសីលហើយឧទ្ទិសផលនោះមកឱ្យខ្ញុំ ទើបខ្ញុំអាចទទួលយកសំពត់ទិព្វមកស្លៀកដណ្ដប់បាននៅពេលនេះ" ។

ក្នុងសំពៅលោកមានជនម្នាក់ មុននឹងចុះសំពៅមកបានទទួលសីល៥ ហើយបានកាន់ជាប់បរិសុទ្ធដរាបមក ។ ពាណិជ្ជម្ចាស់សំពៅបានឱ្យទានសំពត់ស្លៀកដណ្ដប់ ១ ប្រដាប់ដល់ជននោះ ហើយឧទ្ទិសផលនោះដល់នាងវិមានិកប្រេត។ ក៏បានទទួលផលនោះ បានសំពត់ពណ៌ល្អស្រស់ស្លៀកពាក់យ៉ាងល្អឆើតឆាយ ហើយបានសោយសម្បត្តិទិព្វជានាងទេពធីតា នៅក្នុងវិមាននោះជាសុខសប្បាយ ។

www.elibraryofcambodia.org

ពាណិជ្ជបានធ្វើកុសលកម្មនេះហើយ ក៏មានចិត្តរីករាយឥតឧបមារួច ចេញស់ពៅជួញតាមស្រុកផ្សេងៗ ។ លុះត្រឡប់មកស្រុកខ្លួនវិញ បានយកសេចក្តីនោះទៅក្រាបបង្គំទូលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងរឿងនេះ ប្រាប់ពុទ្ធបរិស័ទទាំងឡាយទ្រង់បញ្ជាក់ថា ការធ្វើបុណ្យឧទ្ទិសផលទៅបេតបុគ្គលនោះនឹងឱ្យផ្ទាល់មិនបានទេ លុះតែឱ្យទានដល់អ្នកមានសីលសិន ហើយសឹមឧទ្ទិសឱ្យផលនោះទៅឱ្យ ទើបបានទៅដល់ពិតប្រាកដដូចពាណិជ្ជនោះឯង ។

## រឿងព្រាហ្មណ៍សែននៅផ្នូរខ្មោចកូន

ក្នុងកាលកន្លងទៅហើយ ព្រាហ្មណ៍ម្នាក់ មានកូនប្រុសជាទីស្រឡាញ់ ស្លាប់ហើយយកទៅកប់នៅផ្នូរក្នុងព្រៃស្មសាន ។ កប់ហើយព្រាហ្មណ៍យកបាយចំណីទៅដាក់នៅផ្នូរ ហើយនិយាយថា "សូមឱ្យកូនបរិភោគអាហារនេះចុះ" ។

តាមនិទានឯណាលថា កូនព្រាហ្មណ៍នោះស្លាប់ទៅ ទៅកើតជាទេវតានៅទីនោះបានឃើញបិតាធ្វើដូច្នោះ ក៏សំដែងខ្លួនឱ្យឃើញជារូបកូននោះ យកស្មៅទៅឱ្យគោស្លាប់នៅទីជិតនោះស៊ី ។ ព្រាហ្មណ៍បានឃើញដូច្នោះក៏និយាយថា "នែកូនអ្នកឆ្កួតទេឬបានជាយកស្មៅឱ្យគោស្លាប់ស៊ី?" ។ កូនឆ្លើយថា "បណ្តាយើងទាំងពីរនាក់នេះ តើអ្នកណាឆ្កួតជាង បើ១មនុស្សស្លាប់១គោស្លាប់" ។ ហើយកូនប្រាប់ថា "បើបិតាចង់ឱ្យបុត្របានអាហារបរិភោគ សូមយកអាហារទៅឱ្យអ្នកមានសីលបរិភោគ ហើយឧទ្ទិសផលឱ្យកូនទើបកូនបានទទួលទាននោះមែន" ។ ព្រាហ្មណ៍បានធ្វើតាមកូននោះ កូននោះក៏បានទទួលផលដូចសេចក្តីប្រាថ្នា ។

www.elibraryofcambodia.org

# ៧-អានិសង្សវិហារ

តាមព្យញ្ជនៈក្នុងភាសាបាលី ហៅទីវត្តអារាមទាំងមូលថាវិហារ. តែតាមទម្លាប់ពាក្យរបស់ពុទ្ធបរិស័ទ ហៅចំពោះតែអាគារ១ខ្នងធំ នៅចំកណ្ដាលវត្ត ដែលដំកល់ព្រះពុទ្ធបដិមាករ១ព្រះអង្គធំ ជាទីព្រះសង្ឃធ្វើសង្ឃកម្មផ្សេង១ មានឧបោសថកម្មជាដើម ហៅថាវិហារ ។

វិហារជាទីសាធារណៈ សំរាប់ព្រះសង្ឃមកពីទិសទាំង៤ធ្វើសង្ឃកម្មនិងសំរាប់ពុទ្ធបរិស័ទទាំង៤ទិស ធ្វើវត្តប្រតិបត្តិតាមព្រះពុទ្ធសាសនា ជាពិសេសគឺជាទីបណ្ដុះបុណ្យកុសលរបស់អ្នកកាន់ព្រះពុទ្ធសាសនាទាំងមូល ដើម្បីបានសំរេចលោកិយសម្បត្តិនិងលោកុត្តរសម្បត្តិ សមគួរតាមឧបនិស្ស័យរៀងខ្លួន ។

ដោយវិហារ ជាទីសាធារណៈ សម្រាប់ដំកល់ព្រះពុទ្ធរូបស្នងព្រះពុទ្ធអង្គផង សំរាប់ព្រះសង្ឃធ្វើសង្ឃកម្មផង សំរាប់ចតុព្វិធពុទ្ធបរិស័ទប្រតិបត្តិធម៌វិន័យពុទ្ធសាសនា ដើម្បីបានសំរេចលោកិយសម្បត្តិនិងលោកុត្តរសម្បត្តិផង ដូចពោលមកនេះ ទើបលោកថែងថាការសាងវិហារ ឬសាលា ក្ដីជាដើម ដំកល់ទុកជាទានក្នុងព្រះពុទ្ធសាសនា ជាការកុសល បានផលានិសង្សច្រើនជាអនេក ព្រោះជាការអាចញ៉ាំងព្រះពុទ្ធសាសនាឱ្យរុងរឿងអស់កាលជាអង្វែង ហើយជាការដែលថ្ងៃក្រោយទៅពុទ្ធបរិស័ទអ្នកចូលធ្វើបុណ្យកុសលផ្សេង១ ក្នុងវិហារនោះទាំងប៉ុន្មាន ឈ្មោះថាធ្វើបានដោយសារបានវិហារដែលគេសាងទុកនោះឯង ។ហើយអ្នកម្ចាស់ទាននោះ បានផលានិសង្សតាមលំដាប់រយៈពេល ដែលអ្នកចូលមកធ្វើបុណ្យកុសលជារៀងរាល់រយៈពេលនោះ១ ។

គម្ពីរចុល្លវគ្គ ត្រង់សេនាសនក្ខន្ធកៈ ថែងថាៈ

www.elibraryofcambodia.org

ក្នុងបឋមពោធិកាល ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទើបនឹងបានត្រាស់ថ្មីៗ ពុំទាន់ទ្រង់អនុញ្ញាតទីសេនាសនៈ គឺសាលា កុដិ ឬវត្តអារាម ដល់ភិក្ខុនៅឡើយ ភិក្ខុទាំងពួងគង់នៅភាត់ភាយក្នុងទីផ្សេងៗមានគល់ឈើ និងក្នុងព្រៃស្ងាត់ជាដើម បម្រើនសមណធម៌រកមគ្គផលនិព្វានបានសម្រេចតាមឧបនិស្ស័យរៀងរាល់អង្គ ។

# រឿងរាជគហសេដ្ឋី

វេលានោះ សេដ្ឋីម្នាក់ នៅនគររាជគ្រឹះជ្រះថ្លានឹងគុណសម្បត្តិរបស់ព្រះសង្ឃ ព្រមទាំងព្រះសម្មាសម្ពុទ្ធ បានសាងវត្តថ្វាយ ។ លុះសាងរួចហើយ និមន្តព្រះបរមគ្រូ ព្រមទាំងព្រះសង្ឃឆាន់ ហើយប្រគេនវត្តនោះ ចំពោះព្រះពុទ្ធអង្គព្រមទាំងព្រះសង្ឃ ដែលមកពីទិសទាំងបួន ។

ព្រះអង្គត្រាស់ទេសនាអនុមោទនាវិហារនោះថាៈ

សីតំ ឧណ្ហំ បដិហន្តិ ততো វាឡមិគានិ ច

សរីសបេ ច មកសេ សិសិរេ ចាបិ វុដ្ឋិយោ

តតោ វាតាតបោ ឃោរោ សញ្ជាតោ បដិហញ្ញតិ

លេណត្ថញ្ច សុខត្ថញ្ច ឈាយិតុញ្ច វិបស្សិតុំ

វិហារទានំ សង្ឃស្ស អគ្គំ ពុទ្ធេហិ វណ្ណិតំ ១

សេចក្ដីថាៈ សាធុសប្បុរសទាំងឡាយ! វិហារ គឺទីអាវាសវត្តអារាមមានរោងឧបោសថ កុដិ សាលាជាដើម ជាទីប្រកបដោយប្រយោជន៍ច្រើនប្រការ ការពារនូវរងារ ត្រជាក់ ក្ដៅ ដែលកើតពីរដូវប្រែប្រួលផង នូវភយន្តរាយដែលកើតពីម្រឹគសាហាវ និងពស់តូចពស់ធំ ល្អៀម មូស សុច ស្រាំងស្រូយទាំងពួងផង នូវភ្លៀងផង នូវខ្យល់និងកំដៅថ្ងៃដ៏ ខ្លាំងផង ។

វិហារទាន គឺការកសាងវត្តអារាម មានរោងឧបោសថកុដិ សាលាជាដើម ដែលបុគ្គលបានថ្វាយចំពោះសង្ឃ ដើម្បីជាទីជ្រកកោនជាទីសុខកាយស្រួលចិត្ត ជាទីដុតបង់នូវកិលេស ជាបាបធម៌និងជាទីស្ទឹងស្ទាធពិចារណា នូវវិបស្សនាព្រះពុទ្ធទាំងឡាយ តែងទ្រង់សរសើរថា ជាទានដ៏ប្រសើរ ។

ព្រោះហេតុនោះ បុរសឬស្ត្រីជាបណ្ឌិតទាំងឡាយ ដែលពិចារណាឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ហើយគួរសាងវិហារ គឺវត្តអារាមឬទីសេនាសនៈទាំងឡាយ មានរោងឧបោសថ ឬកុដិ សាលាជាដើម ឱ្យជាទីគួររីករាយចុះ ហើយគួរនិមន្តលោកជាពហុស្សុតទាំងឡាយ គឺលោកអ្នកចេះដឹងធម៌អាថ៌ច្រើន ឱ្យគង់នៅទីនោះ និងបានមានចិត្តជ្រះថ្លា ចំពោះលោកទាំងនោះ ដែលមានកាយនិងចិត្តស្មោះត្រង់ បានប្រគេនបាយទឹក សំពត់ និងគ្រឿងដេកអង្គុយ ដល់លោកទាំងនោះ លោកទាំងនោះ ក៏ដំដែងធម៌ជាគ្រឿងបន្ទោរបង់សេចក្តីទុក្ខទាំងពួង ដល់ជនទាំងនោះៗ បានដឹងធម៌អាថ៌ណាហើយ ក៏រមែងជាបុគ្គលមិនមានអាសវៈ បានដល់ព្រះនិព្វាន ។

កាលព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងអនុមោទនាផលានិសង្សវិហារទានពន្យល់រាជគហសេដ្ឋី ឱ្យត្រេកអរតាមទានរបស់ខ្លួន ដូច្នេះហើយក៏ទ្រង់សម្រាន្តព្រះឥរិយាបថក្នុងវិហារ (វត្ត) នោះ ។

# រឿងអនាថបិណ្ឌិកសេដ្ឋី

កាលដែលព្រះពុទ្ធអង្គទ្រង់គង់នៅវត្តរាជគហសេដ្ឋីទើបនឹងសាងថ្មីៗ អនាថបណ្ឌិកសេដ្ឋីបានទៅកាន់ផ្ទះរាជគហសេដ្ឋីនោះ ។ រាជគហសេដ្ឋីប្រាប់ថា "ព្រះពុទ្ធព្រះធម៌ព្រះសង្ឃឧបត្តិឡើងក្នុងលោកហើយ ឥឡូវទ្រង់គង់នៅក្នុងវត្តដែលខ្ញុំសាងថ្វាយនៅទិសឯណោះ" ។ អនាថបណ្ឌិកសេដ្ឋី ក៏មានសេចក្តី

www.elibraryofcambodia.org

ផ្ទះថ្វាក្រែពេក អាស្រ័យដំណេកយប់នោះពុំលក់សោះ បេះតែរឹកមមៃចង់ទៅថ្វាយបង្គំព្រះអង្គទាំងយប់ ។ លុះពេលវេលាអាធ្រាត្រ ដោយចង់ទៅពេកសេដ្ឋីកើតបីតិមានពន្លឺភ្លឺស្វាងឃើញទ្វារផ្ទះរបើក ស្មានថាភ្លឺ ក៏ចេញពីផ្ទះចុះដើរតម្រង់ទៅរកព្រះអង្គ តាមទិសដែលរាជគហសេដ្ឋីប្រាប់ ដើរកាត់ព្រៃស្មាតដែលគេបោលខ្មោចស្រស់ឃើញសាកសពច្រើនដេរដាស សពខ្លះកំពង់ហើមហោងប្រេងប្រងាងខ្លះនៅតែរាងឆ្អឹង មានចិត្តតក់ស្លុត ក៏បាត់ពន្លឺរស្មីទៅជាងងឹតសូន្យ ដោយភ័យខ្លាចខ្លាំងពេកក៏គិតត្រឡប់ថយក្រោយ តែបានឮសូរសំឡេងរុក្ខទេវតាស្រែកប្រាប់ថា "សូមអ្នកទៅមុខចុះ កុំភ័យអ្វី ខ្ញុំការពារអ្នកហើយ" ។

កាលឮដូច្នោះ អនាថបណ្ឌិក កើតបីតិប្រាមោជ មានពន្លឺភ្លឺមើលឃើញទិសទីឡើងវិញ ក៏ដើរទៅមុខទៀត លុះពេលជិតភ្លឺក៏បានទៅដល់ទីដែលព្រះថេម្មាសម្ពុទ្ធគង់ ។ ឯព្រះពុទ្ធអង្គកាលទ្រង់ប្រមើលមើលនិស្ស័យសត្វឃើញថាអនាថបណ្ឌិកមករកព្រះអង្គ ក៏ទ្រង់របេញទៅគង់ក្រោមដើមឈើ១ចាំទទួល ។ សេដ្ឋីបានឃើញព្រះអង្គក៏ចូលទៅថ្វាយបង្គំ ។ ព្រះពុទ្ធអង្គត្រាស់ហៅថា "សុទត្ត! ចូរអ្នកចូលមក" ។ កាលឮព្រះអង្គហៅថា សុទត្ត ជាឈ្មោះដើមរបស់ខ្លួន សេដ្ឋីដឹងច្បាស់ថាហ្នឹងហើយជាព្រះសព្វញ្ញុពុទ្ធព្រោះទ្រង់ជ្រាបឈ្មោះដើមរបស់ខ្លួន ដែលគេឈប់ហៅយូរហើយ ។

ក្រោយពីស្ដាប់ព្រះធម៌ក្នុងពេលដ៏ខ្លីនោះ សេដ្ឋីបានសម្រេចសោតាបត្តិផលជាអរិយបុគ្គលក្នុងព្រះពុទ្ធសាសនា រួចហើយសេដ្ឋីបាននិមន្តព្រះអង្គទៅឆាន់នៅផ្ទះរាជគហសេដ្ឋី ។ ទ្រង់ឆាន់ហើយព្រះអង្គធ្វើភត្តានុមោទនា សេដ្ឋីបាននិមន្តទៅក្រុងសាវត្ថី ដើម្បីនឹងសាងវត្ត ១ ថ្វាយ ។

ពោលដោយសង្ខេប លុះអនាថបណ្ឌិកត្រឡប់ទៅស្រុកវិញ បានទិញដី

ស្ងួនព្រះរាជកុមារ ឈ្មោះជេត សាងជាវត្តឡើងហៅថា វត្តជេតពន ត្រឹមតែ២ ខែក៏សាងវត្តនោះហើយស្រេច ៕

កាលព្រះពុទ្ធអង្គទ្រង់ទទួលនិមន្តអនាថបណ្ឌិកសេដ្ឋីហើយទ្រង់ចេញពីក្រុងរាជគ្រឹះ យាងទៅប្រោសសត្វក្នុងទីនានាអស់រយៈវេលា ២ ខែ ទើបទ្រង់ដល់ទៅក្រុងសាវត្ថីត្រូវនឹងពេលអនាថបណ្ឌិកកសាងវត្តជេតពនរួចហើយនោះឯង ។ អនាថបណ្ឌិកបាននិមន្តព្រះអង្គគង់នៅក្នុងវត្តជេតពននោះ ដូចយើងជាពុទ្ធបរិស័ទធ្លាប់ឮឈ្មោះមកដល់សព្វថ្ងៃ ។

ក្រោយពីអនាថបណ្ឌិកសេដ្ឋីសាងវត្តជេតពន នាងវិសាខាបានសាងវត្តបុព្វារាម និងឃោសិតសេដ្ឋី បានសាងវត្តឃោសិតារាមថ្វាយព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយក្នុងកាលជាលំដាប់មក ជនទាំងឡាយដទៃទៀតបានសាងវត្តនានាត១គ្នាមកទៀត ជាតំណមកដល់សព្វថ្ងៃ ។

គម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្តមានសំដែងថា កាលព្រះបរមគ្រូគង់ព្រះជន្មនៅឡើយ មានទេវតាចូលទូលសួរព្រះអង្គថា:

បពិត្រព្រះអង្គដ៏ចំរើន! ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថាឱ្យកម្លាំង? ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថាឱ្យពណ៌សម្បុរ? ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថាឱ្យសេចក្ដីសុខ? ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថាឱ្យចក្ខុ? ខ្ញុំព្រះអង្គក្រាបទូលសួរ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសទេសនាប្រាប់នូវការឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថាឱ្យគ្រប់មុខ ?

ព្រះអង្គត្រាស់ថា:

អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ
យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ

សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ
អមតន្ទទោ ច យោ ហោតិ យោ ធម្មមនុសាសតិ ។

ម្នាលទេវតា! ការឱ្យបាយជាទាន បានឈ្មោះថាឱ្យកម្លាំង ការឱ្យសំពត់ជាទាន បានឈ្មោះថាឱ្យពណ៌សម្បុរ កាឱ្យយានជាទាន បានឈ្មោះថាឱ្យសេចក្តីសុខ ការឱ្យប្រទីបជាទាន បានឈ្មោះថាឱ្យចក្ខុ. ចំណែកអ្នកដែលឱ្យទីលំនៅជាទាន បានឈ្មោះថាឱ្យគ្រប់មុខ. ជាពិសេស អ្នកណាបានប្រដៅធម៌ (ដល់អ្នកដទៃ) ជននោះ បានឈ្មោះថាឱ្យអម្រឹត គឺព្រះនិព្វាន ។

មួយទៀត ទេវតាក្រាបបង្គំទូលសួរថា:

បពិត្រព្រះអង្គដ៏ចម្រើន ! បុណ្យរមែងចម្រើនទាំងយប់ទាំងថ្ងៃ សព្វកាលទាំងពួងដល់ជនណា? ជនណាបានឈ្មោះថាជាអ្នកឋិតនៅក្នុងធម៌សម្បូណ៌ដោយសីលហើយ តែងបានទៅកើតក្នុងឋានសួគ៌?

ព្រះអង្គត្រាស់ថា:

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។

ម្នាលទេវតា! ជនទាំងឡាយណាបានដាំសួនឈើផ្កា ដាំសួនឈើដើម សង់ស្ពាន សាងរោងទឹក សាងអណ្តូងទឹកនឹងសាងទីលំនៅឱ្យទាន បុណ្យរបស់ជនរម្យាលនោះ រមែងរឹងរិតតែចម្រើនឡើងៗទាំងយប់ទាំងថ្ងៃ សព្វកាល

ទាំងពួង. ហើយជនអម្បាលនោះ បានឈ្មោះថាជាអ្នកឋិតនៅក្នុងធម៌សម្បូណ៌ ដោយសីលបានទៅកើតក្នុងឋានសួគ៌ ។

មួយវិញទៀត សាធុជនឯណាបានសាងវិហារ សាលា កុដិ វត្តអារាម ប្រគេនព្រះសង្ឃ ក៏ឈ្មោះថាថ្វាយព្រះពុទ្ធនិងព្រះធម៌ផង សូម្បីសាងមន្ទីរធម្ម-សភាជាទីកន្លែងដឹកលស់ព្រះធម៌ ក៏ឈ្មោះថាថ្វាយចំពោះព្រះពុទ្ធ និងព្រះសង្ឃផងដែរ ព្រោះព្រះរតនត្រ័យ គឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាវត្ថុជាប់គ្នា ខ្វះណាមួយមិនបានឡើយ គឺថាបើព្រះពុទ្ធបានត្រាស់ហើយមិនទ្រង់សំដែងធម៌ទេ ព្រះធម៌ក៏មិនច្បាស់ប្រាកដឡើងដល់លោក កាលបើព្រះធម៌មិនច្បាស់ប្រាកដ ព្រោះព្រះពុទ្ធមិនសំដែងហើយ កុលបុត្រទាំងពួងក៏មិនអាចបួសតាមបាន បើមិនមានកុលបុត្រណាមួយបួសតាមបានហើយ នឹងមានព្រះសង្ឃមកពីណា.លុះតែព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងហើយទ្រង់សំដែងធម៌ ទើបជនដែលប្រកបដោយសទ្ធានាំគ្នាបួសជាព្រះសង្ឃតាម ក៏មានព្រះរតនត្រ័យ គឺព្រះពុទ្ធរត័នព្រះធម្មរត័ន ព្រះសង្ឃរត័ន ប្រាកដឡើងក្នុងលោក ។

បរមត្ថជោតិកា អដ្ឋកថាខុទ្ទកនិកាយ ខុទ្ទកបាឋប្រៀបធៀបថា: ព្រះពុទ្ធដូចជាវង់ព្រះអាទិត្យកំពុងរះពេញពន្លឺចំ ព្រះធម៌ដែលព្រះពុទ្ធទ្រង់សំដែងដូចជាពន្លឺរស្មីនៃព្រះអាទិត្យ ព្រះសង្ឃដែលបានដឹងធម៌តាមព្រះពុទ្ធ ដូចឱកាសលោកដែលបានកំចាត់បង់នូវងងឹតងងល់អន្ធការ ដោយសារពន្លឺរស្មីនៃព្រះអាទិត្យ ។ វង់ព្រះអាទិត្យ និងពន្លឺ ហើយនិងសត្វលោកតែងអាស្រ័យគ្នានិងគ្នាលះបង់គ្នាមិនបាន យ៉ាងណាមិញ ព្រះរតនត្រ័យក៏អាស្រ័យគ្នានិងគ្នាយ៉ាងនោះ។ ព្រោះហេតុនោះ បានជាលោកសំដែងថា សាធុជនដែលបានសាងវិហារ សាលា កុដិ វត្តអារាមថ្វាយព្រះពុទ្ធ ក៏ដូចថ្វាយព្រះធម៌ និងព្រះសង្ឃ ទោះបីធ្វើ

ធម្មមន្ទីរសម្រាប់ដំកល់ព្រះត្រៃបិដកជាពុទ្ធវចនៈដែលហៅថា ព្រះធម៌ក៏ដូចជាថ្វាយព្រះពុទ្ធនិងព្រះសង្ឃដែរ ។

រួមសេចក្ដីដោយសង្ខេបទៅ ឃើញថា អ្នកដែលបានសាងវិហារ សាលា កុដិ វត្តអារាម ទុកក្នុងព្រះពុទ្ធសាសនា ហៅថា បានបូជាព្រះរតនត្រ័យដោយពិត ។

# រឿងនន្ទិយឧបាសក

ព្រះពុទ្ធឃោសាចារ្យ បានសំដែងរឿងនន្ទិយៈឧបាសកប្រារព្ធការកសាងទីសេនាសនៈ ថ្វាយព្រះសង្ឃមានព្រះពុទ្ធជាប្រធានថា ៈ

សម័យមួយ ព្រះបរមគ្រូជាម្ចាស់ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី. គ្រានោះមានកុលបុត្រម្នាក់ឈ្មោះនន្ទិយៈ ជាអ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា ជាអនុជាតបុត្រប្រព្រឹត្តបម្រើព្រះសង្ឃតាមវង្សត្រកូលមាតាបិតា លុះមាតាបិតាក្ស័យជីវិតទៅ គាត់បានជាមហាទានាធិបតី ថ្វាយទានចំពោះព្រះសង្ឃ និងឱ្យទានដល់មនុស្សកំសត់ទុគ៌ត អនាថា បានសាងសាលា ១ ខ្នង មានមុខ ៤ បួនល្វែងនៅព្រៃឥសិបតនមិគទាយវ័ន ព្រមទាំងសេនាសនៈជារបស់សម្រាប់សាលានោះជាច្រើន លុះធ្វើស្រេចហើយ គាត់ប្រគេនចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ហើយញ៉ាំងទឹកទក្ខិណោទកឱ្យធ្លាក់ចុះលើបាតព្រះហស្តព្រះតថាគត គ្រានោះ ប្រាសាទជាវិការៈនៃកែវ៧ប្រការ ទំហំ១២យោជន៍ កំពស់១៧យោជន៍ ព្រមទាំងនាងទេពធីតា កើតឡើងក្នុងឋានត្រៃត្រិង្សទេវលោក ។

ថ្ងៃមួយ ក្នុងកាលជាខាងក្រោយ ព្រះមហាមោគ្គល្លានត្ថេរហោះទៅកាន់ទេវចារិកក្នុងទេវលោក បានឃើញប្រាសាទទិព្វនោះ ក៏សួរនាងទេពធិតាទាំងឡាយថា "ប្រាសាទទិព្វនោះជារបស់នរណា?" ។ ទេពធីតាទាំងឡាយពិត

ផែវវាចាថា "របស់ទនិយឧបាសក" ។

ពួកនាងទេពធីតាដែលអង្គុយចាំគ្រៀបគ្រាក្នុងប្រាសាទនោះ ក៏ផ្ដាំមក និងព្រះមហាមោគ្គល្លានឱ្យប្រាប់នន្ទិយឧបាសកផង ឱ្យប្រញាប់ទៅកើតក្នុងទីនេះ កុំខាន ។

ព្រះមហាមោគ្គល្លានត្រឡប់ចុះពីទេវលោកមកវិញ បានចូលទៅក្រាបទូលបង្គំសេចក្ដីនោះ ចំពោះព្រះបរមសាស្ដា. ព្រះអង្គទ្រង់សំដែងព្រះគាថាថា:

ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ

ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ

តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ

បុញ្ញានិ បដិគ្គណ្ហន្តិ បិយំ ញាតីវ អាគតំ ។

សេចក្ដីថា: ពួកជនជាញាតិសន្ដានព្រៀងលាន និងមិត្រ សំឡាញ់ស្នេហ៍ម្រាក់ដែលជាអ្នកមានចិត្តល្អជាដល់គ្នានិងគ្នា រមែងមានចិត្តត្រេកអរចំពោះបុរសជាញាតិមិត្រ ដែលព្រាត់ប្រាសគ្នាជាយូរអង្វែងហើយ គេបានដល់នូវសិរីសួស្ដី គឺបានជានាយឈ្មួញមានទ្រព្យចម្រើនឬជានាហ្មឺន ដែលមកអំពីចម្ងាយ រមែងទទួលរាក់ទាក់ មាននិយាយសំដីពិរោះពិសារ និងលើកដៃសំពះសួរគ្នាជាដើម មានឧបមាយ៉ាងណាមិញ. បុណ្យទាំងឡាយក៏រមែងរង់ចាំទទួលជនដែលធ្វើបុណ្យ ហើយច្យុតអំពីលោកនេះទៅកាន់លោកខាងនាយ តែងនាំយកគ្រឿងបណ្ណាការ ១០ យ៉ាង គឺអាយុវែងយឺនយូរ សម្បុរល្អស្រស់សុខកាយស្រួលចិត្តយសស័ក្តិ អធិបតីជាធំ រូបល្អ សំឡេងពីរោះ ក្លិនក្រអូប សេដ្ឋាញ់ពិសារនិងគ្រឿងចាប់កាន់ពាល់ត្រូវយ៉ាងល្អមកប្រគល់ឱ្យ ដូចជាញាតិទាំង

ឡាយ ដែលជាទីស្រឡាញ់ពេញចិត្តគ្នា ហើយមកសួរគ្នា គេតែងទទួលគ្នា ដោយគ្រឿងសក្ការៈ មានបាយទឹកនំចំណីថ្មីថ្មោងយ៉ាងគាប់ចិត្តជាដើម ។

ឯឧទ្ទិយឧបាសកនោះ កាលបើអស់អាយុអំពីមនុស្សនេះ ក៏បានទៅសោយសុខក្នុងប្រាសាទកែវ ដែលកើតឡើងចាំទទួលគាត់ ពីកាលដែលវេរសាលាថ្វាយព្រះបរមគ្រូជាម្ចាស់នោះឯង ។

# ៨.អានិសង្សកុដិសាលា

រតនៈទាំង ៣ គឺពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ លោកហៅថារតនត្រ័យ ព្រះរតនត្រ័យនេះជាវត្ថុជាប់គ្នា ខ្វះណាមួយមិនបានជាដាច់ខាត គឺថាបើព្រះពុទ្ធបានត្រាស់ហើយ មិនទ្រង់សំដែងព្រះធម៌ទេ ព្រះធម៌ក៏មិនច្បាស់ប្រាកដឡើងដល់សត្វលោក កាលបើព្រះធម៌មិនច្បាស់ប្រាកដ ព្រោះព្រះពុទ្ធមិនសំដែងហើយ កុលបុត្រទាំងពួងក៏មិនអាចបួសតាមបាន បើមិនមានកុលបុត្រណាមួយបួសហើយ នឹងមានព្រះសង្ឃមកពីណា. លុះតែព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងហើយ ទ្រង់សំដែងព្រះធម៌ ទើបជនដែលប្រកបដោយសទ្ធា នាំគ្នាបួសតាមបាន ក៏មានព្រះរតនត្រ័យ គឺព្រះពុទ្ធរត័ន ព្រះធម្មរត័ន ព្រះសង្ឃរត័ន ប្រាកដឡើងក្នុងលោក ។

បរមត្ថជោតិកា អដ្ឋកថា ខុទ្ទកបាឋ ប្រៀបធៀបថា ព្រះពុទ្ធដូចជាវង់ព្រះអាទិត្យរះពេញពន្លឺ ព្រះធម៌ដែលព្រះពុទ្ធទ្រង់សំដែង ដូចជាពន្លឺរស្មីនៃព្រះអាទិត្យ. ព្រះសង្ឃដែលបានដឹងធម៌តាមព្រះពុទ្ធ ដូចឱកាសលោកដែលបានកំចាត់បង់នូវងងឹតអន្ធការ ដោយសារពន្លឺរស្មីនៃព្រះអាទិត្យ ។ ធម្មតាវង់ព្រះអាទិត្យហើយនិងពន្លឺ ព្រមទាំងសត្វលោកតែងអាស្រ័យគ្នានិងគ្នា លះបង់គ្នាមិនបាន យ៉ាងណាមិញ ព្រះរតនត្រ័យក៏អាស្រ័យគ្នានិងគ្នាយ៉ាង នោះដែរ ។

ព្រោះហេតុនោះ បានជាលោកសំដែងថា សាធុជន អ្នកមានសទ្ធាបាន សាងកុដិសាលាឬវិហារថ្វាយព្រះពុទ្ធ ក៏ដូចថ្វាយព្រះធម៌ និងព្រះសង្ឃ. ថ្វាយព្រះសង្ឃ ក៏ដូចថ្វាយព្រះធម៌និងព្រះពុទ្ធ. ទោះបីសាងធម្មសភាជាទីប្រជុំធម៌ ឬធម្មមន្ទីរជាទីដំកល់ព្រះត្រៃបិដក គឺពាក្យប្រដៅរបស់ព្រះពុទ្ធដែលហៅថាព្រះធម៌ ក៏ឈ្មោះថាថ្វាយចំពោះព្រះរតនត្រ័យដោយពិត ។

ជនដែលបានសាងទីសេនាសនៈ មានកុដិសាលាជាដើម ថ្វាយព្រះរតនត្រ័យហៅថា "អ្នកធ្វើបុណ្យ" ។ បុណ្យនេះ បើជនណាបានធ្វើហើយ ចោរលួចមិនបានព្រោះជានាមធម៌នៅក្នុងរូប ហើយនៅក្នុងចិត្តផងទៀត ។ សមដូចគម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្ត ដែលព្រះដ៏មានបុណ្យទ្រង់ឆ្លើយប្រស្នាទេវតាថា :

**សីលំ យាវជរា សាធុ សទ្ធា សាធុ បតិដ្ឋិតា**
**បញ្ញា នរានំ រតនំ បុញ្ញំ ចោរេហិ ទុហរំ ។**

សីលញុំាងប្រយោជន៍ឱ្យសម្រេចបានដរាបដល់ចាស់ជរា សទ្ធាដែលបុគ្គលដំកល់មាំហើយ ញុំាងប្រយោជន៍ឱ្យសម្រេចបាន បញ្ញាជាដួងកែវរបស់នរជនទាំងឡាយ បុណ្យពួកចោរនាំយកទៅមិនបាន ។

គម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាតសំដែងថា:

**បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ**

បុណ្យទាំងឡាយ ជាទីពឹងរបស់សត្វទាំងឡាយ ក្នុងបរលោក ។

អធិប្បាយថា: បុណ្យដែលជនណាបានធ្វើ នៅក្នុងជាតិនេះហើយ ជាទីពឹងដល់ជននោះ ក្នុងជាតិខាងមុខ ដូចព្រះបាទមហាកប្បិននោះឯង ។

www.elibraryofcambodia.org

# រឿងព្រះបាទមហាកប្បិនដិងព្រះនាងអនោជា

អដ្ឋកថាធម្មបទ និទានរឿងព្រះបាទមហាកប្បិន ពិស្តារតែក្នុងទីនេះសូមទ្រង់ស្រង់យកតែគោល១ ខ្លះ ដោយសង្ខេបដូចតទៅនេះ:

ក្នុងពុទ្ធកាលនៃព្រះពុទ្ធ ព្រះនាមកស្សប គហបតីម្នាក់និងភរិយា ព្រមទាំងគហបតីជាមិត្ត ប្រមាណមួយពាន់នាក់មានចិត្តសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ។ ថ្ងៃមួយ ជនទាំងនោះចូលទៅកាន់វត្តមួយ ដើម្បីស្តាប់ធម៌ទេសនាក្នុងវេលាយប់ ស្រាប់តែមហាមេឃបង្អោរភ្លៀងមួយមេយ៉ាងធំ ។ ពួកជនដែលគេស្គាល់ស្និទ្ធស្នាលនិងភិក្ខុក្នុងវត្ត គេរត់ចូលជ្រកក្នុងកុដិ សម្រាកបានងាយស្រួល ។ ឯគហបតីធំនិងភរិយាព្រមទាំងគហបតីជាមិត្តទាំងមួយពាន់នាក់ ដែលឥតមានស្គាល់លោក នាំគ្នាចូលជ្រកក្រោមកុដិលោក និងទីក្បៀនកោះផ្សេងៗតាមតែប្រទះឱ្យតែគត់ភ្លៀង ។ គហបតីធំនិងភរិយា ព្រមទាំងគហបតីមួយពាន់នាក់ជាមិត្ត បានគិតគ្នាថា គពីនេះទៅ យើងត្រូវសាងកុដិប្រគេនលោកដើម្បីឱ្យស្រួលធ្វើបុណ្យទានតទៅ ។ គិតគ្នាហើយ លុះត្រឡប់មកផ្ទះវិញគហបតីធំនិងភរិយា ព្រមទាំងគហបតីជាមិត្តទាំងមួយពាន់នាក់ ក៏ផ្តើមចាត់ការសាងកុដិ១ខ្នងម្នាក់ប្រគេនលោកក្នុងវត្តនោះ បានរួចស្រេចដោយរហ័សរួចហើយបានចាត់ការធ្វើបុណ្យឆ្លងវេរកុដិថ្វាយព្រះសង្ឃ ។ វេលាធ្វើបុណ្យនោះ នាងដែលជាភរិយាគហបតីធំនិងភរិយាគហបតីជាមិត្តទាំងមួយពាន់នាក់ចាត់ចែងត្រៃចីវរ ដើម្បីប្រគេនព្រះសង្ឃ ។

ឯនាងជាភរិយាគហបតីធំ បានយកអនោជបុប្ផ (ផ្កានោង) ដាក់លើត្រៃចីវររបស់ខ្លួន ជាពាំអ និងជាសក្ការបូជា ។ ព្រោះវេរកុដិ និងត្រៃចីវរប្រគេន

ព្រះសរីរៈ នាងបានប្រាថ្នាថា "ដោយអំណាចផលទានរបស់នាងខ្ញុំ ដែលមានផ្កានោះ ជាសក្ការៈនេះ សូមឱ្យនាងខ្ញុំទៅកើតក្នុងជាតិណាៗ ឱ្យមានសម្បុរដូចជាផ្កានោះនោង ហើយឱ្យមានឈ្មោះថា "នាងអនោជា" ផង ។

ក្រោយផលានិសង្សនៃកុសលនេះហើយ គហបតីធំនិងភរិយាលុះធ្វើមរណកាលពីមនុស្សនេះទៅ បានទៅកើតជាទេវតាក្នុងឋានត្រៃត្រឹង្សតិទេវលោក. នាងជាភរិយាបានកើតជានាងទេពធីតាឈ្មោះថា អនោជា. គហបតីជាមិត្រ និងភរិយា បានទៅកើតជាទេវបុត្រ ទេពធីតាជាមិត្តសំឡាញ់ទាំងមួយពាន់ សោយសម្បត្តិទិព្វក្នុងទិព្វវិមានអស់កាលដ៏យូរលង់ ចំនួន ១ ពុទ្ធន្តរ (ចន្លោះព្រះពុទ្ធមួយព្រះអង្គ) ។ លុះដល់មកក្នុងពុទ្ធកាលនៃព្រះសក្យមុនីគោតមបរមគ្រូនៃយើងនេះ ទើបច្យុតមកកើតជាមនុស្ស ក្នុងជម្ពូទ្វីប ។ គហបតីធំបានកើតជាព្រះរាជាមួយអង្គ ព្រះនាមមហាកបិន នាងភរិយាបានកើតជាព្រះអគ្គមហេសី មានព្រះនាមថាអនោជាទេវី មានព្រះឆវិវណ្ណ ភ្លឺថ្លាដូចផ្កានោង ។

ដោយនិស្ស័យជាអ្នកមានសទ្ធាចំពោះព្រះពុទ្ធសាសនា ហើយមានបញ្ញាជាសម្មាទិដ្ឋិពីបុព្វជាតិមក លុះបានសោយរាជឡើង ព្រះមហាកបិនរាជ ទ្រង់ចេះតែមានព្រះទ័យចង់ឃើញចង់ជួបនិងព្រះអរហន្តដែលជាបុគ្គលបរិសុទ្ធវិសេស គួរគោរព គួរបូជា ទ្រង់ចេះតែសួរដំណឹងរកតាមអ្នកដំណើរ ដែលជាទេសចរក៏ផ្សេងៗ ។

កំពុងតែទ្រង់សួររក ស្រាប់តែមានពាណិជម្នាក់មកពីក្រុងសាវត្ថីបានក្រាបទូលថា "ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតឡើងហើយក្នុងលោក. សព្វថ្ងៃគង់នៅនគរសាវត្ថី" ។

www.elibraryofcambodia.org

ព្រះមហាកប្បិនបានទ្រង់ព្រះសណ្ដាប់ ទ្រង់ត្រេកអរក្រៃពេក ទ្រង់លះរាជសម្បត្តិចេញចាកព្រះនគរ ដោយព្រះទីនាំងអស្សតរជាមួយនឹងរាជអមាត្យជាមិត្តមួយពាន់នាក់ កាត់ទៅរកព្រះសម្មាសម្ពុទ្ធឯវត្តជេតពនក្រុងសាវត្ថី ។ លុះទ្រង់យាងទៅដល់ពាក់កណ្ដាលផ្លូវ ជួបនឹងស្ទឹងធំ ១ ខាន់ផ្លូវ តែដោយព្រះរាជាទ្រង់បួងសួងដល់បុណ្យព្រេងវាសនាថា "បើខ្ញុំមានបុណ្យបានសាងពីជាតិមុនមកច្រើន ត្រូវបានជួបបានថ្វាយបង្គំផ្ទាល់ព្រះពុទ្ធជាម្ចាស់ពេលនេះមែន សូមឱ្យសេះឆ្លងស្ទឹងនេះរួចដោយសុវត្ថិភាព" ។ ទ្រង់បួងសួងស្ទើរតែមិនទាន់ផុតពីព្រះឱស្ឋ ទឹកស្ទឹងស្រាប់តែគោករីង សេះដើរឆ្លងទៅបានដោយស្រួល ។ ព្រះរាជាទ្រង់យាងទៅដោយស្មាន ៗ មិនជ្រាបថាត្រូវទៅតាមផ្លូវណា តែដោយការម៉ឺចាស់ក្លានៃព្រះអង្គផង ដោយព្រះពុទ្ធអង្គទ្រង់មេត្តាប្រោសព្រះអង្គផង ព្រះបរមគ្រូក៏ស្ដេចមកគង់ចាំត្រង់ទី១ ហើយទ្រង់ផ្សាយព្រះឆព្វណ្ណរង្សី៦ពណ៌ ក្ដីផ្លេក ៗ ភ្លែត ៗ ជាខ្សែ ៗ ទៅនាំព្រះរាជដំណើរ ។ ព្រះរាជាទតឃើញព្រះឆព្វណ្ណរង្សីនោះ ក៏ទ្រង់ស្រូតព្រះរាជដំណើរ មិនយូរប៉ុន្មានស្ដេចបានជួបនឹងព្រះពុទ្ធជាម្ចាស់ ទ្រង់ចូលថ្វាយបង្គំសុំបួសដោយគោរព ។ ព្រះពុទ្ធអង្គទ្រង់បំបួសព្រះរាជាព្រមទាំងរាជអាមាត្យទាំងមួយពាន់ ដោយឯហិភិក្ខុឧបសម្បទា បានសម្រេចព្រះអរហត្តផល ។

ក្រោយពីនោះ ព្រះនាងអនោជាទេវី និងស្ត្រីជាភរិយាអាមាត្យទាំងមួយពាន់នាក់ ក៏យាងទៅតាមព្រះរាជា តាមស្វាមីរៀងខ្លួន យាងទៅដោយរាជរថ និងទៅដោយសេះទាំងមួយពាន់ ។ ដល់នៅស្ទឹងដែលខាំងផ្លូវព្រះរាជាពីមុនស្ទឹងនោះក៏ខាំងព្រះរាជដំណើរព្រះនាងទៀត តែដោយព្រះនាងបួងសួងដល់បុណ្យពីបុព្វេ ដូចព្រះរាជា ព្រះនាងក៏យាងទៅរួចដោយសុវត្ថិភាព ហើយ

ព្រះពុទ្ធអង្គស្តេចមកគង់ចាំកណ្តាលផ្លូវ ព្រមទាំងព្រះមហាកបិនភិក្ខុនិងភិក្ខុមួយពាន់អង្គ ដែលទើបនឹងបួសថ្មី ទ្រង់ផ្សាយព្រះឆព្វណ្ណរង្សីឱ្យទៅនាំព្រះដំណើរដូចគ្នា។ ពេលដែលព្រះនាងយាងដល់ ថ្វាយបង្គំព្រះពុទ្ធជាម្ចាស់ ព្រះអង្គមិនឱ្យព្រះនាងឃើញព្រះមហាកបិនភិក្ខុនិងភិក្ខុទាំងមួយពាន់អង្គនោះឡើយ ក្រែងចិត្តស្ត្រីមានសេចក្តីសោកស្តាយស្វាមីរបស់ខ្លួន មិនអាចសម្រេចមគ្គផលបាន ។ លុះព្រះនាងអនោជានិងស្ត្រីភរិយាអាមាត្យទាំងមួយពាន់នាក់ បានស្តាប់ធម្មទេសនាបានឧបសម្បទាជាឯហិភិក្ខុនីសម្រេចមគ្គផលហើយ ទើបទ្រង់ឱ្យឃើញព្រះមហាកបិនភិក្ខុនិងភិក្ខុទាំងមួយពាន់អង្គនៅក្បែរនោះ ដោយសេចក្តីជ្រះថ្លា ។

ជនទាំងឡាយ មានព្រះមហាកបិនភិក្ខុជាដើមបានលោកិយសម្បត្តិនិងលោកុត្តរសម្បត្តិដូចពោលមកនេះ គឺបានដោយសារផលានិសង្សនៃការកសាងបុញ្ញកិរិយាវត្ថុទាំងឡាយ ពីបុព្វជាតិ គឺការសាងកុដិនាំឱ្យបានជាស្តេច ជាព្រះទេពីស្តេច ជារាជអាមាត្យ ជាភរិយារាជអាមាត្យមានរាជសម្បត្តិ មានប្រាសាទពិមាន មានទ្រព្យសម្បត្តិ និងយសសក្តិ ការសាងត្រៃចីវរនាំឱ្យបានជាឯហិភិក្ខុ ឯហិភិក្ខុនីដែលវេលាបួសមានត្រៃចីវរកើតឡើង ដោយឥទ្ធិឫទ្ធិ គឺកើតឯងក្នុងពេលដែលបួសនោះ ។

## ៩_អានិសង្សបង្គន់

បង្គន់ជាទីបន្ទោរបង់ឧច្ចារៈបស្សាវៈ (មូត្រ-លាមក) លោករាប់ចូលក្នុងសេនាសនបច្ច័យ ដូចកុដិ សាលា ឬផ្ទះសម្ងែងនិងទីសេនាសនៈឯទៀតដែរ ព្រោះជាទីជ្រកអាស្រ័យ ដើម្បីបន្ទោរបង់និងដើម្បីការពារត្រជាក់ក្តៅដូចគ្នា ប៉ុន្តែកុដិសាលា ឬផ្ទះសម្ងែងសម្រាប់ដេកទៅ បង្គន់សម្រាប់បន្ទោរបង់មូត្រលាមកប៉ុណ្ណោះ ដែលនរណា១ ក៏ត្រូវតែបិទបាំងខ្មាសក្នុងពេលបន្ទោរបង់

www.elibraryofcambodia.org

ជាការចាំបាច់ខានពុំបាន ។

ព្រោះហេតុនេះ កាលបើពោលដល់ផលានិសង្សខាងការសាងបង្គន់ជាទាន ក៏ប្រហាក់ប្រហែលនិងអានិសង្សខាងការសាងកុដិសាលា និងសេនាសនៈដូចគ្នា តែបើពោលឱ្យល្អិតទៅ ការសាងបង្គន់អានផលានិសង្សប្លែកពីការសាងសេនាសនៈឯទៀតៗបន្តិច ចំពោះការបិទបាំងខ្មាស និងការបន្ទោបង់ដែលជាការចាំបាច់ត្រូវតែបិទបាំង ត្រូវតែបន្ទោបង់ ជាការប្រញាប់ឱ្យទាន់ពេលខានពុំបាន ។

កាលបើបង្គន់ជាទីសំខាន់ត្រង់ការបន្ទោរបង់ ជាការចាំបាច់ដូចពោលហើយ ផលានិសង្សនៃការសាងបង្គន់ ក៏ត្រូវតែមានច្រើន ជាការសំខាន់ដែរព្រោះជាការសង្គ្រោះដោះទុក្ខអ្នកមានធុរៈ ដែលរាប់ចូលក្នុងសង្គហវត្ថុគ្រឿងសង្គ្រោះផង ។

ដែលថាការសាងបង្គន់បានផលានិសង្សច្រើននោះដោយអាងដល់រឿងព្រះពាកុលត្ថេរ ដែលព្រះអដ្ឋកថាចារ្យសំដែងទុកក្នុងអដ្ឋកថាធម្មបទប្រាវត្តិនិងការសាងបង្គន់ដូចតទៅនេះ:

## រឿងព្រះពាកុលត្ថេរ

ក្នុងសាសនាព្រះពុទ្ធកស្សប មុនសាសនាព្រះសមណគោតមបរមគ្រូនៃយើងនេះ មានគហបតីម្នាក់ បានឃើញព្រះអរហន្ត ១ អង្គ លោកឈឺបន្ទោបង់ឧច្ចារៈភាន់ខ្លាំងត្រង់ទីកណ្ដាលវាល ដែលមានមនុស្សច្រើន លោកដើររកបង្គន់ដើម្បីបន្ទោរបង់លាមក. គហបតីនោះបានឃើញបានដឹងរឿងនោះ ក៏ប្រញាប់ប្រញាល់យកសំពត់ធ្វើជារនាំងបិទបាំងជាបង្គន់ប្រគេនលោកភ្លាមទាន់ពេល លោកក៏បន្ទោបង់ដោយស្រួល ហើយគហបតីនោះទូលលោកថា "ផ្កាយ

អំណាចផលដែលខ្ញុំព្រះករុណាបានធ្វើបង្គន់ប្រគេនលោកម្ចាស់ ដោយរួសរាន់ទាន់ពេលនេះ បើលោកម្ចាស់បានសម្រេចធម៌ណាក្នុងអត្តភាពនេះ សូមឱ្យខ្ញុំព្រះករុណាបានសម្រេចធម៌នោះដូចលោកម្ចាស់ផង ក្នុងជាតិខាងមុខកុំខាន ។

ព្រះថេរៈទទួលថា អ្នកប្រាថ្នាយ៉ាងណា សូមឱ្យបានសំរេចយ៉ាងនោះ ។

គហបតីនោះ លុះអស់អាយុទៅបានទៅកើតជាទេវបុត្រឋិតនៅក្នុងឋានទេវលោក អស់ ១ ពុទ្ធន្តរ (១ចន្លោះព្រះពុទ្ធ) លុះមកដល់ពុទ្ធកាលនៃព្រះសមណគោតមបរមគ្រូជាម្ចាស់យើងនេះ ទេវបុត្រនោះច្យុតចាកឋានសួគ៌មកកើតក្នុងត្រកូលសេដ្ឋីមួយនៅក្បែរមាត់ទន្លេ ។ វេលាប្រសូត្រមាតាបិតាយកទារកនោះទៅធ្វើមង្គលនៅមាត់ទន្លេ ផ្ងូតទឹកក្នុងទន្លេ ទារកនោះរបូតពីដៃមាតាធ្លាក់ទៅក្នុងទឹក មានត្រីធំ ១ លេបទៅក្នុងពោះហែលតាមទន្លេទៅ. មានអ្នកនេសាទចាប់ត្រីនោះបាន យកទៅលក់ឱ្យសេដ្ឋីម្នាក់នៅមាត់ទន្លេជិតនោះដែរ ។ សេដ្ឋីនោះឱ្យវះពោះត្រីនោះ ឃើញកូននោះនៅក្នុងពោះ ក៏ត្រេកអរពន់ប្រមាណ យកកូននោះទុកជាកូនស្រឡាញ់ដូចកូនបង្កើតរបស់ខ្លួន ។

ឯសេដ្ឋីជាមាតាបិតាបង្កើតបានដំណឹងនោះ ក៏មកសុំកូននោះទៅវិញ តែសេដ្ឋីជាមាតាបិញ្ចឹមពុំឱ្យ ហើយត្រកូលសេដ្ឋីទាំងពីរ បានដាក់វេនគ្នាបិញ្ចឹមកូននោះ ៤ ខែម្នាក់ ។ កូននោះក៏បានឈ្មោះថា ពាកុលកុមារ (កុមារត្រកូលពីរ) តាំងពីថ្ងៃនោះមក ។

លុះពាកុលកុមារនោះ មានវ័យចម្រើនឡើងបានអាយុ ២០ ឆ្នាំបានបួសជាភិក្ខុមាននាមថា ពាកុលត្ថេរ បានជាព្រះអរហន្ត ១ អង្គ ក្នុងព្រះពុទ្ធសាសនា លោកមានសុខភាពល្អណាស់ ឥតមានរោគាអ្វីបន្តិចបន្តួចទេតាំងពីប្រសូតរហូតដល់ចាស់ លោកមានព្រះជន្ម១៦០ឆ្នាំ ទើបចូលនិព្វាន ។

www.elibraryofcambodia.org

## ១០_អានិសង្សពិតានរនាំងវាំងននៈ

សំពត់ដែលគេដេរភ្ជាប់ជាផ្ទាំង ៤ ជ្រុងស្មើ ឬ ៤ជ្រុងទ្រវែងសម្រាប់បិទបាំងភ្ជាប់ពីក្រោមដំបូលកុដិ ឬគ្រឹះស្ថាន ឬក៏ដំបូលគ្រែ ទំហំធំ ឬតូចតាមភាពទីកន្លែង ដើម្បីការពារកំដៅ ការពារវត្ថុមិនស្អាត កុំឱ្យធ្លាក់ចុះមកលើទីដេក ទីអង្គុយហៅថាពិតាន. សំពត់ដែលគេដេរភ្ជាប់ជាផ្ទាំងធំៗវែងៗ សម្រាប់បិទបាំងទីដេកទីអង្គុយ ដើម្បីកំចាត់សេចក្ដីអៀនខ្មាស ហៅថា រនាំងឬវាំងនន ។ ពិតានឬរនាំងវាំងននោះ ជាគ្រឿងបិទបាំងផង ជាគ្រឿងលំអផង គ្រឿងបូជាផង សូម្បីព្រះសុគន្ធ កុដិរបស់ព្រះពុទ្ធអង្គកាលគង់ព្រះធរមាននៅឡើយ ក៏មានពិតានរនាំងវាំងននដែរសឹងមាននិទានជាភស្តុតាងដូចតទៅនេះ

## រឿងចុល្លេកសាដកព្រាហ្មណ៍

អដ្ឋកថាធម្មបទ សំដែងរឿងចុល្លេកសាដកព្រាហ្មណ៍ថាៈ

កាលព្រះពុទ្ធអង្គគង់នៅវត្តជេតពន ទេ្យបក្រុងសាវត្ថី មានព្រាហ្មណ៍ទុគិតម្នាក់ឈ្មោះ ចុល្លេកសាដកៈ ។គាត់មានសំពត់សាដកតូច១ដណ្ដប់២នាក់ប្ដីប្រពន្ធ ។ គាត់ជាអ្នកមានសទ្ធាជឿព្រះពុទ្ធសាសនា តែងទៅស្ដាប់ព្រះធម៌នៃព្រះបរមសាស្ដារាល់ថ្ងៃ រាល់យប់ តែដោយគាត់មានសំពត់ដណ្ដប់តែ ១ សំរាប់ប្រើ២នាក់ប្ដីប្រពន្ធ ទើបប្រពន្ធទៅស្ដាប់វេលាថ្ងៃប្ដីទៅស្ដាប់វេលាយប់ ។

នៅយប់ ១ នោះ ចុល្លេកសាដកៈជាប្ដីបានទៅស្ដាប់ព្រះធម៌ជាមួយ និងពួកពុទ្ធបរិស័ទទាំងឡាយ មានព្រះរាជាបសេ្សនទិកោសលជាដើម កាលស្ដាប់ទៅកើតសេចក្ដីជ្រះថ្លាចង់បូជាព្រះធម៌ដោយវត្ថុអ្វីមួយ តែគាត់ពុំមានវត្ថុអ្វីក្រៅពីសាដកដែលដណ្ដប់នៅខ្លួននោះ គាត់ស្ដាប់ផង គិតផងថា "អញមាន

www.elibraryofcambodia.org

សំពត់ដណ្ដប់តែមួយគត់ ដណ្ដប់ពីរនាក់ប្ដីប្រពន្ធ បើបូជាសំពត់នេះទៅខ្លួនអញជាប្រុសមិនជាអ្វីទេ តែចំណែកខាងប្រពន្ធអញជាស្រីមុខជាគ្មានអ្វីដណ្ដប់ទេនឹងចេញទៅក្រៅផ្ទះពុំបាន" ។

តាមចិត្តសទ្ធារបស់គាត់ ចង់បូជាសំពត់នោះឱ្យខាងតែបាន តែចិត្តសទ្ធាតែ១ ចិត្តកំណាញ់ដល់ទៅ១០០០មកគ្របសង្កត់ ។ ចិត្តទាំង២នោះច្បាំងគ្នា ចិត្តសទ្ធាថាបូជា ចិត្តកំណាញ់ថាកុំ ។ គាត់គិតតែក្នុងចិត្តឥតនរណាដឹងឡើយ ។ ដោយចិត្តសទ្ធាតែ ១ តែមានកម្លាំងខ្លាំងជាង ក្នុងទីបំផុតចិត្តសទ្ធាក៏ឈ្នះចិត្តកំណាញ់ ។ កាលឈ្នះហើយគាត់ស្រែកខ្លាំងៗ ថា "ជិត បេ ៗ អញឈ្នះហើយ ៗ" ។

ធម្មតាពាក្យថា "ឈ្នះហើយ" ជាសត្រូវនឹងព្រះកាណ៌របស់ព្រះរាជា ។ វេលាចុល្លេកសាដកព្រាហ្មណ៍ស្រែកដូច្នោះព្រះរាជាបសេនទិកោសល ស្ដេចទ្រង់គង់ជិតនោះទ្រង់ព្រះសណ្ដាប់ឮ ក៏ទ្រង់សួរថា "ម្នាលព្រាហ្មណ៍ អ្នកស្រែកថា "អញឈ្នះហើយ ៗ នោះ តើអ្នកឈ្នះយើង ឬឈ្នះនរណា?" ។ ព្រាហ្មណ៍ទូលថា "ទូលព្រះបង្គំមិនឈ្នះព្រះអង្គឬឈ្នះនរណាទេ ឈ្នះតែចិត្តកំណាញ់របស់ទូលព្រះបង្គំ ដែលច្បាំងគ្នានិងចិត្តសទ្ធា គឺចិត្តសទ្ធាចង់យកសំពត់សាដកតែ ១ ដែលប្រើគ្នា ២ នាក់ប្ដីប្រពន្ធផ្លាស់វេនគ្នា ថ្ងៃប្រពន្ធមកស្ដាប់ព្រះធម៌ទូលព្រះបង្គំនៅផ្ទះ វេលាយប់ទូលព្រះបង្គំមកស្ដាប់ព្រះធម៌ប្រពន្ធនៅផ្ទះ ហើយចិត្តសទ្ធារបស់ទូលព្រះបង្គំតែ ១ ច្បាំងឈ្នះចិត្តកំណាញ់ចំនួន ១០០០ អាចឱ្យទូលព្រះបង្គំយកសំពត់នេះបូជាព្រះធម៌ក្នុងពេលនេះបាន សូមទ្រង់ជ្រាប" ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ ក៏ទ្រង់ស្ងើចក្រៃពេក ទ្រង់ព្រះរាជបញ្ជាឱ្យរាជអាមាត្យយកសំពត់កម្ពលយ៉ាងល្អ ៗ ៨ គូមកព្រះរាជទានដល់ព្រាហ្មណ៍

ហើយទ្រង់ព្រះរាជនិវត្តទៅកាន់ព្រះរាជវាំង ។

បុល្លេកសាដកព្រាហ្មណ៍ កាលបានទទួលសំពត់ហើយ ក៏ចាត់ធ្វើជាពិតានជារនាំងវាំងននថ្វាយនៅក្នុងព្រះសុគន្ធកុដិ នៃព្រះពុទ្ធអង្គទៅទៀត ។ ថ្ងៃក្រោយព្រះរាជាទ្រង់យាងមក ទ្រង់ឃើញសំពត់កម្ពលនោះ ទ្រង់សួរទ្រង់ជ្រាបថា បុល្លេកសាដកព្រាហ្មណ៍ថ្វាយព្រះពុទ្ធអង្គ ស្តេចទ្រង់ឱ្យយកសំពត់កម្ពល ១៦ គូមកព្រះរាជទានទៀត ព្រាហ្មណ៍ក៏យកសំពត់នោះ ប្រគេនជាបរិក្ខារដល់ព្រះសង្ឃទៀត ឥតយកទៅជារបស់ខ្លួនឡើយ ។ ព្រះរាជាទ្រង់ទតឃើញ ទ្រង់ឱ្យយក ៣២ គូ មកព្រះរាជទានទៀត។ លុះបាន ៣២ គូ ទើបព្រាហ្មណ៍ដកយក ១៦គូ ទុកជារបស់ខ្លួន ១៦ គូប្រគេនដល់ព្រះសង្ឃ ។

ព្រះរាជាទ្រង់ជ្រាបដូច្នោះក៏ទ្រង់ព្រះរាជទាន គោ ក្របី ដំរី សេះ និងព្រះរាជទ្រព្យផ្សេងៗ មានមាសប្រាក់ជាដើមព្រមទាំងយសសក្តិដល់ព្រាហ្មណ៍។

បុល្លេកសាដកព្រាហ្មណ៍ ក៏ឡើងយសសក្តិជាគហបតីមានទ្រព្យសម្បត្តិច្រើន ដោយសារចិត្តសទ្ធាច្បាំងឈ្នះចិត្តកំណាញ់ ហើយបានថ្វាយសំពត់សាដកចំពោះព្រះពុទ្ធអង្គ ដល់ព្រះរាជាព្រះរាជទានសំពត់កម្ពលមក ព្រាហ្មណ៍យកធ្វើជាពិតានរនាំងវាំងនន នៅព្រះសុគន្ធកុដិថ្វាយព្រះពុទ្ធអង្គទៀតនោះឯង ។

## ១១_អានិសង្សផ្លូវថ្នល់

ផ្លូវដែលគេលើកដីឱ្យខ្ពស់ជាងដីធម្មតា ឱ្យផុតពីភក់ល្បាប់ មានបណ្តោយឬទទឹងវៀមរទេះធំតូចចៀសគ្នាទៅមុខបាន ឆ្លងកាត់ពីទី១ ទៅទី ១ មានកាត់

ពីភូមិស្រុកចូលទៅវត្តអារាមជាដើម សម្រាប់ឱ្យមនុស្សម្នាមហាជនធ្វើចរាចរ ជាសាធារណៈ តាមព្យញ្ជនៈក្នុងភាសាបាលីហៅថា វិធី ភាសាខ្មែរហៅថាថ្នល់ តាមអត្ថ គឺជាផ្លូវគមនាគមន៍ នាំឱ្យអ្នកដំណើរធ្វើដំណើរដោយជើង ឬដោយយានជំនិះ មានរទេះគោរទេះកង់ និងរថយន្តជាដើម ទៅមកបានដោយស្រួល ។ បើលើកហើយក្រាលថ្មបាក់កៅស៊ូស្អាតបាតក៏រឹតតែស្រួល ហើយបើដាំឈើជាម្លប់តាមបរិវេណដងផ្លូវនោះទាំងសងខាងផងទៀត ក៏រឹតតែម្លប់ត្រជាក់ស្រួលដល់អ្នកដំណើរក្រៃពេក ។

ជនដែលបានធ្វើផ្លូវថ្នល់ឱ្យសាធារណជនធ្វើដំណើរបានស្រួលនោះបានឈ្មោះថាឱ្យសេចក្ដីសុខដល់អ្នកដទៃ ។

ក្នុងបាលីអនុមោទនាគាថា ថែងថាៈ

**សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ**

ប្រែថា ជនដ៏មានប្រាជ្ញាណាមួយបានឱ្យសេចក្ដីសុខដល់អ្នកដទៃជននោះឯងតែងបានជួបប្រទះនឹងសេចក្ដីសុខជាដរាប ។

អធិប្បាយថា ការសាងផ្លូវថ្នល់ សម្រាប់ឱ្យសាធារណជនធ្វើដំណើរទៅមកស្រួល បានឈ្មោះថា ឱ្យសេចក្ដីសុខដ៏ធំទូលាយដល់ជនទូទៅ អ្នកដែលមានចិត្តប្រកបដោយមេត្តាករុណា បានឱ្យសេចក្ដីសុខដល់គេនោះ តែងបានសម្បត្តិសុខដ៏ធំទូលាយក្នុងមនុស្សលោក និងក្នុងទេវលោកពិតប្រាកដពុំខាន ។

មួយទៀត ការដែលសាធុជនបានលះសេចក្ដីសុខដ៏ខ្លីរបស់ខ្លួនជាឯកជនហើយស៊ូអត់ដំណេកស្រេកអត្តុយយកកម្លាំងកាយទៅខ្វល់ខ្វាយធ្វើផ្លូវថ្នល់ឱ្យសាធារណៈជនធ្វើដំណើរស្រួល បានឈ្មោះថាលះសុខតូចដូរយកសុខធំ ឬលះសុខខ្លីដូរយកសុខវែងជាពិតប្រាកដ ត្រូវតាមពុទ្ធភាសិតគាថាក្នុងធម្មបទខុទ្ទក-

និកាយថា:

មត្តាសុខបរិច្ចាគា  បស្សេ ចេ វិបុលំ សុខំ
ចជេ្ជ មត្តាសុខំ ធីរោ  សម្បស្សំ វិបុលំ សុខំ

ប្រែថា បើជនដែលបានឃើញនូវសុខដ៏ធំទូលាយ ហើយបានលះបង់នូវសុខដ៏តូច តែងបានសេចក្ដីសុខដ៏ធំទូលាយ ។

ដូច្នេះ ឃើញថា សាធុជនដែលបានសាងផ្លូវថ្នល់ជាសាធារណៈឱ្យជនទូទៅបានធ្វើដំណើរស្រួលនោះ ប្រាកដជាបានជួបប្រទះនិងសម្បត្តិសុខដ៏ធំទូលាយ ពិតប្រាកដពុំខាន ដូចនិទានតទៅនេះ:

# រឿងមាឃមាណព

ក្នុងកាលដ៏កន្លងទៅហើយ មានមាណពម្នាក់ឈ្មោះមាឃនៅស្រុកមួយជាមនុស្សមាននិស្ស័យចូលចិត្តខាងការធ្វើផ្លូវថ្នល់ ឱ្យសាធារណជនធ្វើដំណើរទៅមកស្រួល គាត់បបួលជនដែលមាននិស្ស័យត្រូវគ្នាបាន ៣២ នាក់ រួមទាំងខ្លួនគាត់ផងជា ៣៣ នាំគ្នាធ្វើថ្នល់ តម្រង់ទៅរាជធានី កាលធ្វើទៅហើយ ទោះបីមានឧបសគ្គដោយត្រូវតាមភោជក.(មេស្រុក) ចោទប្រកាន់ថា ជនទាំង៣៣ នោះរួមគំនិតគ្នាធ្វើថ្នល់ប្រាថ្នាទៅវាយទីក្រុង ដើម្បីដណ្ដើមរាជពីស្ដេច គេហាមឃាត់យ៉ាងណាក៏ចេះតែធ្វើ ។ លុះឃាត់មិនស្ដាប់តាមភោជកនាំសេចក្ដីនោះទៅប្ដឹងរាជការៗ ក៏ចាប់ជនទាំងនោះមកឱ្យដេកតម្រៀបគ្នាលើផែនដីបរដំរីឱ្យជាន់ ។ វេលានោះមាណពជាមេ បានប្រាប់ជនទាំង ៣២ នាក់ ឱ្យផ្សាយមេត្តាដល់ដំរីៗ ក៏អាណិតជនទាំងនោះមិនហ៊ានជាន់ ទោះបីគេគ្របកន្ទេលជិតបាំងមិនឱ្យដំរីឃើញ ក៏ដំរីនៅតែមិនហ៊ានជាន់ ។ ព្រះរាជាយល់សេចក្ដីអស្ចារ្យដូច្នោះ ក៏ទ្រង់សួរបញ្ជាក់ថា "ដែលអ្នកទាំងអស់គ្នានាំគ្នាធ្វើ

ផ្លូវចូលមកទីក្រុងនេះ តើប្រាថ្នាដណ្ដើមរាជសម្បត្តិឬ? ។

មាឃមាណពក្រាបទូលថា "មិនមែនប្រាថ្នាដណ្ដើមរាជ្យទេ គឺដើម្បីឱ្យស្រួលដល់ជនដែលធ្វើដំណើរទៅកាន់ព្រះរាជធានី និងឱ្យអ្នកដំណើរទៅមករកទទួលព្រះរាជទាន ចិញ្ចឹមជីវិតបានស្រួល" ។

ព្រះរាជាទ្រង់ជឿថាពិតដូច្នោះ ក៏ទ្រង់ព្រះរាជទានដីជាជំនិះសម្រាប់អ្នកទាំង ៣៣ នាក់នោះ ធ្វើការជានិច្ចកាល អ្នកទាំងនោះក៏រឹតតែមានកម្លាំងធ្វើការដោយពេញកិត្តិយសតទៅ ។

បន្ទាប់ពីនោះមាឃមាណពធ្វើចាប់ផ្ដើមធ្វើសាលា នៅត្រង់ពាក់កណ្ដាលផ្លូវ សម្រាប់សាធារជនអ្នកធ្វើដំណើរជ្រកអាស្រ័យ ។

មាឃមាណពនោះមានភរិយា ៤ នាក់ ឈ្មោះនាងសុជាតា ១ នាងសុធម្មា ១ នាងសុនន្ទា ១ នាងសុចិត្រា ១ ។ បណ្ដាភរិយាទាំង ៤ នោះ នាងសុជាតាជាភរិយាដើម មិនរវល់ក្នុងការធ្វើផ្លូវនិងសាលានោះបន្តិចសោះដោយគិតថា ប្ដីធ្វើហើយមុខជាបានផលដល់ខ្លួនដែរព្រោះសម្បត្តិរួមគ្នា ។

ឯនាង ៣ នាក់ក្រៅពីនោះ គេខំរកឱកាសធ្វើបុណ្យអ្វីឱ្យទាក់ទងនឹងស្វាមី គឺនាងសុនន្ទាដាំឈើធ្វើសួនច្បារនៅក្បែរសាលា សម្រាប់ជាម្លប់និងជាលំអរ ឱ្យសាធារណជន អ្នកដំណើរដើរមើលលេងកំសាន្ត នាងសុចិត្រាជីកស្រះមានទឹកថ្លាស្អាតដាំឈូកព្រលិតលំចង់ស្បង្គ សម្រាប់សាធារណជនបរិភោគនិងងូតតាមសប្បាយ. ឯនាងសុធម្មាមានប្រាថ្នាជាងគេនាងពិតរកឱកាសចូលបុណ្យក្នុងសាលានោះ ហើយឱ្យបានឈ្មោះថាជាសាលារបស់នាងផង នាងនិយាយនិងជាងធ្វើសាលាថា "សូមជាងធ្វើហោជាងឱ្យខ្ញុំ១ផ្ទាក់ឈ្មោះសុធម្មា កាប់និងហោជាងនោះបិទមាសក្រហមឆ្អៅ .ដល់ពេលលើកជហ្វា បើប្ដីខ្ញុំឱ្យ

យកហោជាងមកដាក់សួមជាងប្រាប់ថា មិនទាន់ធ្វើ បើគាត់ឱ្យធ្វើប្រាប់គាត់ថាយកឈើថ្មីធ្វើមិនល្អទេ លុះតែរកទិញហោជាងគេស្រាប់ ទើបបានល្អ បើគាត់ឱ្យរកទិញជាងតម្រូវមករកខ្ញុំខ្ញុំនឹងឱ្យយកទៅដាក់ ។

លុះដល់ពេលលើកហោជាង ជាងក៏ប្រាប់មាឃមាណពតាមដំណើរនោះ។ មាណពឱ្យរក ជាងទៅរកទិញហើយត្រឡប់មកវិញប្រាប់នាងសុធម្មាមានមាណពសុំទិញ នាងពុំលក់ នាងថាសុំចូលបុណ្យផង។ មាណពមិនចង់ឱ្យស្រ្តី១ ចូលបុណ្យក្នុងសាលានោះទេ ព្រោះមិនចង់ឱ្យជួបនិងភរិយាអស់ទាំងនោះ ក្នុងជាតិខាងមុខទៀត តែជាងចេះតែបង្ខំឱ្យយក មាឃមាណពទ្រាំពុំបាន ក៏ទទួលយកទៅ។ លុះលើកជហ្វានោះហើយឃើញឈ្មោះនាងសុធម្មា យ៉ាងខ្ពស់ត្រដែត។

តាំងពីលើកជហ្វាឡើង សាលានោះបានឈ្មោះថា សាលាសុធម្មា រហូត។

ដោយអំណាចផលនៃការសាងផ្លូវថ្នល់ ជីកស្រះ និងធ្វើសួនច្បារ បណ្ដាជនទាំងនោះ គឺមាឃមាណព នាងសុធម្មា-សុនន្ទា-សុចិត្រា ព្រមទាំងជន ៣២ នាក់ ដែលបានរួមចិត្តគ្នាសាង ក៏មាឃមាណពបានទៅកើតជាព្រះឥន្ទស្ដេចទេវតានៅត្រៃត្រឹង្សសួគ៌. ជនទាំង ៣២ នាក់ បានទៅកើតជាទេវបុត្រ ៣២ រូប ជាមិត្តសំឡាញ់. ដំរីបានកើតជាដំរីអៃរាវណ្ណជាជំនិះព្រះឥន្ទ ។ ឋាននោះបានឈ្មោះថាឋានត្រៃត្រឹង្សប្រែថាឋានសាមសិបបី តាំងពីគ្រឹមនោះមក។

នាងភរិយា ៣ នាក់ គឺនាងសុធម្មា សុនន្ទា និងនាងសុចិត្រា ក៏បានទៅកើតទេពធីតា ក្នុងឋាននោះដែរ នៅមានឈ្មោះថា សុធម្មា សុនន្ទា និងសុចិត្រាដដែល ។

ដោយអំណាចបុណ្យដែលនាងទាំង ៣ នាក់បានសាងឋានត្រៃត្រឹងក៏មានទេវសភា ជាទីប្រជុំទេវតាក្នុងឋាននោះឈ្មោះថាសុធម្មា មានសួនច្បារ

ឈ្មោះនន្ទវ័ន មានព្រៃឈ្មោះចិត្តលតាវ័ន សម្រាប់ទេវតាទៅឋាននោះកំសាន្តសប្បាយ ។

ឯនាងសុជាតា ដោយមិនបានសាងអ្វីនឹងគេសោះ ទៅកើតជាសត្វកុកញីនៅជ្រោះភ្នំ ។

វេលាមាឃមាណពបានកើតជាព្រះឥន្ទហើយ ទ្រង់ពិនិត្យមើលឃើញនាងទាំង ៣ នាក់ មកកើតជាមួយផង បាត់តែនាងសុជាតា ហើយទ្រង់រំពឹងមើលទៅ ទ្រង់ជ្រាបថា នាងសុជាតា ទៅកើតជាកុកញី ។ ព្រះឥន្ទបានទៅប្រដៅនាងកុក ឱ្យកាន់សីល ៥ ហើយនាងបានទៅកើតជាកូនស្មូនឆ្នាំង វេលាទៅកើតជាកូនស្មូនឆ្នាំង ព្រះឥន្ទបានទូន្មានឱ្យកាន់សីលទៀត ហើយនាងកូនស្មូនឆ្នាំង គឺនាងសុជាតា បានទៅកើតជាបុត្រីព្រះបាទវេបចិត្តិ ជាស្តេចអសុរនៅជើងភ្នំព្រះសុមេរុ ឈ្មោះនាងសុជាតា ។ លុះនាងធំពេញរូបរាងឡើង ព្រះបាទវេបចិត្តិ ធ្វើពិធីប្រជុំពួកអសុរ ដើម្បីរើសប្តីឱ្យកូន គឺឱ្យនាងសុជាតាបោះភួងផ្កា ទៅត្រង់អសុរណា ដែលនាងស្រឡាញ់ ។ ព្រះឥន្ទទៅបន្លំធ្វើអសុរចាស់ ក្នុងចំណោមពួកអសុរក្មេងៗ ដែលប្រឡងរាសនានោះ ។ ហេតុតែនាងធ្លាប់ជាភរិយាព្រះឥន្ទកាលនៅជាមាឃមាណពនោះ នាងក្រឡេកឃើញអសុរចាស់ក៏ស្រឡាញ់ ហើយបោះភួងផ្កាទៅឱ្យតានោះ តាអសុរចាស់ក៏ចាប់ភួងផ្កាហើយ យកនាងអសុរកញ្ញានោះហោះទៅឋានត្រៃត្រិង្សទៅ នៅជាសុខក្នុងទីនោះរហូតមកដល់សព្វថ្ងៃ ។

នេះហើយជាអានិសង្សនៃការសាងផ្លូវថ្នល់ ឱ្យបានសុខស្រួលដល់សាធារណជន តែងបានសេចក្តីសុខស្រួលដល់ខ្លួនវិញ ដែលត្រូវតាមគន្លងព្រះពុទ្ធភាសិតថា:

www.elibraryofcambodia.org

សុខស្ស ធាតា មេធាវី សុខំ សោ អធិគច្ឆតិ

ជនដ៏មានប្រាជ្ញាណាបានឱ្យសេចក្ដីសុខដល់អ្នកដទៃ ជននោះឯងរមែងបានជួបប្រទះនឹងសេចក្ដីសុខ ។

## ១២_អានិសង្សស្ពាន

វត្ថុដែលគេធ្វើដោយឫស្សី ឬឈើ ឬក៏ដោយដែកស៊ីម៉ង់ សម្រាប់ឱ្យសាធារណជនធ្វើដំណើរឆ្លងទីដែលមានទឹកភក់ ឬជ្រៅហៅថា ស្ពាន ។

ស្ពាននោះកាលគេធ្វើហើយ ជារបស់នៅជាប់បានឆាប់ឬយូរតាមគុណភាពរបស់ដែលត្រូវធ្វើ គឺបើធ្វើដោយឫស្សីឆាប់ខូច ធ្វើដោយឈើជាប់បានយូរបន្តិច ដោយដែកស៊ីម៉ង់ជាប់បានយូរអង្វែងឆ្នាំ ៕

ស្ពានជាថាវរវត្ថុឋិតនៅទាំងថ្ងៃ ទាំងយប់ គ្រប់កាលវេលាមនុស្សម្នាត្រូវការធ្វើដំណើរនៅពេលណាក៏បាន ជនណាបានសាងស្ពានដែលជារបស់ឋិតនៅទាំងថ្ងៃទាំងយប់ គ្រប់កាលវេលា ជននោះបានបុណ្យទាំងថ្ងៃទាំងយប់គ្រប់កាលវេលាដូចគ្នា ។

គម្ពីរសំយុត្តនិកាយ ទេវតាសំយុត្ត សំដែងប្រារព្ធចំពោះការស្ថាបនាស្ពានថា មានទេវតាទូលសួរព្រះបរមសាស្ដាថា

បពិត្រព្រះដ៏មានបុណ្យដ៏ចម្រើន! បុណ្យរមែងតែងចំរើនមិនដាច់ ទាំងថ្ងៃទាំងយប់គ្រប់កាលវេលា ដល់ជនពួកណា? ជនពួកនោះឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីលគួរទៅកាន់ស្ថានសួគ៌បាន?

ព្រះអង្គត្រាស់ថា:

អារាមរោបា វនរោបា    យេ ជនា សេតុការកា

បបញ្ច ឧទបានញ្ច    យេ ទទន្តិ ឧបស្សយំ

ឥធេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ

ជនទាំងឡាយណា ដែលបានដាំសួនឈើផ្កា សួនឈើម្លប់ សាងស្ពាន សាងរោងទានឱ្យមានទឹក ជីកអណ្តូងឬស្រះ ជនទាំងឡាយណាបានសាងទីលំនៅឱ្យជាទាន ផលបុណ្យរមែងចម្រើនមិនដាច់ ទាំងថ្ងៃទាំងយប់ គ្រប់កាលទាំងពួងដល់ជនទាំងនោះ. ជនទាំងនោះបានឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីលហើយនឹងបានទៅកើតក្នុងឋានសួគ៌ ។

## រឿងសុមេធតាបស

អដ្ឋកថាធម្មបទ បានសំដែងប្រារព្ធរឿងធ្វើផ្លូវថ្នល់ និងស្ពានថា:

ក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ ព្រះពោធិសត្វជាអម្ចាស់នៃយើង ព្រះអង្គជាព្រះតាបសមួយអង្គ ព្រះនាមសុមេធ: បានសម្រេចឈានជាលោកិយ ហោះធ្យានបាន ។ វេលាមួយ លោកហោះលើអាកាស ក្រឡេកចុះមកក្រោមបានឃើញមហាជនកំពុងធ្វើផ្លូវថ្នល់ លោកចុះមកសួរថា "អ្នកទាំងឡាយ ធ្វើផ្លូវថ្នល់ដើម្បីអ្វី?" ។ ពួកអ្នកធ្វើថ្នល់បានប្រាប់ថា "ធ្វើដើម្បីនិមន្តព្រះពុទ្ធទីបង្ករ ព្រមទាំងព្រះអរហន្តជាសាវ័កមកឆាន់ក្នុងវេលាព្រឹកស្អែកនេះ" ។

ព្រះសុមេធតាបស បានសុំគេធ្វើមួយចំណែក ។ ដោយគេឃើញថា ព្រះតាបសមានឥទ្ធិឫទ្ធិ គេចែកឱ្យលោកមួយចំណែកធំ ។ កាលបើបានដីមួយភាគធំមកហើយ ព្រះតាបសក៏រកចបមកចូកចាំងលើកដីបុកបង្ហាប់ បោសជ្រះស្អាតល្អ ។

ព្រឹកស្អែកឡើង ព្រះសុមេធតាបស កំពុងតែធ្វើផ្លូវថ្នល់នៅសល់តែដីដែលមានផុក ប្រមាណ ៤ ហត្ថ ព្រះពុទ្ធអង្គយាងមកដល់ ។

ព្រះតាបសបានឃើញ ក៏ស្ទុះយ៉ាងប្រញាប់ទៅក្រាបថ្វាយបង្គំហើយលូន

ក្រាបក្រាលលើផុកនោះ ធ្វើជាស្ពានចម្លងព្រះអង្គ ដោយតាំងចិត្តប្រាថ្នាថា "សូមឱ្យបានត្រាស់ជាព្រះពុទ្ធ ១ អង្គ ក្នុងកាលជាអនាគត" ។ ព្រះពុទ្ធទីបង្ករ បានទតឃើញចម្លែកអស្ចារ្យដូច្នោះ ក៏ទ្រង់ប្រមើលមើលឧបនិស្ស័យព្រះតាបស ទ្រង់ឃើញហើយទ្រង់ព្យាករថា:

"ទៅ ២០ អសង្ខេយ្យកប្បទៀត សុមេធតាបស និងបានជាព្រះពុទ្ធ ១ អង្គ ក្នុងភទ្ទកល្បខាងមុខឯណោះ ព្រះនាមព្រះសមណគោតម" ។

លុះទ្រង់ព្យាករហើយ ទ្រង់អនុមោទនាថា "តាបសអ្នកប្រាថ្នាយ៉ាងណា សូមឱ្យអ្នកបានសម្រេច ដូចសេចក្តីប្រាថ្នាចុះ" ។

កាលទ្រង់អនុមោទនាហើយ ទ្រង់យាងជាន់លើព្រះសុមេធបណ្ឌិតនោះ ជាស្ពានឆ្លងផុតផុកទៅ ។

ដោយសារព្រះពុទ្ធជាម្ចាស់យើង ព្រះអង្គធ្លាប់បានធ្វើថ្វាយព្រមទាំងបាន យកខ្លួនធ្វើស្ពានថ្វាយព្រះពុទ្ធទីបង្ករ ក្នុងកាលនៅជាពោធិសត្វ ព្រះនាម សុមេធបណ្ឌិតជាដើមនោះ បានជាដល់ព្រះអង្គបានត្រាស់ដឹងឡើង ទ្រង់បាន ទទួលសក្ការបូជាដោយពិធីទទួលបដិសណ្ឋារ យ៉ាងអឹកធឹក អំពីមនុស្សនិង ទេវតាជាច្រើនលើកច្រើនគ្រា ។

សារត្ថបុប្ផ័យ អដ្ឋកថាធម្មចក្កប្បវត្តនសូត្រ សំដែងប្រាប់ពីរឿងព្រះ ពុទ្ធអង្គទ្រង់បានទទួលសក្ការបូជាដោយពិធីបដិសណ្ឋារកិច្ចថា:

កាលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់បានត្រាស់ដឹងហើយទ្រង់គង់នៅក្នុង សត្តមហាឋាន ( ឋានធំ ៧ កន្លែង) មានពោធិមណ្ឌលជាដើម ១ កន្លែង ៧ថ្ងៃ រួបជា៤៩ ថ្ងៃ. នៅថ្ងៃចុងក្រោយបំផុតទ្រង់រំពឹងពីក្នុងវេលាយប់ថា ព្រឹកឡើង តថាគតនឹងទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ដើម្បីសំដែងធម្មចក្កប្បវត្ត

នសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុ ៥ អង្គ ។ ខណៈនោះទ្រង់រំពឹងថា "ដំណើរតថាគតទៅប្រោសបញ្ចវគ្គិយភិក្ខុនោះ គួរទៅតាមអាកាសឬតាមផែនដី" ។ ទ្រង់ឃើញថាគួរទៅតាមផែនដីបុះ ព្រោះថាបើទៅតាមអាកាសនឹងដាច់និស្ស័យឧបកាជីវក បើទៅតាមផែនដីឧបកាជីវកនឹងបានជួបបានសន្ទនាបន្តិចបន្តួចជាមួយតថាគត ហើយគាត់នឹងចំណាំឈ្មោះតថាគតថ្ងៃក្រោយគាត់នឹងមករកតថាគត១បានសំដែងធម៌ ប្រោសគាត់១នឹងបានសម្រេចមគ្គផលជាអរហន្ត ១ រូបក្នុងពុទ្ធសាសនា ។ កាលទ្រង់រំពឹងឃើញហើយ ទ្រង់កំណត់ព្រះទ័យថានឹងយាងតាមផែនដីកាត់ព្រៃពីពោធិមណ្ឌលទៅព្រៃឥសិបតនមិគទាយវ័ន ។

ដោយអំណាចផលានិសង្ស ដែលព្រះពុទ្ធអង្គទ្រង់ធ្លាប់បានសាងផ្លូវថ្នល់និងស្ពាន កាលនៅជាពោធិសត្វឈ្មោះសមេធនោះ វេលាយប់នោះវស្សវណាហកទេវបុត្របានញ៉ាំងមហាមេឃឱ្យបង្អោរភ្លៀងយ៉ាងធំអស្ចារ្យ កំចាត់ស្លឹកកំទេចកំទីសម្រាមទាំងប៉ុន្មានដែលមានក្នុងផ្លូវ ជាទីទៅនៃព្រះពុទ្ធអង្គឱ្យខ្ចាត់ខ្ចាយចេញអស់ ព្រះពាយផាយផាត់យកខ្សាច់មានពណ៌ភ្លឺផ្លេកដូចប្រាក់ពីស្ទឹងមកបំពេញទីក្រហេងក្រហូងឱ្យពេញស្មើជាផ្លូវយ៉ាងល្អស្អាត ហើយបក់ផាត់បំបែរផ្កាឈើតូចធំនៅសងខាងផ្លូវទាំងប៉ុន្មានឱ្យបែរទងផ្កាមករកផ្លូវ រង់ចាំថ្វាយជាសក្ការបូជាទទួលព្រះដំណើរព្រះអង្គផង ។

ព្រឹកឡើងវេលាទ្រង់ធ្វើព្រះដំណើរទៅ តាមដងផ្លូវនោះ ព្រះអង្គបញ្ចេញព្រះឆព្វណ្ណរង្សី ( រស្មី ៦ ពណ៌ ) ពីព្រះកាយភ្លឺផ្លេក១ពេញព្រៃសងខាងផ្លូវ ។ ខណៈនោះ ឧបកាជីវកជាអ្នកបួសស្ពាយបរិក្ខាររយីងរយោងដើរតាមព្រៃនោះ បានឃើញព្រះឆព្វណ្ណរង្សីក៏ចូលមកក្នុងផ្លូវបានឃើញព្រះពុទ្ធអង្គ ក៏មានសេចក្តីជ្រះថ្លាក្រៃពេក ចំពោះឥរិយាបថរបស់ព្រះអង្គ បានចូលទៅជិត

ព្រះអង្គសួរថា "លោកជាអ្វី"។ ព្រះអង្គឆ្លើយថា "យើងជាអ្នកបួស" ។ សួរទៀតថា "លោកបួសតាមគ្រូណា បានជាប្លែកពីគេម្ល៉េះ? លោកឈ្មោះអ្វី?"។

ព្រះពុទ្ធអង្គឆ្លើយថា "យើងបួសខ្លួនឯងបានត្រាស់ដឹងខ្លួនឯង យើងឈ្មោះ អនន្តជិនៈ (អ្នកឈ្នះរកទីបំផុតគ្មាន)" ។

សន្ទនាប៉ុណ្ណេះហើយឧបកាជីវកចំណាំព្រះនាមនេះទុកហើយ ឱនសិរសាចេញទៅ ។ ព្រះពុទ្ធជាម្ចាស់ក៏ទ្រង់យាងទៅកាន់ព្រៃឥសិបតនមិគទាយវ័នដោយព្រះសុវត្ថិភាព ។

ដោយឧបនិស្ស័យដែលបានជួបនិងព្រះពុទ្ធជាម្ចាស់ ហើយចំណាំព្រះនាមទុក ពេលក្រោយឧបកាជីវកទៅសួររកព្រះអង្គ ហើយបួសក្នុងព្រះពុទ្ធសាសនា។

## ១៣-អានិសង្សអណ្តូង ស្រះ

អណ្តូងនិងស្រះ ជាទីកន្លែងដែលគេបញ្ចេញទឹកពីក្នុងដី និងបញ្ចូលទឹកភ្លៀងពីលើមេឃមក សម្រាប់ទុកបរិភោគ ទុកប្រើប្រាស់តាមត្រូវការ ។

ទឹកជាវត្ថុរាវ មានគុណភាពល្អណាស់ អាចញ៉ាំងប្រយោជន៍ឱ្យសម្រេចច្រើនប្រការ ហើយជាវត្ថុដែលមនុស្សនិងសត្វគ្រប់រូបក្នុងសាកលលោកត្រូវការផឹកងូតជាដើម ដែលជាការចាំបាច់ខានពុំបាន ។

ព្រោះហេតុទឹក ជាវត្ថុដែលគេត្រូវការប្រើជាចាំបាច់ដូចពោលមកហើយ ទើបការសាងអណ្តូង សាងស្រះ ឱ្យទានដល់សាធារណជន ជាការមានផលានិសង្សច្រើន ហើយផលានិសង្សនោះរមែងរីងរឹតតែចម្រើនឡើងៗ នៅរាល់យប់រាល់ថ្ងៃ សព្វកាលទាំងពួង ។

សេចក្តីនេះ សមដូចគម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្តសម្តែងថា សម័យពុទ្ធកាលមានទេវតាចូលក្រាបថ្វាយបង្គំទូលសួរព្រះដ៏មានព្រះភាគថា:

បពិត្រព្រះដ៏មានបុណ្យដ៏ចម្រើន បុណ្យរមែងតែចម្រើនទាំងយប់ទាំងថ្ងៃ សព្វកាលទាំងពួងដល់ជនណា? ជនណាបាន់ឈ្មោះថាជាអ្នកឋិតនៅក្នុងធម៌ សម្បូណ៌ដោយសីល ហើយបានទៅកើតក្នុងឋានសួគ៌ ?

ព្រះអង្គត្រាស់ថា:

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។

ជនទាំងឡាយណា បានដាំសួនឈើផ្កា ឈើម្លប់ សង់ស្ពាន សាងរោងឱ្យទានទឹក អណ្តូង ឬស្រះ ជនទាំងឡាយណាដែលបានសាងទីលំនៅឱ្យជាទាន ផលបុណ្យរមែងតែចម្រើនមិនដាច់ទាំងយប់ទាំងថ្ងៃ សព្វកាលទាំងពួង ដល់ជនអម្បាលនោះ ជនអម្បាលនោះ បានឈ្មោះថា ជាអ្នកឋិតនៅក្នុងធម៌ បរិបូណ៌ដោយសីល ហើយបានទៅកើតក្នុងឋានសួគ៌ )

ពុទ្ធភាសិតនេះ ព្រះដ៏មានព្រះភាគទ្រង់សរសើរអានិសង្សនៃការសាងសួនច្បារ សាងស្ពាន សាងរានដាក់ទានទឹក អណ្តូងទឹក ស្រះទឹក និងសាងទីលំនៅឱ្យជាទាន ថាមានផលានិសង្សច្រើន ហើយអានិសង្សនោះចម្រើនទាំងយប់ទាំងថ្ងៃ យូរពេលវេលា ព្រោះវត្ថុទាំងនោះជាថាវរវត្ថុ ឋិតថេរជាប់នៅបានយូរ គឺកាលបើជនណាបានសាងហើយ សាធារណជនបានទស្សនា បានជ្រក បានផ្ចិតភាចរ បានងូត ផឹក ប្រើប្រាស់ អាស្រ័យនៅគ្រប់កាលវេលាអស់កាលដ៏យូរ ។

## រឿងនាងសុចិត្រា

ចំពោះការសាងអណ្តូងស្រះ ដែលថាបានផលានិសង្សនោះមានច្រើន ឧទាហរណ៍ដូចនាងសុចិត្រា ជាភរិយានៃមាឃមាណព នៅពេលដែលមាណព នេះ បានសាងផ្លូវថ្នល់សាងសាលាឈូងឈាក់ នាងនេះបានសាងស្រះ នៅក្បែរផ្លូវ ថ្នល់ ក្បែរសាលានោះ ឱ្យជាទានដល់សាធារណជន ដែលធ្វើចរាចរទៅមកដល់ ទីនោះ បានផឹកងូតតាមត្រូវការ ប្រកបដោយសេចក្តីរីករាយ ។ លុះមាឃមាណព អស់អាយុពីមនុស្សលោកនេះទៅ បានកើតជាព្រះឥន្ទ នៅឋានត្រៃត្រឹង្ស. នាង សុចិត្រាក៏បានកើតនៅឋានត្រៃត្រឹង្សដែរ ជាភរិយានៃព្រះឥន្ទ្រាធិរាជ មាន ឈ្មោះថា នាងសុចិត្រាដដែល សោយទិព្វសម្បត្តិជាមួយព្រះឥន្ទ្រាធិរាជ ស្តេចទេវតា ប្រកបដោយសុខុមាលសុខយ៉ាងក្រៃលែង[១] ។

## ១៤_អានិសង្សបោសជ្រះ

ការប្រោសជ្រះសម្អាតទីនានា ដែលគួរបោស មានបោសសម្អាតផ្ទះ សម្បែង និងវត្តអារាមជាដើម ជាការញុំាងចិត្តអ្នកបោសនិងសាធារណជន ដែលបានទស្សនា ឱ្យកើតបីតិប្រាមោជ្យរីករាយហើយនិងឱ្យកើតសេចក្តីសុខ សិរីសួស្តីដល់គ្រួសារ និងដល់បរិស័ទ ជាពិតប្រាកដ ។

សុភាសិតខ្មែរបុរាណ លោកបានឱ្យដំបូន្មានថា "ត្រែះបាឱ្យជិតផ្ទង់ កុំឱ្យ ផងផុយធូលី ជម្រះបារបោសដី ឱ្យហ្មត់ហ្មងកើតសុខា" ។

អធិប្បាយៈ ផ្ទះដែលបានបោសជ្រះសម្អាត ឱ្យស្អាតល្អរមែងតែបាន

---

១-បើចង់ជ្រាបពិស្តារ សូមទស្សនារឿងមាឃមាណព ក្នុងអានិសង្សសាងផ្លូវថ្នល់ ខាងដើម ។

www.elibraryofcambodia.org

ទទួលសេចក្ដីសរសើរអំពីអ្នកទស្សនា ហើយនិងបានសេចក្ដីសុខក្សេមក្សាន្ត មានសិរីសួស្ដី សុភមង្គលដល់គ្រួសារ ។ ការទុកសម្រាមឱ្យនៅស្អុតស្អាញ ស្អុយរលួយ ផុកជ្រាំក្រោមផ្ទះ ឬជុំវិញផ្ទះ រមែងតែកើតមានក្អែបខ្មួយ និងពស់តូច ធំនៅសម្ងំនៅក្នុងនោះ នាំឱ្យមានគ្រោះថ្នាក់ដល់គ្រួសារ ដោយក្អែបខាំខ្មួយទិច និងពស់ចឹកជាដើម ហើយរមែងកើតជម្ងឺដម្កាត់ដល់គ្រួសារ នាំឱ្យពិបាកព្យាបាល ។ ព្រោះហេតុនេះ បានជាសុភាសិតបុរាណលោកឱ្យដំបូន្មានដូចខាងដើម ។

ទីវត្តអារាមក៏ដូចគ្នាដែរ កាលបើភិក្ខុសាមណេរបានគោរពតាមពុទ្ធឱវាទ បានបោសជ្រះឱ្យស្អាតបាត រមែងបានសេចក្ដីសុខសប្បាយដល់ភិក្ខុសាមណេរ ដែលនៅក្នុងវត្តនោះ និងបានជាទីជ្រះថ្លាដល់ពុទ្ធបរិស័ទ ដែលបានចូលមកធ្វើបុណ្យទាននោះ ជាពិតប្រាកដ ។

គម្ពីរមិលិន្ទបញ្ហា សំដែងអំពីផលានិសង្សនៃការបោសសម្អាតវត្តអារាម មានសេចក្ដីដូចតទៅនេះ :

## រឿងព្រះនាគសេននិងក្សត្រមិលិន្ទ

ក្រោយសម័យបរិនិព្វាននៃព្រះសម្មាសម្ពុទ្ធ ជាបរមគ្រូយើងទាំងឡាយ មានព្រះមហាថេរមួយអង្គ គង់នៅក្នុងអារាមមួយក្បែរឆ្នេរមហាទន្លេ លោកជាអ្នកព្យាយាមបោសជ្រះសម្អាតទីវត្តអារាមរាល់តែថ្ងៃ ។ វេលាមួយនោះលោកបានកាន់អំបោស បោសសម្រាមគរទុកមួយគំនរ បម្រុងនឹងកើបយកទៅចោល មានឆ្កែមួយទៅជុះលាមកដាក់លើគំនរសម្រាមនោះ លោកប្រើសាម-ណេរមួយរូប ឱ្យកើបសម្រាមនិងលាមកឆ្កែនោះ ទៅចោលនៅឆ្នេរមហាទន្លេ ។ សាមណេរបានកើបសម្រាមនោះយកទៅចោល តាមបញ្ជារបស់ព្រះមហាថេរ

តែដោយខ្មៅមលាមកស្តែពេក សាមណេរក៏កើបទៅចាក់ចោលទាំងទោមនស្ស ។ លុះយកទៅចាក់ចោលហើយ បានឃើញរលកទឹកមហានទី បោកបែកផ្កាត្រែងខ្ពស់ៗខ្លាំងៗ ក៏តាំងសេចក្តីប្រាថ្នាថា "ដោយអំណាចបុញ្ញកម្មដែលខ្ញុំបានកើបសម្រាមនិងលាមកស្តែ យកមកចោលនេះ សូមឱ្យខ្ញុំកើតក្នុងជាតិជាអនាគតមានប្រាជ្ញាខ្លាំងច្រើន ដូចរលកទឹកមហានទីដែលបែកផ្កាត្រែងនេះ កុំបីឱ្យបុគ្គលណាមួយ មានប្រាជ្ញាលើសខ្ញុំឡើយ" ។

ព្រះមហាថេរឮសាមណេរប្រាថ្នាដូច្នោះ លោកក៏តាំងសេចក្តីប្រាថ្នាថា "ដោយអំណាចផលដែលខ្ញុំបានបោសសំរាម ហើយឱ្យសាមណេរយកទៅចាក់ចោលនេះ សូមឱ្យខ្ញុំបានកើតក្នុងជាតិខាងមុខមានប្រាជ្ញាខ្ពស់ខ្លាំងដូចច្រាំងមហានទី ដែលរលកមិនអាចពារលើបានដូច្នោះឯង" ។

ដោយអានិសង្សផ្នួស អានិសង្សប្រព្រឹត្តធម៌វិន័យពុទ្ធសាសនានិងអានិសង្សបោសជ្រះជម្រះសម្អាតវត្តអារាម. ព្រះមហាថេរនិងសាមណេរនោះ លុះធ្វើមរណកាលទៅ បានទៅកើតក្នុងឋានសួគ៌ ហើយលុះដល់ព្រះពុទ្ធជាម្ចាស់ទ្រង់និព្វានទៅបាន ៥០០ ឆ្នាំ ព្រះមហាថេរបានមកកើតជាព្រះនាគសេនត្ថេរនៅជិតមណ្ឌលពោធិព្រឹក្ស សាមណេរបានមកកើតជាព្រះបាទមិលិន្ទ្រាធិរាជនៅសាគលនគរជាស្តេច មានអំណាចមានប្រាជ្ញាមហិមា ទ្រង់ដេញដោលសួរប្រស្នាផ្សេងៗ នឹងព្រះសង្ឃក្នុងជម្ពូទ្វីប គ្មានព្រះសង្ឃណាមួយឆ្លើយរួចឡើយ ។ គ្រានោះ ភិក្ខុទាំងឡាយរត់ទៅជ្រកក្នុងព្រៃមិនហ៊ាននៅក្នុងវត្ត ។ ទីបំផុតស្តេចបានសួរប្រស្នាធម៌ពុទ្ធសាសនា និងព្រះនាគសេនត្ថេរ ព្រះមហាថេរបានវិសជ្ជនាឥតទើសទាល់សល់ចំពាក់ត្រង់ណាសោះ លោកបានផ្ចាញ់ផ្ចាល់ព្រះបាទមិលិន្ទ្រាធិរាជ ឱ្យចាលចាញ់ចុះចូលព្រះពុទ្ធសាសនាដោយស្មោះស្ម័គ្រ ។

ក្នុងធម្មបទដ្ឋកថា សំដែងថា:

កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះជរមានទៅឡើយ វេលាមួយ ក្រុងវេសាលីកើតទុព្ភិក្ខភ័យ មនុស្សក្រៗ ស្លាប់ដោយអត់បាយអស់ជាច្រើន រហាលសាកសពពាសពេញទីក្រុង ។ ក្លិនបដិកូលនោះ បណ្តាលឱ្យកើតអហិវាតរោគមានពួកអមនុស្សជាច្រើនចូលទីក្រុង ។ ទោះបីអ្នកនគរប្រជុំគ្នាកែខៃយ៉ាងណា ក៏មិនរម្ងាប់សោះ ទើបព្រមព្រៀងគ្នាទៅនិមន្តព្រះបរមសាស្តា ដែលទ្រង់គង់នៅឯក្រុងរាជគ្រឹះ ។ វេលានោះ ព្រះរាជា. នាហ្មឺនសព្វមុខមន្ត្រីនិងប្រជារាស្ត្ររៀបចំព្រះនគរ និងផ្លូវសម្រាប់ទ្រង់យាងយ៉ាងស្អាតល្អអស្ចារ្យ ចាំទទួលព្រះបរមសាស្តា ។ កាលទ្រង់យាងមកដល់នគរវេសាលី ព្រះជិនស្រីទ្រង់ចាត់ព្រះអានន្ទឱ្យទៅរម្ងាប់អហិវាតរោគនោះ ។ព្រះអានន្ទក៏បានត្រេចកាន់បាត្របាចទឹកព្រះបរិត្តជុំវិញកំពែងព្រះនគរ ដោយប្រកាសព្រះពុទ្ធគុណ ដែលមានពាក្យថា:

**មណិធានតោ បដ្ឋាយ តថាគតស្ស ឧស ធារមិះយោ** ជាដើម ។ ពួកមនុស្សដែលឈឺទៀបស្លាប់ក៏ជាសះស្បើយពួកបិសាចក៏រត់ខ្ចាត់ខ្ចាយអស់ ។ កាលដែលព្រះពុទ្ធអង្គយាងទៅនិងយាងត្រឡប់មកវិញ ពួកមនុស្សនិងទេវតាបានធ្វើសក្ការបូជាជាមហោឡារិក គគ្រឹកគគ្រេង កក្រើកអំពើក យ៉ាងក្រៃលែង ។

ក្រោយពីនោះមក មានពួកភិក្ខុទូលសួរព្រះអង្គ អំពីអានិសង្ស ដូចម្តេចដែលទ្រង់បានទទួលសក្ការបូជាដ៏អស្ចារ្យនោះ. ព្រះអង្គទ្រង់មានព្រះបន្ទូលពីបុព្វកម្មរបស់ព្រះអង្គ មានសេចក្តីដូចតទៅនេះ:

www.elibraryofcambodia.org

# រឿងសុសិមមាណព

ក្នុងកាលកន្លងរំលងទៅហើយ ... តថាគតកើតជាមាណពម្នាក់ឈ្មោះសុសិមៈ ជាកូនព្រាហ្មណ៍ម្នាក់ឈ្មោះសង្ខ នៅនគរតក្កសីលា បានលាព្រាហ្មណ៍ជាបិតាទៅរករៀនសិល្បសាស្ត្រនឹងអាចារ្យទិសាបាមោក្ខ នៅនគរពារាណសីរៀនចេះសព្វគ្រប់ហើយ ក៏ត្រឡប់មកស្រុកវិញ មកដល់ពាក់កណ្ដាលផ្លូវបានឃើញព្រះបច្ចេកពុទ្ធ មានសេចក្ដីជ្រះថ្លាបានបួស ហើយបានត្រាស់ជាព្រះបច្ចេកពុទ្ធ អ្នកស្រុកជ្រះថ្លាបានថ្វាយទានដល់ព្រះអង្គហើយដល់ពេលអស់ព្រះជន្ម ក៏ព្រះសុសិមបច្ចេកពុទ្ធនិព្វាននៅទីនោះទៅ ។ អ្នកស្រុកនោះបានសាងព្រះចេតិយបញ្ចុះព្រះអដ្ឋិធាតុព្រះអង្គក្នុងទីដ៏សមគួរមួយទុកជាបូជនីយដ្ឋាន ។

ក្រោយមក ព្រាហ្មណ៍ជាបិតានឹករឭកដល់សុសិមមាណពជាបុត្ររបស់ខ្លួន ថាទៅរៀនអ៊ីយូរម្ល៉េះ មិនឃើញត្រឡប់មកផ្ទះវិញសោះក៏ត្រេចទៅសួរក បានដឹងដំណឹងថា សុសិមមាណពនោះត្រឡប់មកពីរៀនវិញ បានបួសជាបព្វជិត បានត្រាស់ជាព្រះបច្ចេកពុទ្ធហើយ ចូលបរិនិព្វាននៅទីនេះ អ្នកស្រុកនៅទីនេះគេបូជាព្រះសពព្រះអង្គហើយបញ្ចុះព្រះអដ្ឋិធាតុ ក្នុងព្រះចេតិយនៅទីនេះ ទុកជាទីសក្ការៈតទៅ ។

ព្រាហ្មណ៍ជាបិតាឮហើយ កើតសេចក្ដីសង្វេគស្លុតចិត្តសោកស្ដាយបុត្ររបស់ខ្លួនក្រៃពេក បានចូលទៅលើកដៃប្រណម្យចំពោះព្រះសពព្រះសុសិមបច្ចេកពុទ្ធជាបុត្រ ដោយគោរព បានយកដីខ្សាច់មានគ្រាប់សល្អដូចប្រាក់ មកបាចជុំវិញព្រះចេតិយ បានយកទឹកប្រុស់ព្រំជុំវិញព្រះចេតិយ បានយកសំពត់ឈ្មួតក្បាលរបស់ខ្លួន ដោតចងធ្វើជាទង់ ជាសក្ការៈបូជាព្រះចេតិយនោះ ។

ព្រាហ្មណ៍ជាបិតានៃព្រះសុសិមបច្ចេកពុទ្ធ គឺតួអង្គតថាគតនេះឯង ។

www.elibraryofcambodia.org

ដោយផលានិសង្សដែលគថាគតបានបោសសម្អាតទីលានព្រះចេតិយនិងបាន យកសំពត់ឈ្នួតក្បាលរបស់ខ្លួន ធ្វើជាទង់ថ្វាយព្រះចេតិយនៃព្រះសុសិមបច្ចេក-ពុទ្ធនោះ ហើយបានជាតថាគតទទួលគ្រឿងសក្ការបូជាយ៉ាងឧឡារិកគគ្រឹកគគ្រេង គគ្រេកអំពើកជាមហាអស្ចារ្យអំពីមនុស្ស និងទេវតា ឃើញប្រាកដដូច្នេះឯង ។

## ១៥_អានិសង្សកឋិន

ការបុណ្យដែលទាយកធ្វើ ដោយនាំចីវរទៅប្រគេនចំពោះភិក្ខុសង្ឃ ដែលបានគង់ចាំវស្សាអស់រយៈវេលា ៣ ខែក្នុងអាវាសណាមួយ ហើយក្នុងវេលា ២៩ ថ្ងៃ ថ្ងៃណាមួយ គឺតាំងពីថ្ងៃ ១ រោច ខែអស្សុជទៅទល់នឹង ១៥ កើត ខែកត្តិកឱ្យលោកក្រាលគ្រងនោះហៅបុណ្យកឋិន ឬកឋិនទាន ។

កឋិនទាន ជាចីវរទានដូចចីវរទានទាំងពួងដែរ តែមានឈ្មោះវិសេសតាមកាលបរិច្ឆេទ ដែលធ្វើហៅថាកាលទាន ជាទានមានផលច្រើនជាងចីវរទានទាំងពួង ព្រោះប្លែកពីចីវរទានឯទៀត ដោយលក្ខណាការ ៥ យ៉ាងគឺ:

**១_ប្លែកដោយកាល** ព្រោះមានពុទ្ធានុញ្ញាតថា កឋិនកាលមានតែ ២៩ ថ្ងៃ គឺខែអស្សុជ ១៤ ថ្ងៃ ពីត្រឹម ១ រោចដល់ ១៤ រោច ( ខែដាច់ ). ខែកត្តិក ១៥ ថ្ងៃ ពីត្រឹម ១ កើតដល់១៥កើត ( ពេញបូណ៌មី ) ។ រយៈកាលនេះពាក្យសាមញ្ញហៅថា រដូវកឋិន ក្នុងរដូវនេះ ទាយកចង់ធ្វើថ្ងៃណាមួយក៏បាន ក្រៅពីថ្ងៃទាំង ២៩ នេះពុំបាន ហើយវត្ត១ធ្វើបានតែម្តង ក្នុងរដូវ១ទាំងភិក្ខុដែលបានទទួលកឋិនក្នុងរដូវនោះម្តងហើយ ទទួលម្តងទៀតពុំបាន ។

**២_ប្លែកដោយវត្ថុ** គឺសំពត់ដែលព្រះអង្គកឋិននោះបានតែស្បង់ ឬចីពរ ឬក៏សង្ឃាដី ដែលគេធ្វើត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ. សំពត់ក្រៅពីនេះពុំបាន. ហើយសំពត់ទាំង៣មុខទៀត នឹងយកទាំងអស់ជាអង្គកឋិន១ ក៏ពុំបាន

បានតែ ១. ទោះបីទាយកយកវេរបីវរ១ត្រៃ គឺបីពរ ១ ស្បង់ ១ សង្ឃាដី ១ ជាសំពត់កឋិនមកវេរប្រគេន ក៏ភិក្ខុអ្នកក្រាលគ្រង លោករើសយកតែវត្ថុណាមួយ ធ្វើជាអង្គកឋិន គឺលោកចង់យកស្បង់ក៏បាន បីពរក៏បាន សង្ឃាដីក៏បាន ស្រេចលើព្រះទ័យលោក ឱ្យតែវត្ថុនោះត្រឹមត្រូវតាមវិនយបញ្ញត្តិ. តែតាមធម្មតា លោកអ្នកក្រាលគ្រងច្រើនយកតែសង្ឃាដីជាអង្គកឋិន ដោយលោកយល់ថា·បណ្តាបីវរ១ត្រៃសង្ឃាដីជាចីវរធំជាងគេ ។

៣.**វិប្ផលដោយអំពើ** គឺបុគ្គលអ្នកធ្វើគប្បីធ្វើឱ្យត្រូវរបៀបតាមវិនយបញ្ញត្តិ ហើយសង្ឃក៏គប្បីក្រាលគ្រងនិងអនុមោទនាឱ្យត្រឹមត្រូវតាមវិនយបញ្ញត្តិដែរ ទើបកើតជាកឋិនពេញលក្ខណៈបាន ។

៤.**វិប្ផលដោយបដិគ្គាហកៈ** គឺអ្នកទទួលសំពត់កឋិន បានតែភិក្ខុក្រៅពីភិក្ខុពុំបាន. ហើយភិក្ខុនោះទៀតលុះតែបានទៅចាំវស្សាគ្រប់៣ខែក្នុងវត្តណាមួយ ទើបទទួលក្រាលគ្រងនិងអនុមោទនាកឋិនក្នុងវត្តនោះបាន. ភិក្ខុដែលមិនបានទៅចាំវស្សា ឬបានទៅចាំវស្សាដែរ តែឱ្យដាច់ក៏ទទួលពុំបាន ។

៥.**វិប្ផលដោយអានិសង្ស** គឺទាយកអ្នកធ្វើក៏បានអានិសង្សច្រើន ភិក្ខុសង្ឃអ្នកទទួលក្រាលគ្រងនិងអនុមោទនាក៏បានអានិសង្ស ៥ យ៉ាងក្នុងរវាង ៥ ខែ ដូចមានក្នុងវិនយបិដកភាគ ៨ ត្រង់កឋិនក្ខន្ធកៈថា:

១.**អនាមន្តចារោ** ត្រាច់ទៅកាន់ទីដទៃ ដោយមិនបាច់លាភិក្ខុផងគ្នាបាន. មិនមានទោស.

២.**អសមាទានចារោ** ត្រាច់ទៅដោយមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់ជាប់ទៅជាមួយបាន.

៣.**គណភោជនំ** ឆាន់គណភោជនបាន.

www.elibraryofcambodia.org

៤-យាវទសត្ថចីវរំ ទុកដាក់អតិរេកចីវរបានតាមត្រូវការ.

៥-យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ ចីវរណា ដែលកើតឡើងក្នុងអាវាសនោះ ចីវរនោះនឹងមានដល់ភិក្ខុនោះ ។

ដោយកឋិនទានជាទានធ្វើឱ្យភិក្ខុសង្ឃអ្នកទទួលក្រាលគ្រង និង អនុ-មោទនាបានអានិសង្ស៥យ៉ាង ដូចពោលមកនេះហើយ បានជាទាយកអ្នកធ្វើកឋិនត្រូវបានផលានិសង្សច្រើនជាអនេកគ្រាប់រាប់ពុំបាន ព្រោះជាចីវរទានពិសេសប្លែកពីចីវរទាននានា ដូចពោលហើយផង ជាចីវរទានឱ្យបានផលានិសង្ស៥យ៉ាង ដ៏ប្រកបដោយសេចក្ដីសុខស្រួលដល់ព្រះភិក្ខុសង្ឃអ្នកទទួលទានផង សមដូចព្រះពុទ្ធដីកាថា:

សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ

ជនដ៏មានប្រាជ្ញា (ណាមួយ) បានឱ្យនូវសេចក្ដីសុខស្រួល (ដល់អ្នកដទៃ) ជននោះឯងរមែងបានជួបប្រទះនឹងសេចក្ដីសុខស្រួល (ជាពិតប្រាកដពុំខានឡើយ) ។

អធិប្បាយថា ជនណាបានធ្វើកឋិនទាន ដែលនាំឱ្យព្រះភិក្ខុសង្ឃបានអានិសង្ស៥យ៉ាង ក្នុងរវាង៥ខែនោះ បានឈ្មោះថាជាអ្នកឱ្យសេចក្ដីសុខស្រួលដល់អ្នកដទៃ ក្នុងបច្ចុប្បន្នជាតិនេះ ជននោះឯង តែងតែបានសុខក្នុងមនុស្សលោកនិងទេវលោក ទៅក្នុងអនាគតជាតិ ហើយដោយអំណាចផលានិសង្សនៃកឋិនទាននោះក្នុងកាលជាអនាគត ជននោះនឹងបានជាឯហិភិក្ខុ ឬឯហិភិក្ខុនីដែលមានត្រៃចីវរកើតឯងដោយឫទ្ធិ នៅពេលបព្វជ្ជា ជាបព្វជិតក្នុងសាសនាព្រះពុទ្ធអង្គណាមួយ ហើយបានសម្រេចមគ្គផលនិព្វាន ក្នុងពេលបព្វជ្ជានោះជាពិតប្រាកដពុំខានឡើយ ។

# រឿងភិក្ខុ ៣០ រូប

វិនយបិដក កឋិនក្ខន្ធកៈ មានចែងអំពីប្រភព នៃកឋិនចីវរ ថាៈ

ក្នុងបឋមពោធិកាល ដែលព្រះបរមសាស្ដាទ្រង់ឱ្យភិក្ខុប្រើប្រាស់តែបង្សុកូលចីវរ ពុំទាន់ទ្រង់អនុញ្ញាតឱ្យប្រើគហបតីចីវរនៅឡើយនោះ. សម័យមួយ កាលដែលទ្រង់គង់ចាំវស្សានៅវត្តជេតពន ជិតដល់ថ្ងៃចូលវស្សា ភិក្ខុ ៣០ អង្គ នៅស្រុកបាវា ប្រាថ្នាចង់មកថ្វាយបង្គំព្រះអង្គ មុនថ្ងៃចូលវស្សាតែមកមិនទាន់ ក៏ចូលវស្សានៅជនបទមួយ ត្រង់កណ្ដាលផ្លូវ ដល់ចេញវស្សាហើយ ទើបភិក្ខុទាំង ៣០ រូបនោះនាំគ្នាមក ។ ដោយពេលដែលមកនោះមានភ្លៀងធ្លាក់ច្រើនពេក ភិក្ខុទាំងនោះមានត្រៃចីវរទទឹកជោកដោយទឹកភ្លៀង ហើយដោយហេតុតែចង់ឃើញព្រះពុទ្ធរហ័ស ក៏នាំគ្នាចូលទៅថ្វាយបង្គំព្រះអង្គទាំងទទឹកនោះ ។ ព្រះអង្គបានទតឃើញដូច្នោះ ក៏ទ្រង់ព្រះមេត្តាប្រោសអនុញ្ញាតឱ្យភិក្ខុក្នុងព្រះពុទ្ធសាសនាទាំងមូលទទួលសំពត់កឋិនដែលជាគហបតីចីវរបាន ហើយទ្រង់បានអនុញ្ញាតឱ្យភិក្ខុដែលបានទទួលក្រាលគ្រង បានទទួលអនុមោទនាកឋិននោះ បានអានិសង្ស ៥ ប្រការ ។ ដោយពុទ្ធានុញ្ញាតនេះភិក្ខុក្នុងព្រះពុទ្ធសាសនមណ្ឌល ក៏បានទទួលកឋិនចីវរ ជាគហបតីចីវរនិងគហបតីចីវរនានា តាំងតែពីពេលនោះរៀបរាបដរាប មកដល់សព្វថ្ងៃនេះ ។

ជនដ៏មានសទ្ធាដែលបានធ្វើកឋិនទាន ឈ្មោះថាជាអ្នកគោរពព្រះពុទ្ធដីកាដែលទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃ បានអានិសង្ស ៥ ប្រការផង ជាអ្នកមានចិត្តអាណិតអាសូរព្រះសង្ឃ ដែលបានគង់ចាំវស្សា សិក្សាធម៌វិន័យចម្រើនមេត្តាភាវនា អស់ ១ វស្សា ឱ្យលោកបានអានិសង្ស ៥ ប្រការ តាមពុទ្ធានុញ្ញាតនោះផង ជាអ្នកបានតអាយុពុទ្ធសាសនា ឱ្យបានយឺនយូរ ឋិតថេរថេរកាល រុងរឿង

ចម្រើនតទៅផង ។

ដោយសារកឋិនទាន ជាកាលទានពិសេស ប្រកបដោយការគោរព ពុទ្ធានុញ្ញាត. ការមានចិត្តអាណិតអាសូរភិក្ខុសង្ឃនិងការគាំពារពុទ្ធសាសនា ប្លែកអំពីចីវរទានទាំងឡាយ ដូចដែលពណ៌នាមកនេះហើយ បានជាលោកពោលថា មានផលានិសង្សច្រើនលើសចីវរទានទាំងពួង ។

## ១៦_អានិសង្សផ្កា

ការបុណ្យដែលជនធ្វើដោយមានផ្កាជាសក្ការៈ ហៅថាបុណ្យផ្កា ។ បុណ្យផ្កានៅប្រទេសកម្ពុជាយើង នាសម័យបច្ចុប្បន្ននេះមាន ២ បែបគឺ:

១_បុណ្យផ្ការុក្ខជាតិ និងផ្កាវារីជាតិ គឺគេបេះតែផ្កាឈើ និងផ្កាឈូក ថ្វាយព្រះពុទ្ធរូប ។

២-បុណ្យផ្កាប្រាក់ គឺគេសន្មតប្រាក់ថាជាផ្កា បវរណាចំពោះព្រះសង្ឃ ដើម្បីសាងថាវរវត្ថុអ្វីមួយ ។

ប្រទេសកម្ពុជាយើងសម័យបុរាណ ពុទ្ធបរិស័ទទាំងព្រះរាជាទាំងប្រជារាស្ត្រ តែងទ្រង់ធ្វើ តែងធ្វើបុណ្យផ្ការុក្ខជាតិ និងផ្កាវារីជាតិយ៉ាងឧឡារិក. ប្រជារាស្ត្រច្រើនតែធ្វើនៅខែប្រាំងរវាងខែមាឃផល្គុនចេត្រ តែដល់ខែទាំងនេះ គេនាំគ្នាបេះផ្កាទាំងនោះ មានផ្កាឈូកនិងផ្កាម្លិះជាដើម មកចងក្រង ហើយហែរយកទៅថ្វាយព្រះពុទ្ធរូប នៅព្រះវិហារវត្តណាមួយដែលនៅជិត. ព្រះរាជាតែងទ្រង់ធ្វើនៅខែវស្សា គឺនៅថ្ងៃ ១៥ កើតខែស្រាពណ៍ ដោយទ្រង់ស្តេចយាងទៅក្រសាលបឹងតាមព្រះទីនាំងនាវា ទ្រង់ព្រះរាជបញ្ជាឱ្យបេះផ្កាឈូកស ឈូកក្រហម ព្រលិត លំចង់ ស្បូវ៉ជ យកមកថ្វាយព្រះក្នុងព្រះរាជមន្ទីរ និងទ្រង់ចាត់ឱ្យហែរហម ដោយក្បួនហែរដ៏មហោឡារិក យកទៅថ្វាយ

www.elibraryofcambodia.org

ព្រះពុទ្ធរូប គ្រប់អារាមហ្លួង ដែលនៅជិតព្រះបរមរាជវាំង ។

សម័យអតីត ប្រទេសខ្មែរយើងមានធ្វើបុណ្យផ្ការុក្ខជាតិធំដុំដាច់ដោយឡែក តែសម័យបច្ចុប្បន្នធ្វើតែបន្តិចបន្តួច រួមជាមួយនិងបុណ្យផ្កាប្រាក់ គេទុកបុណ្យផ្កាប្រាក់ថាជាបុណ្យធំដុំ ជំនួសវិញ ព្រោះគេបានរួមបច្ច័យកសាងថាវរវត្ថុផ្សេងៗ ទាំងសងខាងពុទ្ធចក្រទាំងខាងអាណាចក្រ ដោយគេយល់ថាបុណ្យផ្កាប្រាក់នាំឱ្យព្រះពុទ្ធសាសនា និងប្រទេសជាតិថ្កើងរុងរឿង ។

## រឿងព្រះបទុមត្ថេរ

គម្ពីរបាលីមត្តកវិន័យវិនិច្ឆ័យ ត្រង់អេសជ្ជករណាទិវិនិច្ឆ័យកថាថែងពីប្រភពនៃបុណ្យផ្កាថា:

បានឮថា ព្រះមហាបទុមត្ថេរនៅលង្កាទ្វីប កាលដែលរោគកើតឡើងដល់ព្រះរាជទេពី នៃព្រះមហាក្សត្រដ៏ស័ក្តិស្ថាលនិងលោក ព្រះរាជាទ្រង់ចាត់ឱ្យស្ត្រីបម្រើម្នាក់មកសួរថ្នាំលោក. លោកជាអ្នកកាន់វិន័យត្រឹមត្រូវ មិនប្រាប់ថាចេះឬថាមិនចេះទេ លោកធ្វើជាបែរទៅសួរពួកភិក្ខុថា "ម្នាលអាវុសោ! កាលដែលរោគដូច្នេះ កើតឡើងដល់ភិក្ខុ គេប្រកបថ្នាំអ្វី?" ។ ពួកភិក្ខុទូលតបថា "គេប្រកបថ្នាំនេះមួយៗ" ។ ស្ត្រីបម្រើបានឮ ក៏នាំដំណឹងនោះទៅទូលព្រះរាជាៗ បានជ្រាបទ្រង់ក៏ចាត់ការព្យាបាលរោគនោះដោយថ្នាំដូច្នោះ ក៏ជាសះស្បើយទៅ ។ កាលជាសះស្បើយហើយព្រះរាជាទ្រង់យកចីវរ ១ ត្រៃ និងរូបិយវត្ថុ ៣០០ កហាបណៈ ដាក់ក្នុងប្រអប់១ ទៅដំកល់ទុករៀបព្រះបាទាព្រះមហាបទុមត្ថេរ ហើយបវារណាថា "ភន្តេ បុប្ផបូជំ ករោថ បពិត្រព្រះករុណាម្ចាស់ដ៏ចម្រើន! សូមព្រះករុណាម្ចាស់ ចាត់ចែងផ្កាបូជា (ព្រះពុទ្ធរូប) ចុះ" ។ ព្រះមហាបទុមត្ថេរទទួលដោយតុណ្ហីភាព ហើយគិតថា "រូបិយវត្ថុ

មួយចំណែកនេះ ជាចំណែកអាចារ្យ ។ លុះគិតហើយក៏ញ៉ាំងអាចារ្យនោះ ឱ្យទទួលយកនូវចំណែកនោះ ដោយកប្បិយវោហារ. សល់ពីនោះលោកចាត់ចែងជាបជាព្រះពុទ្ធរូប ។

សម័យបុរាណប្រហែលជាពុទ្ធសាសនិកជនយកតម្រាប់តាមរឿងនេះ បានជាគេធ្វើបុណ្យផ្ការុក្ខជាតិ និងផ្កាប្រាក់ ជាពុទ្ធបូជារួមជាមួយគ្នា ជាប់ជាប្រពៃណីក្នុងព្រះពុទ្ធសាសនាហើយសម័យតៗ មកអ្នកមានសទ្ធាដែលត្រូវការសាងថាវរវត្ថុផ្សេងៗមានកុដិវិហារ សាលាបុណ្យ សាលារៀន ស្ពាន ស្រះជាដើម ជារបស់ត្រូវចាយប្រាក់ច្រើន តែបើគេមានធនធានតិច មិនអាចសាងម្នាក់ឯងបាន ក៏ផ្ដើមធ្វើជាបុណ្យផ្កាឡើង រៃអង្គាសញាតិមិត្តឱ្យចូលជាប្រាក់ជួយសាងថាវរវត្ថុនោះផងតាមកម្លាំងសទ្ធា តែតាមទម្លាប់ស្រុកខ្មែរនាសម័យបច្ចុប្បន្ន ទោះបីមានធនធានច្រើន ដែលអាចកសាងម្នាក់ឯងបាន ក៏តែងធ្វើបុណ្យផ្កាហើយផ្សាយដំណឹងបុណ្យនោះ ដល់ញាតិមិត្តជិតឆ្ងាយឱ្យជួយឧបត្ថម្ភផង ។ ជនអ្នកមានសទ្ធាជ្រះថ្លា ក៏តែងជួយចូលកុសលជាច្រើននាក់ បានប្រាក់ចំនួនច្រើន បវារណាចំពោះព្រះសង្ឃហើយប្រគល់ឱ្យគណៈកម្មការចាត់ចែងការសាងថាវរវត្ថុនោះៗ តាមត្រូវការ ដកល់ទុកជាកំណាប់បុណ្យព្រេងតទៅ ។ ព្រោះហេតុហ្នឹងហើយ បានជាយើងតែងឃើញគេធ្វើបុណ្យផ្កាប្រាក់ ដាក់ផ្ការុក្ខជាតិ ជាទីតាំងផង គេតែងតែយកសាច់លុយ ឬក្រដាសផ្សេងៗ ទៅដោតធ្វើជាផ្កាប្រាក់ ដាក់ជើងជាសំគាល់ផង ដើម្បីឱ្យសមតាមឈ្មោះថាបុណ្យផ្កានោះឯង ។

ផ្ការុក្ខជាតិ និងផ្កាវារីជាតិ ជាសោភនវត្ថុ មានលំអត្ថដោយទស្សនាដោយពណ៌សម្បុរ ដោយរូបភាព និងគួរជាទីចាប់អារម្មណ៍ដោយក្លិន ជារបស់

ដែលមនុស្សលោកតែងតែរាប់អាន តែងតាំងជាល់អនៅគ្រឹះស្ថានរបស់ខ្លួន តែងថ្វាយជាសក្ការបូជាចំពោះសរណវត្ថុ តាំងពីបុរាណកាលរៀងមក ។

ព្រោះផ្ការុក្ខជាតិ និងផ្កាវារីជាតិ មានគុណភាពដូចពោលមកហើយ បាន ជាការបូជាផ្កាដល់បូជនីយវត្ថុ ឬបូជនីយដ្ឋានបានផលានិសង្សច្រើន តាមតែ កម្លាំងចិត្តសទ្ធានិងជ្រះថ្លា ដូចជារឿងនាយសុមនមាលាការ ដែលបានបូជាផ្កា ម្លិះ ចំពោះព្រះសម្មាសម្ពុទ្ធនោះឯង ។

# រឿងសុមនមាលាការ

កាលព្រះសក្យមុនីគោតមបរមគ្រូជាម្ចាស់ ទ្រង់យាងបិណ្ឌបាតក្នុងក្រុង រាជគ្រឹះ...មានបុរសម្នាក់ឈ្មោះសុមនមាលាការ ជាអ្នកក្រងផ្កាថ្វាយព្រះបាទ ពិម្ពិសាររាជ តែងតែក្រងផ្កាម្លិះយកទៅថ្វាយព្រះរាជារាល់ថ្ងៃ ។ វេលាព្រឹក មួយនោះសុមនមាលាការ យកផ្កាទៅថ្វាយព្រះរាជា បានឃើញព្រះសម្ពុទ្ធ ទ្រង់យាងបិណ្ឌបាត មានចិត្តជ្រះថ្លាបានយកផ្កានោះទៅថ្វាយព្រះអង្គ ផ្កានោះ អណ្តែតត្រសែតឡើងលើនភាល័យ ដូចជាពិតានតាំងនៅលើព្រះសិរសា មាន រស្មីភ្លឺផ្លេក១ ដោយចាំងនឹងព្រះឆព្វណ្ណរង្សី ។ មហាជនក៏ផ្អើលឈូឆរមក ទស្សនាជាមហាអស្ចារ្យ ។ ភរិយាសុមនមាលាការដឹងថាស្វាមីខ្លួនយកផ្កាថ្វាយ ព្រះសម្មាសម្ពុទ្ធ ខ្លាចព្រះរាជាទ្រង់ផ្តន្ទាទោសស្វាមីហើយទោសនោះប៉ះពាល់ ដល់ខ្លួន ក៏ម្នីម្នាទៅក្រាបបង្គំទូលជាមុនថា ខ្លួនមិនទទួលដឹងរឿងប្តីយកផ្កាទៅ ថ្វាយព្រះពុទ្ធទេ ខ្លួនបានលែងលះស្វាមី ពីថ្ងៃនេះទៅហើយ ។ ព្រះរាជាទ្រង់ ជ្រាបថា សុមនមាលាការយកផ្ការបស់ព្រះអង្គ ទៅថ្វាយព្រះសម្មាសម្ពុទ្ធ ហើយផ្កានោះអណ្តែតជាពិតានថ្វាយព្រះអង្គដូច្នោះ ក៏ទ្រង់ជ្រះថ្លា ទ្រង់ព្រះ រាជទានព្រះរាជទ្រព្យ និងយសបរិវារជាច្រើនដល់សុមនមាលាការ ។ សុមន-

www.elibraryofcambodia.org

មាលាការក៏បានសេចក្ដីសុខចម្រើន រុងរឿង ដោយអានិសង្សថ្វាយផ្កាចំពោះព្រះសម្មាសម្ពុទ្ធនោះឯង ។

## រឿងនាងទេវធីតាផ្កាននោង

កាលព្រះបរមសាស្ដាជាអម្ចាស់ ទ្រង់ចូលព្រះនិព្វានទៅព្រះបាទអជាតសត្រូវ បានព្រះបរមធាតុ ១ ចំណែក យកមកបញ្ចុះនៅទីទួលមួយ ។ គ្រាមួយនោះ នាងកុលធីតាម្នាក់មានផ្ទះនៅក្បែរទីនោះ ភ្ញាក់ពីព្រលឹមទៅលប់មុខនៅខាងក្រៅផ្ទះ បានក្រឡេកទៅឃើញផ្កាននោងរបស់ខ្លួន ទើបនឹងរីកថ្មីៗ នាងមានសេចក្ដីជ្រះថ្លាបានបេះផ្កាននោងនោះ កាន់យកទៅថ្វាយព្រះបរមធាតុនៅទីនោះ ។ ដោយមានបីតិប្រាមោជ្ជខ្លាំងពេក ដើររលះរលាំងទៅតាមផ្លូវដើម្បីឱ្យឆាប់ដល់ទីបូជា មេគោមានកូនខ្ចីមួយវាការពារកូនវា ជល់នាងដួលស្លាប់កណ្ដាលផ្លូវទៅ ។

ដោយអំណាចកុសលចេតនាជ្រះថ្លា ចំពោះការបូជាផ្កាននោងនោះ នាងកុលធីតានោះបានទៅកើតក្នុងឋានត្រៃត្រិង្សទេវលោក ក្នុងកណ្ដាលហ្វូងពួកទេពធីតាដែលកំពុងហែព្រះឥន្ទកណ្ដាលអាកាស ។ កើតឡើងភ្លាមមានសម្បុរលឿងឆ្អៅដូចមាសទពគុណ មានអាភរណៈនិងគ្រឿងស្លៀកពាក់ ព្រមទាំងរទេះរថ សុទ្ធតែសម្បុរលឿងៗ ដូចផ្កាននោង ។

ពួកទេវធីតាផ្អើលឈូឆរ ហោមរោមមើលនាងសួរនាងថា "នាងបានធ្វើបុណ្យអ្វី បានជាមកកើតក្នុងទីនេះ មានប្រដាប់សុទ្ធតែលឿងៗដូច្នេះ?" ។ នាងឆ្លើយថា លាក់បាំងអ្វីខ្ញុំមិនចង់ប្រាប់ទេ ព្រោះខ្ញុំធ្វើបុណ្យតិចតួចណាស់ គឺគ្រាន់តែបានបេះផ្កាននោងក្បែរផ្ទះខ្ញុំកាន់ដើរទៅតាមផ្លូវដើម្បីនឹងបូជាព្រះបរមធាតុនៃព្រះពុទ្ធ ដែលបញ្ចុះនៅទីទួលខ្ពស់ ជិតផ្ទះខ្ញុំ ខ្ញុំកាន់ផ្កានោះដើរទៅ

www.elibraryofcambodia.org

ទើបនឹងដល់ពាក់កណ្ដាលផ្លូវ មេគោមានកូនខ្ចី១ វាការពារកូនវាមកបុះខ្ញុំដួលស្លាប់ ហើយបានមកកើតក្នុងទីនេះ ទាំងមិនដឹងខ្លួនដូច្នេះឯង ។

ពួកទេវធីតាបានស្ដាប់ពតិមានេះ ហើយនាំគ្នាហៅនាងនោះថាអនោជាទេវធីតា ប្រែថា នាងទេពធីតាផ្កាននោងតទៅ ។

ព្រះឥន្ទ្រទ្រង់សាកសួរបានជ្រាបសេចក្ដីនោះសព្វគ្រប់ ក៏ទ្រង់ទទួលរាប់បញ្ចូលជានាងទេពអប្សរបរិវារព្រះអង្គ ដូចនាងទេពធីតាទាំងពួង ។

នាងទេពធីតានោះ បានសោយសម្បត្តិទិព្វដូចរៀបរាប់មកនេះ ដោយអានិសង្សផ្កាននោង ដែលនាងបានបេះយកទៅដើម្បីបូជាព្រះបរមសារីរិកធាតុនៃព្រះជិនស្រី ដោយចិត្តប្រកបដោយញាណសម្បយុត្តអសង្ខារិកដែលនឹងចង់ធ្វើពុទ្ធបូជា ដោយខ្លួនឯង ពុំមាននរណាដាស់តឿន ឬបបួលឡើយនោះឯង ។

## ១៣_អានិសង្សផ្លូស

សម័យពុទ្ធកាល ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូគង់ព្រះធរមាននៅឡើយនិងក្រោយពុទ្ធនិព្វានប្រមាណ ១០០០ ឆ្នាំ ពុទ្ធបរិស័ទអ្នកកាន់ពុទ្ធសាសនាមាន ៤ ពួក គឺភិក្ខុ ១ ពួក ភិក្ខុនី ១ ពួក ឧបាសក ១ ពួក ឧបាសិកា ១ ពួក ។ ក្រោយពីសម័យនោះមករហូតដល់សម័យបច្ចុប្បន្ននេះ ក៏មានពុទ្ធបរិស័ទ ៤ ពួកដែរ គ្រាន់តែសម័យនេះគ្មានភិក្ខុនី មានតែសាមណេរជំនួសតែប៉ុណ្ណោះ ក៏រាប់ថាពុទ្ធបរិស័ទ ៤ ពួកបាន ។ ពុទ្ធបរិស័ទទាំង ២ ពួកនេះ បើពោលដោយបំព្រួញ ទោះបីសម័យពុទ្ធកាលក្ដី សម័យបច្ចុប្បន្នក្ដី មានតែ ២ ពួក គឺខាងបព្វជិតជាភិក្ខុសាមណេរ ១ ពួក ហៅថាអ្នកកាន់ពុទ្ធសាសនាផ្ទាល់ ជាឧត្តមភេទ ដោយមានគ្រឿងស្លៀកដណ្ដប់ជ្រលក់ទឹកអម្ចត់ពណ៌លឿងតែមួយយ៉ាងដូចព្រះពុទ្ធអង្គ. ខាងគ្រហស្ថជាឧបាសកឧបាសិកា ១ ពួក ហៅថា អ្នកកាន់

ពុទ្ធសាសនាប្រយោលជាហីនភេទ មានគ្រឿងស្លៀកពាក់ជ្រលក់ពណ៌ផ្សេងៗ តាមប្រពៃណីនិយម ។

អ្នកបួសក្នុងព្រះពុទ្ធសាសនា មាននាមពាយ៉ាង.

១-ហៅថា ភិក្ខុ ប្រែថា អ្នកសូម គឺជាអ្នកសូមទេយ្យទានមានអាហារបិណ្ឌបាតជាដើម អំពីទាយក.

២-ហៅថា បព្វជិត ប្រែថាអ្នកវៀរចាកអំពើមានទោសគ្រប់យ៉ាង.

៣-ហៅថា សមណៈ ប្រែថា អ្នកស្ងប់ គឺជាអ្នករម្ងាប់ចាកសេចក្តីអាក្រក់គ្រប់ជំពូក ។

ក្នុងឱវាទបាតិមោក្ខ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានព្រះឱវាទថា:

ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ

បុគ្គលដែលសម្លាប់ ឬបៀតបៀនគេ មិនឈ្មោះថាបព្វជិត ឬសមណៈទេ ។ គឺបុគ្គលដែលប្តេជ្ញាខ្លួន ថាជាបព្វជិត ឬសមណៈនោះ លុះតែមានអធិវាសនខន្តី អត់ធន់ មិនប្រទូស្តអ្នកដទៃ ឱ្យគេវិនាសចាកជីវិត ចាកទ្រព្យសម្បត្តិ ឬមិនបៀតបៀនគេឱ្យបានសេចក្តីលំបាក ទើបសមតាមឈ្មោះថាបព្វជិត ឬថា សមណៈ ពិតប្រាកដ ។

ជនដែលបានបព្វជ្ជាជាសាមណេរ និងបានឧបសម្បទា ជាភិក្ខុក្នុងព្រះពុទ្ធសាសនា ហើយបានប្រតិបត្តិត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិនោះបានផលានិសង្សច្រើនណាស់ ហើយបានឈ្មោះថាជាអ្នកជម្រះខ្លួនជាមនុស្សបរិសុទ្ធចាកបាបផង ជាអ្នកទ្រទ្រង់ព្រះពុទ្ធសាសនាឱ្យរុងរឿងចម្រើនឋិតថេរតទៅផង ។

មួយទៀត ជនដែលបានបួសខ្លួនឯង ឬបានបំបួសបុត្រក្នុងព្រះពុទ្ធសាសនានោះ ទើបបានឈ្មោះថាជាញាតិជិតនឹងព្រះពុទ្ធសាសនា ។

ព្រះមោគ្គលីបុត្តតិស្សត្ថេរបានថ្វាយធម្មទេសនារឿងនេះ ចំពោះព្រះបាទធម្មាសោក ជាស្តេចចុល្លចក្រពត្រក្នុងជម្ពូទ្វីប ( ប្រទេសឥណ្ឌា) ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។ ព្រះបាទធម្មាសោក បានស្តាប់ព្រះធម្មទេសនា នោះក៏ទ្រង់បំបួសព្រះរាជបុត្រាព្រះនាម មហិន្ទៈ ជាភិក្ខុ និងព្រះរាជបុត្រីព្រះនាមសង្ឃ មិត្រា ជាភិក្ខុនី ហើយព្រះមហិន្ទភិក្ខុ បានជាព្រះមហាមហិន្ទត្ថេរ ព្រះនាងសង្ឃមិត្រាភិក្ខុនី ជាជាព្រះសង្ឃមិត្រាថេរីនិមន្តទៅផ្សាយព្រះពុទ្ធសាសនាទៅលង្កាទ្វីប ជាសាស្តាបំបួសព្រះទេពីនិងព្រះរាជបុត្រា បុត្រីនៃព្រះបាទទេវានម្បិតិស្សៈ ព្រះរាជាលង្កាទ្វីបនិងបុត្រាបុត្រីនៃប្រជារាស្ត្រនៅទ្វីបនោះឱ្យជាភិក្ខុភិក្ខុនីជាច្រើនរូប ។

សៀវភៅរឿងព្រះបាទអសោក របស់វិជ្ជាឋានពុទ្ធសាសនាបណ្ឌិត្យត្រង់ទំព័រ ១៤ ពុទ្ធសករាជ ២៩៥ ព្រះបាទអសោកស្តេចបានទៅនមស្សការទីប្រសូតរបស់ព្រះពុទ្ធ. ពុទ្ធសករាជ ៣០១ ទ្រង់បានឧបសម្បទាជាភិក្ខុផ្ទាល់ព្រះអង្គក្នុងព្រះពុទ្ធសាសនា ។

គម្ពីរមហាវង្សពង្សាវតារលង្កាទ្វីប និទានរឿងព្រះមហាមហិន្ទត្ថេរពិស្តារ. តែទីនេះ សូមពណ៌នាដោយសង្ខេបដូចតទៅ:

## រឿងព្រះមហាមហិន្ទត្ថេរ

ព្រះមហាមហិន្ទត្ថេរ ជាព្រះរាជបុត្រានៃព្រះបាទធម្មាសោក ក្រោយពេលដែលលោកបានបព្វជ្ជា ឧបសម្បទាបានសម្រេចមគ្គផល ព្រមទាំងអភិញ្ញា ៦ ហើយលោកបាននាំព្រះថេរ ៤ អង្គ ដែលបានសម្រេចមគ្គផល

www.elibraryofcambodia.org

ព្រមទាំងអភិញ្ញាណ ៦ ដូចគ្នា ទៅផ្សាយព្រះពុទ្ធសាសនានៅលង្កាទ្វីប ។ លោកចេញចាកជម្ពូទ្វីបទៅកាន់លង្កាទ្វីប ដោយឥទ្ធិឫទ្ធិ ។ មុនដំបូងលោកនៅគង់នៅភ្នំ ១ មិនឆ្ងាយប៉ុន្មានពីព្រះរាជវាំងព្រះទេវានម្បិយតិស្សព្រះរាជាលង្កាទ្វីប ។ ថ្ងៃដែលលោកនិមន្តទៅដល់ ព្រះរាជាស្ដេចចេញក្រសាលព្រៃបានជួបនឹងលោក ស្ដេចសួរលោកបានជ្រាបថាលោកជាព្រះរាជបុត្រព្រះបាទធម្មាសោកជាមហាមិត្ត ក៏ទ្រង់ជ្រះថ្លាទ្រង់បាននិមន្តទៅឆាន់នៅព្រះរាជវាំង ។

វេលានោះ ជាវេលាដ៏មហោឡារិកក្រៃពេក ករគ្រឹកអំពើតទាំងផ្ទៃព្រះនគរជាលើកទី ១ ដោយមហាជនទាំងព្រះរាជាព្រះរាជវង្សានុវង្សទាំងនាហ្មឺនសព្វមុខមន្ត្រី ព្រមទាំងប្រជារាស្ត្ររាល់សែននាក់ ផ្អើលឈូឆរណែនណាន់តាន់តាប់មកទស្សនាព្រះមហាថេរ។ បាននាំធម៌ទេសនាមានពណ៌នាអំពីពុទ្ធប្រវត្តិជាដើម ជាសណ្ដាប់ដល់មហាសន្និបាតនោះ ។ ខណៈនោះមហាជនមានព្រះរាជាជាប្រធានបានទ្រង់ព្រះសណ្ដាប់បានស្ដាប់ហើយបានប្ដេជ្ញាព្រះអង្គប្ដេជ្ញាខ្លួនជាឧបាសកឧបាសិកាមានព្រះត្រៃសរណគមន៍ជាទីពឹងទីរលឹក ជនខ្លះបានសម្រេចមគ្គផលសមគួរតាមឧបនិស្ស័យរៀនខ្លួន ។

ក្រោយពីនោះ បុរសអ្នកមានសទ្ធាបានបព្វជ្ជាបានឧបសម្បទាជាភិក្ខុសាមណេរក្នុងព្រះពុទ្ធសាសនា ។ ចំណែកខាងស្ត្រី ព្រះនាងអនុលាជាព្រះរាជទេពីនៃព្រះបាទទេវានម្បិយតិស្សៈ ក៏ទ្រង់សព្វព្រះទ័យបួសជាភិក្ខុនីដែរ តែព្រះមហាមហិន្ទត្ថេរមានព្រះថេរដីកាថា ការបួសជាភិក្ខុនីលុះតែមានភិក្ខុនីសង្ឃផង ព្រោះឧបសម្បទាកម្មរបស់ភិក្ខុនីជាឧភតោសង្ឃកម្ម គឺត្រូវបួសដោយមានឧបជ្ឈាយ៍ និងកម្មវាចាខាងពួកភិក្ខុនី ហើយមកបួសខាងពួកភិក្ខុថែម

ទៀត ទើបសម្រេចជាភិក្ខុនីបាន ។

ព្រះនាងអនុលាទេវីបានទ្រង់ជ្រាបរឿងនោះ ទ្រង់សូមព្រះរាជានិងព្រះមហាថេរចាត់ការនោះ ។ ព្រះរាជានិងព្រះមហាថេរក៏ទ្រង់ចាត់ការឱ្យមកនិមន្តព្រះសង្ឃមិត្តាថេរី ជាព្រះអនុជានៃព្រះមហាមហិន្ទត្ថេរ ព្រមទាំងភិក្ខុនីសង្ឃអំពីជម្ពូទ្វីបទៅកាន់លង្កាទ្វីប ។

ព្រះបាទធម្មាសោកក៏ទ្រង់និមន្តព្រះសង្ឃមិត្តាថេរី ព្រមទាំងភិក្ខុនីសង្ឃខ្លះឱ្យទៅលង្កាទ្វីប តាមព្រះរាជបំណង ។

វេលាព្រះសង្ឃមិត្តាថេរីនិមន្តទៅនេះ ទ្រង់បាននាំយកមែកពោធិព្រឹក្សដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងក្រោមម្លប់នោះទៅផង ។

វេលានោះ កក្រើកអំពើកទាំងផ្ទៃព្រះនគរជាលើកទី ២ ដោយមហាជនទាំងព្រះរាជា ទាំងប្រជារាស្ត្ររាល់សែននាក់ផ្តើលឈូងរមកទស្សនា មកគោរពព្រះភិក្ខុនីសង្ឃនិងមែកពោធិព្រឹក្សជាមហាអស្ចារ្យ ។

លំដាប់ពីនោះ ព្រះសង្ឃមិត្តាថេរីក៏បានជាព្រះឧបជ្ឈាយ៍បំបួសព្រះនាងអនុលាទេវីជាភិក្ខុនីជាប្រថម ជាមួយស្ត្រីដទៃទៀតជាច្រើនរូប ។

ប្រទេសលង្កា ជាប្រទេសពុទ្ធសាសនិក កាន់ព្រះពុទ្ធសាសនាខ្ជាប់ខ្ជួនមួនមាំ រុងរឿង ចម្រើន តាំងពីសម័យនោះរហូតមកដល់សម័យបច្ចុប្បន្ន ដោយសារព្រះរាជបេសកកម្មរបស់ព្រះបាទធម្មាសោកនោះឯង ។

ប្រទេសកម្ពុជាយើងក៏ជាប្រទេសពុទ្ធសាសនិកកាន់ព្រះពុទ្ធសាសនាដំណាលគ្នានិងប្រទេសលង្កា ដោយសារព្រះរាជសកម្មភាពរបស់ព្រះបាទធម្មាសោកទ្រង់ផ្សាយមកដែរ ព្រោះសម័យជាមួយគ្នានោះ ព្រះមោគ្គលីបុត្តតិស្សត្ថេរបានបញ្ជូនព្រះថេរៈ ២អង្គ គឺព្រះសោណៈ និងព្រះឧត្តរៈ ជាសមណទូតឱ្យមក

www.elibraryofcambodia.org

ផ្សាយព្រះពុទ្ធសាសនាទៅជ្រោយសុវណ្ណភូមិ មានប្រទេសកម្ពុជាជាដើម ហើយកុលបុត្រខ្មែរទាំងប្រទេសក៏បានបព្វជ្ជា ឧបសម្បទា ជាភិក្ខុសាមណេរត។គ្នាញ៉ាំងព្រះពុទ្ធសាសនាឱ្យថ្កើងរុងរឿងរហូតមក ។

ព្រះមហាក្សត្រខ្មែរសម័យបុរាណ ទ្រង់សព្វព្រះរាជហឫទ័យ និបពជ្ជាកម្មណាស់ ។ សិលាចារឹកនៅសសរប្រាសាទនគរវត្តត្រង់ថ្នាក់កណ្តាលពីខាងមុខ មាននិយាយដល់រឿងព្រះរាជាទ្រង់បំបួសព្រះរាជបុត្រ ។ សិលាចារឹកក្នុងទីដទៃទៀតមាននិយាយពីព្រះបាទជ័យវរ្ម័ធិរាជ ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាណាស់ បានថ្វាយព្រះអង្គជាមហាឧបាសកក្នុងព្រះពុទ្ធសាសនា សូម្បីព្រះរាជបុត្រនៅក្នុងព្រះឧទរនៃព្រះអគ្គមហេសីនៅឡើយ មិនទាន់ទាំងជ្រាបថាជាប្រុសឬស្រីផង ក៏ទ្រង់ឧទ្ទិសទុកជាមុនថា "កាលប្រសូតមកបើជាព្រះរាជបុត្រីនិងថ្វាយជាអ្នកឧបដ្ឋាកព្រះរតនត្រ័យ បើជាព្រះរាជបុត្រានិងឱ្យទ្រង់ផ្នួសសំណាក់ព្រះពុទ្ធសាសនា" ។

## ១៨-អានិសង្សសំដែងធម៌

ការសំដែងធម៌ ឬការបង្រៀនធម៌ដល់ជនដទៃក្តី ការសាងគម្ពីរដីកា ជាសាស្ត្រាស្លឹករឹត ឬក្រាំងសៀវភៅធម៌ក្តីហៅថាធ្វើធម្មទាន ជាទានដ៏ឧត្តមមានផលច្រើនយ៉ាងក្រៃលែង ។

ពាក្យនេះ សមនិងពុទ្ធភាសិតថា *សព្វទានំ ធម្មទានំ ជិនាតិ* ធម្មទានឈ្នះទានទាំងពួង គឺបានផលច្រើនជាងអាមិសទានដែលជាទានផ្តល់ខាងផ្លូវសម្ភារៈ ជួយឧបត្ថម្ភតែខាងផ្លូវកាយ. ឯធម្មទានជាទានផ្តល់ខាងផ្លូវចិត្ត ជួយឧបត្ថម្ភអ្នកស្តាប់អ្នកអាន ឱ្យបានប្រយោជន៍ ៥ យ៉ាងគឺ

**១-អស្សុតំ សុណាតិ** ឱ្យអ្នកស្តាប់អ្នកអានបានស្តាប់ឮបានមើល

ឃើញនូវធម៌ដែលមិនធ្លាប់បានស្តាប់បានឃើញ.

២-សុតំ បរិយោទបេតិ ឱ្យអ្នកស្តាប់អ្នកអានបានញ៉ាំងធម៌ ដែលធ្លាប់ស្តាប់ធ្លាប់ឃើញហើយ ឱ្យភ្លឺស្វាងជូរជង់ឡើង.

៣-កង្ខំ វិហនតិ ឱ្យអ្នកស្តាប់អ្នកអានបានបន្ទោរបង់សេចក្តីសង្ស័យ

៤-ទិដ្ឋឹ ឧជុំ ករោតិ ឱ្យអ្នកស្តាប់អ្នកអានបានធ្វើនូវទិដ្ឋិឱ្យយល់ត្រូវបង់.

៥-ចិត្តមស្ស បសីទតិ ឱ្យអ្នកស្តាប់អ្នកអានកើតចិត្តជ្រះថ្លា ។

ការសំដែងធម៌ មិនមែនងាយសំដែងបានទេ ព្រោះព្រះធម៌ជាពុទ្ធវចនៈមានន័យជ្រាលជ្រៅណាស់ អ្នកមានព្យាយាមស្តាប់ព្យាយាមរៀន អស់កាលដ៏យូរ ទើបបានចេះបានចាំយល់សេចក្តីច្បាស់លាស់ ហើយលុះតែចេះចាំយល់សេចក្តីច្បាស់លាស់ស្រួលបួល ទើបអាចសំដែងបាន ។ កាលដែលគេស្តាប់គេរៀននោះ បានផលព្រោះស្តាប់ព្រោះរៀនមួយលើកទៅហើយ ដល់មកសំដែងបានផលមួយលើកទៀត ផ្សំគ្នា ទើបការសំដែងធម៌នោះ មានផលច្រើនផលខ្ពស់ ព្រោះបើមិនស្តាល់ មិនរៀន ធ្វើម្តេចមកសំដែងបាន ។

មួយទៀត ការធ្វើធម្មទាន បានជាបានផលច្រើនជាងអាមិសទានទាំងពួង ព្រោះការធ្វើធម្មទាន ជាការឧបត្ថម្ភព្រះពុទ្ធសាសនាមួយភាគយ៉ាងធំ នាំឱ្យព្រះពុទ្ធសាសនាថ្កើងរុងរឿងឋិតថេរយូរអង្វែងទៅបាន ព្រោះព្រះពុទ្ធសាសនារុងរឿងដោយហេតុ ៥ យ៉ាងគឺ

១-ពុទ្ធបរិស័ទ ស្តាប់ ធម៌វិន័យដោយគោរព

២- - រៀន

៣- - កត់ចំណាំ

៤- ពុទ្ធបរិស័ទ ត្រិះរិះពិចារណាឱ្យយល់ ធម៌វិន័យដោយគោរព

៥- - ដឹងហើយប្រតិបត្តិតាម -

ព្រោះការសំដែងធម៌ បានឈ្មោះថាជាការឧបត្ថម្ភព្រះពុទ្ធសាសនានាំឱ្យព្រះពុទ្ធសាសនារុងរឿងឋិតថេរក្នុងលោក ដើម្បីប្រោសសត្វលោក បានយូរបានចម្រើន តទៅនោះហើយបានជាការសំដែងធម៌ជាធម្មទាន មានផលានិសង្សច្រើនជាងអាមិសទាន ។

គម្ពីរទីឃនិកាយ ត្រង់មហាបរិនិព្វានសូត្រ បានចែងពីការបូជាថាមាន ២ យ៉ាងគឺ

១-បូជាដោយអាមិស ហៅថា អាមិសបូជា.

២-បូជាដោយធម៌ ហៅថា ធម្មបូជា ។

ការថ្វាយគ្រឿងសក្ការៈ មានភ្ញីផ្កាជាដើម ហៅអាមិសបូជា

ការសំដែងធម៌ ពន្យល់ធម៌ ដល់ពុទ្ធបរិស័ទ ឱ្យយល់ធម៌ត្រឹមត្រូវតាមគន្លងពុទ្ធវចនៈ ដើម្បីញុំាងព្រះពុទ្ធសាសនាឱ្យរុងរឿងឱ្យឋិតថេរនោះ រាប់ចូលក្នុងធម្មបូជា ។

ព្រោះធម្មទាន រាប់ចូលជាធម្មបូជាបាននេះហើយ បានជាធម្មទានមានផលច្រើនណាស់នោះឯង ។

គម្ពីរបរមត្ថជោតិកា អដ្ឋកថាខុទ្ទកនិកាយ ខុទ្ទកបាឋសំដែងជាពាក្យឧបមាថា ព្រះពុទ្ធទុកដូចជាអ្នកបង្ហាញផ្លូវ.ព្រះធម៌ទុកជាអ្នកតួផ្លូវ. ព្រះសង្ឃទុកជាអ្នកដើរតាមផ្លូវ ដែលព្រះពុទ្ធអង្គទ្រង់ចង្អុលប្រាប់ហើយ ។

តាមន័យនេះ. ព្រះធម្មកថិកដែលបានស្តាប់ បានរៀនពុទ្ធវចនៈតាមគម្ពីរដីកាមានព្រះត្រៃបិដកជាដើម ហើយបាននាំយកពុទ្ធវចនៈនោះៗ មក

www.elibraryofcambodia.org

សំដែងប្រាប់ពន្យល់ពុទ្ធបរិស័ទផងគ្នាតទៅទៀត ក៏មានឈ្មោះថាជាអ្នកបង្ហាញផ្លូវ. ព្រះធម៌ដែលព្រះធម្មកថិកនាំមកសំដែងនោះ ក៏ឈ្មោះថាជាតួផ្លូវ ហើយពុទ្ធបរិស័ទដែលបានស្ដាប់ព្រះធម្មកថិកសំដែងនោះ ក៏មានឈ្មោះថាជាអ្នកដើរតាមផ្លូវដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទេសនាប្រាប់ហើយនោះ ជាពិតប្រាកដ ។

ព្រោះអ្នកសំដែងធម៌ ទុកដូចអ្នកប្រាប់ផ្លូវ. ធម៌ដែលអ្នកសំដែងនោះទុកដូចជាតួផ្លូវ. អ្នកដែលស្ដាប់ធម៌របស់អ្នកសំដែង ហើយប្រតិបត្តិតាមផ្លូវគឺគន្លងព្រះពុទ្ធសាសនា សំដៅទៅរកមគ្គផលនិព្វាននោះហើយ បានជាអ្នកសំដែងធម៌នោះត្រូវតែបានផលច្រើន មែនពិត ឥតសង្ស័យឡើយ ។

មួយទៀត ពុទ្ធបរិស័ទទាំងពួង ដែលបានចេះដឹងកិច្ចការបុណ្យផ្សេងៗមានកិច្ចធ្វើទាននិងកិច្ចរក្សាសីល ឬកិច្ចភាវនាជាដើម ហើយបានធ្វើទានរក្សាសីល និងចម្រើនភាវនាបានផលជាសុខក្នុងលោកនេះនឹងលោកខាងមុខនោះមកពីបានស្ដាប់តាមព្រះធម្មកថិកសំដែង និងបានអានបានរៀនតាមគម្ពីរដីកាជាសាស្ត្រាស្លឹករឹត ឬក្រាំង-សៀវភៅដែលសប្បុរិសជន បានសាងទុកសម្រាប់ទុកឱ្យពុទ្ធបរិស័ទស្ដាប់ អាន-រៀនសូត្រនិងប្រតិបត្តិតាម ។

ព្រោះការសំដែងធម៌ និងសាងគម្ពីរដីកា ជាការនាំឱ្យពុទ្ធបរិស័ទបានចេះដឹងកិច្ចបុណ្យទាន ដែលជាកុសលកម្មនាំឱ្យបានសុខក្នុងភពលោក និងបរលោកដូចពោលមកនេះ ទើបលោកពោលថា ការសំដែងធម៌ និងការសាងគម្ពីរដីកានោះបានផលានិសង្សច្រើនជាងទានទាំងពួង ។

## ១៩_អានិសង្សស្ដាប់ធម៌

អ្នកស្ដាប់ធម៌ រមែងបានអានិសង្ស ៥ យ៉ាងគឺ:

១_អស្សុតំ សុណាតិ រមែងបានស្ដាប់នូវធម៌ ដែលមិនធ្លាប់បានស្ដាប់

២. សុតំ បរិយោទបេតិ រមែងញុំាងធម៌ដែលធ្លាប់បានស្ដាប់ហើយ ឱ្យភ្លឺស្វាងថ្លៃរថែមឡើង.

៣. កង្ខំ វិហនតិ រមែងកំចាត់បង់នូវសេចក្ដីសង្ស័យបាន.

៤. ទិដ្ឋឹ ឧជុំ ករោតិ រមែងបានធ្វើនូវសេចក្ដីយល់ឱ្យត្រូវត្រង់.

៥. ចិត្តមស្ស បសីទតិ ចិត្តរបស់អ្នកស្ដាប់រមែងជ្រះថ្លា ។

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជរមាន៍នៅឡើយ ពុទ្ធបរិស័ទតែងបានស្ដាប់ បានរៀនព្រះធម៌ ជាព្រះពុទ្ធឱវាទផ្ទាល់ព្រះពុទ្ធឱស្ឋ. តាំងពីពេលព្រះអង្គចូលព្រះនិព្វានទៅរហូតមកដល់បច្ចុប្បន្ននេះ ពុទ្ធបរិស័ទបានស្ដាប់បានរៀនព្រះពុទ្ធវចនៈតាមគម្ពីរព្រះត្រ័យបិដក ដែលព្រះសង្គីតិកាចារ្យ មានព្រះមហាកស្សប ព្រះឧបាលី និងព្រះអានន្ទជាដើម បានសង្គាយនា (រួបរួម) ទុកមក ។

## រឿងព្រះអានន្ទ

ក្នុងពេលព្រះពុទ្ធជាម្ចាស់ ទៀបចូលព្រះនិព្វាន ព្រះអានន្ទត្រេរថ្ងូញថ្ងូរទូលព្រះអង្គថា "តពីព្រះអង្គទៅ គ្មានព្រះពុទ្ធជាគ្រូឡើយ" ។ ព្រះអង្គមានព្រះពុទ្ធដីកាថា "ម្នាលអានន្ទ! អំណើសពីតថាគតនិព្វានទៅ អ្នកកុំសំគាល់ថាគ្មានព្រះពុទ្ធជាគ្រូ. ធម៌ដែលតថាគតសំដែងទុកហើយ វិន័យដែលតថាគតបញ្ញត្តទុកហើយនោះទុកជាព្រះពុទ្ធ ជាគ្រូប្រោសសត្វជំនួសតថាគតដូចតថាគតរស់នៅដែរ. ជាពិសេសកាលតថាគតរស់នៅមានព្រះពុទ្ធ១អង្គទេ ដល់តថាគតនិព្វានទៅនោះ មានព្រះពុទ្ធដល់ទៅ ៨៤០០០ អង្គ តាមចំនួនធម្មក្ខន្ធ (កងធម៌) ៨៤០០០ ដែលមានក្នុងព្រះត្រៃបិដកនោះឯង. ចូរពុទ្ធបរិស័ទខំស្ដាប់ខំរៀន ខំប្រតិបត្តិ ដោយយកចិត្តទុកដាក់បុះនឹងបានសម្រេចមគ្គផលនិព្វានតាមឧបនិស្ស័យរៀងខ្លួន ។

www.elibraryofcambodia.org

កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ព្រះអានន្ទបានបម្រើព្រះអង្គទាំងថ្ងៃទាំងយប់បានស្តាប់ព្រះធម៌ដោយគោរពសព្វគ្រប់ទាំងអស់ ព្រោះអានិសង្សស្តាប់ធម៌នោះហើយ បានជាលោកបានព្រះនាមថា ពហុស្សូត ចេះចាំព្រះធម៌សព្វគ្រប់ទាំងអស់ លោកជាព្រះធម្មកថិកឯក ជាឯកទគ្គៈខាងសំដែងធម៌ក្នុងសម័យពុទ្ធកាល ។ ក្រោយពុទ្ធបរិញ្វាន ៣ ខែ ព្រះអរហន្ត ៥០០ អង្គ មានព្រះមហាកស្សបជាប្រធានបានប្រជុំធ្វើសង្គាយនាព្រះត្រៃបិដក ព្រះមហាកស្សបជាអ្នកបុច្ឆា ព្រះឧបាលី ជាអ្នកវិសជ្ជនាព្រះវិនយបិដក ព្រះអានន្ទជាអ្នកវិសជ្ជនាព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។ ចំណែកព្រះសុត្តន្តបិដក ព្រះអានន្ទលោកសង្គាយនាទុកថា "ឯវម្មេ សុត្តំ ខ្ញុំបានស្តាប់មកយ៉ាងនេះ" គ្រប់ព្រះសូត្រ ។

អ្នកស្តាប់ធម៌ រៀនធម៌ យល់ធម៌ របស់ព្រះពុទ្ធច្បាស់លាស់ឈ្មោះថាបានឃើញ បានស្គាល់ព្រះពុទ្ធច្បាស់លាស់ ។ ពាក្យនេះសមតាមព្រះពុទ្ធដីកាដែលទ្រង់សំដែងចំពោះព្រះវក្កលិត្ថេរថា :

យោ ធម្មំ បស្សតិ សោ មំ បស្សតិ

ជនណាបានឃើញធម៌ ជននោះឈ្មោះថាបានឃើញតថាគត ។

តាមន័យក្នុងព្រះពុទ្ធដីកានេះ. ការដែលព្រះធម្មកថិកស្រង់យកព្រះពុទ្ធវចនៈពីព្រះវិន័យបិដកក្តី ព្រះសុត្តន្តបិដកក្តី ព្រះអភិធម្មបិដកក្តីមកសំដែង ហើយពុទ្ធបរិស័ទបានគិតពិចារណាយល់ធម៌នោះ ព្រមទាំងបានប្រតិបត្តិតាមធម៌នោះផង ឈ្មោះថាបានឃើញព្រះពុទ្ធជាម្ចាស់ ដោយបញ្ញាចក្ខុពិតប្រាកដ ។ បានសេចក្តីថា កាលព្រះពុទ្ធអង្គទ្រង់ព្រះធរមាន៍នៅទ្រង់សំដែងធម៌នោះ ពុទ្ធ

បរិស័ទគេបានឃើញព្រះភក្ត្រព្រះអង្គដោយមំសចក្ខុផង បញ្ញាចក្ខុផង ឯពុទ្ធបរិស័ទសព្វថ្ងៃបានឃើញព្រះអង្គតែដោយបញ្ញាចក្ខុម្យ៉ាង មិនបានឃើញដោយមំសចក្ខុឡើយ. ឧទាហរណ៍ដូចជនដែលបានស្ដាប់ បានរៀនពុទ្ធប្រវត្តិ ឬបានចម្រើនពុទ្ធានុស្សតិកម្មដ្ឋានជាដើម ដែលបានចេះចាំរឿងប្រវត្តិរបស់ព្រះពុទ្ធនិងយល់ពុទ្ធគុណច្បាស់លាស់នោះ ឈ្មោះថាបានឃើញព្រះពុទ្ធដោយបញ្ញាចក្ខុជាការបានផលានិសង្សច្រើនណាស់ ត្រារាប់ពុំបាន គឺបានផលទាំងជាតិនេះផង ជាតិខាងមុខផង ដល់អវសានជាតិ នឹងបានសម្រេចព្រះនិព្វានផងមានសេចក្ដីអធិប្បាយដូចតទៅនេះ

ដែលថាអ្នកស្ដាប់ធម៌ បានផលច្រើនក្នុងជាតិនេះ គឺអ្នកស្ដាប់ធម៌កាលណាបានស្ដាប់ធម៌ណាហើយ តែងតែបានចេះចាំធម៌នោះ. កាលបានចេះចាំច្រើនជាពហុស្សូតហើយ អាចសំដែងប្រាប់អ្នកដទៃបាន កាលសំដែងហើយតែងតែបានទទួលសេចក្ដីសរសើរអំពីសំណាក់អ្នកស្ដាប់ នឹងបានលាភៈសក្ការៈច្រើន. ទោះបីមិនសំដែងប្រាប់គេ គ្រាន់តែបានកាន់តាមធម៌ដែលបានស្ដាប់នោះ មានកាន់សីល ៥ កម្មបថ ១០ ជាដើម ក៏រមែងបានសុខ រួចចាកទុក្ខទោសទណ្ឌកម្មផ្សេង១ មានទោសគុកច្រវាក់ និងពាក្យតរហានិន្ទាជាដើមក្នុងជាតិនេះ ។

-ដែលថាអ្នកស្ដាប់ធម៌ បានផលច្រើនក្នុងជាតិខាងមុខ គឺអ្នកដែលបានស្ដាប់ធម៌ បានកាន់តាមធម៌ដែលបានស្ដាប់នោះ មានធ្វើការរក្សាសីលជាដើម តែងតែបានទៅកើតជាមនុស្សមានទ្រព្យសម្បត្តិច្រើន មានអាយុយឺនយូរក្នុងមនុស្សលោក នឹងបានទៅកើតជាទេវតាមានអាយុ វណ្ណៈ សុខៈ ពលៈជាទិព្វក្នុងឋានទេវលោក ក្នុងជាតិខាងមុខ ។

www.elibraryofcambodia.org

-ដែលថាអ្នកស្តាប់ធម៌ បានផលដល់អវសានជាតិ នឹងបានសម្រេចព្រះនិព្វាន គឺការស្តាប់ការរៀនធម៌ ជាពុទ្ធវចនៈតែងបានមានបញ្ញាជាសម្មាទិដ្ឋិ (យល់ត្រូវល្អ) ក្នុងជាតិដែលបានស្តាប់បានរៀនផង ក្នុងជាតិជាលំដាប់តទៅផង ហើយដល់អវសានជាតិ (ជាតិទីបំផុត) នឹងបានសម្រេចមគ្គផលនិព្វាន ។

ពុទ្ធបរិស័ទអ្នកកាន់ព្រះពុទ្ធសាសនា មានការស្តាប់ធម៌វិន័យ ជាការចាំបាច់តាមឋានៈរៀងខ្លួន គឺ

ចំណែកខាងឧបាសកអ្នករក្សាឧបោសថសីល ត្រូវស្តាប់ធម៌ក្នុងថ្ងៃដែលសមាទាន ជាថ្ងៃធម្មស្សវនកាល ១ ខែ ៤ ដង គឺថ្ងៃ ៨ កើត ៨ រោច ១៥ កើត ១៥ រោច ឬ ១៤ រោច តាមខែពេញនិងខែខ្វះ ហើយរាល់ថ្ងៃនោះត្រូវចម្រើនសមថកម្មដ្ឋានផង ខានពុំបាន បើខានថ្ងៃណា ឧបោសថសីលថ្ងៃនោះ ឈ្មោះថាពុំពេញបរិបូណ៌ទេ ។

ចំណែកខាងភិក្ខុ ត្រូវស្តាប់ធម៌ក្នុងថ្ងៃធម្មស្សវនកាល ១ ខែ ២ ដងផង ត្រូវស្តាប់វិន័យ គឺស្តាប់បាតិមោក្ខ ១ ខែ ២ ដង គឺថ្ងៃ ១៥ កើត ១៥ រោច ឬ ១៤ រោចផង ខានពុំបានជាដាច់ខាត កុំថាដល់ភិក្ខុជាបុថុជ្ជនមានកិលេស សូម្បីព្រះអរិយបុគ្គលអស់កិលេសហើយ ក៏ខានធ្វើឧបោសថកម្ម ខានស្តាប់បាតិមោក្ខពុំបានដែរ ឧទាហរណ៍ដូចរឿងព្រះមហាកប្បិនត្ថេរដែលសំដែងខាងមុខនេះ :

## រឿងព្រះមហាកប្បិនត្ថេរ

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះធរមាន៍នៅឡើយ សម័យមួយ ព្រះមហាកប្បិនត្ថេរ ជាព្រះអរហន្តបានចូលនិរោធសមាបត្តិ មានចិត្តស្ងប់រម្ងាប់បរិសុទ្ធ អស់ ៧ ថ្ងៃ ៧ យប់ ពេលចេញពីនិរោធសមាបត្តិត្រូវលើថ្ងៃឧបោសថព្រះសង្ឃធ្វើឧបោសថកម្ម សំដែងបាតិមោក្ខលោករំពឹងគិតថា "ថ្ងៃនេះជាថ្ងៃ

www.elibraryofcambodia.org

ឧបោសថ អាត្មាអញចាំបាច់ទៅស្តាប់បាតិមោក្ខធ្វើអ្វី បើគ្មានសៅហ្មងអ្វីទេ"។ គ្រាន់តែព្រះមហាកប្បិនគិតប៉ុណ្ណោះ ជ្រាបដល់ព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ចេញរស្មីមកភ្លាម ដូចព្រះអង្គទ្រង់យាងមកសណ្ឋិតចំពោះមុខព្រះមហាកប្បិននោះមានព្រះពុទ្ធដីកាថា "ម្នាលកប្បិន! បើអ្នកជាភិក្ខុមិនទៅធ្វើឧបោសថ មិនទៅស្តាប់បាតិមោក្ខជាវិន័យរបស់ខ្លួន គេឱ្យអ្នកណាក្រៅពីភិក្ខុទៅធ្វើទៅស្តាប់ជំនួសវិញ. មិនគួរខានទៅទេ. ទោះបីខ្លួនអ្នកបរិសុទ្ធឥតសៅហ្មង ក៏ត្រូវតែទៅធ្វើឧបោសថកម្ម ស្តាប់បាតិមោក្ខកុំខាន" ។

តាមវិន័យក្នុងព្រះពុទ្ធដីកានេះ ឃើញថាពុទ្ធបរិស័ទជាឧបាសកត្រូវតែស្តាប់ធម៌ក្នុងថ្ងៃធម្មស្សវនកាល. ជាភិក្ខុត្រូវតែស្តាប់ធម៌ក្នុងថ្ងៃធម្មស្សវនកាលផង ស្តាប់វិន័យក្នុងថ្ងៃធ្វើឧបោសថកម្មផង ទើបឧបាសកភាព និងភិក្ខុភាពរបស់ខ្លួនមានផលច្រើន ហើយបានឈ្មោះថាអ្នកធ្វើព្រះពុទ្ធសាសនាឱ្យរុងរឿងឋិតថេរបេរកាលតទៅ ។

## ២០-អានិសង្សមេត្តា

មិត្តបុណ្យដែលបានផ្សាយសេចក្តីរាប់រាន រាលឥតអាសូរដល់សត្វទាំងពួងថា "សត្វក្នុងលោកគ្រប់ប្រាណ ដែលបានកើតហើយមានរាងកាយមានខ្យល់ចេញចូល ទោះជាទេវតាក្តី មនុស្សក្តី គ្រុឌ នាគ វិទ្យាធរ អសុរកាយក្តី មានចិត្តក្តី មិនមានចិត្តក្តី មានជីវិតរស់នៅ ខាងលើតាំងពីផែនដីឡើងទៅដល់អកនិដ្ឋព្រហ្ម ខាងក្រោមតាំងពីផែនដីចុះទៅដល់អវិចីមហានរក ខាងទទឹងគ្រប់ទិសទាំង៨រហូតដល់អនេកកោដិចក្រវាឡ ចូរកុំមានពៀរនឹងគ្នាពុំព្យាបាទគ្នា កុំមានទុក្ខសោក រោគ ភ័យ ចូរមានអាយុយឺនយូរ សម្រេចនូវសម្បត្តិទាំងពួង ចូររក្សាខ្លួនជាសុខសាន្ត រួចចាកទុក្ខទាំងពួងចុះ" ។ ដូច្នេះ

www.elibraryofcambodia.org

ឈ្មោះថា ចិត្តមេត្តា ។

ការផ្សាយមេត្តាចិត្តដល់កម្រិតខ្ពស់ អាចញ៉ាំងមនុស្សឬសត្វជាសត្រូវ ដែលប៉ងមកប្រទូសខ្លួន ឱ្យឈប់ប្រទូសបាន ។

អដ្ឋកថាធម្មបទ បានសំដែងរឿងអានិសង្សនៃការផ្សាយមេត្តាដូចតទៅ

## រឿងមាឃមាណព

ក្នុងកាលដ៏កន្លងទៅយូរហើយ មានមាណពម្នាក់ឈ្មោះមាឃៈបានរួមជាមួយជន ៣២ នាក់ ជា ៣៣ នឹងខ្លួន សាងផ្លូវថ្នល់ជាសាធារណៈ កាត់ពីភូមិស្រុករបស់ខ្លួន តម្រង់ទៅរាជធានី សម្រាប់ជនទូទៅ ធ្វើដំណើរទៅមកស្រួល ។ ទោះបីគាមភោជក (មេស្រុក) ឃាត់ឃាំងយ៉ាងណាក៏ចេះតែធ្វើ ។ គាម-ភោជកប្ដឹងទៅរាជការថា ជនទាំងនោះធ្វើផ្លូវដើម្បីទៅដណ្ដើមរាជ្យ រាជការបានឱ្យយកកន្ទេលគ្របជនទាំងនោះ ឱ្យដំរីជាន់ ។ អ្នកទាំង ៣៣ នាក់មានមាឃមាណពជាដើម បានផ្សាយមេត្តាចិត្តដល់កម្រិតខ្ពស់គ្រប់ៗគ្នា ។ អំណាចទឹកចិត្តដែលផ្សាយមេត្តានោះ ហាក់ដូចទឹកកុនិស្រោចចូលចំបេះដូងដំរី បណ្ដាលឱ្យដំរីលុតជង្គង់មិនហ៊ានជាន់ ។ ព្រះរាជាទ្រង់ជ្រាបការពិតថា ជនទាំងនោះមិនមែនធ្វើផ្លូវដើម្បីដណ្ដើមរាជ្យទេ ក៏ទ្រង់ព្រះរាជទានដំរីដែលឱ្យជាន់មិនជាន់នោះ ដល់មាឃមាណពធ្វើយានជិះចាត់ការធ្វើថ្នល់តទៅ ។

មាឃមាណពដែលនាំជន ៣២ នាក់សាងផ្លូវនោះ គឺមកពីមានចិត្តមេត្តាដល់អ្នកដំណើរ ហើយដល់ពេលគេបរដំរីឱ្យជាន់ បានផ្សាយមេត្តាដល់ដំរីទៀត ហៅថា ចម្រើនមេត្តាភាវនា ។ ដោយអំណាចផលានិសង្សនៃមេត្តាភាវនានិងអានិសង្សនៃសាងផ្លូវថ្នល់ ដល់ពេលអស់អាយុ មាឃមាណពបានទៅកើតជាព្រះឥន្ទ ស្ដេចទេវតាមានទេវបុត្រ ៣២ នាក់ជាមិត្តភក្ដិ ទៅឋាន

ត្រៃត្រឹង្សសូតិ រហូតដល់សព្វថ្ងៃ ។

ក្នុងពុទ្ធជយមង្គលគាថា សំដែងពីអានិសង្សនៃការផ្សាយមេត្តា ថា:

នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនី វ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ

. . . . . . . . . . . . . . . . . .

ព្រះមុនិន្ទសម្ពុទ្ធ ទ្រង់បានឈ្នះដំរីដ៏ប្រសើរឈ្មោះនាឡាគិរី ជាដំរីបុះប្រេងខ្លាំងកាចមហិមា ដូចជាភ្លើងព្រៃ ឬចក្រក្រុតនិងកាំអសនី ដោយពិធីស្រោចស្រប់នូវទឹក គឺព្រះមេត្តា ។

## រឿងដំរីនាឡាគិរី

អដ្ឋកថាធម្មបទ សំដែងរឿងដំរីនាឡាគិរីដែលព្រេជព្រះសម្មាសម្ពុទ្ធនោះ ថា:

កាលព្រះទេវទត្តទីងទីងព្រះសម្មាសម្ពុទ្ធ ចង់សម្លាប់ព្រះអង្គ ដើម្បីធ្វើព្រះពុទ្ធខ្លួនឯង ទៅរួមគំនិតនឹងព្រះបាទអជាតសត្រូវ ដែលចង់សម្លាប់ព្រះបាទពិម្ពិសារជាព្រះបិតា ដើម្បីយករាជ្យសោយនោះ ព្រះបាទអជាតសត្រូវឱ្យបំបឹកស្រាដំរីនាឡាគិរី ដែលកំពុងបុះប្រេង កាចសាហាវដូចភ្លើងព្រៃ ដូចចក្រក្រុត និងដូចកាំរន្ទះ ឱ្យពេជឃាតធ្វើគត់ព្រះពុទ្ធជាម្ចាស់ក្នុងពេលព្រះអង្គកំពុងនាំភិក្ខុសង្ឃ មានព្រះអានន្ទជាដើម ត្រាច់បិណ្ឌបាតប្រោសសត្វ ។ ខណៈដំរីស្ទុះចូលមកព្រេជនោះ ព្រះអង្គផ្សាយព្រះមេត្តា ដោយទឹកព្រះទ័យដ៏ត្រជាក់បហាក់ទឹកអម្រឹត ទៅស្រោចស្រប់ចំបេះដូងដំរីនាឡាគិរីនោះ ។ ដំរីនោះ

គ្រជាក់ចិត្តរលត់ក៏ហើង លុតជង្គង់គ្រិបក្រាបថ្វាយបង្គំព្រះអង្គកណ្តាលទីប្រជុំជនរាប់ហ្មឺនសែននាក់យ៉ាងមហាស្ចារ្យ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ឈ្នះដំរីនាឡាគិរី បានរស់ព្រះជន្មក្នុងពេលនោះដោយសារអានិសង្សនៃការផ្សាយព្រះមេត្តានោះឯង ។

អដ្ឋកថាជាតក ទុកនិបាត ត្រង់អរកជាតក ថែងថា កាលព្រះបរមគ្រៃលោកនាថសាស្តាចារ្យ ទ្រង់ប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធមេត្តាសូត្រហើយត្រាស់ព្រះធម្មទេសនាមានពាក្យផ្តើមថាៈ យោ វេះត្តេន ចិត្តេន ជាដើម ។

សេចក្តីពិស្តារថាៈ

សម័យមួយ សម្តេចព្រះទសពលញ្ញាណជាម្ចាស់ ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់ត្រាស់ថាៈ ម្នាលភិក្ខុទាំងឡាយ ! មេត្តាភាវនា ដែលជាចេតោវិមុត្តិ គឺគុណជាគ្រឿងរួចចាកកិលេសដែលបុគ្គលណាបានសេពច្រើន បានចម្រើនច្រើនបានឱ្យប្រព្រឹត្តទៅច្រើន បានធ្វើឱ្យដូចជាយានដែលបានទឹមទុក បានធ្វើឱ្យជាទីតាំងនៅមាំ មិនញាប់ញ័រ បានសន្សំទុកដោយជុំវិញ បានព្យាយាមប្រារព្ធជានិច្ចដោយល្អហើយ គប្បីសង្ឃឹមថា បាននូវអានិសង្ស ១១ យ៉ាងដូចបំណង គឺ

១- ដេកលក់សប្បាយ.

២- ភ្ញាក់សប្បាយ.

៣- មិនយល់សុបិនអាក្រក់.

៤- ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ.

៥- ជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ.

៦- ទេវតាទាំងឡាយតែងរក្សានូវបុគ្គលនោះ.

www.elibraryofcambodia.org

៧- ភ្លើង ឬថ្នាំពិស ឬក៏សាស្ត្រាវុធ ធ្វើបាបបុគ្គលនោះមិនបាន.

៨- កាលបើចិត្តរវើរវាយញាប់ញ័រឡើង ក៏នឹងត្រឡប់ជាតាំងនៅមាំមួន មិនញាប់ញ័រទៅវិញបានដោយរហ័ស.

៩- ទឹកមុខអ្នកនោះស្រស់ថ្លរជង់ជានិច្ច.

១០- វេលាទៀបស្លាប់ទៅ បុគ្គលនោះតែងមានស្មារតីល្អមិនវង្វេង.

១១- បើបុគ្គលនោះ មិនទាន់បានសម្រេចធម៌វិសេសនៅឡើយ ក៏គង់បានទៅកើតក្នុងព្រហ្មលោក ។

ម្នាលភិក្ខុទាំងឡាយ! មេត្តាភាវនាដែលជាចេតោវិមុត្តិបុគ្គលណោបានសេពច្រើនបានចម្រើនច្រើន បានឱ្យប្រព្រឹត្តទៅច្រើន បានធ្វើឱ្យដូចជាយានទីមទុក បានធ្វើឱ្យជាទីតាំងនៅមាំ មិនញាប់ញ័ររង្គើរ បានសន្សំទុកដោយជុំវិញ បានព្យាយាមប្រារព្ធជានិច្ចដោយល្អហើយ តែងបានអានិសង្ស ១១ យ៉ាងគឺថា ទោះបីមិនប្រាថ្នាក៏គង់តែបានសម្រេចជាប្រាកដ ឥតសង្ស័យឡើយ ។

កាលត្រាស់ដូច្នោះហើយ ក៏ទ្រង់ពណ៌នាអំពីមេត្តាភាវនាដែលតាំងនៅមាំថា: ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុគប្បីចម្រើនមេត្តាភាវនា គឺនឹកផ្សាយចិត្តមេត្តាទៅក្នុងសត្វទាំងឡាយ ដោយចំពោះ និងមិនចំពោះ ; គឺសត្វដែលខ្លួនស្រឡាញ់ ក៏ផ្សាយទៅដោយចិត្តស្រឡាញ់សត្វដែលខ្លួនមិនស្រឡាញ់ ក៏ផ្សាយទៅដោយចិត្តស្រឡាញ់ ភិក្ខុគប្បីផ្សាយចិត្តមេត្តាទៅក្នុង សត្វទាំងឡាយដោយចំពោះ និងមិនចំពោះដូច្នេះបុះ ។ ឯចិត្ត ករុណា មុទិតា ឧបេក្ខាក៏គប្បីចម្រើនទៅក្នុងសត្វទាំងអស់ទូទៅដូចមេត្តានេះបុះ ។

ភាវនាកម្មក្នុងព្រហ្មវិហារទាំង ៤ ជាការគួរធ្វើមែន ព្រោះកាលបុគ្គលបានធ្វើដូច្នោះហើយ ទោះបីមិនបានសម្រេចមគ្គផល ក៏គង់មានសុគតិព្រហ្ម

www.elibraryofcambodia.org

លោកជាខាងមុខ សូម្បីបោរាណកបណ្ឌិតទាំងឡាយ បានចម្រើនតែ ៧ ឆ្នាំ ក៏បានទៅកើតក្នុងព្រហ្មលោកដល់ ៧ សំវដ្តកប្ប ។ ត្រាស់ដូច្នេះហើយ ក៏ទ្រង់នាំរឿងអរកឥសីមកសំដែងដូចតទៅនេះ:

## រឿងអរកឥសី

ក្នុងអតីតកប្បមួយ ព្រះពោធិសត្វកើតជាព្រាហ្មណ៍ក្នុងត្រកូលព្រាហ្មណ៍មួយ លុះមានវ័យចម្រើនឡើង ក៏លះកាមទាំងឡាយចេញបួសជាឥសី បានចម្រើនព្រហ្មវិហារទាំង ៤ បានជាសាស្តាធំមាននាមថា អរកៈ អាស្រ័យនៅក្នុងព្រៃហេមពាន្ត មានបរិវារជាច្រើនក្រៃលែង ។ ព្រះឥសីពោធិសត្វនោះប្រៀនប្រដៅដល់ពួកឥសីថា "បព្វជិតគួរញ៉ាំងមេត្តាចិត្តនិងករុណា មុទិតា ឧបេក្ខាឱ្យច្រើន ព្រោះថាមេត្តាចិត្ត បើបានចម្រើនដល់កប្បនាហើយ រមែងធ្វើគុណមានព្រហ្មលោកជាខាងមុខឱ្យសម្រេចបាន" ។ ទ្រង់ផ្តើមប្រដៅដូច្នេះហើយ កាលនឹងប្រកាសអានិសង្សមេត្តាភាវនា ទើបពោលគាថាមានសេចក្តីថា:

"បុគ្គលណាបានអនុគ្រោះដល់សត្វលោកទាំងពួង ដោយចិត្តមេត្តារកប្រមាណមិនបាន ទាំងខាងលើ ខាងក្រោម និងទាំងទទឹងដោយអាការទាំងពួង បុគ្គលនោះបានឈ្មោះថា ចំរើននូវចិត្តប្រកបដោយប្រយោជន៍រកប្រមាណមិនបាន ឱ្យបរិបូណ៌ កម្មឯណាដែលបុគ្គលបានធ្វើល្មមប្រមាណហើយ កម្មនោះនឹងបានសល់នៅក្នុងចិត្ត ប្រកបដោយប្រយោជន៍ក្នុងសព្វសត្វ មិនមានប្រមាណនោះក៏ទេ" ។

អដ្ឋកថាអធិប្បាយថា បណ្តាជនទាំងឡាយមានក្សត្រជាដើមក្តី សមណៈនិងព្រាហ្មណ៍ទាំងឡាយក្តី បុគ្គលណាម្នាក់អនុគ្រោះដល់សត្វលោកទាំងអស់ដោយចិត្តមេត្តា គឺចិត្តដ៏ជាអប្បនាឆ្ងាយទូលាយរកប្រមាណមិនបាន ព្រោះ

កាន់យកសត្វជាទូទៅ ក្នុងទុគ្គតិកពនិងសុគតិកពវភារម្មណ៍គឺចម្រើនមេត្តាចិត្ត ទូទៅក្នុងទិសទាំងឡាយ គឺជាទិសខាងលើតាំងពីផែនដីឡើងទៅដរាបដល់នេវសញ្ញាយតព្រហ្មលោក ទិសខាងក្រោមតាំងពីផែនដីចុះទៅដល់នរកធំព្រមទាំងឧស្សទនរកទិសខាងទទឹងគឺចក្កវាឡទាំងមូលដែលកំពុងមាននៅថា "បណ្ដាសត្វទាំងឡាយដែលកើតហើយ ក្នុងទីមានប្រមាណប៉ុណ្ណោះ ចូរកុំមានពៀរនិងគ្នា កុំព្យាបាទគ្នា កុំមានទុក្ខតានតឹង ចង្អៀតចង្អល់ ចូររក្សាខ្លួនដោយសុខសាន្តចុះ" ដូច្នេះ ដោយអាការទាំងពួង បុគ្គលនោះបានឈ្មោះថាបានចម្រើននូវចិត្តដ៏ប្រកបដោយប្រយោជន៍ក្នុងសព្វសត្វទាំងឡាយ រកប្រមាណមិនបានឱ្យបរិបូណ៌ មិនវិកល ។ កម្មជាចំណែកកាមាវចរបរិច្ឆិន្នដែលបុគ្គលមិនបានចម្រើនដោយអំណាចនៃអារម្មណ៍ និងដល់នូវសេចក្ដីជំនាញដូចចិត្តដោយមានអារម្មណ៍ មិនមានប្រមាណនេះហើយ កម្មមានប្រមាណបរិច្ឆិន្នដូច្នោះ ក៏មិនសល់នៅក្នុងកម្មជារូបាវចរ ដែលរាប់ថាចិត្តប្រកបដោយប្រយោជន៍ប្រមាណមិនបានដូច្នោះនោះឡើយ ដូចជំនន់ទឹកតូចដែលជំនន់ទឹកធំគ្របសង្កត់ហើយនោះបើជំនន់ទឹកធំនោះមិននាំទៅ ក៏គង់តែមិនសល់នៅប្រាកដក្នុងជំនន់ទឹកធំបាន គឺជំនន់ទឹកធំនោះឯង សង្កត់ជំនន់ទឹកតូចបានដោយពិត យ៉ាងណាមិញកម្មមានប្រមាណតិចនោះកាលមហគ្គតកម្ម កាត់បង់មិនឱ្យឱកាសឱ្យផលបានហើយ ឈ្មោះថាមិនសល់មិនជាប់នៅក្នុងមហគ្គតកម្ម គឺថាកម្មមានប្រមាណតិច មិនអាចឱ្យផលតាមទំនើងខ្លួនឯងបាន ដោយមហគ្គតកម្មនោះឯង គ្របសង្កត់ទុក ហើយឱ្យផលខ្លួនតែដោយពិតដូច្នោះ ។

ព្រះពោធិសត្វសំដែងអានិសង្សមេត្តាភាវនា ប្រាប់អន្តេវាសិកទាំងឡាយដូច្នេះហើយ មិនសូន្យចាកឈាន កាលវិលាងបញ្ចក្ខន្ធហើយ បានទៅកើតក្នុង

ព្រហ្មលោក មិនកាន់លោកនេះវិញ ដល់៧ សំវដ្តកប្ប និងវិវដ្តកប្ប ។

ព្រះបរមសាស្ដាចារ្យទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ថា ពួកឥសីទាំងឡាយក្នុងកាលនោះ បានជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកអរកៈសាស្ដាក្នុងកាលនោះ បានមកជាតថាគតក្នុងកាលឥឡូវនេះឯង ។

## ៦១.អានិសង្សកាយវិការ

កុសលធម៌ ដែលជម្រះសន្តានចិត្តឱ្យស្អាតផូរផង់ ហៅថា បុណ្យដូចបទ វិគ្រោះដែលលោកបង្ហាញក្នុងអភិធានប្បទីបិកាសូចិថា **សន្តានំ បុណាតិ សោធេតីតិ បុញ្ញំ** ប្រែថា កុសលធម៌ណាដែលជម្រះសន្តានចិត្តឱ្យស្អាត បរិសុទ្ធ កុសលធម៌នោះឈ្មោះថា បុណ្យ គឺបុណ្យនោះកើតឡើងក្នុងផ្លូវចិត្តជា មុន ទើបកើតក្នុងកាយ និងផ្លូវវាចាជាក្រោយ ។

បុណ្យដែលកើតក្នុងផ្លូវកាយ ហៅថា កាយវិការ គឺកម្រើកដៃជើងធ្វើ ការកុសលផ្សេងៗ មានបញ្ចេញវចីភេទ អានក្រាបថ្វាយបង្គំព្រះរតនត្រ័យ និងធ្វើការហត្ថកម្មជាការកុសលផ្សេងៗ ជាដើម ។

បុណ្យដែលកើតក្នុងផ្លូវវាចា ហៅថា វចីវិការ គឺកម្រើកវាចាធ្វើការ កុសលផ្សេងៗ មានបញ្ចេញវចីភេទ សូត្រធម៌ថ្វាយបង្គំព្រះរតនត្រ័យ និង និយាយបបួលអ្នកដទៃ ឱ្យទៅធ្វើការកុសលផ្សេងៗ មានទៅធ្វើទាន ទៅ សមាទានសីលនិងទៅស្ដាប់ធម៌ទេសនាជាដើម ។

បុណ្យដែលកើតក្នុងផ្លូវចិត្ត មិនបញ្ចេញមកខាងក្រៅ ហៅថាមនោវិការ គឺកម្រើកចិត្តគិតចង់ធ្វើការផ្សេងៗ មាននឹកបង់នមស្សការព្រះរតនត្រ័យជាដើម

ការកំរើកកាយធ្វើការកុសល បានផលតាមចំណែកកាយកំរើកវាចាធ្វើ ការកុសល បានផលតាមចំណែកវាចា កំរើកចិត្តធ្វើការកុសល បានផលតាម

www.elibraryofcambodia.org

បំណែកបិត្ត ។

ក្នុងទីនេះ សូមពណ៌នាពីផលានិសង្សនៃការកំរើកកាយធ្វើការកុសល ដោយសង្ខេបជាមុន ដូចតទៅនេះ.

# រឿងព្រះបាទចណ្ឌបជោត

អដ្ឋកថាធម្មបទ និទានរឿងព្រះបាទចណ្ឌបជោតថា:

ក្នុងកាលដ៏កន្លងរំលងទៅហើយ មានព្រះបច្ចេកពុទ្ធ ១ ព្រះអង្គទ្រង់និមន្តទៅបិណ្ឌបាតចង្ហាន់ទៅភូមិមួយ ពុំមានអ្នកណាដាក់បាត្រព្រះអង្គសោះ ។ ដល់ថ្ងៃត្រង់ ជិតហួសពេលឆាន់ ព្រះអង្គទៅឈរស្ងៀមនៅក្បែរផ្ទះមន្ត្រីម្នាក់ ។ មន្ត្រីនោះចេញមកពីគាល់ព្រះរាជាវិញ បានឃើញព្រះបច្ចេកពុទ្ធទ្រង់ឈរស្ងៀម ក៏ស្ទុះទៅបើកគ្របបាត្រមើលឃើញគ្មានចង្ហាន់បន្តិចសោះ ក៏ស្ទុះប្រញាប់ចូលទៅក្នុងផ្ទះ បង្គាប់កម្មករម្នាក់ឱ្យយកបាយនិងម្ហូប ដែលអ្នកផ្ទះរៀបចំទុកឱ្យខ្លួន ទៅដាក់បាត្រព្រះអង្គ ថា "ចូរអ្នកយកចង្ហាន់នេះ ទៅដាក់បាត្រលោកជាប្រញាប់ ព្រោះថ្ងៃជិតហួសពេលឆាន់ទៅហើយ ទៅចុះ យើងចែកផលបុណ្យពាក់កណ្ដាលម្នាក់ ។ កម្មករឮដូច្នោះ ក៏ត្រេកអរឥតឧបមា ហើយខំកម្រើកដៃជើង ស្ទុះរត់ប្រញាប់ប្រញាល់យកចង្ហាន់នោះទៅដាក់បាត្រព្រះបច្ចេកពុទ្ធភ្លាម ។ លុះដាក់ហើយ សូមប្រាថ្នាថា ដោយផលដែលខ្ញុំខំ រត់ទាំងកណ្ដាលថ្ងៃក្ដៅយកចង្ហាន់មកដាក់បាត្រព្រះអង្គនេះ សូមឱ្យខ្ញុំកើតក្នុងជាតិខាងមុខ មានកម្លាំងច្រើន មានយានជំនិះសុទ្ធតែលឿនៗមានអំណាចខ្លាំងដូចព្រះអាទិត្យឋិតកណ្ដាលអាកាស" ។

ដោយអានិសង្សនៃកាយវិការដែលកំរើកកាយ ស្ទុះប្រញាប់យកចង្ហាន់ទៅដាក់បាត្រព្រះបច្ចេកពុទ្ធនោះ បុរសនោះ ច្យុតពីមនុស្សលោក

www.elibraryofcambodia.org

នេះទៅ បានទៅកើតក្នុងទេវលោកសោយសុខអស់ ១ ពុទ្ធន្តរ (ចន្លោះព្រះពុទ្ធ ១ ព្រះអង្គ) លុះដល់មក ពុទ្ធកាលនៃព្រះសក្យមុនីគោតមបរមគ្រូនៃយើងនេះ ចុះមកកើតក្នុងមនុស្សលោក ជាស្ដេច ១ ព្រះអង្គក្នុងជម្ពូទ្វីប ព្រះនាមចណ្ឌបជោត ទ្រង់មានយានជំនិះសេះ ដំរី សុទ្ធតែលឿនៗ ធ្វើដំណើរបាន ១២០ យោជន៍ក្នុង ១ ថ្ងៃៗ ទ្រង់មានកម្លាំងខ្លាំង អំណាចរុងរឿងដូចព្រះអាទិត្យរះ ចែងចាំងកណ្ដាលនភាល័យ ។

នេះជាអានិសង្សនៃកាយវិការ ដែលកំរើកដៃជើងធ្វើការកុសល ដោយចិត្តជ្រះថ្លា។ ការកំរើកដៃជើងធ្វើការកុសលនេះ សូម្បីគ្រាន់តែកំរើកលើកដៃ ១ ក្អែតចង្អុលបង្ហាញផ្លូវលោកជាព្រះអរហន្តពិសេស តាមដែលលោកត្រូវការសួររកអ្វីមួយដោយចិត្តមេត្តា ដូចព្រះនាងអសទ្ធិមិត្តាកាលដែលទៅជានាងកុម្ភទាសី បានលើកដៃចង្អុលផ្លូវ ថ្វាយព្រះបច្ចេកពុទ្ធនោះក៏អាចសម្រេចផលានិសង្សយ៉ាងច្រើន ។

## រឿងព្រះនាងអសទ្ធិមិត្តា

គម្ពីរមហាវង្សពង្សាវតារលង្កាទ្វីប និទានរឿងព្រះនាងអសិទ្ធិមិត្តាថា:

ក្នុងសម័យជាចន្លោះពុទ្ធកាល មានព្រះបច្ចេកពុទ្ធ ១ ព្រះអង្គគង់នៅភ្នំគន្ធមាទន៍កើតវណ្ណរោគ (ស្អមលឿង) ហើយព្រះបច្ចេកពុទ្ធ ១ ព្រះអង្គទៀតត្រេចទៅស្វែងរកទឹកឃ្មុំយកមកធ្វើថ្នាំ ទ្រង់ក៏ទៅដល់ក្រុងពារាណសី បានជួបនិងនាងកុម្ភទាសី (ខ្ញុំស្រីដងទឹក) ម្នាក់ទ្រង់សួរថា "នាង! ស្រុកនេះមានទីណាមានទឹកឃ្មុំ? អាត្មានឹងសុំគេយកទៅធ្វើថ្នាំ" ។ នាងពុងនោះក៏មានចិត្តអាណិតព្រះអង្គ បានលើកដៃចង្អុលប្រាប់ផ្ទះមធុពាណិជ (អ្នកលក់ទឹកឃ្មុំ) ហើយនាងអរនឹងការកុសលរបស់គេណាស់. បើមិនបានអញនឹងយកក្រមាបង់

ក ១ នេះទៅចំណាយយកប្រាក់មកទិញទឹកឃ្មុំថ្វាយព្រះអង្គទាល់តែបាន ។ ឯព្រះបច្ចេកពុទ្ធដែលទៅរកទឹកឃ្មុំនោះ ទទួលពេលនោះ ពាណិជអ្នកលក់ទឹកឃ្មុំមានបងប្អូន ៣ នាក់ តែបងបង្អស់និងបងកណ្ដាលចេញទៅក្រៅ នៅតែពាណិជជាប្អូននៅផ្ទះម្នាក់ឯង លុះឃើញព្រះបច្ចេកពុទ្ធមករកទឹកឃ្មុំក៏មានសេចក្ដីជ្រះថ្លា បានយកទឹកឃ្មុំមកដាក់បាត្រព្រះបច្ចេកពុទ្ធ ពេញហៀរហូរហួសកណ្ដាប់មាត់បាត្រ ហើយធ្វើសេចក្ដីប្រាថ្នាថា "ដោយអំណាចកុសលចេតនារបស់ខ្ញុំដ៏បរិសុទ្ធស្អាតក្នុងមធុទាននេះ សូមឱ្យខ្ញុំបានជាស្ដេចឯករាជ្យជាធំលើជម្ពូទ្វីប សូមឱ្យអាណាចក្ររបស់ខ្ញុំផ្សាយទៅលើផែនដី ១ យោជន៍ ទៅក្រោមផែនដី ១ យោជន៍ កុំឱ្យនរណាមានសម្បត្តិសម្បូណ៌ស្មើនិងសម្បត្តិរបស់ខ្ញុំព្រះអង្គឡើយ" ។

ព្រះបច្ចេកពុទ្ធបានធ្វើអនុមោទនា ហើយនិមន្តត្រឡប់មកជួបនិងនាងកុម្ភទាសីវិញ នាងសួរថា "បពិត្រព្រះអង្គដ៏ចម្រើន! ព្រះអង្គបានទឹកឃ្មុំឬទេ?" ព្រះបច្ចេកពុទ្ធត្រាស់តបថា "ម្នាលនាង! អាត្មាបានទឹកឃ្មុំហើយ" ។ នាងកុម្ភទាសីទូលសួរថា "កាលដែលពាណិជថ្វាយទឹកឃ្មុំនោះ គេប្រាថ្នាទៅអនាគតដូចម្ដេចខ្លះព្រះអង្គ? ព្រះបច្ចេកពុទ្ធរៀបរាប់ប្រាប់សេចក្ដីប្រាថ្នាសព្វគ្រប់. នាងបានឮដូច្នោះក៏និមន្តព្រះបច្ចេកពុទ្ធរង់ចាំសិន នាងត្រឡប់ទៅផ្ទះយកសំពត់សាដកថ្មីមកថ្វាយព្រះបច្ចេកពុទ្ធអង្គនោះ សម្រាប់ធ្វើជាសំពត់រុំដំបៅ ហើយតាំងប្រាថ្នាថា "ដោយអំណាចកុសល ដែលខ្ញុំម្ចាស់បានថ្វាយសំពត់សាកដនេះ អំណើះទៅអនាគត បើមធុពាណិជនោះបានជាស្ដេចចុល្លចក្រពត្រជាធំក្នុងជម្ពូទ្វីបពេលណា សូមឱ្យខ្ញុំម្ចាស់បានជាអគ្គមហេសីនៃស្ដេចអង្គនោះពេលនោះ ហើយសូមឱ្យខ្ញុំម្ចាស់មានរូបឆោមលោមពណ៌ល្អ ល្អត្រូវជាទីពិតពិលរមិលមើល បានយសសក្ដិនិងសម្បត្តិសុខសិរីសួស្ដី ជាទីពេញចិត្តនៃជន

www.elibraryofcambodia.org

ទាំងពួងក្នុងលោក ។ ព្រះបច្ចេកពុទ្ធបានធ្វើអនុមោទនាហើយ លោកហោះឡើងទៅកាន់អាកាស រហូតដល់ភ្នំគន្ធមាទន៍ទៅ ។

ឯពាណិជជាបងទាំងពីរនាក់ ត្រឡប់មកផ្ទះវិញ ក៏ត្រេកអរនិងការកុសលដែលប្អូនបានធ្វើហើយនោះក្រៃពេក ។

លុះពាណិជទាំង ៣ នាក់ធ្វើកាលកិរិយាទៅ បានទៅកើតទេវបុត្រក្នុងឋានទេវលោក ដល់មកក្នុងសាសនា នៃព្រះសក្យមុនីគោតមបរមគ្រូនៃយើងនេះ ខាងក្រោយពុទ្ធនិព្វានប្រមាណជាង ២០០ ឆ្នាំ ក៏ពាណិជជាប្អូនដែលបានថ្វាយទឹកឃ្មុំផ្ទាល់ដៃខ្លួននោះបានជាព្រះបាទធម្មាសោក ជាចុល្លចក្រពត្រ ក្នុងជម្ពូទ្វីប. នាងកុម្ភទាសី ដែលចង្អុលផ្លូវបង្ហាញភានផ្សារលក់ទឹកឃ្មុំ និងបានថ្វាយសំពត់សាដកដល់ព្រះបច្ចេកពុទ្ធនោះ បានជាអគ្គមហេសី នៃព្រះបាទធម្មាសោក ព្រះនាម អសន្ធិមិត្តា. ពាណិជ្ជជាបងច្បងបានជានិគ្រោធសាមណេរជាឃ្មួយព្រះបាទធម្មាសោក ដែលបានថ្វាយធម្មទេសនា ញុំាងព្រះបាទធម្មា-សោកឱ្យទ្រង់ឋិតនៅក្នុងព្រះត្រៃសរណគមន៍ រាប់អានព្រះពុទ្ធសាសនា. ពាណិជជាបងកណ្តាលបានជាព្រះបាទទេវានម្បិយតិស្ស: ព្រះចៅលង្កាទ្វីបជាមហាមិត្តនិងព្រះបាទធម្មាសោក ដែលបានទទួលកាន់ព្រះពុទ្ធសាសនា តាមការផ្សាយរបស់ព្រះមហាមហិន្ទត្ថេរនិងព្រះសង្ឃមិត្រាថេរី ជាព្រះរាជបុត្រនៃព្រះបាទធម្មសោក ឱ្យប្រទេសលង្កា បានជាប្រទេសកាន់ព្រះពុទ្ធសាសនារហូតដល់សព្វថ្ងៃ ។

តាមសេចក្តីសរសើរក្នុងគម្ពីរនានា មានគម្ពីរមហាវង្សជាដើម ថាព្រះនាងអសន្ធិមិត្តា ជាព្រះអគ្គមហេសីព្រះធម្មាសោកនោះ បានជាមានព្រះនាម ឲ្យ អសន្ធិមិត្តាដូច្នោះ ព្រោះព្រះនាងមានរោមលោមពណ៌ល្អណាស់ មាន

www.elibraryofcambodia.org

ព្រះហស្ថមូលត្រសូលដូចបណ្ដូលចេក មិនឃើញមានសង្វាក់ដៃដូចស្ត្រីទាំងពួងឡើយ គួរជាទីពិតពិលរមិលមើលជាទីស្រឡាញ់ពេញចិត្តនៃជនទាំងពួង ។

ដែលព្រះនាងមានព្រះហស្ថល្អដូចពោលមកនេះ ដោយសារព្រះនាងបានញុំាងកាយវិការឱ្យកំរើកឡើង លើកដៃបង្ហូលផ្លូវប្រាប់ភានផ្សារលក់ទឹកឃ្មុំ ដល់ព្រះបច្ចេកពុទ្ធពីជាតិដែលនៅជានាងកុម្ភទាសីនោះឯង ។

## ២២. អានិសង្សបីវិការ

កុសលធម៌ ដែលកើតក្នុងចិត្ត ជម្រះសន្ដានចិត្តឱ្យស្អាត ហៅថា "បុណ្យ" ដូចបទវិគ្រោះដែលលោកចងទុកក្នុងអភិធានប្បទីបិកាសូចិ ថា សន្តានំ បុនាតិ សោធេតីតិ បុញ្ញំ ប្រែថា កុសលធម៌ណាដែលជម្រះសន្ដានចិត្តឱ្យស្អាតបរិសុទ្ធ កុសលធម៌នោះឈ្មោះថា បុណ្យ តែបុណ្យនោះកើតក្នុងផ្លូវចិត្តជាមុន ហើយទើបកើតក្នុងផ្លូវកាយនិងវាចាជាក្រោយ ។

បុណ្យដែលធ្វើដោយផ្លូវកាយ ហៅថាធ្វើដោយកាយវិការ គឺកំរើកជើងដៃធ្វើការកុសលផ្សេងៗ មានអង្គុយបត់ជើង លើកដៃប្រណម្យនមស្សការព្រះរតនត្រ័យ និងធ្វើការហត្ថកម្មផ្សេងៗ ជាការកុសលជាដើម ។

បុណ្យដែលធ្វើដោយផ្លូវវាចា ហៅថាធ្វើដោយវចីវិការ គឺកំរើកវាចា ធ្វើការកុសលផ្សេងៗ មានសូត្រធម៌នមស្សការព្រះរតនត្រ័យនិងសូត្រធម៌សំដែងធម៌ឱ្យគេស្ដាប់ ឬបបួលគេឱ្យធ្វើការកុសលផ្សេងៗ មានធ្វើទានសមាទានសីល និងស្ដាប់ធម៌ទេសនាជាដើម ។

បុណ្យដែលធ្វើដោយផ្លូវចិត្ត ហៅថាធ្វើដោយមនោវិការ គឺកំរើកចិត្ត

www.elibraryofcambodia.org

នឹកគិតដល់ការកុសលផ្សេងៗ មាននឹករលឹកដល់គុណព្រះរតនត្រ័យជាដើម ។

ការកំរើកកាយធ្វើការកុសល បានអានិសង្សតាមចំណែកកាយ ការកំរើកវាចាធ្វើការកុសល បានអានិសង្សតាមចំណែកវាចា. ការកំរើកចិត្តធ្វើការកុសល បានអានិសង្សតាមចំណែកចិត្ត ។

ក្នុងទីនេះ សូមពណ៌នាអំពីអានិសង្សនៃការកំរើកវាចាធ្វើការកុសលដោយសង្ខេបដូចតទៅនេះ

## រឿងឃោសិតសេដ្ឋី

អដ្ឋកថាធម្មបទ និទានរឿងឃោសិតសេដ្ឋីថា:

ក្នុងសម័យមុនពុទ្ធកាលនៃព្រះសក្យមុនីគោតម ជាអម្ចាស់យើងនេះ មានបុរសកំសត់ម្នាក់ ត្រេចស្វែងអាហារក្នុងវេលាស្រុកកើតទុរភិក្សអត់បាយដោយអស់កម្លាំងពេក វេលាទៀបស្លាប់ដេកសំឡឹងមើលមេឆ្កែសេដ្ឋីម្នាក់ ដែលគេឱ្យវាស៊ីបាយដោយភាជន៍ប្រាក់ ក៏នឹកស្ងើចក្នុងចិត្តគិតចង់កើតជាឆ្កែ ដ៏មានភ័ព្វបានអាហារឆ្ងាញ់ៗបរិភោគ ក៏ស្លាប់ទៅ ទៅកើតជាកូនឆ្កែនោះ លុះកើតជាកូនឆ្កែហើយ សេដ្ឋីស្រឡាញ់ណាស់ ទៅណាមកណាតែងយកទៅតាមខ្លួន ។ សេដ្ឋីនោះជាអ្នករាប់អានព្រះបច្ចេកពុទ្ធ ១ អង្គដែលមានអាស្រមនៅព្រៃ ១ ក្បែរភូមិរបស់ខ្លួន ។ វេលាមួយសេដ្ឋីបាននាំកូនឆ្កែនោះទៅពីល្ងាចនិមន្តព្រះបច្ចេកពុទ្ធមកឆាន់នៅផ្ទះខ្លួនក្នុងវេលាព្រឹកស្អែក ។ សេដ្ឋីនិមន្តហើយទូលព្រះបច្ចេកពុទ្ធថា "ព្រឹកស្អែកខ្ញុំព្រះករុណានឹងប្រើកូនឆ្កែ ឱ្យមកនាំដំណើរព្រះអង្គទៅផ្ទះខ្ញុំព្រះករុណា" សូមព្រះអង្គនិមន្តទៅតាមសញ្ញាដែលកូនឆ្កែនេះនាំព្រះអង្គចុះ.

ដល់ព្រឹកឡើង សេដ្ឋីបានប្រាប់កូនឆ្កែឱ្យទៅនិមន្តព្រះអង្គ។ កូនឆ្កែនោះពិតមែនមិនចេះនិយាយភាសាមនុស្ស តែមានគំនិតប្រាជ្ញាវាងវៃ អាចស្តាប់ដឹងសេចក្តីសព្វគ្រប់បាន ។ កាលសេដ្ឋីប្រើហើយ កូនឆ្កែនោះក៏រត់តាមផ្លូវតម្រង់ទៅអាស្រមព្រះបច្ចេកពុទ្ធ ។ ពេលរត់ទៅតាមផ្លូវកូនឆ្កែនោះវាស្រែកព្រុះខ្លាំងៗ ដេញសត្វនានាតាមព្រៃស៊ុំទ្រុំ និងតាមដំបូកដែលនៅក្បែរផ្លូវនោះចេញអស់ ដើម្បីកុំឱ្យសត្វចឹកខាំព្រះបច្ចេកពុទ្ធ ។ លុះវារត់ទៅដល់អាស្រមវាឈរព្រុះខ្លាំងៗ នៅមុខអាស្រមជាសញ្ញានិមន្តព្រះអង្គ ។ ព្រះបច្ចេកពុទ្ធឮសំឡេងព្រុះក៏ជ្រាបថាកូនឆ្កែមកនិមន្តហើយ ក៏ព្រះអង្គរៀបចំឃ្លុំចីពរប្រដាប់ដោយបាត្រ និមន្តតាមក្រោយកូនឆ្កែទៅកាន់ផ្ទះសេដ្ឋី ។ លុះដល់ផ្លូវបំបែកជាពីរព្រះអង្គចង់ដឹងគំនិតកូនឆ្កែ ក៏ធ្វើជានិមន្តទៅតាមផ្លូវ ១ ដែលខុសពីផ្លូវទៅផ្ទះសេដ្ឋី ។ កូនឆ្កែឃើញដូច្នោះវាស្ទុះទៅខាំទាញជាយស្បង់បំបែរព្រះអង្គឱ្យមកខាងផ្លូវត្រូវ ។ ដល់ផ្លូវជាល់ដាប់មក ព្រះអង្គធ្វើជាដូច្នោះទៀត កូនឆ្កែខាំទាញស្បង់ទៀត ទាល់តែរហែកជាយស្បង់ ។

លុះព្រះបច្ចេកពុទ្ធនិមន្តមកដល់ផ្ទះ សេដ្ឋីសួររឿងរហែកជាយស្បង់ព្រះអង្គប្រាប់តាមដំណើរនោះសព្វគ្រប់ សេដ្ឋីក៏ចាត់ចែងដេរជាយស្បង់ ហើយនិមន្តឆាន់ដោយរីករាយ ។ ឆាន់ហើយព្រះអង្គធ្វើអនុមោទនា រួចលាសេដ្ឋីត្រឡប់ទៅអាស្រមវិញ ។

កាលព្រះបច្ចេកពុទ្ធត្រឡប់ទៅ កូនឆ្កែតាមជូនទៅដែរដល់ផុតពីភូមិទៅព្រះបច្ចេកពុទ្ធព្រះអង្គហោះឡើងទៅលើអាកាស ។ វេលាព្រះអង្គហោះឡើងកូនឆ្កែក្រឡេកមើលមានចិត្តស្រងេះស្រងោចអាល័យព្រះអង្គ ដរាបដល់បែកទ្រូងស្លាប់ក្នុងពេលនោះទៅ បានទៅកើតជាទេវបុត្រនៅឋានត្រៃត្រិង្សទេវលោក។

www.elibraryofcambodia.org

ដោយអានុភាពនៃការស្រែកព្រះនិមន្តព្រះបច្ចេកពុទ្ធ ទេវបុត្រនោះកើតឡើងមានសំឡេងកងរំពងខ្លាំងជាងទេវបុត្រ គេឱ្យឈ្មោះថាឃោសកទេវបុត្រ សោយសុខក្នុងទេវលោកអស់១ពុទ្ធន្តរ(ចន្លោះព្រះពុទ្ធ១ព្រះអង្គ)។

លុះសម័យពុទ្ធកាលនៃព្រះបរមសាស្ដារបស់យើង ឃោសកទេវបុត្រច្យុតចាកឋានទេវលោក មកកើតក្នុងផ្ទៃនៃស្ត្រីពេស្យានៅក្រុងកោសម្ពី ។ ធម្មតាស្ត្រីពេស្យា កាលណាកើតកូនស្រីគេទុក តែកើតកូនប្រុសគេចោល ។ ឯស្រីពេស្យាជាមាតានោះលុះកូននោះកើតហើយ ក៏យកទារកនោះទៅចោលនៅគំនរសម្រាម ១ ។ ចោលហើយមានអ្នកដំណើររើសយកទៅចិញ្ចឹមស្រឡាញ់ដូចកូនរបស់ខ្លួន ។

សេដ្ឋីនៅនគរកោសម្ពីដោយខ្លួនពុំមានកូន បានឱ្យប្រាក់ ១០០០ កហាបណៈដល់អ្នករើស ហើយយកទារកនោះទៅចិញ្ចឹមស្រឡាញ់ដូចកូនបង្កើត ឱ្យឈ្មោះថាឃោសកកុមារ ដោយមានសំឡេងកងរំពង ។ ដល់ខ្លួនមានកូនកើតឡើង ក៏ថយសេចក្ដីស្រឡាញ់ ហើយខ្លាចដណ្ដើមកេរ្តិ៍មត៌ក ក៏ប្រុងធ្វើឃាតកម្មដល់ ៦ លើក គឺ

-លើកទី ១ ឱ្យមនុស្សបម្រើយកទៅចោលត្រង់មាត់ទ្វារក្រោលគោ ប្រាថ្នាឱ្យពួកគោនៅក្នុងក្រោល ចេញពីក្រោលជាន់ស្លាប់ តែពេលនោះមានគោ ១ ចេញមុនគេ ឈរក្រុងពីលើកូននោះមិនឱ្យគោឯទៀតជាន់ ។ មាស់គោឃើញក៏រើសយកស្រឡាញ់ដូចកូនបង្កើត ។ លុះដំណឹងនោះដឹងដល់សេដ្ឋី មានសេចក្ដីអាណិតឱ្យយកប្រាក់ ១០០០ កហាបណៈមកសុំយកទៅវិញ ។

-លើកទី ២ យកទៅចោលក្នុងហ្វូងពពែ ប្រាថ្នាឱ្យពួកពពែជាន់ តែមានពពែ ១ មកឈរក្រុងដូចមេគោនោះទៀត សេដ្ឋីឱ្យយកប្រាក់ ១០០០

កហាបណៈមកសុំពីគេយកទៅវិញទៀត ។

-លើកទី ៣ យកទៅផ្តេកចោលនៅផ្លូវរទេះគោ ក្នុងវេលាយប់ប្រាថ្នាឱ្យគោជាន់ស្លាប់ តែគោអ្នកបររទេះមិនហ៊ានជាន់ហើយម្ចាស់រទេះរើសយកទៅចិញ្ចឹម សេដ្ឋីឱ្យយកប្រាក់ ១០០០ កហាបណៈមកសុំគេទៅវិញទៀត ។

-លើកទី ៤ យកទៅចោលក្នុងព្រៃជ្រោះភ្នំប្រាថ្នាឱ្យស្លាប់ តែជាភ័ព្វល្អបានជាងអ្នកកាប់ឫស្សីទៅគុកញ្ចក់ផង គេរើសយកទៅចិញ្ចឹម ហើយសេដ្ឋីឱ្យយកប្រាក់ ១០០០ កហាបណៈមកសុំយកទៅវិញទៀត ។

-លើកទី ៥ សេដ្ឋីកាន់តែខឹងខ្លាំងឡើងៗ បានសរសេរសំបុត្រប្រាប់ទៅនាយស្មូនឆ្នាំងជាមិត្តជិតស្និទ្ធរបស់ខ្លួនថា "បើអ្នកឃើញកូនខ្ញុំកាន់សំបុត្រនេះមកដល់ពេលណា ចូរអ្នកចាប់បោះទៅក្នុងឡឆ្នាំងដែលកំពុងដុតនោះទៅកុំឱ្យនរណាដឹង" ។ សរសេរហើយឱ្យឃោសកកុមារកាន់យកទៅ ។ ឃោសកកុមារកាន់សំបុត្រនោះទៅដល់មាត់ច្រកភូមិកូនសេដ្ឋីបង្កើតកំពុងលេងអង្គុញជាមួយក្មេងឯទៀតបេះតែចាញ់គេ បានឱ្យឃោសកកុមារលេងជំនួសខ្លួនក៏យកសំបុត្រទៅឱ្យស្មូនឆ្នាំងៗ បានឃើញក៏ចាប់បោះទៅក្នុងឡឆ្នាំងស្លាប់ទៅ ។

លើកទី ៦ ដោយរវល់តែខឹងសេដ្ឋីប្រុងសម្លាប់ជាច្រើនលើក ឃោសកកុមារមានអាយុពេញការឡើងពុំបានចេះអក្សរឡើយ ។ សេដ្ឋីជាឪពុកទៅក្រុងបានសរសេរសំបុត្រមួយប្រាប់ទៅគហបតីនៅបច្ចន្តជនបទថា "បើអ្នកឃើញឃោសកកុមារមកដល់ពេលណា ចូរចាត់ការសម្លាប់ចោលពេលនោះ" ។ សំបុត្រនោះ សេដ្ឋីខ្ចប់ទីងជាយសំពត់សាដករបស់ឃោសកកុមារ ហើយប្រាប់ថា ចូរអ្នកនាំសំបុត្រនេះទៅឱ្យគហបតីនៅបច្ចន្តជនបទ វេលាទៅតាមផ្លូវចូរអ្នកទៅឈប់សំណាក់នៅផ្ទះសេដ្ឋី ១ នៅពាក់កណ្តាលផ្លូវ ហើយសឹមចេញ

ដំណើរពីនោះនាំសំបុត្រទៅ ។

សេដ្ឋីទៅពាក់កណ្ដាលផ្លូវ មានកូនស្រីម្នាក់ អាយុ ១៦ ឆ្នាំ ។ នាងនោះត្រូវជាភរិយារបស់ឃោសកកុមារកាលពីជាតិមុន ។ ពេលឃោសកកុមារទៅដល់ផ្ទះសេដ្ឋីនោះនាងបានឃើញមានចិត្តប្រតិព័ទ្ធ ដោយហេតុធ្លាប់ជាគូវាសនានឹងគ្នាមកពីបុរេ ។

វេលាឃោសកកុមារទៅដល់ សេដ្ឋីបានទទួលដោយរាក់ទាក់បានរៀបអាហារឱ្យបរិភោគ ហើយឱ្យឈប់សម្រាកនៅក្នុងបន្ទប់ ១ ក្នុងវេលាថ្ងៃ ។ ពេលឃោសកកុមារដេកលក់ស៊ប់ នាងសេដ្ឋីធីតាលបចូលទៅក្នុងបន្ទប់ឥតឱ្យនរណាដឹង នាងស្រាយជាយសំពត់មើលឃើញសំបុត្រមិនស្រួល ក៏ហែកចោលហើយសរសេរជាថ្មីមានសេចក្ដីថា "សេដ្ឋីក្នុងក្រុងប្រាប់មកគហបតីក្នុងជនបទឱ្យបានដឹង ដោយខ្ញុំមានរវល់ច្រើនពេកមកមិនបាន បើអ្នកឃើញឃោសក-កុមារកូនខ្ញុំមកដល់ពេលណា សូមអ្នកចាត់ការជួសខ្ញុំ នាំបណ្ណាការទៅដណ្ដឹងកូនស្រីសេដ្ឋីកណ្ដាលផ្លូវ ហើយរៀបការជាប្រញាប់កុំខាន" ។ សរសេរហើយនាងវេចទៅជាយសំពត់ដូចដើម ។

ឃោសកកុមារភ្ញាក់ឡើងលាសេដ្ឋីទៅដោយរហ័ស ។ ទៅដល់ផ្ទះគហបតីជនបទបង្ហាញសំបុត្រនោះ ។ គហបតីជនបទឃើញសំបុត្រ ក៏ប្រញាប់នាំបណ្ណាការមករៀបការឃោសកកុមារ និងនាងសេដ្ឋីធីតាឱ្យបានជាស្វាមីភរិយានៅជាសុខសប្បាយ ។

លុះដំណឹងនោះឮដល់ទៅ សេដ្ឋីក្នុងក្រុងក៏កើតវិប្បដិសារីជាខ្លាំងពន់ប្រមាណ កើតជារោគក្អកឈាមស្រស់ៗ ។ រៀបធ្វើមរណកាល សេដ្ឋីបានឱ្យបម្រើទៅហៅឃោសកមកជួបនឹងខ្លួន ដើម្បីប្រាប់ញាតិសន្ដានឱ្យដឹងថា

សម្បត្តិទាំងប៉ុន្មានមិនឱ្យឃោសកទេ តែជាភ័ព្វឃោសកដែលបាននាងសេដ្ឋីធីតាជាភរិយា នាងមានប្រាជ្ញានាងប្រាប់ឃោសកថា "យើងត្រូវទៅឱ្យទាន់ឪពុកនៅរស់ កាលទៅដល់សូមអ្នកអង្គុយនៅចុងជើងឪពុក ឱ្យខ្ញុំអង្គុយនៅខាងក្បាលដើម្បីខ្ញុំចាត់ការ" ។

លុះឃោសកនិងភរិយាទៅដល់ សេដ្ឋីក្រឡេកឃើញហៅឱ្យចូលមកជិត ឃោសកអង្គុយខាងចុងជើង នាងជាភរិយាអង្គុយខាងក្បាល ហើយសេដ្ឋីប្រុងហាមាត់និយាយថា "សូមអស់លោកជាញាតិជួយដឹងជួយឮ សម្បត្តិរបស់ខ្ញុំទាំងប៉ុន្មានខ្ញុំមិនឱ្យឃោសកទេ" តែរៀបហាមាត់និយាយ នាងភរិយាឃោសកធ្វើជាយំបោកសក់ឱ្យធ្លាក់ខ្ពោកទៅលើដើមទ្រូងសេដ្ឋី សេដ្ឋីភ័ន្តស្មារតី ក៏ត្រឡប់ជានិយាយថា "សូមអស់លោកញាតិមិត្រជាសាក្សី សម្បត្តិរបស់ខ្ញុំទាំងប៉ុន្មាន ខ្ញុំឱ្យឃោសកជាកូនខ្ញុំទាំងអស់ ដូច្នេះទៅវិញ។ ពេលនោះ ញាតិមិត្តគេបានចាត់ការធ្វើសំបុត្រយ៉ាងត្រឹមត្រូវតាមពាក្យសេដ្ឋីទាំងអស់ ។ លុះចាត់ការហើយ សេដ្ឋីក៏ធ្វើមរណកាលទៅ ។

បន្ទាប់ពីនោះ ឋានៈជាសេដ្ឋីពេញលក្ខណៈក៏កើតមានដល់ឃោសកដោយព្រះរាជាទ្រង់តាំងជាសេដ្ឋីពេញច្បាប់តទៅ ។

លុះបានជាសេដ្ឋីហើយ គេហៅថា ឃោសិតសេដ្ឋី ។ ឃោសិតសេដ្ឋីមានចិត្តជ្រះថ្លាចំពោះព្រះពុទ្ធសាសនា បានសាងវត្ត ១ ឈ្មោះថាឃោសិតារាមនៅជិតក្រុងកោសម្ពី ថ្វាយព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

នេះជាអានិសង្សនៃវេយ្យាវច្ចកម្ម កម្រើកវាចាកាលនៅជាកូនឆ្កែព្រះនិមន្តព្រះបច្ចេកពុទ្ធនោះឯង ។

www.elibraryofcambodia.org

# រឿងកុមារសម្មាទិដ្ឋិ

អដ្ឋកថាធម្មបទ និទានរឿងកុមារសម្មាទិដ្ឋិ ដូចតទៅនេះ :

កាលព្រះពុទ្ធអង្គគង់នៅវត្តជេតពន ជិតក្រុងសាវត្ថីនោះមានព្រាហ្មណ៍សម្មាទិដ្ឋិម្នាក់ មានកូនម្នាក់ជាសម្មាទិដ្ឋិដែរ ជ្រះថ្លាចំពោះព្រះពុទ្ធគុណពន់ពេក កូននោះតែងពេញវាចាថ្វាយបង្គំព្រះពុទ្ធថា នមោ ពុទ្ធស្ស ខ្ញុំសូមថ្វាយបង្គំព្រះពុទ្ធៗ ជារឿយៗ ។ សូម្បីវាលេងបោះអង្គញជាមួយពួកក្មេងៗ ជាមិច្ឆាទិដ្ឋិ ដៃវាបោះអង្គញ មាត់វាថា នមោ ពុទ្ធស្ស ហើយវាលេងអង្គញចេះតែឈ្នះក្មេងៗ ទាំងពួង ។

ព្រាហ្មណ៍ជាបិតាកុមារនោះ ជាអ្នករកស៊ីកាប់អុសលក់ ។ ថ្ងៃ ១ គាត់បររទេះគោចូលព្រៃរកកាប់អុស យកទាំងកូននោះទៅផង ។

កាលទៅដល់ព្រៃ ព្រាហ្មណ៍ដោះគោលែងឱ្យស៊ីស្មៅតាមដងព្រៃ ។ គោទាំង ២ ចូលទៅក្នុងកំពែងព្រះនគរ ពេលជិតព្រលប់ព្រាហ្មណ៍តាមរកគោឃើញហើយ តែគេបិទទ្វារព្រះនគរ ព្រាហ្មណ៍ចេញពុំរួច ក៏នៅក្នុងកំពែងនោះទៅ ។ ឯកូននៅចាំរទេះតែម្នាក់ឯង ចេះតែទន្ទេញថា នមោ ពុទ្ធស្ស ពុំដាច់ពីមាត់ កំពុងតែទន្ទេញ ក៏ដេកលក់តែម្នាក់ឯងទៅ ។

ព្រៃនោះមានយក្ស ២ នាក់ ១ ជាសម្មាទិដ្ឋិ ១ ជាមិច្ឆាទិដ្ឋិ យក្សទាំងនោះនាំគ្នាចេញរកចំណីអាហារក្នុងវេលាយប់ បានឃើញកុមារនោះដេកក្នុងរទេះ ហើយយក្សមិច្ឆាទិដ្ឋិប្រុងចាប់ស៊ី យក្សសម្មាទិដ្ឋិឃាត់មិនព្រមឈប់ ពេលយក្សមិច្ឆាទិដ្ឋិចូលទៅចាប់ទាញជើងកុមារៗ ស្រែកថា នមោ ពុទ្ធស្ស ឡើង យក្សនោះភ័យញ័ររន្ធត់ ទន់ជើងទន់ដៃស្ទើរស្លាប់រកចាប់ពុំកើត ។

យក្សទាំង ២ ខ្លាចឫទ្ធិកុមារផង អាណិតកុមារផង ក៏នៅចាំរក្សាអស់១

យប់ ។ យក្សសម្មាទិដ្ឋិបង្គាប់ឱ្យយក្សមិច្ឆាទិដ្ឋិ ឱ្យទៅយកក្រយាស្ងោយព្រះរាជាក្រុងសាវត្ថី ព្រមទាំងភាជន៍ដាក់ព្រះស្ងោយ មកឱ្យកុមារនោះបរិភោគ ហើយនិម្មិតខ្លួនធ្វើជាមាតាបិតាព្យាបាលកុមារនោះដោយស្រួល ។ កុមារនោះសំគាល់ខ្លួនថាទៅក្នុងផ្ទះ ក៏បរិភោគជាសុខឥតមានភ័យបារម្ភអ្វីឡើយ ។ ទៀបភ្លឺយក្សចារឹកអក្សរថា "ក្រយាស្ងោយនឹងភាជន៍នេះ យក្សយកទៅឱ្យកុមារនេះបរិភោគ" ។

ភ្លឺច្បាស់ឡើងឪពុកកុមារនាំគោមកដល់រទេះ បានឮកូនសព្វគ្រប់ក៏មានសេចក្ដីស្ញើចក្រៃពេក ។

ចំណែកពួកនាយពិសេសអ្នកធ្វើក្រយាស្ងោយព្រះរាជាកាលដឹងថាបាត់ភាជន៍ក្រយាស្ងោយ ក៏តាមរកសព្វប្រកព្លកទៅ ឃើញភាជន៍នៅក្នុងរទេះនោះ ក៏យកភាជន៍នោះនិងកុមារនោះទៅថ្វាយព្រះរាជា។ ទតឃើញកុមារនឹងភាជន៍ដែលមានចារឹកអក្សរនោះ ក៏ទ្រង់ទឹកស្ញើច ហើយទ្រង់នាំព្រាហ្មណ៍នឹងកុមារព្រមទាំងភាជន៍នោះទៅថ្វាយព្រះសម្មាសម្ពុទ្ធ ក្រាបបង្គំទូលសព្វគ្រប់តាមដំណើរការណ៍នោះ ។

ព្រះបរមគ្រូជាម្ចាស់ត្រាស់ថា អានិសង្សនៃចិត្តដែលជ្រះថ្លាចំពោះពុទ្ធគុណ នឹងវចីវិការ ដែលកម្រើកវាចានមស្សការព្រះពុទ្ធ តែងឃើញផលប្រាកដដូច្នេះឯង ។

## ២៣_អានិសង្សមនោទិការ

កុសលធម៌ ដែលកើតឡើងក្នុងចិត្ត ជម្រះសន្ដានចិត្តឱ្យល្អស្អាតហៅថា "បុណ្យ" ដូចក្នុងបទវិគ្រោះដែលលោកបង្ហាញទុកក្នុងអភិធានប្បទិបិកា សូចិថា **សន្តានំ បុនាតិ សោធេតីតិ បុញ្ញំ** ប្រែថាកុសលធម៌ណា ដែលជម្រះ

សន្តានចិត្តឱ្យស្អាតបរិសុទ្ធ. កុសលធម៌នោះឈ្មោះថា "បុណ្យ" គឺបុណ្យនោះកើតឡើងក្នុងផ្លូវចិត្តជាមុន ហើយទើបកើតក្នុងកាយ និងវាចាជាក្រោយ ។

បុណ្យដែលធ្វើដោយផ្លូវកាយ ហៅថាធ្វើដោយកាយវិការ គឺកម្រើកដៃជើងធ្វើការកុសលផ្សេងៗ មានអង្គុយបត់ជើងលើកដៃប្រណម្យនមស្សការព្រះរតនត្រ័យ និងធ្វើការហត្ថកម្មផ្សេងៗ ជាកុសលជាដើម ។

បុណ្យដែលធ្វើដោយផ្លូវវាចា ហៅថាធ្វើវចីវិការ គឺកំរើកវាចាធ្វើការកុសលផ្សេងៗ មានសូត្រធម៌នមស្សការព្រះរតនត្រ័យ និងសូត្រធម៌ឱ្យគេស្តាប់ ឬបបួលគេឱ្យធ្វើការកុសលផ្សេងៗ មានធ្វើទាន សមាទានសីល និងស្តាប់ធម៌ទេសនាជាដើម ។

បុណ្យដែលធ្វើដោយផ្លូវចិត្ត ហៅថាធ្វើដោយមនោវិការ គឺកម្រើកចិត្តនឹកគិតដល់ការកុសលផ្សេងៗ មាននឹករលឹកដល់គុណព្រះរតនត្រ័យជាដើម ។

ការកំរើកកាយធ្វើការកុសលជាដើម បានអានិសង្សតាមចំណែកកាយ. ការកម្រើកវាចាធ្វើការកុសល បានអានិសង្សតាមចំណែកវាចា. ការកម្រើកចិត្តធ្វើការកុសល បានអានិសង្សតាមចំណែកចិត្ត ។

ក្នុងទីនេះ សូមពណ៌នាពីអានិសង្សនៃការកម្រើកចិត្តធ្វើការកុសលដោយសង្ខេបដូចតទៅនេះ:

## រឿងមដ្ឋកុណ្ឌលីមាណព

អដ្ឋកថាធម្មបទ និមានរឿងមដ្ឋកុណ្ឌលីមាណពថា:

កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅវត្តជេតពន ទៀបក្រុងសាវត្ថីមានព្រាហ្មណ៍ម្នាក់ ជាមនុស្សកំណាញ់មិនដែលឱ្យអ្វីតិចតួចដល់អ្នកណាសោះ ទើបអ្នកស្រុកហៅថា អទិន្នបុព្វកៈ ។ ព្រាហ្មណ៍នោះ មានកូនប្រុសម្នាក់ឈ្មោះ

មដ្ឋកុណ្ឌលី ព្រោះគាត់អារដុំមាសខ្លួនគាត់ខាត់ឱ្យរលីង ធ្វើកុណ្ឌលឱ្យពាក់ ។ កូននោះអាយុ ១៦ ឆ្នាំមានជម្ងឺជាទម្ងន់ ។ អទិន្នបុព្វកៈព្រាហ្មណ៍ មិនហ៊ាន ទុកកូននៅល្វែងផ្ទះខាងក្នុង ខ្លាចញាតិសន្តានគេចូលទៅសួរកូន ហើយឃើញ សម្បត្តិទ្រព្យគេសុំ គាត់ក៏យកកូន មកដាក់ឱ្យដេកនៅតាកខាងក្រៅផ្ទះ ។

មដ្ឋកុណ្ឌលីមាណពជាកូនគិតថា "ឪពុកអញគាត់កំណាញ់ណាស់ ទៅ ផ្ទះជិតវត្តជេតពនល្អពេកតែគាត់មិនដែលនិមន្តព្រះសង្ឃឆាន់ មិនដែលដាក់ បាត្រព្រះពុទ្ធឬព្រះសង្ឃ ១ វែកសោះ ទាំងខ្លួនអញក៏គាត់មិនឱ្យទៅវត្តទៅ ស្តាប់ធម៌ទៅគោរពប្រណិប័តន៍ព្រះពុទ្ធនឹងព្រះសង្ឃសោះ. ឥឡូវខ្លួនអញឈឺ ធ្ងន់ក្រោកមិនរួច ជិតដល់មរណៈទៅហើយធ្វើម្តេចនឹងបានឃើញព្រះពុទ្ធជា ម្ចាស់?" ។ ពេលគិតនោះមដ្ឋកុណ្ឌលីមាណពដេកបែរមុខទៅក្នុងផ្ទះ ស្រាប់តែ ព្រះសម្ពុទ្ធជាអម្ចាស់ព្រះអង្គប្រមើលមើលនិស្ស័យសត្វទ្រង់ជ្រាបថា "មដ្ឋ- កុណ្ឌលីមាណពឈឺធ្ងន់ទៀបស្លាប់ ព្រះអង្គក៏យាងទៅឈរនៅមុខផ្ទះទ្រង់ បញ្ចេញព្រះឆព្វណ្ណរង្សី ៦ ពណ៌ចាំងភ្លែតៗ ទៅត្រង់ទីដែលមាណពដេក ។ មាណពឃើញព្រះឆព្វណ្ណរង្សីក៏ងាកមកក្រៅផ្ទះ បានឃើញព្រះអង្គក៏មានបីតិ ប្រមោទ្យត្រេកអរឥតឧបមា នឹកថា "ព្រះអង្គមកប្រោសខ្ញុំៗ ក្រោកពុំរួចទេ សូមថ្វាយព្រះអង្គតែដោយចិត្ត" ហើយក៏ធ្វើមរណកាលទៅបានទៅកើតជា ទេវបុត្រក្នុងឋានត្រៃត្រិង្សត្តិ មានអត្តភាពប៉ុនទេវបុត្រទាំងពួងដែលកើត ១៦ ឆ្នាំ ក្រឡេកមើលខ្លួនប្រាណដឹងថាខ្លួនមកកើតក្នុងទេវលោក ហើយមើល មកមនុស្សលោក ឃើញសាកសពរបស់ខ្លួនគេកំពុងនាំយកទៅធ្វើឈាបនកិច្ច ក្នុងទីប៉ាឆា ។ វេលាធ្វើឈាបនកិច្ចហើយ អទិន្នបុព្វកព្រាហ្មណ៍ តែងទៅយំ សោក បោកខ្លួននៅទីប៉ាឆាជារាល់ថ្ងៃ ។ ថ្ងៃ ១ ព្រាហ្មណ៍កំពុងតែយំកន្ទក់

កន្ទេញ មដ្ឋកុណ្ឌលីទេវបុត្រក៏ចុះមកជាមដ្ឋកុណ្ឌលីមាណពយំសោកក្នុងទីជិតគ្នានោះដែរ ។

អទិន្នបុព្វកៈឃើញដូច្នោះ ក៏ងាកមកសួរថា "អ្នកជានរណា?"

មដ្ឋកុណ្ឌលីទេវបុត្រឆ្លើយថា "ខ្ញុំជាកូនរបស់អ្នកដែលស្លាប់ហើយទៅកើតជាទេវបុត្រ នៅឋានត្រៃត្រឹង្សទេវលោក" ។

-អ្នកគ្មានធ្វើបុណ្យអ្វីសោះ ម្ដេចទៅកើតជាទេវបុត្រនៅឋានសួគ៌បាន?

-ខ្ញុំគ្រាន់តែនឹងថ្វាយបង្គំព្រះពុទ្ធតែក្នុងចិត្ត នៅពេលដែលខ្ញុំទៀបស្លាប់ប៉ុណ្ណោះ ស្លាប់ទៅក៏បានទៅកើតក្នុងឋានសួគ៌ ។

-បើទៅកើតក្នុងឋានសួគ៌ហើយ ម្ដេចក៏មកយំធ្វើអ្វី?

-បានជាខ្ញុំមកយំ ព្រោះកង់រថរបស់ខ្ញុំបាត់ម្ខាង ខ្ញុំមកសុំវង់ព្រះអាទិត្យដែលកំពុងរះនៅលើអាកាសនោះ ធ្វើជាកង់រថរបស់ខ្ញុំជំនួសកង់រថដែលបាត់ទៅ ។

-អ្នកយំចង់បានវត្ថុដែលមិនគួរបាន ដូច្នេះមានតែអ្នកជាមនុស្សវិកលចរិត?

-បើថាខ្ញុំយំចង់បានវង់ព្រះអាទិត្យដែលមានវង់មូលក្រឡង់មើលឃើញជាក់នឹងភ្នែកលាំង១ ជាមនុស្សវិកលចរិត ខ្លួនអ្នកជាឪពុក យំចង់បានកូនដែលស្លាប់បាត់រូបរាងទៅហើយនេះ ជាមនុស្សវិកលចរិតជាងខ្ញុំទៅទៀត មិនមែនឬ?

អទិន្នបុព្វកៈព្រាហ្មណ៍ទាល់ប្រាជ្ញាក៏លែងយំ ហើយគិតថា "ចាំអញទៅសួរព្រះសមណគោតមមើល តើមនុស្សគ្មានធ្វើទានអ្វីសោះ គ្រាន់តែនឹងថ្វាយបង្គំព្រះពុទ្ធតែក្នុងចិត្តប៉ុណ្ណោះ បានទៅកើតជាទេវបុត្រក្នុងឋានសួគ៌ទេវលោកមែនឬ? បើមែនអញនឹងជឿកាន់ព្រះពុទ្ធសាសនាតទៅ" ។

លំដាប់ពីនោះ អទិន្នបុព្វកៈព្រាហ្មណ៍ចូលទៅកាន់វត្តជេតពនឈរសួរព្រះដ៏មានបុណ្យថា "មនុស្សគ្មានធ្វើបុណ្យអ្វីសោះ គ្រាន់តែនឹងថ្វាយបង្គំព្រះពុទ្ធ

www.elibraryofcambodia.org

តែក្នុងចិត្តប៉ុណ្ណោះ តើបានទៅកើតជាទេវបុត្រក្នុងឋានសួគ៌មែនឬ?"

ព្រះអង្គឆ្លើយថា "ចាំអ្នកមកសួរតថាគតធ្វើអ្វីទៀត បើព្រឹកមិញអ្នកបាន ឃើញជាក់នឹងភ្នែក នូវមដ្ឋកុណ្ឌលី ជាកូនអ្នកដែលទៅកើតជាទេវបុត្រ នៅស្ថានសួគ៌ចុះមកជួបនឹងអ្នកទៅទីចាំឆាបានសួរដេញដោលធ្លាស់ពត្រប់ស្រាប់ហើយ" ។

ព្រាហ្មណ៍នឹកស្ញើចក្នុងចិត្តថា "ឱ! ព្រះពុទ្ធ ព្រះអង្គគង់នៅឯវត្តជេតពនឯណោះ ម្ដេចក៏ទ្រង់ជ្រាបសព្វគ្រប់ម៉្លេះ! ការនេះច្បាស់ជាព្រះអង្គជាព្រះអរហន្ត មានព្រះញាណទិព្វមែនហើយ បានជាទ្រង់ជ្រាប. ហើយព្រាហ្មណ៍ក៏ជ្រះថ្លាបាន យកព្រះរតនត្រ័យជាទីពឹង ហើយធ្វើទានរក្សាសីល ក្នុងព្រះពុទ្ធសាសនាតទៅ ។

ទីបំផុតនិទាននេះ ព្រះសម្ពុទ្ធទ្រង់ទេសនាថា:

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

ប្រែថា: ធម៌ទាំងឡាយមានចិត្តដល់មុនជាប្រធានស្រេចហើយនៅចិត្ត កាលចិត្តជ្រះថ្លាហើយ ធ្វើក្ដី និយាយក្ដី ក៏សុទ្ធតែល្អទាំងអស់ ហើយសេចក្ដីសុខក៏ជាប់តាមទៅដូចស្រមោល ។

តាមរឿងនិទាននេះ មដ្ឋកុណ្ឌលីមាណព ដែលបានទៅកើតជាទេវបុត្រ ក្នុងទេវលោក ដោយសារអានិសង្សនៃមនោវិការ ដែលកម្រើកមនោសញ្ចេតនា នឹករលឹកដល់ព្រះពុទ្ធគុណនោះឯង ។

## ២៤_អានិសង្សសច្ចំ

ពាក្យថា សច្ចំ ក្នុងទីនេះ សំដៅដល់ពាក្យពិត ពាក្យទៀងត្រង់ ពាក្យ

www.elibraryofcambodia.org

មិនភូតកុហក ជុំយពីពាក្យមុសាវាទ ។ មុននឹងពណ៌នាពីសច្ចំនិងអានិសង្សនៃសច្ចំ សូមពណ៌នាពីពាក្យមុសាវាទ និងទោសនៃពាក្យមុសាវាទសិន ។

មុសាវាទ ប្រែថា ពាក្យកុហក ពាក្យវៀច គឺមិនឃើញថាឃើញ មិនឮថាឮ មិនដឹងថាដឹងជាដើម ដោយអ្នកពោលប្រុងនឹងឱ្យអ្នកស្តាប់ចូលចិត្តខុស ទោះអ្នកស្តាប់ជឿក្តី មិនជឿក្តី ក៏ហៅថា ពាក្យវៀចទាំងអស់ ។

ពាក្យមុសាវាទៈ ធ្វើអ្នកដទៃឱ្យវិនាសជីវិតក៏មាន វិនាសទ្រព្យសម្បត្តិក៏មាន ឱ្យដល់នូវសេចក្តីលំបាកវេទនាផ្សេងៗ ក៏មាន ។

ពាក្យមុសាវាទ កាលបេចញនិយាយទៅហើយ តែងឱ្យផលអាក្រក់ផ្សេងៗ ជាអាទិ៍គឺកាលអ្នកស្តាប់គេដឹងថានរណាភូតហើយ ទុកជាថ្ងៃក្រោយនិយាយត្រង់ ក៏គេលែងជឿ ។

តាមពិត ពាក្យកុហក សូម្បីនិយាយដើម្បីដោះខ្លួនឱ្យរួចចាកភ័យ ឬដើម្បីបង្រួបបង្រួមអ្នកដទៃឱ្យសាមគ្គី ក៏មិនត្រូវនិយាយ ត្រូវនិយាយតែពាក្យត្រង់ៗ ចុះ ព្រោះសំនួនវោហារដែលត្រូវនិយាយឱ្យគេស្តាប់មានច្រើនល្មមប្រើដែរមិនខ្វះទេ. ទុកជាភូតលេង ក៏មិនត្រូវនិយាយឡើតនាំឱ្យធ្លាប់មាត់ និងនាំឱ្យអ្នកស្តាប់ស្និទ្ធស្នាល ហើយនាំគ្នានិយាយភូតលេងតៗ ទៅ ។

ពាក្យភូតកុហកបើមានកម្លាំងច្រើន អាចឱ្យទោសក្នុងជាតិនេះ បើមានកម្លាំងតិច ឱ្យទោសក្នុងជាតិខាងមុខ ។ លោកសំដែងថា នរណានិយាយភូតកុហក អ្នកនោះទៅកើតក្នុងជាតិណាៗ តែងជាមនុស្សវៀចមាត់ឆែបមាត់ និងច្រើនមានអ្នកដទៃបោកបញ្ឆោត ចោទបង្កាច់ដោយពាក្យមិនពិតផ្សេង ។

ដោយពាក្យភូតកុហក មានផលអាក្រក់ក្នុងឥធលោកនិងបរលោកដូចពោលមក ទើបលោកហៅថា បាប ជាអំពើលាមកអាក្រក់មិនគួរនិយាយ ។

អ្នកប្រាជ្ញទាំងឡាយលោកឃើញទោសនៃពាក្យកុហកដូចពោលហើយ ទើបលោកមិនភូតកុហកសោះ លោកពោលតែពាក្យសច្ចៈ ។

ពាក្យសច្ចៈនេះ ជាពាក្យមានរសជាតិ មានគុណភាពខ្ពង់ខ្ពស់ ថ្លៃថ្នូរ អាចនាំអ្នកនិយាយឱ្យបានសុខចម្រើន ឥតមានមោះមៃភ័យអន្តរាយក្នុងលោកនេះ និងលោកខាងមុខ ។

ពុទ្ធភាសិត ១ បទ សំដែងបញ្ជាក់នូវគុណសម្បត្តិរបស់ពាក្យសច្ចៈថា សច្ចំ វេ អមតា វាចា ពាក្យសច្ចៈជាពាក្យមិនស្លាប់គឺមិនសាបរលាប នាំអ្នកនិយាយឱ្យបានសុខចម្រើន មានកេរ្តិ៍ឈ្មោះល្អជាដរាប ។

ជនដែលពោលពាក្យសច្ចៈ តែងមានអ្នកស្តាប់ទទួលស្គាល់ ថាជាមនុស្សប្រាកដប្រជា អាចឱ្យអ្នកផងយកតម្រាប់តាម និងយកធ្វើជាមុខជាបាច់ ។

កាលបើជនណាបានទទួលកិត្តិយសដូច្នោះហើយលាភយសនិងសេចក្តីសរសើរ ព្រមទាំងសេចក្តីសុខចម្រើនក៏ហូរចូលមកកាន់ជននោះឃើញប្រាកដទាន់ភ្នែកក្នុងបច្ចុប្បន្នកាល ។

សច្ចធម៌កាលបើបុគ្គលណាបានកាន់ពិតប្រាកដ ស៊ូបង់ជីវិត មិនឱ្យដាច់ដូចភាសិតខ្មែរថា "ស៊ូរស្លាប់ទៅតាប់ រសធម៌កុំបីបង់" នោះឯង. បុគ្គលនោះ ទោះបីមានភ័យអន្តរាយដល់ជីវិត ក៏អាចរស់រួចដោយសុវត្ថិភាពបាន អ្នកប្រាជ្ញបុរាណបាននិទានទុកក្នុងសាស្ត្រាអភិធម្ម ៩ បរិច្ឆេទថា:

## រឿងមេគោ កូនគោ និងខ្លា

កាលពីព្រេងនាយមានសត្វ ៣ គឺមេគោ ១ កូនគោ ១ ខ្លាធំ ១ ត្រេចស្វែងរកអាហារ ក្នុងព្រៃ ១ ជាមួយគ្នាខ្លាឃើញមេគោក៏លបសង្គ្រុបចាប់បាន

ប៉ងនឹងខាំស៊ី តែមេគោអង្វរថា "សូមអ្នកអាណិតខ្ញុំបើកឱ្យខ្ញុំទៅបំបៅកូនតូចសិន បំបៅហើយខ្ញុំត្រឡប់មកឱ្យអ្នកស៊ីពុំខាន ខ្លាក៏បើកឱ្យទៅ ។ មេគោទៅបំបៅកូនហើយ លាកូនថា "ម៉ែត្រូវទៅឱ្យខ្លាស៊ីព្រោះគេចាប់ម៉ែប្រុងនឹងខាំស៊ី តែម៉ែអង្វរគេថា មកបំបៅកូនឯងសិន ហើយនឹងត្រឡប់ទៅឱ្យគេស៊ីវិញ" ។ កូនថា "ខ្ញុំទៅដែរ ហើយមេគោក៏បណ្ដើរកូនទៅជួបនឹងខ្លាតាមពាក្យសន្យារបស់ខ្លួន ។ មេគោនិងកូនទៅជួបនឹងខ្លា ។ប្រារព្ធនឹងខាំមេគោ កូនគោស្ទុះចូលទៅនិយាយ "មេខ្ញុំមានគុណលើរូបខ្ញុំណាស់ ខ្ញុំសូមសងគុណគាត់ សូមអ្នកខាំស៊ីខ្ញុំជាកូនចុះ ទុកមេខ្ញុំឱ្យរស់នៅវិញ" ។

វេលានោះ ខ្លាឃ្លានអាហារណាស់ តែដល់ឃើញមេគោត្រឡប់មកវិញតាមពាក្យសន្យា និងឃើញកូនគោដឹងគុណមេជាអស្ចារ្យដូច្នោះ ក៏មានចិត្តអាណិត អាសូរទ្រាំរត់សម្រេកតម្លានឈប់ខានស៊ីមេគោ និងកូនគោនោះ ហើយសត្វទាំងបីក៏យកគ្នាជាមិត្តសំឡាញ់ ត្រេចស្វែងរកអាហារក្នុងព្រៃជាមួយគ្នាជាសុខសាន្ត រហូតដល់អស់ជីវិតរៀងខ្លួន ។

និទាននេះលោកប្រារព្ធសេចក្ដីថា:

មេគោ ជាសត្វកាន់សច្ចំ ទៀងត្រង់.

ខ្លា ជាសត្វកាន់ខន្តី អត់ធន់.

កូនគោ ជាសត្វកាន់កតញ្ញូដឹងគុណអ្នកមានគុណ ។

សច្ចំ ខន្តី កតញ្ញូ ជាធម៌មានគុណភាពខ្ពស់ អាចញ៉ាំងអ្នកកាន់ អ្នកប្រព្រឹត្ត ពិតប្រាកដ ឱ្យរួចរំដោះចាកទុក្ខ បានសុខដូចពោលមកនេះ ។

## ២៥_អានិសង្សខន្តី

កាលនឹងអធិប្បាយ ពីអានិសង្សខន្តី សូមពណ៌នាពីពាក្យថាខន្តី ជាមុន ។

www.elibraryofcambodia.org

ព្រះបរមពុទ្ធោវាទក្នុងឱវាទបាតិមោក្ខ ជាភាសាបាលីថា

ខន្តី បរមំ តបោ តីតិក្ខា

ប្រែជាភាសាខ្មែរថា ខន្តី គឺសេចក្តីអត់ធន់ តីតិក្ខា សេចក្តីធន់ តបោ ជាតបធម៌ បរមំ ដ៏ឧត្តម ។

មានសេចក្តីអធិប្បាយដូចតទៅនេះ :

សេចក្តីអត់ធន់ ពោលដោយបរិយាយ លោកបានចែងជា ៣ យ៉ាងគឺ

១- អត់ធន់ចំពោះសេចក្តីទុក្ខដែលនាំឱ្យកើតលោភៈ

២- អត់ធន់ចំពោះសេចក្តីទុក្ខដែលនាំឱ្យកើតទោសៈ

៣- អត់ធន់ចំពោះសេចក្តីទុក្ខដែលនាំឱ្យកើតមោហៈ

អធិប្បាយៈ

១-ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលនាំឱ្យកើតលោភៈនោះ គឺ អត់ទ្រាំនឹងចំណង់ដែលកើតឡើងក្នុងទ្វារទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ការអត់ទ្រាំ គឺការមិនប្រព្រឹត្តទុច្ចរិតផ្សេងៗ តាមចំណង់ក្នុងទ្វារទាំង ៦ នោះឯង ។ មនុស្សដែលមិនចេះអត់ទ្រាំនឹងសេចក្តីលោភតែង លួចឆក់ ដណ្តើម បំបាត់ ប្រវញ្ចទ្រព្យសម្បត្តិរបស់គេ ដែលនាំឱ្យត្រូវទោសទណ្ឌកម្មផ្សេងៗ មានជាប់គុកច្រវាក់ជាដើម ។ មនុស្សដែលចេះអត់ទ្រាំមិនរវះរវាមនឹងចំណង់ផ្សេងៗ តែងបានប្រកបដោយសេចក្តីសុខចម្រើន ។ ការចេះអត់ទ្រាំនឹងសេចក្តីទុក្ខដែលនាំឱ្យកើតលោភៈ ដូចពោលនេះ លោកហៅ ខន្តី សូម្បីអត់ទ្រាំនឹងសេចក្តីទុក្ខដែលនាំឱ្យកើតរាគៈ ក៏គួរសង្គ្រោះចូលខន្តីនេះដែរ ។

២-ឯសេចក្តីអត់ធន់នឹងសេចក្តីទុក្ខដែលនាំឱ្យកើតទោសៈនោះ គឺការ

អត់ទ្រាំនិងពាក្យបរម្បវាទផ្សេងៗ ដែលបុគ្គលដទៃស្តីថា ត្មះតិះដៀលឬអត់ទ្រាំនិងអំពើបៀតបៀនរបស់បុគ្គលដទៃ ដែលនាំឱ្យកើតទោសៈ ក៏ឈ្មោះថាខន្តី ។

៣-ឯសេចក្តីអត់ធន់និងសេចក្តីទុក្ខ ដែលនាំឱ្យកើតមោហៈនោះ គឺអត់ទ្រាំនឹងទុក្ខវេទនាផ្សេងៗ ដែលកើតក្នុងកាយនិងចិត្ត ហើយមិនលុះអំណាចទុក្ខវេទនានោះ ប្រព្រឹត្តទុច្ចរិតឡើយ ។ សូម្បីអត់ទ្រាំនឹងទុក្ខវេទនា ក្នុងវេលាឈឺថ្កាត់ដែលនាំឱ្យមានសតិសម្បជញ្ញៈ សេចក្តីរលឹកនិងសេចក្តីដឹងខ្លួន ក៏ឈ្មោះថា ខន្តី ។

បណ្តាសេចក្តីអត់ទ្រាំទាំង ៣ យ៉ាងនេះ សេចក្តីអត់ទ្រាំនិងសេចក្តីទុក្ខ ដែលនាំឱ្យកើត លោភៈ ទោសៈ មោហៈ ជាខន្តី ដោយបរិយាយ ចំណែកសេចក្តីអត់ទ្រាំនឹងសេចក្តីទុក្ខ ដែលនាំឱ្យកើតទោសៈ (សេចក្តីប្រទូស្ត) ទើបជាខន្តីដោយត្រង់ លោកហៅថា អធិវាសនខន្តី ។

អធិវាសនខន្តីនេះ មានអានិសង្សច្រើនយ៉ាង មានដើមថា:

សីលសមាធិគុណានំ ខន្តិ បធានការណំ
សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ ។

សេចក្តីអត់ធន់ ជាហេតុ ជាទីពឹងនៃសីលគុណ និងសមាធិគុណទាំងឡាយ ធម៌ជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្តីអត់ធន់មែនពិត ។

កេវលានំបិ បាបានំ ខន្តិមូលំ និកន្តតិ
គរហកលហាទីនំ មូលំ ខនតិ ខន្តិកោ ។

សេចក្តីអត់ធន់ តែងកាត់បង់ បាននូវឫសគល់នៃបាបទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជាអ្នកជីកគាស់រំលើង នូវឫសគល់នៃទោសទាំងឡាយ

មានពាក្យតិះដៀលនិងការឈ្លោះប្រកែកជាដើម ។

ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ
ខន្តិ ពលំវ យតីនំ ខន្តិ ហិតសុខាវហា ១

សេចក្ដីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្ដីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកមានតបធម៌ សេចក្ដីអត់ធន់ ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្ដីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍និងសេចក្ដីសុខ ។

ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា
បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ

អ្នកអត់ធន់ ជាអ្នកមានមិត្តស្រឡាញ់ ជាអ្នកមានលាភជាអ្នកមានយស ជាអ្នកមានសេចក្ដីសុខជាប្រក្រតី អ្នកអត់ធន់ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតានិងមនុស្សទាំងឡាយ ។

អត្តនោបិ បរេសញ្ច អត្ថាវហោ ច ខន្តិកោ
សគ្គមោក្ខគមំ មគ្គំ អារូឡ្ហោ ច ហោតិ ខន្តិកោ

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ ជាអ្នកឡើងកាន់ផ្លូវ ជាទីទៅកាន់ឋានសួគ៌និងព្រះនិព្វាន ។

សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ
បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ

អ្នកអត់ធន់ ឈ្មោះថាធ្វើតាមនូវព្រះពុទ្ធដីកាជាព្រះឱវាទនៃព្រះសាស្តាមែនពិត. អ្នកអត់ធន់ ឈ្មោះថាបូជានូវព្រះពិជិតមារ ដោយការបូជាដ៏ឧត្តម ។

អ្នកមានអធិវាសនខន្តីខាប់ខ្ជួនមាំមួនល្អ តែងឈ្នះអ្នកមានសេចក្តីក្រេវក្រោធ ដូចនាងឧត្តរាដែលឈ្នះនាងសិរិមា ក៏ដោយសារអធិវាសនខន្តីមាំមួននោះឯង ។

# រឿងនាងឧត្តរា

អដ្ឋកថាធម្មបទ សំដែងរឿងនាងឧត្តរា ពិស្តារ តែក្នុងទីនេះសូមនិទានដោយសង្ខេបដូចតទៅ:

នាងឧត្តរា ជាឧបាសិកាអ្នកបានសម្រេចសោតាតាំងពីក្មេង ជាធីតារបស់បុណ្ណសេដ្ឋី ជាភរិយារបស់រាជគហសេដ្ឋីនៅក្រុងរាជគ្រឹះ ដែលជាមនុស្សមិច្ឆាទិដ្ឋិ ។ តាំងពីថ្ងៃដែលនាងទៅនៅក្នុងផ្ទះស្វាមី មិនមានឱកាសនឹងបរិច្ចាគទាន នាងក៏បានជួលនាងសិរិមាជាស្រីផ្កាមាស ឱ្យមកនៅបម្រើស្វាមីរបស់នាងហើយនាងចេញទៅធ្វើការកុសលតាមប្រាថ្នា ។

ឯនាងសិរិមាផ្កាមាស កាលបើបានមកនៅជាមួយនឹងស្វាមីនាងឧត្តរាត្រឹមតែកន្លះខែ ក៏កម្រើកចិត្តគិតចង់ដណ្តើមយកឋានៈជាមេផ្ទះបានប្រទូស្តនឹងនាងឧត្តរាមានប្រការផ្សេងៗ ដរាបដល់ប្រើមនុស្សឱ្យយកទឹកក្តៅកំពុងពុះ ស្រោចចុះលើនាងឧត្តរា ដែលកំពុងតែចាត់ចែងចង្ហាន់ប្រគេនព្រះសង្ឃ តែនាងឧត្តរាឥតក្រោធបន្តិចសោះ ទឹកក្តៅក៏ត្រឡប់ជាត្រជាក់ដូចទឹកធម្មតា ។ នាងសិរិមាដឹងខ្លួនថាមានទោសក៏ចូលទៅស្មាលាទោសនឹងនាងឧត្តរាៗ ក៏ចូលទៅគាល់ព្រះដ៏មានបុណ្យក្រាបបង្គំទូលរឿងនោះ។ ព្រះអង្គទ្រង់ប្រទានធម្មទេសនាទូន្មានថា:

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេន អលិកវាទិនំ

សេចក្ដីថា បុគ្គលគប្បីឈ្នះសេចក្ដីក្រោធ (របស់គេ) បានដោយសេចក្ដីមិនក្រោធ (របស់ខ្លួន) គប្បីឈ្នះសេចក្ដីមិនល្អ (របស់គេ) បាន ដោយសេចក្ដីល្អ (របស់ខ្លួន) គប្បីឈ្នះសេចក្ដីកំណាញ់ស្វិត (របស់គេ) បាន ដោយការឲ្យ (របស់ខ្លួន) គប្បីឈ្នះមនុស្សដែលហៃនិយាយទ្បេះទ្បោះបាន ដោយការនិយាយតែពាក្យពិតទៅវក ។

អ្នកមានអធិវាសនខន្តី តែងបានអានិសង្ស ៥ យ៉ាងគឺ

១-បិយោ មនាបោ អ្នកអត់ធន់តែងបានជាទីស្រឡាញ់ពេញចិត្តរបស់ជនជាច្រើន.

២-ន វេរពហុលោ មិនមានពៀរច្រើន.

៣-ន វជ្ជពហុលោ មិនមានទោសច្រើន.

៤-អសម្មុឡ្ហោ មិនវង្វេងស្មារតីក្នុងមរណសម័យ.

៥-សុគតី ទម្លាយខន្ធទៅបានទៅកើតក្នុងឋានសួគ៌ បណ្ដាអានិសង្សទាំង ៥ នោះ ត្រង់បទទី ១-២-៣-៤-៥ មានសេចក្ដីងាយស្ដាប់ មិនបាច់អធិប្បាយទេ សូមអធិប្បាយតែបទទី ២ ដែលថា "អ្នកអត់ធន់មិនមានពៀរច្រើន" នោះដោយសង្ខេបដូចតទៅនេះ :

សេចក្ដីឈ្នានិះឈ្នាទៅវិញទៅមកដោយសភាពផ្សេង ១ ហៅថាពៀរ នរណាប្រកបដោយខន្តីសេចក្ដីអត់ធន់ មិនចងពៀរនឹងគេមុន គេក៏មិនចងពៀរនឹងអ្នកនោះវិញដែរ ។

ព្រះដ៏មានបុណ្យជាបរមគ្រូទ្រង់សំដែងបញ្ជាក់សេចក្ដីនេះថា:

www.elibraryofcambodia.org

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ១

សេចក្តីថា: ក្នុងកាលណា១ក៏ដោយ ធម្មតាពៀរទាំងឡាយក្នុងលោកនេះ មិនដែលស្ងប់រម្ងាប់ដោយការចងពៀរឡើយ តាមពិត ពៀរទាំងឡាយតែងស្ងប់រម្ងាប់ដោយការមិនចងពៀរ. ធម៌នេះជាធម៌ចាស់មានយូរណាស់មកហើយ ។

ដើម្បីបញ្ជាក់សេចក្តីនោះឱ្យឃើញជាក់ សូមនិទានរឿងទីឃាវុកុមារ ដែលបានសោយរាជ្យនគរ ២ ដោយសារការមិនចងពៀរ ដោយសង្ខេបដូចទៅនេះ

# រឿងទីឃាវុកុមារ

គម្ពីរវិនយបិដកមហាវគ្គ ត្រង់សង្ឃភេទក្ខន្ធកៈ សំដែងទីឃាវុកុមារថា.

ក្នុងកាលដ៏កន្លងទៅហើយ ព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងនគរពារាណសី ដែនកាសី ព្រះបាទទីឃីតិ សោយរាជ្យក្នុងនគរសាវត្ថីដែនកោសល ។ ព្រះបាទព្រហ្មទត្តលើកពលទៅវាយក្រុងសាវត្ថីបាន ។ ព្រះបាទទីឃីតិនាំព្រះអគ្គមហេសីទ្រង់គភ៌ភៀសព្រះអង្គ ទៅអាស្រ័យនឹងផ្ទះស្មូនឆ្នាំងម្នាក់ នៅស្រុក ១ ក្នុងទីបំផុតដែន ។ លុះព្រះអគ្គមហេសីប្រសូតព្រះរាជបុត្រមកសន្មតព្រះនាមថា ទីឃាវុកុមារ ។ វេលាមួយព្រះបាទព្រហ្មទត្តចាប់ព្រះបាទទីឃីតិបាន ឱ្យពេជ្ឈឃាតនាំទៅធ្វើគត ។ គេកំពុងតែនាំបណ្តើរទៅ ទីឃាវុកុមារមកទាន់ ។ ព្រះបាទទីឃីតិទតឃើញព្រះរាជបុត្រទ្រង់ឱ្យសញ្ញាមិនឱ្យគេស្គាល់ថាព្រះរាជបុត្រ ហើយទ្រង់បន្លឺពាក្យបណ្តាំថា "ទីឃាវុ! អ្នកកុំឃើញកាលវែងពេក ខ្លីពេកធម្មតាពៀរមិនដែលរម្ងាប់ដោយពៀរទេ. ពៀរតែងរម្ងាប់តែ

www.elibraryofcambodia.org

ដោយ ការមិនចងពៀរ ។

ទ្រង់ផ្ដាំស្រេច ពេជ្ឈឃាតក៏ធ្វើគត់ព្រះអង្គទៅ ។

លុះទីឃាវុកុមារមានវ័យពេញការឡើង បានបន្ទំចូលទៅថ្វាយខ្លួនជាខ្ញុំរាជការយ៉ាងជិតស្និទ្ធនឹងព្រះបាទព្រហ្មទត្ត ។

ថ្ងៃមួយព្រះបាទព្រហ្មទត្តទ្រង់យាងប្រពាតព្រៃឱ្យទីឃាវុកុមារជានាយសារថីបររាជរថ។ ទីឃាវុបានឱកាសល្អ ក៏ប្រឹងបរបង្ហួសទៅមុនពួកពលសេនា ដោយប្រាថ្នានឹងធ្វើគតព្រះបាទព្រហ្មទត្ត ។ ខណៈនោះព្រះបាទព្រហ្មទត្តទ្រង់ផ្ទុំទុកព្រះខាន់ក្បែរព្រះអង្គ កើតភ្លៅទីឃាវុក្រោមម្លប់ឈើមួយ ដោយទៀយព្រួយព្រះកាយពល ។ កំពុងតែផ្ទុំស្កល់ទីឃាវុចាប់ព្រះខាន់ឡើងប្រាថ្នានឹងប្រហារព្រះជន្ម តែនឹងភ្នកដល់ព្រះបណ្ដាំព្រះបិតា ក៏ឈប់ទៅវិញ គ្រាន់តែលើកដាក់ ៗ ៣ លើក លើកក្រោយបំផុត ទីឃាវុស្រែកសន្ធាប់ឱ្យព្រះបាទព្រហ្មទត្តជ្រាបថា "ខ្លួនយើងជាព្រះរាជបុត្រព្រះបាទទីឃីតិ ពេលនេះជីវិតរបស់អ្នកនៅក្នុងកណ្ដាប់ដៃយើងហើយ"។ ព្រះបាទព្រហ្មទត្ត ទ្រង់ញាមចុះចាញ់ ។ ហើយក្សត្រទាំង ២ ព្រះអង្គទ្រង់បានទុកព្រះជន្មគ្នាទៅវិញទៅមក រួចទ្រង់យាងត្រឡប់ទៅព្រះនគរវិញ ។

ព្រះបាទព្រហ្មទត្តទ្រង់បង្វែរក្រុងសាវត្ថីប្រទានចំពោះទីឃាវុព្រមទាំងប្រទានព្រះរាជធីតា ជាអគ្គមហេសីផង ហើយទ្រង់អភិសេកជាព្រះរាជាក្រុងសាវត្ថីតំណាងព្រះបាទទីឃីតិជាព្រះបិតាតទៅ ។

បំណោរកាលក្រោយមក ព្រះបាទទីឃាវុ បានសោយរាជ្យក្នុងដែនទាំង ២ គឺដែនកាសី និងដែនកោសល ដោយរុងរឿង ។

នេះហើយជាអានិសង្សនៃអធិវាសនខន្តីសេចក្ដីអត់ធន់ចំពោះទោសៈ

យ៉ាងមាំមួនដល់កម្រិតពេញទី ។

## ២៦_អានិសង្សកតញ្ញូ

តាមសេចក្ដីបរមត្ថ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា **អយំ កាយោ រូបី ចាតុម្មហាភូតិកសម្ភវោ ឱទកុម្មាសុបចយោ** ប្រែថា រូបកាយដែលមានមហាភូតរូបទាំង ៤ នេះ កើតឡើងអំពីមហាភូតរូបរបស់មាតាបិតា ចម្រើនឡើងដោយបាយទឹក នំចំណីដែលមាតាបិតាចិញ្ចឹម ។

អធិប្បាយថា មនុស្សក្នុងលោក សុទ្ធតែកើតអំពីអាហារដែលមាតាបិតាបរិភោគហើយ កើតជាសាច់ឈាមនោះទាំងអស់ គឺមាតាបិតាបរិភោគអាហារណាអាហារនោះឯង តែងកើតទៅជាសាច់ឈាមហើយសាច់ឈាមអ្នកទាំងពីរនោះ ផ្សំគ្នាបានកើតមកជាកូន កើតបានជាកូនហើយមាតាបិតាចិញ្ចឹមកូនដោយបាយទឹកនំចំណីថែមទៀត ទើបលោកពោលថា កូនជាកូនបំណុល មាតាបិតាជាម្ចាស់បំណុល ។

ដូច្នេះ កូនៗដែលបានបុលបំណុលណាពីមាតាបិតា ត្រូវតែសងបំណុលនោះ គឺត្រូវចិញ្ចឹមលោកវិញ ។ កូនណាមិនបានសងបំណុលឈ្មោះថា អកតញ្ញូ អកតវេទីចំពាក់បំណុលលោក កូនណាបានសងហៅថា កតញ្ញូកតវេទីរួចបំណុលលោក ។

កិច្ចដែលកូនត្រូវសងបំណុលសាច់បំណុលឈាមមាតាបិតាពោលដោយខ្លី គឺមាតាបិតាចិញ្ចឹមកូនដោយបច្ច័យណាកូនត្រូវតែចិញ្ចឹម មាតាបិតាដោយបច្ច័យនោះវិញ. បច្ច័យនោះមាន ៤ យ៉ាងគឺ

១_ ចីវរប្បច្ច័យ គ្រឿងស្លៀកពាក់.

២_ បិណ្ឌបាតប្បច្ច័យ គ្រឿងបរិភោគ.

www.elibraryofcambodia.org

៣. សេនាសនប្បច្ច័យ គ្រឿងដេកអង្គុយ.

៤. គេសជ្ជប្បច្ច័យ គ្រឿងថ្នាំកែរោគ ។

មាតាបិតាណាបានទទួលសំណាងជាបច្ច័យ ៤ យ៉ាងនោះ ពីកូនណាពេលនោះហើយ មាតាបិតានោះតែងបានទូវបាន: ៥ យ៉ាងគឺ

១. អាយុ ធម្មជាតិគ្រឿងរស់នៅយឺនយូរ.

២. វណ្ណះ: ពណ៌សម្បុរកាយស្រស់ល្អ.

៣. សុខ: សុខកាយស្រួលចិត្ត.

៤. ពល: កម្លាំងកាយកម្លាំងចិត្ត.

៥. បដិភាណ: ត់ទិតប្រាជ្ញាឈ្លាសវៃ ។

កូនណាបានចិញ្ចឹមមាតាបិតាដោយបច្ច័យ ៤ កូននោះបានឈ្មោះថា ឱ្យទូវបាន: ៥ យ៉ាង ដល់មាតាបិតាក្នុងជាតិជាបច្ចុប្បន្ន ហើយកូននោះតែងបានទូវបាន: ៥ យ៉ាងដល់ខ្លួនវិញក្នុងជាតិជាអនាគត ។

បើការចិញ្ចឹមនោះខ្ពស់បំផុត នឹងបានផលជាទិដ្ឋធម្មវេទនីយឃើញទាន់ភ្នែកក្នុងជាតិជាបច្ចុប្បន្នយ៉ាងពិតប្រាកដ ដូចក្នុងជាតក មានរឿង ១ ដូចតទៅនេះ

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់ ជាមនុស្សចេះរៃចាយទ្រព្យត្រូវតាមគន្លងធម៌ ។ កាលបិតាស្លាប់ទៅបុរសចិញ្ចឹមមាតា ព្រមទាំងកូនប្រពន្ធដោយរបរកាប់ឧសលក់ ។

ថ្ងៃមួយ បុរសនោះបររទេះគោ ទៅកាន់ឧសក្នុងព្រៃបានឧសផ្ទុកពេញកំពុងរទេះហើយ ហេតុតែចង់បានឧសច្រើន ក៏ដឹកគោដឹកឧសហើយខ្លួនរែកឧស ១ អង្រែក ដើរពីមុខរទេះ ។ គាប់ជួនពេលនោះ ព្រះរាជាស្តេចចេញប្រពាតព្រៃ ទ្រង់ទតឃើញប្លែកពីគេ ទ្រង់ហៅបុរសនោះមកទ្រង់សួរថា "នែ

បុរស អ្នកឯងខុសពីគេអ្វីម្ល៉េះ ជីកខុសពេញវេទេះហើយ ម្ដេចក៏រែកខុសដើរមុខគោថែមទៀតយកខុសទៅធ្វើអ្វីខ្លះ?

បុរសទូលថា ខុសនេះ ទូលព្រះបង្គំយកទៅលក់បានកហាបណៈមកយកបកបែកជា ៤ ភាគ :

ភាគទី ១ ដោះបំណុលចាស់ គឺចិញ្ចឹមមាតា.

ភាគទី ២ បុលបំណុលថ្មី គឺចិញ្ចឹមបុត្រ.

ភាគទី ៣ កប់ទុកក្នុងផែនដី គឺធ្វើទាន.

ភាគទី ៤ បង់ក្នុងជ្រោះ គឺបង់ក្នុងទ្វារ ៦ មានទ្វារមាត់ជាដើមរបស់ខ្លួន និងភរិយា ដែលមានទំហំតូចទេ តែមានជម្រៅជ្រៅក្រៃពេកមិនអាច បំពេញបាន ។

ព្រះរាជាទ្រង់សណ្ដាប់ហើយ ទ្រង់ស្ងើច ទ្រង់ព្រះរាជទានទ្រព្យសម្បត្តិនិងយសសក្តិ ដល់បុរសនោះៗ បានសេចក្ដីសុខចម្រើន ក្នុងបច្ចុប្បន្នទាន់ភ្នែកនាលោកនេះ លុះលះលោកយើងនេះទៅ បុរសនោះបានទៅកើតក្នុងទេវលោកសោយសម្បត្តិទិព្វអស់កាលជាយូរអង្វែង ។

ព្រះពុទ្ធសាសនា ចែកបុគ្គលជាគូគ្នាមាន ៣ ពួក :

១- មាតាបិតា ជាគូនិងបុត្រ.

២-ព្រះពុទ្ធ ជាគូនិងបរិស័ទ.

៣-គ្រូ ជាគូនិងសិស្ស

មាតាបិតាជាបុព្វការី (អ្នកធ្វើឧបការៈមុន). បុត្រជាកតញ្ញូកតវេទី (អ្នកដឹងគុណដែលមាតាបិតាបានធ្វើដល់ខ្លួន ហើយបានសងគុណលោកវិញ).

ព្រះពុទ្ធជាបុព្វការី. ពុទ្ធបរិស័ទ ជាកតញ្ញូកតវេទី.

www.elibraryofcambodia.org

គ្រូជាបុព្វការី សិស្សជាកតញ្ញូកតវេទី.

បុគ្គលជាគូគ្នា ៣ ពួកនេះ មានសេចក្តីគួរអធិប្បាយវែងឆ្ងាយណាស់តែក្នុងទីនេះ សូមអធិប្បាយតែចំពោះគូទី ១ គឺមាតាបិតាជាគូគ្នានិងបុត្រធីតាដោយសង្ខេបដូចតទៅ :

លោកឱ្យឈ្មោះមាតាបិតាថា:

-ជាព្រហ្មរបស់បុត្រ ព្រោះមានព្រហ្មវិហារធម៌ ៤ ប្រការចំពោះបុត្រ ។

ព្រហ្មវិហារ ៤ ប្រការនោះគឺ

១- មេត្តា សេចក្តីរាប់អានបុត្រ.

២- ករុណា សេចក្តីអាណិតបុត្រ.

៣- មុទិតា ចិត្តទន់ទោរទៅរកបុត្រ.

៤- ឧបេក្ខា ចិត្តប្រងើយចំពោះបុត្រ ។

មេត្តា របស់មាតាបិតា មានប្រាកដចំពោះបុត្រ ក្នុងពេលបុត្រជាទារកនៅក្នុងផ្ទៃ ។

ករុណា របស់មាតាបិតា មានប្រាកដចំពោះបុត្រ ក្នុងពេលប្រសូតហើយ ។

មុទិតា របស់មាតាបិតា មានប្រាកដចំពោះបុត្រ ក្នុងពេលបុត្រមានវ័យធំហើយ ។

ឧបេក្ខា របស់មាតាបិតា មានប្រាកដចំពោះបុត្រ ក្នុងពេលរៀបចំបុត្រឱ្យមានគូស្រករហើយ ។

-ជាបុព្វាចារ្យ (គ្រូដើម) របស់បុត្រ ព្រោះជាអ្នកបង្ហាត់បង្រៀនច្រើនយ៉ាង មានបង្ហាត់ឱ្យចេះនិយាយស្តី ភាសាជាតិនិងបង្ហាត់ ឥរិយាបថទាំង ៤ ឱ្យចេះ ដេក ដើរ ឈរ អង្គុយ ជាដើម. ឯគ្រូដែលបង្រៀនអក្សរលេខជាដើម

www.elibraryofcambodia.org

នោះ ហៅថាបច្ឆាចារ្យ ( គ្រូចុងគ្រូក្រោយ ) ។

ពោលដោយសង្ខេប. ដោយហេតុមាតាបិតាជាព្រហ្មរបស់បុត្រព្រោះមានព្រហ្មវិហារធម៌ចំពោះបុត្រ និងជាគ្រូដើមមុនរបស់បុត្រដូចពោលមកនេះ បានជាលោកថា មាតាបិតាមានគុណធ្ងន់គុណធំគុណច្រើនជាប់ជុតលើបុត្រធីតា រកអ្វីប្រៀបពុំបាន ។ បើនិយាយពីធ្ងន់ នឹងយកទម្ងន់មហាប្រថពី ឬភ្នំព្រះសុមេរុមកថ្លឹងប្តូរគ្នាក៏ធ្ងន់ពុំស្មើ. បើនិយាយពីធំ នឹងយកទំហំក្រឡាមហាប្រថពី ឬភ្នំព្រះ សុមេរុមកវាស់ប្តូរគ្នា ក៏ពុំធំស្មើ. បើនិយាយពីច្រើន នឹងយកគ្រាប់ខ្សាច់មហាសមុទ្រក្នុងលោកមកគណនាគ្រាប់រាប់ផ្ទួបគ្នាក៏ច្រើនពុំស្មើ ។

ជាពិសេស លោកថាមាតាបិតា ជាព្រះអរហន្តរបស់បុត្រ គឺជាព្រះក្នុងផ្ទះ សម្រាប់បុត្រធីតាធ្វើសក្ការបូជានៅផ្ទះ ។ ព្រះអរហន្តក្រៅពីនេះជាព្រះអរហន្តខាងក្រៅ ។ ការបូជាដោយទេយ្យវត្ថុ ដល់ព្រះអរហន្តក្នុង នឹងព្រះអរហន្តក្រៅ បានផលប៉ុនគ្នា តែព្រះអរហន្តក្នុង ងាយបូជាជាង ព្រោះនៅផ្ទះជាមួយគ្នា ឬជិតគ្នា. តែមិនដូច្នោះ បុត្រធីតាដែលខ្វះវិចារណញ្ញាណ ច្រើនតែមើលមាតាបិតាមិនឃើញមិនបូជា បែរជាទៅឃើញ ទៅបូជា មានលើកដៃសំពះជាដើម ដល់អ្នកដទៃក្រៅទៅវិញ ឯមាតាបិតាឯង ដូចជាស្វាយទេយ្យវត្ថុណាស់ បូជាមិនកើត ដូចជាធ្ងន់ដៃណាស់លើកសំពះពុំរួច ។ បោរាណកបណ្ឌិតលោកឃើញពិត ឃើញមែន ដូចបរិយាយមកនេះ ទើបចងជាសុភាសិតថា "បង់ព្រះទៅសំពះប្រយោប បង់បញ្ចមហាប្រាសាទទៅនៅឯព្រៃភ្នំ" ។

មួយទៀត ឆ្អឹងធាតុមាតាបិតារបស់ខ្លួន កូនមិនហ៊ានទុកនៅក្នុងផ្ទះយូរថ្ងៃទេ ខ្លាចលង តែបើខាងឆ្អឹងធាតុសត្វមានស្នែងគោ ស្នែងក្របី ស្នែងប្រើស ក្តាន់ កុយ ភ្លុកជាដើម បែរជាយកមកតាំងទុកជាលំអ ជាសក្ការៈលើផ្ទះ ផត

ខ្វាបទៅវិញ ។

ដោយហេតុពួកបុត្រធីតាដែលមោហៈគ្របសង្កត់ ខ្វះវិចារណញ្ញាណច្រើនតែយល់ខុសចំពោះគុណមាតាបិតា ដូចពោលមកនេះបានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនាថា "បុគ្គល ២ ពួកគឺបុព្វការីអ្នកធ្វើគុណដល់គេមុន ១ កតញ្ញូកតវេទី អ្នកដឹងគុនគេបានតបគុណគេ ១ ជាបុគ្គលរកបានដោយក្រក្នុងលោក" ។

ជនដែលមានវិចារណញ្ញាណ ដឹងគុណគេ ទឹងរលឹកគុណគេនោះពុំថាឡើយដល់ទទួលគុណពីគេច្រើន សូម្បីទទួលតែបាយ ១ វែកពីនរណាក៏ទឹកឃើញគុណអ្នកនោះ ហាក់ដូចជាធំដុំណាស់ ដូចព្រះសារីបុត្រជាអគ្គសាវ័កនៃព្រះបរមគ្រូលោកជាអ្នកដឹងគុណគេជាទីបំផុត ។ មានសេចក្ដីដំណាលថាៈ

## រឿងព្រះសារីបុត្រ

កាលព្រះសម្ពុទ្ធទ្រង់គង់នៅវត្តជេតពន មានព្រាហ្មណ៍ចាស់ម្នាក់ឈ្មោះរាធៈ ជាអ្នកក្រចង់បួសក្នុងព្រះពុទ្ធសាសនា បានចូលទៅថ្វាយបង្គំព្រះបរមសាស្ដា សុំបួស ព្រះអង្គជ្រាបថា ធម្មតាមនុស្សចាស់ជរាលុះតែមានគេឧបត្ថម្ភទើបបាន ក៏ទ្រង់ហៅភិក្ខុទាំងឡាយមកសួរថា "ភិក្ខុណាអាចទទួលបិញ្ជមរក្សាព្រាហ្មណ៍ចាស់នេះបានទេ បើគាត់បួសហើយ?" ។ គ្រានោះ ព្រះសារីបុត្រក្រាបថ្វាយបង្គំទូលថា "ខ្ញុំព្រះអង្គអាចទទួលបិញ្ជមបាន ព្រោះព្រាហ្មណ៍នេះគាត់មានគុណលើខ្ញុំព្រះអង្គដោយបានប្រគេនបង្ហាន់ដល់ខ្ញុំព្រះអង្គ ១ វែកម្ដង" ។ ព្រះអង្គមានព្រះពុទ្ធដីកាថា "បើដូច្នោះ ចូរអ្នកយកព្រាហ្មណ៍នេះទៅបំបួសហើយបិញ្ជមគាត់ឱ្យសុខសប្បាយ ព្រមទាំងទូន្មានធមិវិន័យឱ្យគាត់បានសម្រេចមគ្គផលផង" ។ ព្រះសារីបុត្រក៏ទទួលយកព្រាហ្មណ៍នោះទៅបំបួស

ហើយចិញ្ចឹមរក្សា ប្រដៅធមិវិន័យឱ្យបានសម្រេចមគ្គផលដោយរហ័ស ។

ភិក្ខុទាំងឡាយ សរសើរព្រះសារីបុត្រ ថាជាកំពូលកតញ្ញូកតវេទីបុគ្គល ដឹងគុណអ្នកមានគុណ បានសងគុណអ្នកមានគុណលើខ្លួន ដោយរីករាយ មិនបំភ្លេចគុណគេឡើយ ។

មង្គលត្ថទីបនី អដ្ឋកថាមង្គលសូត្រ អធិប្បាយថា ភិក្ខុសាមណេរក៏ត្រូវតែគោរពប្រណិប័តន៍មាតាបិតា ចិញ្ចឹមរក្សាដោយអាហារភោជនដោយថ្នាំសង្កូវ ដោយគត់ប្រចាប់កាន់លើកដាក់ ចំណែកមាតាមិនចាំបាច់ធ្វើកិច្ចគត់ប្រចាប់ ចាប់កាន់ពាល់ត្រូវទេ ព្រោះជាបព្វជិត ចាប់កាន់ពាល់ត្រូវពុំបាន កិច្ចក្រៅពីចាប់កាន់ពាល់ត្រូវ ធ្វើបានទាំងអស់ ។

ក្នុងវិន័យ មានពុទ្ធបញ្ញត្តិថា អាហារថ្មោងថ្មី ដែលភិក្ខុទើបនឹងទទួលពីទាយកមក បើខ្លួនមិនទាន់ឆាន់ទេ នឹងចាប់ឱ្យទៅនរណាបរិភោគមុនខ្លួនមិនបាន បើចាប់ឱ្យមុន ត្រូវអាបត្តិទុក្កដ បើមាតាបិតាចាប់ឱ្យបាន ឈ្មោះថាចិញ្ចឹមមាតាបិតា បានផលច្រើនណាស់ទៅវិញ ។

ព្រះពោធិសត្វដែលបានសាងពោធិសម្ភារ តែងមានកតញ្ញូកតវេទីធម៌ជាដរាបរាល់ព្រះអង្គ ដូចព្រះពោធិសត្វនៃព្រះពុទ្ធជាម្ចាស់យើង កាលដែលមានព្រះជាតិ ជាព្រះសុវណ្ណសាម ទ្រង់ដឹងគុណមាតាបិតាណាស់។ សូមនាំរឿងនោះមកសំដែងដោយសង្ខេបដូចតទៅនេះ :

## រឿងភិក្ខុចិញ្ចឹមមាតាបិតា

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅវត្តជេតពន មានភិក្ខុ ១ រូប ចេញចាកវត្តទៅចម្រើនធមិក្នុងព្រៃ ជាយូរឆ្នាំ ។ ថ្ងៃមួយមានភិក្ខុទៅពីស្រុកមាតាបិតា របស់លោកទៅជួបនឹងលោកៗ សួរដំណឹងពីមាតាបិតា ។ ភិក្ខុនោះ

ប្រាប់ថា "មាតាបិតារបស់លោកឥឡូវនេះចាស់ជរាណាស់ហើយ ធ្លាក់ខ្លួនជាអ្នកក្រ សព្វថ្ងៃកាន់អំបែងដើរសុំទានគេបរិភោគ" ។

កាលបានឮដំណឹងនោះ ភិក្ខុនោះក៏ស្លុតចិត្តអាណិតមាតាបិតាជាខ្លាំង ហើយចេញដំណើរពីក្នុងព្រៃជាប្រញាប់ ដើម្បីទៅរកមាតាបិតា។ លុះលោកទៅជិតវត្តជេតពនមានផ្លូវបែកជា ២ ផ្លូវ ១ ទៅចំវត្តជេតពន ផ្លូវ ១ ទៅចំផ្ទះមាតាបិតាលោក។ ឈរគិតថា "អញត្រូវសឹកជាគ្រហស្ថទៅចិញ្ចឹមមាតាបិតាតែម្តង ឬទៅថ្វាយបង្គំព្រះបរមគ្រូសិន" ។ លោកគិតឃើញថា "ទោះបីយ៉ាងណា អញត្រូវតែទៅវត្តស្តាប់ព្រះធម៌ព្រះពុទ្ធអង្គសិន" ហើយលោកក៏ចូលទៅវត្តជេតពនថ្វាយបង្គំព្រះអង្គ អង្គុយស្តាប់ព្រះធម៌ជាមួយភិក្ខុទាំងឡាយ ។

វេលានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឱវាទថា "ភិក្ខុដែលមាតាបិតាចាស់ជរា ត្រូវចិញ្ចឹមដោយចង្ហាន់បិណ្ឌបាតជាដើមបាន" ។ លុះចប់ព្រះធម៌ទេសនាហើយ ភិក្ខុនោះចេញចាកវត្តជេតពន ទៅរកមាតាបិតាលោក ហើយលោកឃាត់មាតាបិតាមិនឱ្យដើរសុំទានគេ ឱ្យចាំទទួលបាយទឹកម្ហូបចំណីពីលោក ។ លំដាប់ពីថ្ងៃនោះ ភិក្ខុនោះក៏ត្រាច់បិណ្ឌបាតតាមចន្លោះភូមិនានា បានចង្ហាន់មកហើយ យកទៅជូនមាតាបិតាបរិភោគជាមុនសិន ទើបលោកឆាន់ជាក្រោយ ជួនកាលបានអាហារតិចលោកជូនទៅមាតាបិតាទាំងអស់ ហើយត្រេចទៅបិណ្ឌបាតម្តងទៀត យកមកឆាន់ខ្លួនឯង ជួនកាលថ្ងៃណាទៅបិណ្ឌបាតលើកក្រោយមិនបាន លោកអត់ចង្ហាន់ ១ ថ្ងៃក៏មាន ជួនកាលបានសំពត់អាវក៏លោកយកទៅជូនមាតាបិតាលោក ។

ភិក្ខុទាំងឡាយ កាលឃើញដូច្នោះ ភិក្ខុខ្លះក៏សរសើរ ភិក្ខុខ្លះក៏ពោលទោស ពួកភិក្ខុពោលទោស បាននាំសេចក្តីនោះទៅក្រាបបង្គំព្រះសម្ពុទ្ធថា

www.elibraryofcambodia.org

"នៅទីឯណោះ មានភិក្ខុ ១រូប ផ្គាប់ផ្គុនបុរសស្ត្រី ២ នាក់ ដោយញុំាងដុំបាយដែលទាយកឱ្យដោយសទ្ធា ឱ្យធ្លាក់ចុះក្នុងដៃបុរសស្ត្រីនោះ ។ ព្រះដ៏មានបុណ្យទ្រង់ឱ្យហៅភិក្ខុនោះមកទ្រង់សួរថា "នែភិក្ខុ! អ្នកឱ្យបាយថ្នោងដែលទាយកគេឱ្យដោយសទ្ធា ទៅបុគ្គលណា បុគ្គលនោះជាអ្វីនឹងអ្នក?" ។

ភិក្ខុនោះទូលថា "បុគ្គលនោះ ជាមាតាបិតារបស់ខ្ញុំព្រះអង្គគាត់ចាស់ណាស់ហើយ ដើរសុំទានគេ បានជាខ្ញុំព្រះអង្គចិញ្ចឹមគាត់" ។

ព្រះអង្គមានព្រះបន្ទូលថា "នែភិក្ខុ! អំពើដែលអ្នកបានធ្វើនេះល្អណាស់ត្រូវតាមប្រពៃណីដែលពោរាណកបណ្ឌិត ធ្លាប់បានធ្វើមកហើយ ហៅថាកតញ្ញូកតវេទិតាធម៌ តថាគតកាលនៅជាពោធិសត្វ ក៏បានប្រព្រឹត្តធម៌នេះយ៉ាងហ្មត់ចត់ ។ ដោយផលានិសង្សនៃកតញ្ញូកតវេទិតាធម៌នេះហើយ ទើបតថាគតបានត្រាស់ជាព្រះពុទ្ធឃើញប្រាកដដូច្នេះឯង" ។

ទ្រង់មានព្រះពុទ្ធដីការួចហើយ ទ្រង់នាំសុវណ្ណសាមជាតកមកសំដែងដោយពិស្តារ តែក្នុងពេលនេះ សូមស្រង់យកតែគោល១ មកពណ៌នាដូចតទៅនេះ :

## រឿងព្រះសុវណ្ណសាម

ក្នុងកាលដ៏កន្លងទៅហើយ នៅនគរមួយមានអ្នកនេសាទ ២ ត្រកូល ត្រកូលមួយនៅត្រើយស្ទឹងម្ខាង ត្រកូលមួយនៅត្រើយស្ទឹងម្ខាង ត្រកូលនេសាទមួយ១ មាននេសាទជាបរិវារ ៥០០ ១ នាក់ ។

ខណៈដែលនេសាទទាំងសងខាងនោះ រស់នៅជាសុខសាន្ត មានព្រហ្ម ២ រូប ប្រុស ១ ស្រី ១ ច្យុតចាកឋានព្រហ្ម មកចាប់បដិសន្ធិក្នុងផ្ទៃនៃភរិយានេសាទជាមេទាំងសងខាង ប្រុសនៅត្រើយស្ទឹងម្ខាងស្រីនៅស្ទឹងម្ខាង ។ វេលា

ប្រសូត្រមក កូនប្រុសមាតាបិតាឱ្យឈ្មោះថា ទលុក: កូនស្រីមាតាបិតាឱ្យឈ្មោះថា បារិកា ។

ត្រកូលទេសាទទាំង ២ នោះ គេបានសន្យានឹងគ្នាថា "យើងទាំង ២ ត្រកូលនេះ បើម្ខាងមានកូនប្រុសម្ខាងមានកូនស្រីយើងត្រូវផ្សំផ្គុំគ្នាឱ្យជាស្វាមីភរិយា. បើទាំង ២ ខាងមានកូនប្រុសដូចគ្នាត្រូវឱ្យវាជាក្លើនឹងគ្នា បើមានកូនស្រីដូចគ្នាត្រូវឱ្យវាម្រាក់នឹងគ្នា ។

លុះកូនទាំង២ នេះមានអាយុ ១៦ ឆ្នាំ មាតាបិតាទាំងសង្ខាងបានចាត់ការធ្វើអាពាហ៍ពិពាហ៍មង្គល តាមសេចក្ដីសន្យានោះ ។

ដោយហេតុតែកូនទាំង ២ នោះច្យុតចាកឋានព្រហ្មមកកើត ក៏គ្មានសេចក្ដីស្នេហានូវកាមគុណដូចជនទាំងពួងសោះ តែដោយអំណាចមាតាបិតាបង្គំក៏ព្រមរៀបចំទៅ ។

រៀបការហើយ ជនទាំង២ដេកលើគ្រែមួយ២នាក់ដូចស្វាមីភរិយាធម្មតាដែរ តែពុំមានត្រូវការកាមគុណទេ ជាតកពោលថា វេលាជនទាំង២ដេកលើគ្រែនោះស្អាតបរិសុទ្ធណាស់ ដូចផ្កា២កម្រងដាក់ទន្ទឹមគ្នា ។

មាតាបិតាទាំងសង្ខាង ប្រាថ្នានឹងឱ្យបុត្រទាំង២នោះប្រកបកិច្ចការជាទេសាទ ដើម្បីចិញ្ចឹមជីវិតតវង្សត្រកូលឱ្យគង់វង្សចំរើនជាភិយ្យោភាពតទៅ តែបុត្រទាំង ២ នោះ ត្រូវការតែចេញបួសជាឥសី ។

សេចក្ដីប្រាថ្នា របស់ជនទាំង ២ នោះរឹតតែកើតមានខ្លាំងឡើង១ រាល់ថ្ងៃ ទ្រាំមិនបានក៏នាំគ្នាលាមាតាបិតាទាំងសង្ខាងចេញបួស ។ ទោះបីមាតាបិតាទាំងសង្ខាងយំសោកស្ដាយមិនបើកឱ្យបួសក៏ចេះតែទទូចលារឿយ១ទាល់តែបាន ។ លុះបានហើយមាតាបិតាក៏រៀបចំបរិក្ខារគ្រប់ប្រដាប់សម្រាប់ឥសីឱ្យ

បុត្រទាំង ២ ។

ទុលកៈនិងនាងបារិកា លុះបានបរិក្ខារគ្រប់គ្រាន់ហើយក៏ស្លៀកពាក់ជាឥសី លាមាតាបិតាយាត្រាចូលទៅនៅក្នុងព្រៃហេមពាន្តចម្រើនមេត្តាភាវនាជាសុខសាន្ត ។

វេលាមួយ ព្រះអមរិន្ទ្រាធិរាជ ស្ដេចបើកទិព្វចក្ខុប្រមើលមើលមកឃើញថា "កម្មពីបុព្វេរបស់តាបសទាំង ២ រូបនោះ តាមមកទាន់ឱ្យផលក្នុងកាលដ៏ខ្ពង់ខាងមុខត្រូវខ្វាក់ភ្នែកទាំង ២ រូប ពុំមានអ្នកណាថែរក្សា ហើយដោយតាបសទាំង ២ រូប ត្រូវជាពុទ្ធមាតាបិតាក្នុងអនាគតកាលផង" ព្រះអង្គក៏អារាធនាសុវណ្ណសាមទេវបុត្រព្រះពោធិសត្វ ដែលឋិតនៅឋានត្រៃត្រិង្សត្ឱ្យចុះមកចាប់បដិសន្ធិ ក្នុងផ្ទៃនៃនាងបារិកាតាបសី ។ តែតាមធម្មតាមនុស្សលោក លុះតែរួមសំវាសគ្នា ទើបសត្វចាប់បដិសន្ធិបាន ក៏ព្រះឥន្ទមកក្នុងវេលាយប់ស្ងាត់ និយាយនឹងតាបសទាំង ២ រូបថា "ក្នុងអនាគតកាលដ៏ខ្ពង់ខាងមុខនេះ លោកទាំង ២ ត្រូវខ្វាក់ភ្នែក ហើយគ្មានអ្នកណាបិញ្ចឹម. ដូច្នេះសូមលោករួមសំវាសគ្នាក្នុងវេលាយប់នេះ ខ្ញុំនិងនិមិត្តទេវបុត្រ ១ អង្គឱ្យចុះមកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះតាបសដើម្បីនឹងបានបុត្រនោះថែរក្សា ។ តាបសពុំព្រមតាមជាដាច់ខាត ។

ព្រះឥន្ទថា "បើលោកម្ចាស់ពុំព្រមរួមសំវាសក៏ហើយចុះគ្រាន់តែយប់ស្ងាត់សូមតាបសលូកស្ទាបអង្អែលផ្ចិតាបសី តើបានឬទេ?" តាបសទាំង ២ ថាបើគ្រាន់តែប៉ុណ្ណោះបាន" ។ លុះតាបសទាំង ២ ទទួលព្រមដូច្នោះហើយ ព្រះឥន្ទក៏អារាធនាសុវណ្ណសាមទេវបុត្រពោធិសត្វ ឱ្យស្ដេចចុះមកចាប់បដិសន្ធិក្នុងផ្ទៃនាងបារិកាតាបសីសម្រេចដូចសេចក្ដីប្រាថ្នា ។

លុះគភ៌គ្រប់ទសមាស ពោធិសត្វក៏ប្រសូតចេញចាកមាតុឧទរដោយសួស្តី ។ មាតាបិតាបានសន្មតព្រះនាមថា សុវណ្ណសាមកុមារ ។ សុវណ្ណសាមកុមារមានវ័យចំរើនឡើងជាលំដាប់ មាតាបិតាតែងត្រេចទៅបេះផ្លែឈើ ជីកមើមឈើមកចិញ្ចឹមជារាល់ថ្ងៃ ។ ថ្ងៃមួយ ជារដូវភ្លៀងមហាមេឃបង្អុរភ្លៀង១មេយ៉ាងធំ តាបសទាំងពីររត់ជ្រកក្រោមដើមឈើមួយមានដំបូក១នោះមានពស់១ធំនៅក្នុងរូង ។ តាបសទាំងពីរមិនដឹងថាមានពស់ ក៏អង្គុយពីលើរូងនោះ ហើយញើសក្អែលស្រក់ទៅលើរូងពស់នោះ ពស់នោះបង្ហុយផ្សែងពិសវាមកត្រូវចំភ្នែក ហើយតាបសទាំងពីរនោះងងឹតភ្នែកទាំងពីរនាក់នោះងងឹតភ្នែកទាំពីរសូន្យឈឹងមើលធ្លាពុំឃើញ អង្គុយយំនៅក្រោមដើមឈើនោះ រកផ្លូវទៅអាស្រមពុំរួច ។

ព្រះសុវណ្ណសាមកុមារ ចាំមាតាបិតានៅអាស្រម បាត់ពុំឃើញមកតាមកំណត់ពេលដូចសព្វមួយដង ក៏រត់រកសព្វច្រកល្ហក ។ លុះឃើញមាតាបិតាងងឹតភ្នែកទាំងពីរនាក់ ក៏ទ្រង់ព្រះកន្សែង ហើយទ្រង់ដឹកដៃមាតាបិតា យាត្រាទៅកាន់អាស្រម ទ្រង់កាប់លំពង់កូនឈើមកចងខ្វាត់ខ្វែង ពីអាស្រមទៅបង្គន់ពីបង្គន់ទៅកន្លែងងូតទឹក ទៅទីបរិភោគ ធ្វើជាស្នូរឱ្យមាតាបិតា សូរទៅសូរមកបានដោយស្រួល ទ្រង់ទៅរកបេះផ្លែឈើជីកមើមឈើ កាន់ក្អមទៅរកដងទឹកស្រះនៅក្បែរជើងភ្នំ មកជូតដុះជម្រះសម្អាតកាយមាតាបិតា គក់ច្របាច់ជើងដៃរាល់យប់ថ្ងៃ ។

ពេលដែលព្រះពោធិសត្វកាន់ក្អមទៅដងទឹករាល់ថ្ងៃ មានក្តាន់មួយៗនាំគ្នាមកដើរទទ្ទឹងគ្នា ទ្រក្អមព្រះអង្គ ។

នៅជិតភ្នំនោះ មានស្តេចមួយព្រះអង្គ ឈ្មោះបិលយក្សទ្រង់ចេញ

ប្រពាតព្រៃ កាន់ធ្នូបាញ់សត្វកំសាន្តព្រះទ័យ ។ ទ្រង់ទតពីចម្ងាយទៅមិនឃើញព្រះពោធិសត្វ ឃើញតែក្អាន់ដើរទន្ទឹមគ្នា ក៏ទ្រង់យិតធ្នូរបាញ់តម្រង់ទៅ មិនត្រូវក្អាន់ត្រូវឯព្រះពោធិសត្វ ចំកណ្តៀតក្អម ដួលទៅលើផែនដី ព្រះអង្គទ្រង់ព្រះកន្សែងថា "ឱនរណាអើយ! ចិត្តអាក្រក់អ្វីម្ល៉េះ មកបាញ់ខ្ញុំជាមនុស្សឥតទោស ជាអ្នកបម្រើមាតាបិតាចាស់ជរា ងងឹតព្រះនេត្រទាំងពីរព្រះអង្គ នៅឯអាស្រមឥតនរណាបម្រើសោះ ដូច្នេះ? អ្នកបាញ់នេះមិនស្លាប់តែរូបខ្ញុំម្នាក់ទេ ស្លាប់ទាំងមាតាបិតាខ្ញុំ ទាំងពីររូបទៀតផង ឱ! ខ្ញុំអាសូរមាតាបិតាខ្ញុំណាស់ ពីថ្ងៃនេះទៅឥតមាននរណាបំរើអ្នកឡើយ" ។

ស្តេចបិលយក្សស្តាប់ឮហើយ ក៏មានចិត្តមេត្តាជាខ្លាំងចូលទៅសួរថា "សូមព្រះអង្គអត់ទោសឱ្យខ្ញុំ ខ្ញុំធានាទៅបម្រើមាតាបិតាព្រះអង្គ ជំនួសព្រះអង្គអស់មួយជីវិត" ។ ទូលហើយក៏លាព្រះពោធិសត្វទៅរកអាស្រមព្រះតាបសទាំងពីរ ។ ទៅដល់ហើយស្តេចបិលយក្សឡើងកាន់អាស្រម ដោយស្នូរព្រះបាទាខ្លាំងៗ ។ តាបសទាំងពីរសួរថា "នរណាដើរអីក៏ឮស្នូរខ្លាំងម្ល៉េះ អ្នកមកពីណា?" ។

ស្តេចបិលយក្សជំរាបថា "ខ្ញុំឈ្មោះបិលយក្ស បានបាញ់ក្អាន់ ដែលព្រះសុវណ្ណសាមជាបុត្ររបស់លោក កំពុងបណ្តើរទៅដងទឹកស្រះ តែមិនត្រូវក្អាន់ទៅជាត្រូវព្រះសុវណ្ណសាមទៅវិញ ឥឡូវព្រះអង្គក្ស័យព្រះជន្មទៅហើយ ខ្ញុំមកនេះមកបម្រើលោកទាំងពីរជំនួសព្រះសុវណ្ណសាម.

និមិត្តតែឮសូរពាក្យនេះភ្លាម ព្រះតាបសទាំងពីររូបក៏យំសោកខ្សឹកខ្សួល គួរឱ្យអាណិតអនាថា ។

ថ្លែងឯនាងមណីមេខលា ទេវធីតា ដែលជាអ្នកនៅរក្សាព្រៃនោះទាំងប៉ុន្មាន មកធ្វើសច្ចាប្រណិធាន ជុំវិញព្រះពោធិសត្វ ដែលទ្រង់ផុសទប់បាត់

ស្មារតី ។

ឯតាបសទាំងពីររូបដែលជាមាតាបិតា ឱ្យស្តេចបិលយក្សនាំមកជួបព្រះសុវណ្ណសាមជាបុត្រ ដល់ហើយតាបសទាំងពីរនិងស្តេចបិលយក្សយំសោកសង្រេងសង្រែ ហើយធ្វើសច្ចាប្រណិធានទាំងអស់គ្នាទៅជុំវិញព្រះពោធិសត្វ ។

ដោយអានុភាពនៃសច្ចវាចានោះផង ដោយអានិសង្សនៃកតញ្ញូ-កតវេទិតាធម៌ របស់ព្រះពោធិសត្វផង ពិសសរក៏រម្ងាប់បាត់មុខរបួសក៏សះជា ហើយព្រះពោធិសត្វទ្រង់មានព្រះស្មារតីឡើងវិញ ទ្រង់ក្រាបថ្វាយបង្គំតាបសទាំងពីរជាមាតាបិតាដោយគោរព ហើយនាំមាតាបិតាទៅកាន់អាស្រមវិញដោយសុវត្ថិភាព ។

ឯស្តេចបិលយក្សទទួលកាន់នូវបញ្ចសីល តាមព្រះឱវាទនៃព្រះសុវណ្ណសាមពោធិសត្វ ហើយត្រឡប់ទៅកាន់នគរវិញ ។

នៅទីបំផុតជាតកនេះ ព្រះបរមសាស្តាទ្រង់សំដែងថាកតញ្ញូនិងកតវេទិតាធម៌ មានផលានិសង្សដូចពោលមកនេះហើយ ដែលតថាគតបានត្រាស់ជាព្រះពុទ្ធម្កុដត្រៃភព ក៏ដោយសារកតញ្ញូ និងកតវេទិតាធម៌នោះឯង ។

## ២៧_អានិសង្សសីល

**សីលមាន ៤ ប្រការ :**

ក) និច្ចសីល.

ខ) ឧបោសថសីល.

គ) ទសសីល.

ឃ) បុប្បារិសុទ្ធសីល

**ក) និច្ចសីល មានសិក្ខាបទ ៥ :**

១- វៀរចាកការសម្លាប់.

២- វៀរចាកការលួច.

៣- វៀរចាកការប្រព្រឹត្តខុសក្នុងកាម.

៤- វៀរចាកការភូតកុហក.

៥- វៀរចាកការផឹកសុរានិងមេរ័យជាទឹកស្រវឹង ។

ខ) **ឧបោសថសីល មានសិក្ខាបទ ៨ :**

១- វៀរចាកការសម្លាប់.

២- វៀរចាកការលួច.

៣- វៀរចាកការសេពមេថុន.

៤- វៀរចាកការភូតកុហក.

៥- វៀរចាកការផឹកសុរានិងមេរ័យជាទឹកស្រវឹង.

៦- វៀរចាកការបរិភោគក្នុងពេលថ្ងៃជ្រេពីត្រង់ ទល់នឹងអរុណរះ.

៧- វៀរចាកការច្រៀងរាំដេញដិប្រគំភ្លេង តូរ្យតន្ត្រីដោយខ្លួនឯង ការមើល ការស្ដាប់អ្នកដទៃ និងការទ្រទ្រង់ ការប្រដាប់តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ

៨- វៀរចាកការដេកអង្គុយ លើទីសេនាសនៈធំខ្ពស់ហួសប្រមាណនិងទីសេនាសនៈដ៏ប្រសើរ ។

គ) **ទសសីល មានសិក្ខាបទ ១០ :**

១- វៀរចាកការសម្លាប់.

២- វៀរចាកការលួច.

៣- វៀរចាកការសេពមេថុន.

www.elibraryofcambodia.org

៤- វៀរចាកការភូតកុហក.

៥- វៀរចាកការផឹកសុរានិងមេរ័យ ជាទឹកស្រវឹង.

៦- វៀរចាកការបរិភោគក្នុងពេលថ្ងៃជ្រេពីត្រង់ ទល់នឹងអរុណរះ.

៧- វៀរចាកការច្រៀងរាំ ដេញដំប្រគំភ្លេង និងការមើលនូវល្បែងផ្សេងៗ.

៨- វៀរចាកការទ្រទ្រង់ ការប្រដាប់ និងការតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ.

៩- វៀរចាកការដេកអង្គុយ លើទីសេនាសនៈធំខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ.

១០- វៀរចាកការទទួលកាន់យកនូវមាសនិងប្រាក់ ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យទទួលកាន់យកហើយត្រេកអរចំពោះមាសនិងប្រាក់នោះ ។

**ឃ) ចតុប្បារិសុទ្ធិសីល មាន ៤ :**

១- ឥន្ទ្រិយសំវរសីល សង្រួមឥន្ទ្រិយ ៦.

២- អាជីវបារិសុទ្ធិសីល ចិញ្ចឹមជីវិតបរិសុទ្ធ.

៣- បច្ចយសន្និស្សិតសីល អាស្រ័យបច្ច័យ ៤.

៤- បាតិមោក្ខសំវរសីល សង្រួមក្នុងបាតិមោក្ខ ។

**អធិប្បាយ**

និច្ចសីល ឧបោសថសីល ទសសីល និងចតុប្បារិសុទ្ធសីល លោកចែកជា ២ ប្រភេទ តាមភេទអ្នករក្សា:

១. **និច្ចសីល និងឧបោសថសីល** ជាសីលសម្រាប់ឧបាសក-ឧបាសិការក្សា ហៅថា អាគារិកសីល គឺជាសីលរបស់អ្នកមានផ្ទះ ។

២ **ទសសីល និងចតុប្បារិសុទ្ធិសីល** ជាសីលសម្រាប់ភិក្ខុ

សាមណេរក្សា ហៅថា អនាគារិកសីល គឺជាសីលរបស់អ្នកគ្មានផ្ទះ ។

សីលទាំង ២ ប្រភេទនេះ មានសិក្ខាបទដែលត្រូវសិក្សាត្រូវកាន់តិចច្រើន តឹងធូរ ទាបខ្ពស់ខុសគ្នាជាលំដាប់តាមថ្នាក់ទាបខ្ពស់ ហើយផលានិសង្ស ក៏បានតិចច្រើនទៅតាមថ្នាក់ទាបខ្ពស់នោះៗ គឺនិច្ចសីល ៥ ជាថ្នាក់ទី ១ ទាប ឧបោសថសីល ៨ ជាថ្នាក់ទី ២ កណ្ដាល. ទសសីល ១០ ជាថ្នាក់ទី ៣ កណ្ដាល បតុប្បារិសុទ្ធសីល ៤ ជាថ្នាក់ទី-៤ ខ្ពស់បំផុត ។ សីលទាំង ៤ ថ្នាក់នោះ ទោះបីថ្នាក់ណាក៏ដោយក៏ត្រូវមានសទ្ធាជាមូលដ្ឋាន សម្រេចដោយសទ្ធា (សេចក្ដីជឿ) ទាំងអស់ព្រោះការបញ្ញត្តិសិក្ខាបទក្នុងសីលនោះៗ មិនមែនជាសាវកវិស័យទេ គឺជាពុទ្ធវិស័យដោយពិត ។ ហេតុដូច្នេះ អ្នកកាន់សីលលុះតែជឿចំពោះពុទ្ធប្បញ្ញត្តិដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តចំពោះសិក្ខាបទនោះៗ ទើបញ៉ាំងសីលនោះៗ ឱ្យបរិសុទ្ធទៅបាន ។

សីលដែលបុគ្គលបានរក្សាឱ្យបរិសុទ្ធហើយ តែងបានអានិសង្ស៥យ៉ាងគឺ

១. អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ អ្នកមានសីល រមែងបានជួបប្រទះនិងគំនរភោគៈយ៉ាងធំព្រោះមានសេចក្ដីមិនប្រមាទជាហេតុ.

២. កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិត្តិស័ព្ទដ៏ល្អរមែងលាន់ឮខ្ចរខ្ចាយ.

៣. វិសារទោ ឧបសង្កមតិ អមង្កុភូតោ អ្នកមានសីលទោះបីចូលទៅកាន់ចំណោមបរិស័ទណា រមែងក្លៀវក្លាអង់អាចមិនមានមុខស្រយុង.

៤. អសម្មូឡ្ហោ កាលំ ករោតិ អ្នកមានសីល រមែងមិនវង្វេង

www.elibraryofcambodia.org

ទៅពេលស្លាប់.

៥. កាយស្ស ភេទា បរម្មរណា សុគតី សគ្គំ លោកំ ឧបបជ្ជតិ អ្នកមានសីល លុះទម្លាយរាងកាយ បន្ទាប់ពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

ព្រោះការរក្សាសីល មានផលានិសង្សដូចពោលមកនេះ ទើបលោកថា: អ្នកណារក្សាសីលណា១ ដើម្បីញុំាងសីលនោះ១ របស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនបរិសុទ្ធ ត្រូវជឿស្ដាប់តាមព្រះពុទ្ធឱវាទដែលទ្រង់ដាស់តឿនក្នុងកិច្ចរក្សាសីលនោះ១ថា

កិកីវ អណ្ឌំ ចាមរីវ វាលធី បិយំវ បុត្តំ នយនំវ ឯកកំ

តថេវ សីលំ អនុរក្ខមានកា សុបេសលា ហោថ សទាសគារវា

សត្វត្រដេវរ៉ុច រក្សាស៊ុតយ៉ាងណាមិញ សត្វចាមរីរក្សាកន្ទុយយ៉ាងណាមិញ មាតាថ្នមបុត្រជាទីស្រឡាញ់យ៉ាងណាមិញ មនុស្សខ្វាក់ភ្នែកម្ខាងប្រុងរក្សាភ្នែកយ៉ាងណាមិញ. អ្នក (រក្សាសីល) ទាំងឡាយចូររក្សាសីលឱ្យដូចយ៉ាងនោះ ហើយចូរជាបុគ្គលមានសីលជាទីស្រឡាញ់ល្អ មានសេចក្ដីគោរពគ្រប់កាលចុះ ។

## រឿងព្រះនាគសេនថ្វាយព្រះពរក្រុងមិលិន្ទ

អ្នករក្សាសីល ត្រូវបង្អោនចិត្តគិតតាមន័យដែលព្រះនាគសេនថ្វាយព្រះពរក្រុងមិលិន្ទថា:

"បពិត្រមហារាជ! ភិក្ខុអ្នកខ្លាចភ័យក្នុងវដ្ដសង្សារ ប្រាថ្នានឹងធ្វើសេចក្ដីសង្រួមក្នុងបាតិមោក្ខសំវរសីលឱ្យបរិបូណ៌ ត្រូវគិតយកទំនងតាមអង្គនៃសត្វ

កណ្ឌៀវ. បពិត្រមហារាជ ! ធម្មតាកណ្ឌៀវរមែងយកដីមកពូនធ្វើដំបូលខាងលើ ជាដំបូក បិទបាំងខ្លួនសម្ងំនៅខាងក្នុងនោះ ហើយត្រេចស្វែងរកអាហារយ៉ាងណាមិញ. ព្រះយោគាវចរ ត្រូវយកសីលមកធ្វើជាដំបូលគ្រឿងបិទបាំង គឺសង្រួមក្នុងសីលយកសីលមកបិទបាំងចិត្តសិនហើយសឹមត្រេចទៅរកបង្ហាន់បិណ្ឌបាតយ៉ាងនោះចុះ ព្រោះព្រះយោគាវចរដែលតែងរួចចាកភ័យទាំងពួងដោយសារគ្រឿងប្រក់គ្រឿងបិទបាំង គឺការសង្រួមក្នុងសីល ដូចជាកណ្ឌៀវតែងរួចចាកសេចក្ដីអន្តរាយ ដោយសារដំបូកដូច្នោះ ។

បពិត្រមហារាជ! សេចក្ដីនេះសមដូចសាវកភាសិតដែលព្រះឧបសេនត្ថេរវង្គន្តបុត្រលោកពោលថា:

សីលសំវរឆទនំ យោគី កត្វាន មានសំ
អនុបលិត្តោ វិហរតិ ភយា សោ បរិមុច្ចតិ ។

យោគីដែលធ្វើគ្រឿងប្រក់ គ្រឿងបិទបាំង គឺប្រព្រឹត្តសង្រួមក្នុងសីល ហើយបិទបាំងចិត្តទុកឱ្យល្អ ជាអ្នកមិនជាប់ចំពាក់ដោយកិលេសរមែងរួចស្រឡះចាកភ័យ ។

បុគ្គលអ្នកប្រាថ្នាសម្បត្តិសួគ៌ ឬសម្បត្តិព្រះនិព្វាន ដែលនឹងសម្រេចដូចប្រាថ្នាបាន ក៏ព្រោះតែការប្រតិបត្តិ មិនមែនសម្រេចដោយគ្រាន់តែសុំប្រាថ្នា ឬដោយគ្រាន់តែមាត់រង្វាវប៉ុណ្ណោះទេ ។ ឯការប្រតិបត្តិគុណធម៌ ក្នុងលទ្ធិសាសនានោះសោត មានច្រើនថ្នាក់ តែលោកពោលថា គុណធម៌ គឺសីលជាថ្នាក់ដើមបំផុត. សីល លោកទុកដូចភូមិផែនដី គុណធម៌ដទៃៗ ទុកដូចពូជ មានផែនដីគឺសីលបរិបូណ៌ហើយ ទើបពូជធារ គឺគុណធម៌ដទៃៗ អាចលូត

លាស់ដុះដាល ចម្រើនឡើងជាលំដាប់ទៅបាន ។

សេចក្ដីនេះ សមដូចពុទ្ធភាសិតដែលទ្រង់សំដែងថា:

សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិដែលសីលអប់រំហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។

សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាដែលសមាធិអប់រំហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។

បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ ចិត្តដែលបញ្ញាអប់រំហើយ តែងរួចស្រឡះចាកអាសវៈទាំងឡាយដោយប្រពៃមែនពិត ។

អ្នកបរិបូណ៌ដោយសីល រមែងមានសេចក្ដីត្រជាក់ចិត្តជាថ្នាក់ៗ ឡើងទៅ ដូចព្រះបរមសាស្ដាជាម្ចាស់ទ្រង់ត្រាស់ទេសនាសរសើរអានិសង្សសីលថា:

សីលមានប្រយោជន៍ឱ្យកើតសំវរៈ (ការសង្រួម) ការសង្រួមមានប្រយោជន៍មិនឱ្យមានវិប្បដិសារៈ (សេចក្ដីក្ដៅក្រហាយចិត្ត) ការមិនមានវិប្បដិសារៈមានប្រយោជន៍ឱ្យកើតបាមោជ្ជ (សេចក្ដីរីករាយចិត្ត). បាមោជ្ជមានប្រយោជន៍ឱ្យកើតបីតិ (សេចក្ដីឆ្អែតចិត្ត) បីតិមានប្រយោជន៍ឱ្យកើតបស្សទ្ធិ (សេចក្ដីស្ងប់រម្ងាប់ចិត្ត) បស្សទ្ធិមានប្រយោជន៍ឱ្យកើតសុខៈ (សេចក្ដីស្រួលចិត្ត). សុខមានប្រយោជន៍ឱ្យកើតសមាធិ (សេចក្ដីដំកល់ចិត្តមាំទាំក្នុងកុសលធម៌) សមាធិមានប្រយោជន៍ឱ្យកើតយថាភូតញ្ញាណទស្សនៈ (សេចក្ដីយល់ឃើញដឹងច្បាស់នូវសភាវធម៌ទាំងពួងតាមពិត) យថាភូតញ្ញាណទស្សនៈមានប្រយោជន៍ឱ្យកើតនិព្វិទា (សេចក្ដី-

www.elibraryofcambodia.org

នឿយណាយក្នុងសង្ខារ) និព្វិទាមានប្រយោជន៍ឱ្យកើតវិរាគៈ (សេចក្តីប្រាសចាកតម្រេក) វិរាគៈមានប្រយោជន៍ឱ្យបានវិមុត្តិ (សេចក្តីរួចស្រឡះចាកកិលេស). វិមុត្តិមានប្រយោជន៍ឱ្យបានវិមុត្តិញ្ញាណទស្សនៈ (សេចក្តីយល់ឃើញដឹងច្បាស់ថាបានវិមុត្តិ). វិមុត្តិញ្ញាណទស្សនៈមានប្រយោជន៍ឱ្យបានអនុបាទាបរិនិព្វាន (ការរំលត់ទុក្ខដោយអស់សេចក្តីប្រកាន់មាំ) ។

ម្យ៉ាងទៀត ទ្រង់ត្រាស់ថា:

ឥជ្ឈតិ ហិ ភិក្ខវេ សីលវតោ ចេតោ បណិធិ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដែលតាំងនៅក្នុងចិត្តអ្នកមានសីលរមែងបានសម្រេចដូចបំណង ។

ព្រោះមានពុទ្ធភាសិតដូច្នេះបានជា ក្នុងទីបំផុតនៃការសមាទានសីល លោកអ្នកឱ្យសីលតែងសំដែងអានិសង្សសីលប្រាប់អ្នកសមាទានសីល ហើយទូន្មានឱ្យអប់រំឱ្យដុសខាត់សម្អាតសីលថា:

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ឬ

សត្វទាំងឡាយបានសុគតិ ព្រោះសីល បានភោគព្រោះសីល បានរំលត់ទុក្ខព្រោះសីល ហេតុនោះ អ្នកសមាទានសីលគប្បីជម្រះសីលឱ្យបរិសុទ្ធចុះ ។

អធិប្បាយ

ជនដែលបានរក្សាសីលបរិសុទ្ធ តែងបានសុខក្នុងឋានមនុស្ស ឋានទេវតា និងព្រះនិព្វាន. ជនដែលមិនរក្សាសីល តែងបានទុក្ខក្នុងឋានមនុស្ស និងអបាយភូមិ ៤ គឺនរក ប្រេត អសុរកាយ និងតិរច្ឆាន ។

ទីនេះអធិប្បាយអំពីតួ ឬប្រភព អំពីវិរតី (ការវៀរ) និងអានិសង្សនៃកិច្ចសីល ដោយសង្ខេបដូចតទៅ :

មានពុទ្ធភាសិតបញ្ជាក់ពីតួសីលថា **ចេតនាហំ ភិក្ខវេ សីលំ វទាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួសីល ឬជាប្រភព គឺដើមកំណើតនៃសីល ។

អធិប្បាយថា ពិតមែនតែការរក្សាសីល គឺការរក្សាកាយនិងវាចាមិនមែនជាការរក្សាចិត្តទេ តែបើចិត្តមិនផ្តើមឡើង ក៏កាយនិងវាចាមិនអាចរក្សាបានជាដាច់ខាត ព្រោះមានពុទ្ធភាសិតក្នុងធម្មបទ ខុទ្ទកនិកាយថា:

**មនោបុព្វង្គមា ធម្មា** ធម៌ទាំងឡាយ មានចិត្តដល់មុនជាប្រធាន ។

តាមសេចក្តីក្នុងពុទ្ធភាសិតនេះ ឃើញថាកាលជនទាំងឡាយជាអ្នករក្សាសីល មានសីល ៥ ជាដើម ពេលកំពុងសមាទានសិក្ខាបទនោះ នៅជាសីលបណ្តោះអាសន្ននៅឡើយទេ លុះតែសមាទានហើយ អ្នកសមាទាននោះបានជួបនឹងសត្វគួរសម្លាប់មិនសម្លាប់ ជួបនឹងទ្រព្យគេគួរលួចមិនលួច ជួបនឹងស្រីគួរប្រព្រឹត្តកាមមេសុមិច្ឆាចារមិនប្រព្រឹត្ត ជួបនឹងពាក្យគួរភូតមិនភូត ជួបនឹងសុរាគួរផឹកមិនផឹក ទើបបានជាសីលស្ថាពរ ។

សេចក្តីនេះបានន័យថា និច្ចសីលគឺសីល ៥ ដែលត្រូវរក្សាជានិច្ចមិនបាច់សមាទានអំពីបុគ្គលដទៃ គ្រាន់តែតាំងចិត្តថាជាអ្នករក្សាសិក្ខាបទទាំង ៥ ហើយវៀរចាកគ្រប់អំពើអាក្រក់ទាំង ៥ យ៉ាង មានការសម្លាប់ជាដើម ខ្លួនឯងទៅក៏បានជាសីលពិតប្រាកដ ។ ការដែលសមាទានអំពីជនដទៃនោះគ្រាន់តែពោលប្រាប់គេថាខ្លួនបានរក្សាសិក្ខាបទនេះមួយៗ ឱ្យគេជួយជាសាក្សីប៉ុណ្ណោះ

www.elibraryofcambodia.org

ត្រង់ការរក្សាសិក្ខាបទនោះ ៗ ស្រេចនៅលើខ្លួនឯងផ្ទាល់ មិនមែនឱ្យសីល នោះគេជួយរក្សាជួសបានទេ ប៉ុន្តែបើនិយាយពីវិរតិ (ការវៀរ) វិញ លោក ពោលថាមាន ២ យ៉ាងគឺ

១-សម្បត្តវិរតិ ការវៀរចាកដោយការដល់ព្រម គឺតាំងចិត្តដោយ ខ្លួនឯង.

២-សមាទានវិរតិ ការវៀរចាកដោយសមាទានពីជនដទៃ ។

តាមន័យនេះបានសេចក្ដីថា កាន់និច្ចសីលដោយខ្លួនឯងក៏បាន ដោយ សមាទានអំពីជនដទៃក៏បាន. ប៉ុន្តែបើនិយាយឱ្យងាយស្ដាប់ ការកាន់ដោយ តាំងចិត្តខ្លួនឯងនិងការកាន់ដោយចាំសមាទានពីជនដទៃសិន ហើយសឹមកាន់ ជាក្រោយ បានផលានិសង្សប្លែកគ្នាបន្តិច គឺការសមាទានអំពីភិក្ខុឬសាមណេរ តាមប្រពៃណីក្នុងសម័យបច្ចុប្បន្ននេះ ដែលមានការនមស្សការព្រះរតនត្រ័យ និងសមាទានព្រះត្រៃសរណគមន៍ជាមុន ទើបសមាទានសីលជាក្រោយនោះ បានផលច្រើនជាងការកាន់ដោយខ្លួនឯង មិនបាច់សមាទាន ។

មួយទៀត ពេលមុនសមាទានគេតែងថ្វាយសក្ការៈចំពោះព្រះរតនត្រ័យ ហើយក្រោយសមាទានគេតែងប្រគេនចង្ហាន់ព្រះសង្ឃ ។ ការថ្វាយគ្រឿង សក្ការៈ និងការប្រគេនចង្ហាន់ ក្នុងពេលសមាទាននេះហើយជាកិច្ចដែលនាំឱ្យ ការវៀរចាកបញ្ចវេរា គឺការកាន់សីល ៥ ដោយសមាទានវិរតិនោះ បានផល ច្រើនជាងសម្បត្តវិរតិនោះឯង ។

ឯការកាន់សីល ៥ ដោយសម្បត្តវិរតិ មានអានិសង្សដូចសំដែងដោយ

សង្ខេបតទៅនេះ :

## រឿងនាងសុជាតា

ក្នុងកាលកន្លងរលងទៅយូរហើយ បុរសម្នាក់ឈ្មោះមាឃមាណពមាន ភរិយា ៤ នាក់ ទី ១ ឈ្មោះសុជាតា ទី ២ ឈ្មោះសុធម្មា ទី ៣ ឈ្មោះសុនន្ទា ទី ៤ ឈ្មោះសុចិត្រា ។

មាឃមាណពបានសាងផ្លូវថ្នល់ សាងសាលាសំណាក់ ។ នាងសុធម្មាបាន សាងហោជាងសាលាជាមួយស្វាមី ។ នាងសុនន្ទាបានធ្វើសួនច្បារក្បែរសាលា នាងសុចិត្រាបានជីកស្រះក្បែរសាលា ។ ឯនាងសុជាតា ដោយអាងថាខ្លួនជា បងប្អូននឹងស្វាមីផង ជាភរិយាទី ១ ផង គិតតែពីតែងខ្លួនផ្គាប់ចិត្តប្តី គ្មានធ្វើ ការកុសលអ្វីសោះ ដោយគិតថាប្តីធ្វើហើយមុខជាបានផលដល់ខ្លួនដែរ ។

លុះមាឃមាណពស្លាប់ពីមនុស្សលោកទៅ បានទៅកើតជាព្រះឥន្ទនៅ ឋានត្រៃត្រឹង្សសួគ៌ ។នាងសុធម្មា សុនន្ទា សុចិត្រាក៏បានទៅកើតជាព្រះទេពី ព្រះឥន្ទក្នុងឋាននោះដែរ ។

ឯនាងសុជាតាទៅកើតជាកុកញី នៅមាត់ទឹកក្បែរជើងភ្នំ ១

កាលមាឃមាណពបានកើតជាព្រះឥន្ទភ្លាម ទ្រង់ឃើញតែភរិយា ៣ នាក់ បាត់នាងសុជាតា ទ្រង់បើកទិព្វចក្ខុតមើលមកឋានមនុស្ស ឃើញនាងកើតជា កុកញី ហើយទ្រង់មកយកនាងទៅកាន់ត្រៃត្រឹង្ស ។ នាងសុជាតាបានឃើញ សម្បត្តិព្រះឥន្ទ នឹងឃើញនាងទាំង ៣ នាក់ គេបានទៅកើតជាមួយស្វាមី ក៏ទឹក ខ្មាស់គេជាខ្លាំង ឱ្យព្រះឥន្ទយកមកទុកឯជើងភ្នំវិញ ។ លុះព្រះឥន្ទយកទៅដាក់ ឯជើងភ្នំហើយទ្រង់ទូន្មានថា "បើនាងចង់ទៅកើតជាទេពធីតានៅឋានសួគ៌ជា មួយយើង ត្រូវនាងកាន់ សីល កុំស៊ីត្រីរស់" ។ នាងកុកក៏កាន់សីលតាម ។ ពេល

ក្រោយព្រះឥន្ទចុះមកល្បងចិត្តនាងកុកមើល ទ្រង់ឃើញនាងឈរនៅមាត់ទឹក ចាំចឹកត្រីងាប់បរិភោគ ទ្រង់និម្មិតជាត្រីងាប់ ១ អណ្តែតមកចំពីមុខនាង ។ នាងកុកឃើញត្រីងាប់ក៏ស្ទុះទៅប្រាថ្នានឹងចឹកប្រាថ្នាបរិភោគ តែព្រះឥន្ទធ្វើជាត្រីរស់វិញ នាងក៏ឈប់ចឹកទៅ ឈររង់ចាំត្រីងាប់តទៅទៀត ។

ដោយអំណាចអានិសង្សសីលនោះ ស្លាប់ពីនាងកុកទៅនាងសុជាតាបានទៅកើតជាកូនស្ទូនឆ្នាំងនៅស្រុកមួយ ។ ព្រះឥន្ទទ្រង់ជ្រាបទ្រង់និម្មិតជាអ្នកបររទេះដឹកត្រឡាចល្ពៅ ដែលជាមាសប្រាក់សុទ្ធៗ តែអ្នកផងមើលឃើញជាត្រឡាចល្ពៅមែនៗ ។ អ្នកដឹកត្រឡាចល្ពៅសួរអ្នកស្រុកថា "នៅទីនេះមាននរណាកាន់សីល ៥ ទេ" ។ អ្នកស្រុកប្រាប់ថា "នាងកុលធីតាកូនស្ទូនឆ្នាំង កាន់សីល ៥ បរិសុទ្ធណាស់" ។ អ្នកបររទេះក៏យកត្រឡាចល្ពៅនោះដូរយកឆ្នាំងក្អមរបស់នាងកុលធីតានោះ ។

ដោយអំណាចផលនៃសីលនោះ នាងកុលធីតាស្លាប់ពីនោះ បានទៅកើតជាបុត្រនៃព្រះបាទវេបចិត្តិ ស្តេចអសុរនៅជើងភ្នំព្រះសុមេរុឈ្មោះនាងសុជាតា ។ នាងមានរូបឆោមល្អលើសអសុរកញ្ញាទាំងពួងក្នុងអសុរពិភព ។ លុះនាងមានព្រះជន្ម ១៦ ឆ្នាំ ព្រះបាទវេបចិត្តិស្តេចធ្វើពិធីរើសស្វាមីឱ្យបុត្រី បើនាងស្រឡាញ់អសុរណា ឱ្យបោះភួងផ្កាទៅលើអសុរនោះ ។

សក្កទេវរាជបានជ្រាបដូច្នោះ ក៏ទ្រង់ធ្វើជាអសុរចាស់កាន់ឈើច្រត់ដើរចូលទៅឈរប្រឡងរូប ក្នុងចំណោមអសុរកម្លោះនោះដែរ ។

កាលទីប្រជុំបានជួបជុំហើយ នាងសុជាតាដើរពិនិត្យមើលពួកអសុរ ដែលឈរដឹកង់ជុំវិញនោះ នាងឥតស្រឡាញ់នរណាសោះ ស្រឡាញ់តែអសុរចាស់ គឺព្រះឥន្ទដែលជាព្រះស្វាមីនាងពីជាតិមុន ហើយនាងបោះកម្រងផ្កាទៅលើព្រះ

www.elibraryofcambodia.org

ហត្ថព្រះឥន្ទ្រ ទ្រង់កម្រងផ្កានោះហើយពាយកនាងទៅឋានត្រៃត្រឹង្សភ្លាមទៅ ។

នាងសុជាតាក៏បានជាព្រះទេពីធំនៃព្រះឥន្ទ្រនៅឋានត្រៃត្រឹង្សហៅថានាងអសុរកញ្ញាតាំងពីនោះរហូតមកដល់សព្វថ្ងៃ ។

នេះជាអានិសង្សនៃសីល ៥ដែលជាសម្បត្តិវិរតិ វៀរចាកបញ្ចវេរា ៥ ដោយតាំងចិត្តខ្លួនឯងមិនបាច់សមាទានពីអ្នកដទៃ ។

ព្រោះហេតុនាងកុក បានទៅឃើញសម្បត្តិទិព្វរបស់ព្រះឥន្ទ្រក្នុងឋានត្រៃត្រឹង្ស ហើយត្រឡប់មកចាំរក្សាសីល ៥ ដោយប្រាថ្នាចង់ទៅកើតក្នុងឋាននោះ បានសម្រេចដូចក្តីប្រាថ្នាមែន ទើបមានពុទ្ធភាសិតថា:

ឥជ្ឈតិ ហិ ភិក្ខវេ សីលវតោ ចេតោ បណិធិ

ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដែលតាំងនៅក្នុងចិត្តអ្នកមានសីល រមែងបានសម្រេចដូចបំណងមែនពិត ពុំខានឡើយ ។

## ២៨_អានិសង្សការនៅក្នុងទីស្ងាត់

ព្រៃភ្នំឬព្រៃឈើ ដែលផុតពីស្រុកនិងឧបចារនៃស្រុកដែលប្រកបដោយពួកឈើធំតូច ឬរុក្ខមូល(គល់ឈើ)និងសុញ្ញាគារដ្ឋាន(ផ្ទះទំនេរឥតមនុស្សនៅ) ដោយហោចទៅសូម្បីតែកុដិ (ខ្ទម) តូចៗ ដែលសង់ក្នុងទីស្ងាត់សម្រាប់ជាទីចម្រើនសមណធម៌. ទីរំបាលនេះជាដើមក៏ហៅថាទីដេក ទីអង្គុយដ៏ស្ងាត់ ។

ធម្មតាព្រៃភ្នំរមែងជាទីស្រួល គួរឱ្យសរសើរច្រើនយ៉ាង ទើបជាទីត្រេកអររបស់ពួកយោគី តែពួកយោគីដែលចូលទៅនៅក្នុងព្រៃនោះ គួរបង្អោនចិត្តគិតប្រៀបធៀបព្រៃ ហើយនិងចិត្តរបស់ខ្លួនតាមន័យដែលព្រះនាគសេនត្ថេរ សំដែងពីអង្គនៃព្រៃធំមាន ៥ ថ្វាយព្រះបាទមិលិន្ទដូចខាងមុខនេះ គឺ

១- ព្រៃធំជាទីបិទបាំងទុក នូវមនុស្សដែលមិនស្អាតបាន ដូចម្តេចមិញ. ព្រះយោគាវចរក៏គប្បីបិទបាំងទុក នូវទោសកំហុសសេចក្តីភ្លាំងភ្លាត់របស់អ្នកដទៃ ឱ្យដូចជាព្រៃធំដែលបិទបាំងទុក នូវមនុស្សដែលមិនស្អាតដូច្នោះ.

២- ព្រៃធំជាទីសោះសូន្យទទេ ឥតមនុស្សទៅមកដូចម្តេចមិញ. ព្រះយោគាវចរក៏គប្បីជាអ្នកសូន្យចាកកិលេសទាំងពួង គឺរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ដែលជាបណ្តាញចាក់ស្រេះនៅក្នុងសន្តានឱ្យដូចជាព្រៃដែលសូន្យចាកមនុស្សដូច្នោះ.

៣- ព្រៃធំ ជាទីស្ងាត់ជ្រងំ ដូចម្តេចមិញ ព្រះយោគាវចរក៏គប្បីជាអ្នកស្ងាត់ចាកពួកអកុសលធម៌ដ៏លាមក ដែលជាចិត្តរបស់បុថុជ្ជន មិនមែនជាចិត្តព្រះអរិយៈ ឱ្យដូចជាព្រៃធំដែលស្ងាត់ជ្រងំដូច្នោះ.

៤- ព្រៃធំ ជាទីស្ងាត់រម្ងាប់ ជាទីបរិសុទ្ធដូចម្តេចមិញ. ព្រះយោគាវចរក៏គប្បីជាអ្នកមានចិត្តស្ងប់រម្ងាប់បរិសុទ្ធ គប្បីជាអ្នករលត់នូវមានះ (សេចក្តីប្រកាន់) មក្ខៈ (សេចក្តីលុបគុណលោក) ឱ្យដូចជាព្រៃធំដែលស្ងប់រម្ងាប់-បរិសុទ្ធដូច្នោះ.

៥-ព្រៃធំ ជាទីសេពគប់របស់ពួកអរិយជន ដូចម្តេចមិញ ព្រះយោគាវចរក៏គប្បីធ្វើខ្លួនឱ្យជាទីសេពគប់របស់អរិយជនដូច្នោះ ។

ការនៅអាស្រ័យក្នុងព្រៃស្ងាត់ រមែងគួរដើម្បីបាននូវសមាធិដែលមិនទាន់បាន និងគួរដើម្បីរក្សាទុកនូវសមាធិដែលបានហើយ ។ ហេតុដូច្នោះ ទើបព្រះបរមសាស្តាទ្រង់ត្រាស់សរសើរភិក្ខុអ្នកកាន់អារញ្ញិកធុតង្គថា ម្នាលភិក្ខុទាំងឡាយ ! តថាគតមានហឫទ័យរីករាយ ចំពោះនាគិតភិក្ខុពន់ពេក ព្រោះនាគិតភិក្ខុនោះ .ជាអ្នកកាន់អារញ្ញិកធុតង្គនៅក្នុងព្រៃ អារម្មណ៍ គឺរូប សម្លេង

ក្លិន រស សម្ផស្ស មិនអាចញ៉ាំងភិក្ខុដែលនៅក្នុងទីសេនាសនៈដ៏ស្ងាត់ដូចនាតិត ភិក្ខុនោះឱ្យរវើរវាយឡើយ ។ ភិក្ខុដែលនៅក្នុងសេនាសនៈដ៏ស្ងាត់នោះ តែង ប្រាសចាកសេចក្ដីរន្ធត់ចិត្ត ហើយរមែងលះបង់នូវអាល័យក្នុងជីវិតបាន ត្រេក អរតែនឹងរសនៃសេចក្ដីសុខដែលកើតអំពីវិវេក ។ មួយទៀត សភាវៈដែល ទ្រទ្រង់នូវធុតង្គមានបំសុកូលិកង្គជាដើម ក៏សមគួរដល់ភិក្ខុជាអ្នកកាន់អារញ្ញិ-កធុតង្គនោះដែរ ។

ព្រះពុទ្ធឃោសាចារ្យ អ្នករចនាគម្ពីរវិសុទ្ធិមគ្គលោកនិពន្ធថា សរសើរ អានិសង្សនៃភិក្ខុអ្នកកាន់អារញ្ញិកធុតង្គមានសេចក្ដីថា:

"ព្រះយតិយោគី អ្នកកាន់អារញ្ញិកធុតង្គជាប្រក្រតី ដែលត្រេកអរក្នុង ទីសេនាសនៈដ៏ស្ងាត់ មិនច្របូកច្របល់ដោយគ្រហស្ថ ឬបព្វជិតត្រេកអរក្នុង អារញ្ញិកសេនាសនៈ រមែងញ៉ាំងព្រះហឫទ័យ នៃព្រះបរមលោកនាថឱ្យទ្រង់ រីករាយដោយកិរិយានៅក្នុងព្រៃនោះបាន មិនតែប៉ុណ្ណោះព្រះយោគាវចរណា មួយ កាលនៅក្នុងអារញ្ញប្រទេស រមែងបាននូវរសដែលកើតអំពីសេចក្ដីសុខ ឯណា. ទុកជាទេពតា មានព្រះឥន្ទជាប្រធានក៏មិនបាននូវរសនៃសេចក្ដីសុខ នោះដូចលោកដែរ ។ ព្រះយោគាវចរនុះឯង កាលបើលោកទ្រទ្រង់នូវបំសុកូ-លិកធុតង្គ ក៏ប្រៀបដូចជាព្រះបរមក្សត្រទ្រង់គ្រឿងក្រោះ ឋិតនៅលើផែនដី ដែលជាទីធ្វើសង្គ្រាម ព្រះហស្ថឆ្វេង-ស្ដាំង ទ្រង់នូវអាវុធធ្វើយុទ្ធនាការ ពោល គឺទ្រទ្រង់នូវធុតង្គ ក្រោយពីនោះ មិនយូរប៉ុន្មានក៏អាចផ្ចាញ់មារព្រមទាំងពល ពាហនៈ គឺកិលេសទាំងធំទាំងតូចបាន" ។

ការនៅទៀបគល់ឈើមានគុណប្រយោជន៍ ១០ យ៉ាង គឺ:

១- មានសេចក្ដីប្រុងប្រៀបតិច.

២- មិនបាច់ថែទាំទីលំនៅ ព្រោះអាស្រ័យនៅតែម្តងម្កាល.

៣- មិនបាច់រវល់ទទួលភ្ញៀវ.

៤-. មិនលាក់បំពួនទូវគ្រឿងដែលគួរតិះដៀល គឺមិនមានទូវណាធ្វើអាក្រក់ក្នុងទីដែលបើកឱកាសដូច្នោះបាន.

៥- មិនបាច់ប្រយ័ត្នខ្លួនក្រែងអន្តរាយដូចនៅកណ្តាលវាល.

៦- មិនបាច់ធ្វើសេចក្តីគ្រប់គ្រង គឺមិនបាច់រវល់ហួងហែង ឬឃាត់មនុស្សដែលនឹងមកសំណាក់អាស្រ័យ.

៧- បោះបង់សេចក្តីអាល័យ ក្នុងទីលំនៅបាន.

៨- មិនមានទូវណាបណ្តេញ ឬដណ្តើមយកទីកន្លែង.

៩- ចង់នៅក៏នៅសប្បាយតាមសេចក្តីពេញចិត្ត.

១០- មិនបាច់ស្តាយ ព្រោះនៅត្រង់ណាក៏អាចរកទីសេនាសនៈគល់ឈើបានងាយ ។

ការនៅទៀបគល់ឈើជាការប្រព្រឹត្តសមគួរដល់និស្ស័យព្រោះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា អ្នកបួសត្រូវអាស្រ័យនៅទៀបគល់ឈើជាសេនាសនៈ ។

ភិក្ខុអ្នកទ្រទ្រង់រុក្ខមូលធុតង្គ ជាអ្នកប្រព្រឹត្តនាំឱ្យព្រះដ៏មានព្រះភាគទ្រង់សរសើរថា បច្ច័យនឹងកើតដល់ភិក្ខុនោះតិច តែបានដោយងាយឥតមានទោស ជាទំនងឱ្យកើតអប្បិច្ឆតាគុណ គឺសេចក្តីប្រាថ្នាតិច ។

មិនតែប៉ុណ្ណោះ អនិច្ចសញ្ញានឹងកើតឡើងដល់ព្រះយោគាវចរភិក្ខុនោះព្រោះហេតុបានជួបប្រទះនូវវិការៈនៃដើមឈើរឿយៗ ប្រាសចាកសេចក្តីកំណាញ់ក្នុងសេនាសនៈ ប្រាសចាកសេចក្តីត្រេកអរក្នុងនវកម្ម (ការងារថ្មី)

ទៅមួយរុក្ខទេវតាហើយប្រព្រឹត្តទៅតាមគុណធម៌ទាំងឡាយ មានអប្បិច្ឆតាគុណធម៌ជាប្រមាណ ។

មួយទៀត លោកសរសើរអានិសង្សនៃភិក្ខុអ្នកកាន់រុក្ខមូលិកង្គធុតង្គមានសេចក្តីថា:

លំនៅនៃបុគ្គលអ្នកស្ងាត់ ព្រះដ៏មានបុណ្យទ្រង់សរសើរថា "ជាទីសមគួរដល់និស្ស័យ. បណ្តាទីស្ងាត់ រកទីណាឱ្យស្មើនឹងរុក្ខមូលនេះគ្មាន ភិក្ខុដែលទ្រទ្រង់រុក្ខមូលិកធុតង្គជាប្រក្រតី រមែងនាំបង់នូវអាវាសមច្ឆរិយៈ (សេចក្តីកំណាញ់ក្នុងអាវាស) បាន. ធម្មតាភិក្ខុដែលមានវត្តប្រតិបត្តិល្អ កាលបើនៅក្នុងទីស្ងាត់ គឺរុក្ខមូលដែលទេវតារក្សាហើយ កាលបើឃើញដើមឈើស្លឹកខៀវខ្ចីនិងមានស្លឹកទុំក្រហម ដែលជ្រុះចាកទង តែងបន្ទោបង់នូវនិច្ចសញ្ញា (សេចក្តីសំគាល់ថាទៀង) ចេញបាន ព្រោះហេតុនោះ បានជាភិក្ខុដែលប្រកបដោយវិចារណបញ្ញាត្រេកអរក្នុងការភាវនា មិនត្រូវមើលងាយរុក្ខមូល សេនាសេនៈដ៏ស្ងាត់ដែលជាទ្រព្យមតិក របស់ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូទ្រង់ប្រទានទុកឱ្យនេះឡើយ" ។

ព្រោះការនៅអាស្រ័យក្នុងទីសេនាសនៈ ដ៏ស្ងាត់ទាំងឡាយមានរុក្ខមូលជាដើម ជាទីប្រកបដោយប្រយោជន៍ច្រើន ដូចពណ៌នាមកនេះ បានជាក្នុងអនុសាសនវិធី ដែលហៅថា "ផ្តាំនាគ" ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់បង្គាប់ឱ្យភិក្ខុប្រៀនប្រដៅភិក្ខុបួសថ្មី ក្នុងវេលាចប់ញត្តិចតុត្ថកម្មវាចាភ្លាមថា:

**រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ** អ្នកបួសអាស្រ័យនៅទៀបគល់ឈើជា

សេនាសនៈ (ទីដេកអង្គុយ) សេចក្ដីឧស្សាហ៍ក្នុងការអាស្រ័យនៅដោយរុក្ខ-មូលសេនាសនៈនោះ អ្នកគប្បីធ្វើដរាបដល់អស់ជីវិត ។

ដោយហេតុរុក្ខមូលសេនាសនៈ រមែងជាទីមនោរម្យរបស់ព្រះយោគីអ្នកប្រាថ្នាសេចក្ដីស្ងប់ រម្ងាប់ចិត្តជាធម្មតា ទើបព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើងទ្រង់ប្រសូត ក្នុងលុម្ពិនីវនឧទ្យានទ្រង់ត្រាស់ដឹងព្រះអនុត្តរសម្មោធិញ្ញាណនារុក្ខមូល គឺទៀបគល់ពោធិព្រឹក្ស. ទ្រង់រំលត់ខន្ធបរិនិព្វានក្នុងសាលវនោទ្យាន ក្រោមលម្វែកសាលព្រឹក្សទាំងគូ. សុទ្ធតែក្នុងព្រៃជាទីស្ងាត់ទាំងអស់ ។

ការអាស្រ័យនៅក្នុងសេនាសនៈដ៏ស្ងាត់ព្យាយាមចម្រើនសមណធម៌ ជាឧបការៈឱ្យបន្ទោបង់នូវសេចក្ដីប្រមាទបាន បានជាព្រះយោគីអ្នកប្រាថ្នាសេចក្ដីស្ងប់ ច្រើនតែអាស្រ័យក្នុងព្រៃជាទីស្ងាត់គួរដល់កាយវិវេក ដែលជាបច្ច័យឱ្យកើតចិត្តវិវេកនិងឧបធិវិវេកជាលំដាប់នោះឯង ។

តែព្រះយោគាវចរដែលអាស្រ័យនៅក្នុងទីសេនាសនៈដ៏ស្ងាត់ គប្បីជាអ្នកស្ងាត់កាយផង ស្ងាត់ចិត្តនិងស្ងាត់ទាំងកិលេសផង ទើបឈ្មោះថាបានសម្រេចប្រយោជន៍តាមអរិយប្បវេណី បើកាយនៅក្នុងព្រៃតែចិត្តត្រេចទៅស្វែងរកកាមក្នុងស្រុក ក៏មិនសម្រេចប្រយោជន៍ទេ ។

ព្រះយោគាវចរអ្នកនៅក្នុងព្រៃ គប្បីបង្អោនចិត្តគិតតាមន័យដែលព្រះបរមសាស្ដារបស់យើង កាលទ្រង់កំពុងប្រព្រឹត្តទុក្ករកិរិយានៅឡើយ ទ្រង់រំពឹងឃើញច្បាស់ដោយសេចក្ដីឧបមា ៣ យ៉ាងគឺ

១- សមណៈព្រាហ្មណ៍ពួកណាមួយ ដែលមានកាយមិនបានចៀសចេញចាកកាមនៅមានសេចក្ដីស្រឡាញ់ពេញចិត្តក្នុងកាម មិនទាន់លះឱ្យស្ងប់រម្ងាប់បានដោយល្អនៅឡើយ. សមណៈព្រាហ្មណ៍អម្បាលនោះ ទោះបីបានទុក្ខវេទនា

www.elibraryofcambodia.org

ដ៏រឹងក្លាផ្សាក្តៅដែលកើតពីសេចក្តីព្យាយាមក្តី មិនបានក្តី ក៏មិនគួរនឹងត្រាស់ដឹង ដូចឈើស្រស់ដែលជោកដោយជ័រ ហើយបុគ្គលត្រាំទុកក្នុងទឹកថែមទៀត. បុគ្គលដែលត្រូវការភ្លើង ក៏កាន់យកឈើពំនូតទៅពួតដោយសង្ឃឹមថានឹងកើតភ្លើង បុគ្គលនោះមិនអាចនឹងធ្វើភ្លើងឱ្យកើតឡើងបាន. បើបរេសតែពួកទៅមុខជាទ្បើយហត់ឥតអំពើ ព្រោះឈើនោះនៅស្រស់មានជ័រ ហើយថែមទាំងត្រាំទឹកទៀត :

២- សមណៈព្រាហ្មណ៍ពួកណាមួយ ទោះបីមានកាយបៀសចេញចាកកាមហើយ តែនៅមានសេចក្តីស្រឡាញ់ពេញចិត្តក្នុងកាមនៅឡើយ មិនទាន់លះឱ្យស្ងប់រម្ងាប់បានដោយល្អ. សមណៈព្រហ្មណ៍អម្បាលនោះ ទោះបីបានរងទុក្ខវេទនាដ៏រឹងក្លា ដែលកើតអំពីសេចក្តីព្យាយាមក្តី មិនបានរងក្តី ក៏មិនគួរនឹងត្រាស់ដឹងទេ ដូចឈើស្រស់ដែលជោកដោយជ័រ សូម្បីបុគ្គលដិកល់ទុកលើគោកឱ្យឃ្លាតឆ្ងាយពីទឹកហើយ ក៏បុរសមិនអាចពួតឱ្យកើតភ្លើងបាន បើបរេសតែពួត មុខជាឡើយហត់ឥតអំពើ ព្រោះឈើនោះដិកល់ទុកនៅលើគោកមែនហើយ តែនៅជារបស់ស្រស់មានជ័រនៅឡើយ.

៣- សមណៈព្រាហ្មណ៍ពួកណាមួយ មានកាយបៀសចេញចាកកាមហើយ ទាំងសេចក្តីស្រឡាញ់ពេញចិត្តក្នុងកាម ក៏លះបង់ឱ្យស្ងប់រម្ងាប់ល្អហើយ សមណៈព្រាហ្មណ៍អម្បាលនោះ ទោះបីបានរងទុក្ខវេទនាដូច្នោះ ដែលកើតពីសេចក្តីព្យាយាមក្តី មិនបានរងក្តី ក៏គួរនឹងត្រាស់ដឹងបាន ដូចឈើក្រៀមដែលឃ្លាតឆ្ងាយចាកទឹក ហើយបុគ្គលដិកល់ទុកលើគោក ទើបបុរសអាចពួតឱ្យកើតភ្លើងបាន ព្រោះជារបស់ស្ងួត ហើយថែមទាំងនៅលើគោកទៀតផង ។

កាលបើព្រះយោគាវចរបាន បង្អោនចិត្តគិតរំពឹងពិចារណាតាមសេចក្តី

ឧបមា ៣ យ៉ាងដែលព្រះបរមគ្រូ ទ្រង់ធ្លាប់បានពិចារណាដូចពោលមកនេះ មុខជានឹងឃើញថា ការដែលខ្លួននៅអាស្រ័យក្នុងព្រៃស្ងាត់នោះ លុះតែស្ងាត់ទាំងកាយទាំងចិត្តនិងស្ងាត់ទាំងកិលេស ទើបវិសេសតាមអរិយប្បវេណីមែន ។

បើកាយនៅក្នុងព្រៃស្ងាត់ហើយ ប៉ុន្តែមិនបានឃាត់ចិត្តឱ្យស្ងាត់ចាកកិលេសកាមទេ បណ្ដោយឱ្យចិត្តប្រព្រឹត្តទៅតាមអំណោចវិតក្កៈទាំង ៣ គឺ កាមវិតក្កៈ ( សេចក្ដីត្រិះរិះក្នុងកាម គឺរូប សម្លេង ក្លិន រស សម្ផស្ស ) ព្យាបាទវិតក្កៈ ( សេចក្ដីត្រិះរិះចងគំនុំនិងអ្នកដទៃ ) វិហិំសាវិតក្កៈ ( សេចក្ដីត្រិះរិះប៉ងនឹងបៀតបៀនអ្នកដទៃ ) ក៏មិនវិសេសជាងអ្នកនៅចម្រើនសមណធម៌ក្នុងស្រុក ដែលគេស្ងាត់ ចាកកិលេសកាមនោះប៉ុន្មានទេ ដូចព្រះថេរៈមួយអង្គឈ្មោះមេឃិយៈ ដែលទៅនៅក្នុងព្រៃមិនបានសម្រេចគុណវិសេសអ្វីឡើយ ព្រោះតែលុះអំណាចវិតក្កៈទាំង ៣ នោះ លុះត្រឡប់មកនៅក្នុងស្រុកវិញ បានស្ដាប់ធម្មិកថា ដែលព្រះបរមសាស្ដាទ្រង់សម្ដែងក្នុងវត្តជេតពន ទើបបានសម្រេចព្រះអរហត្ត ក្នុងទីនោះឯង ។

សូមនាំរឿងព្រះមេឃិយត្ថេរនោះ មកសំដែងដោយសង្ខេប ដូចតទៅនេះ:

## រឿងព្រះមេឃិយត្ថេរ

កាលដែលព្រះអានន្ទត្ថេរ មិនទាន់បានទទួលឋានៈជាពុទ្ធុបដ្ឋាកនៅឡើយ ព្រះមេឃិយត្ថេរលោកជាពុទ្ធុបដ្ឋាក បំរើព្រះដ៏មានព្រះភាគតែសព្វថ្ងៃ ។ វេលាមួយលោកបានទៅឃើញអម្ពវ័ន ( ព្រៃស្វាយ ) ជារមណីយដ្ឋាន ក៏ក្រាបបង្គំលាព្រះអង្គបម្រុងទៅចម្រើនសមណធម៌ក្នុងទីនោះ ។ ព្រះបរម-សាស្ដាទ្រង់ឃាត់ថា "ចូរអ្នកបង្អង់ចាំមានភិក្ខុដទៃមកជាឧបដ្ឋាកតថាគតសិនសិមទៅចុះ" ។ ព្រះមេឃិយៈទូលទាស់ថា "បពិត្រព្រះអង្គបានសម្រេច

សមណកិច្ចហើយ ខ្ញុំព្រះអង្គមិនសម្រេច មានកិច្ចត្រូវធ្វើតទៅ ។ ទូលដូច្នេះហើយក៏ចៀសចេញទៅ ។

លុះទៅនៅក្នុងអម្ពវ័ននោះ ត្រូវអកុសលវិតក្កៈគ្របសង្កត់ចិត្ត អផ្សុកចិត្តទៅមិនបានក៏ត្រឡប់មកគាល់ព្រះបរមគ្រូវិញ ហើយក្រាបបង្គំទូលតាមដំណើរ ។ ព្រះអង្គត្រាស់ព្រះគាថានេះថា :

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ
វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។

សេចក្តីថា: អ្នកមានប្រាជ្ញាតែងពត់ចិត្តដែលញាប់ញ័រឃ្លេងឃ្លោង រក្សាបានដោយកម្រ ឃាត់បានដោយកម្រឱ្យជាចិត្តត្រង់ទៅបានដូចជាងព្រួញធ្វើព្រួញពត់តម្រង់ព្រួញឱ្យត្រង់នោះឯង ។ ធម្មតាវារីជាតិ (សត្វកើតក្នុងទឹកមានត្រីជាដើម) ដែលបុគ្គលស្រង់ឡើងផុតពីក្នុងទឹកហើយគ្រវែងចោលទៅលើគោក តែងបម្រះទន្ទៀល យ៉ាងណាមិញ. ចិត្តនេះដែលយោគាវចរលើកឱ្យផុតពីទឹកធ្លាប់នៅ គឺកាមគុណ ៥ ហើយបោះទៅលើគោក គឺវិបស្សនាកម្មដ្ឋានបម្រុងនឹងលះបំណងមារ ក៏រមែងញាប់ញ័រដូច្នោះដែរ ។

នាំរឿងនេះមក ដើម្បីបញ្ជាក់ឱ្យឃើញច្បាស់ ថាការដែលព្រះយោគីអាស្រ័យក្នុងព្រៃជាទីសេនាសនៈដ៏ស្ងាត់ គួរឱ្យស្ងាត់ទាំងកាយទាំងចិត្ត គឺត្រូវញុំាងចិត្តឱ្យស្ងាត់ចាកឧបក្កិលេសផង ទើបឈ្មោះថាបានទទួលមតិក គឺការទៅក្នុងទីសេនាសនៈដ៏ស្ងាត់ដែលព្រះបរមគ្រូទ្រង់សព្វព្រះហឫទ័យ ហើយទ្រង់

www.elibraryofcambodia.org

ប្រទានទុកឱ្យនោះ ដោយប្រពៃ ។

ប៉ុន្តែយោគីបុគ្គលដែលនៅអាស្រ័យក្នុងព្រៃ ជាទីសេនាសនៈដ៏ស្ងាត់ ចម្រើនធម៌ហើយ មិនត្រូវអួតខ្លួនថាខ្លួនគ្រាន់បើជាងសិក្ខាកាមកុលបុត្រ ដែលសិក្សាព្រះបរិយត្តិធម៌ក្នុងស្រុក ហើយពោលបង្អោនគេដោយវោហារផ្សេងៗឡើយ ។ បើយោគីណាពោលអួតខ្លួនឯងបង្អាប់គេ យោគីនោះបានឈ្មោះថាជា អសប្បុរស ព្រោះក្នុងសប្បុរិសាសប្បុរិសសូត្រសំដែងថា បុគ្គលដែលបានប្រព្រឹត្ត ឬបានសម្រេចធម៌ដល់ថ្នាក់ណាមួយហើយ ទោះបីថ្នាក់ខ្ពស់យ៉ាងណាក្តី បើពោលអួតខ្លួនឯងបង្អាប់គេដែលបានប្រព្រឹត្ត ឬបានសម្រេចធម៌ថ្នាក់ទាបជាងខ្លួន បុគ្គលនោះឈ្មោះថាជា អសប្បុរសដោយពិត ។

ឯសិក្ខាកាមកុលបុត្រដែលបានសិក្សាព្រះបរិយត្តិធម៌ក៏ដូចគ្នា បើបានសិក្សាព្រះបរិយត្តិធម៌ដល់ថ្នាក់ណាមួយហើយ បើពោលអួតបង្អាប់អ្នកដែលទៅចម្រើនធម៌ក្នុងព្រៃ ក៏ឈ្មោះថាជាអសប្បុរស ដែរ ។

## ២៩_អានិសង្សខ្មោច

មនុស្សសត្វដែលកើតមកក្នុងលោក រមែងត្រូវទុក្ខ ៤ កងគ្របសង្កត់:

១_ ជាតិទុក្ខ ទុក្ខព្រោះកើត.

២_ ជរាទុក្ខ ទុក្ខព្រោះចាស់.

៣_ ព្យាធិទុក្ខ ទុក្ខព្រោះឈឺ.

៤_ មរណទុក្ខ ទុក្ខព្រោះស្លាប់.

www.elibraryofcambodia.org

បណ្ដាទុក្ខទាំង ៤ គងនោះ ទុក្ខព្រោះស្លាប់ ជាទុក្ខធំខ្លាំងជាងគេទាំងអស់ ព្រោះគ្មាននរណាម្នាក់ចង់ស្លាប់សោះ ចង់តែរស់គ្រប់គ្នា ទោះបីស្លាប់ខ្លួនឯងឬស្លាប់ប្រពន្ធ-កូន-ម្ដាយ ឪពុក បង-ប្អូន ជីដូន-ជីតា មា មីង ញាតិសន្ដាន ក៏កើតទុក្ខទាំងអស់គ្នា ប្លែកតែខ្លាំងនិងតិចប៉ុណ្ណោះ ។

វៀរតែព្រះអរិយបុគ្គល ដែលបានសម្រេចព្រះអរហត្តជាព្រះអរហន្តអស់កិលេសតណ្ហាហើយ ទើបលោកមិនខ្លាចស្លាប់លោកត្រឡប់ជាខ្លាចកើតវិញ ព្រោះលោកយល់ថា កើតនាំឱ្យចាស់ នាំឱ្យឈឺ នាំឱ្យស្លាប់ ស្លាប់ហើយកើត. កើតហើយស្លាប់ សារចុះសារឡើង វិលវល់ក្នុងវដ្ដសង្សារ ។

ឯមនុស្សបុថុជ្ជន មានកិលេសក្រាស់ គ្មាននរណាម្នាក់មិនខ្លាចស្លាប់ទេ ទោះបីជាមនុស្សពិការពិរាយយ៉ាងណាក៏ចង់រស់ដែរ ។

សេចក្ដីស្លាប់ បើប៉ះពាល់លើគ្រួសារណាមួយហើយ គ្រួសារនោះ តែងតែមានទុក្ខព្រួយយ៉ាងក្រៃលែង រកអ្វីប្រៀបពុំបាន ។

ក្នុងពេលមរណទុក្ខមកគ្របសង្កត់លើគ្រួសារណា គ្រួសារនោះរមែងតែនឹកដល់ញាតិមិត្ត ចង់ឱ្យគេមកជួយសម្រាលទុក្ខទំនុកបម្រុងបុណ្យសពរបស់ខ្លួន ។ បើមានញាតិមិត្តមកជួយឈឺឆ្អាលផង គ្រួសារនៃសពនោះតែងមានចិត្តសោមនស្សនឹកអរគុណគេជាខ្លាំង ហាក់ដូចជាគេមកជួយរំលែកសេចក្ដីទុក្ខឱ្យធូស្រាលខ្លះ ។ ហេតុហ្នឹងហើយបានជាលោកសំដែងថា សប្បុរសជនដែលមានចិត្តសទ្ធា និងមេត្តាបានឈឺឆ្អាលសម្រាលទុក្ខគេក្នុងបុណ្យសព គឺបុណ្យខ្មោច បានអានិសង្សច្រើនណាស់ ដោយហេតុ ២ យ៉ាងគឺ

១-ដោយជួយរំលែកទុក្ខគ្រួសារនៃសព.

២-ដោយកើតសេចក្ដីសង្វេគ.

ហេតុទី ១ ដែលថាអ្នកបានជួយឈឺឆ្អាល ជួយរំលែកសេចក្ដីទុក្ខជួយ ទំនុកបំរុងបុណ្យសព បានផលច្រើននោះ ព្រោះគេធ្វើត្រូវលើសង្គហវត្ថុ ៤ យ៉ាងគឺ :

១- **ទាន** ការឱ្យទាន គឺបានចូលចាប់កុសលក្នុងបុណ្យសព.

២- **បិយវាចា** បានពោលពាក្យល្អ គឺបានជួយសូត្រធម៌ជាដើម.

៣- **អត្ថចរិយា** ភាពជាមិត្តល្អ គឺបានជួយឈឺឆ្អាលមិត្ត.

៤- **សមានត្តតា** ភាពជាអ្នកមានជីវភាពស្មើ គឺទុកការព្រួយរបស់ មិត្តដូចទុក្ខព្រួយរបស់ខ្លួន ។

ជនដែលបានជួយឈឺឆ្អាលសម្រាលទុក្ខ ដល់អ្នកដែលមានទុក្ខរមែង មានគេជួយឈឺឆ្អាលខ្លួនវិញ ទាំងជាតិនេះទាំងជាតិមុខ ព្រោះការជួយនោះ ត្រូវនឹងខេមរសុភាសិតថា "ចិត្តជាទាន់គ្រាក្រ សប្បុរសល្អទាន់ខែកត្តិក" ហើយត្រូវនឹងពុទ្ធភាសិតថា "អ្នកធ្វើអំពើល្អ តែងបានទទួលផលល្អ" នេះឯង ។

ហេតុទី ២ ដែលថា ការជួយបុណ្យសពកើតសេចក្ដីសង្វេគបានផល ច្រើននោះ ព្រោះសេចក្ដីសង្វេគ ជាប្រភពនៃបុណ្យ ដូចលោកពោលថា ហេតុ កើតបុណ្យមាន ៣ យ៉ាងគឺ

១. **បសាទោ** សេចក្ដីជ្រះថ្លា.

២. **សំវេគោ** សេចក្ដីស្លុតចិត្ត.

៣. **ឆេសុចរិតា** សេចក្ដីប្រព្រឹត្តល្អដោយទ្វារទាំង ៣ គឺកាយ វាចា ចិត្ត ។

បណ្ដាហេតុកើតបុណ្យ ៣ យ៉ាងនេះ ត្រង់ហេតុទី ២ ថាសំវេគោ សេចក្ដីស្លុតចិត្តក្នុងបុណ្យសពនោះ ត្រូវជាទីបំផុត ព្រោះធម្មតាមនុស្សឃើញសព បានជួយបុណ្យសពនោះ បើមិនសង្វេគច្រើនក៏តិចដែរ អ្នកដែលសង្វេគតិច ឬឆាប់បានផលតិច សង្វេគច្រើនឬយូរ បានផលច្រើន ប៉ុន្តែអ្នកដែលឃើញសាកសព ឬឃើញគេហែសព ជួនកាលសង្វេគជួនកាលមិនសង្វេគក៏មាន អ្នកដែលមិនសង្វេគ ព្រោះគេមិនគិតដល់ព្រះត្រៃលក្ខណ៍ គឺ **អនិច្ចំ ទុក្ខំ អនត្តា** បើគិតដល់ព្រះត្រៃលក្ខណ៍គង់មានសង្វេគខ្លះពុំខាន ។

ការគិតដល់ត្រៃលក្ខណ៍សញ្ញា អសុភសញ្ញា សង្វេគសញ្ញា សូម្បីតែមួយស្របក់ ក៏បានជាឧបនិស្ស័យ អាចញុំាងអនាគតរបស់ខ្លួនឱ្យបានសម្រេចមគ្គផល ដូចរឿងព្រះចូឡបន្ថកត្ថេរ ដែលបានសម្រេចមគ្គផល ព្រោះឧបនិស្ស័យនៃការគិតដល់សញ្ញាទាំង ៣ នោះ តែមួយស្របក់ពីបុព្វជាតិ ។

## រឿងព្រះចូឡបន្ថកត្ថេរ

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជរមាន៍នៅឡើយ មានព្រះថេរៈមួយអង្គឈ្មោះ ចូឡបន្ថកៈ ជាប្អូនព្រះមហាបន្ថកៈ ។ ព្រះថេរៈជាបងចង់ឱ្យប្អូនរេះ . .

ដឹងធម៌វិន័យ ក៏ដាស់តឿនឱ្យខំរៀន តែទោះបីព្រះចូឡបន្ថកៈខំរៀនយ៉ាង ណាក៏មិនចាំសោះ ព្រោះមានពាំនៀវកាលពីជាតិមុនលោកជាអ្នកចេះដឹង បាន និយាយបន្ទះបង្អាប់ភិក្ខុល្ងង់ ។

ថ្ងៃមួយ គហបតីម្នាក់ បាននិមន្តព្រះសម្មាសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃ ច្រើនរូប មានព្រះមហាបន្ថកៈជាដើមទៅឆាន់ ។ ព្រះមហាបន្ថកៈមានឋានៈ ជាភត្តុទ្ទេសក៍ គឺអ្នកចាត់ភិក្ខុឱ្យទៅឆាន់ តាមចំនួនដែលទាយកនិមន្ត គ្រានោះ ព្រះមហាបន្ថកៈមិនចាត់ព្រះចូឡបន្ថកៈឱ្យទៅទេ ។

វេលាព្រះមហាបន្ថកៈ និងភិក្ខុឯទៀតទៅហើយ. ព្រះចូឡបន្ថកៈខឹង ណាស់ ដើរចេញតាមទ្វារវត្តទៅក្រៅ ប្រាថ្នានឹងសម្លាប់ខ្លួន ។ ព្រះពុទ្ធជា អម្ចាស់ទ្រង់ជ្រាប ទ្រង់យាងទៅឈរស្ទាក់ពីមុខ ។ ដោយទ្រង់ជ្រាបថា កាល ពីជាតិមុនព្រះចូឡបន្ថកៈ កើតជាព្រះរាជាមួយព្រះអង្គវេលាទ្រង់យាង ប្រទក្សិណព្រះនគរ ទ្រង់បែកញើស ចេញជោកព្រះភក្ត្រ ទ្រង់យកកន្សែងថ្មី សស្អាតជូតញើស ជូតមួយរំពេចក៏ប្រឡាក់មន្ទិលភ្លាម ទ្រង់ពិចារណាថា "ឱ! រូបកាយរបស់មនុស្សសត្វ ជាទីប្រជុំចុះនូវធូលី" ហើយទ្រង់នឹកសង្វេគស្លុតព្រះ ទ័យជាខ្លាំង ។ ព្រះរាជានោះ គឺព្រះចូឡបន្ថកៈនេះឯង ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបឧបនិស្ស័យនេះ ទ្រង់ហុចកន្សែងដៃតូច ១ ទៅព្រះចូឡបន្ថកៈ ដោយព្រះបន្ទូលថា "ចូរអ្នកយកកន្សែងនេះទៅកាន់ឈ្មី ហើយភាវនាថា "រជោហរណំ ជាទីប្រជុំចុះនៃធូលី" ។

ដោយឧបនិស្ស័យ ដែលកាលពីបុព្វជាតិបានគិតសង្វេគដល់រូបកាយតែ

www.elibraryofcambodia.org

មួយស្របក់ប៉ុណ្ណោះ. ព្រះចូឡបន្ថកៈយកកន្ទេលទៅកាន់ឈើពីរបីបោះតែមួយស្របក់ ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងអភិញ្ញាសមាបត្តិ ៦ មានមនោយិទ្ធិ (ឫទ្ធិសម្រេចតាមចិត្តអាចនិម្មិតរូបកាយជារឿក៏បាន) ជាដើម ហើយលោកនិម្មិតជាភិក្ខុពេញវត្ត ។

វេលាព្រះពុទ្ធជាម្ចាស់ យាងទៅដល់ផ្ទះគហបតី ទ្រង់មានព្រះបន្ទូលឱ្យទៅនិមន្តព្រះចូឡបន្ថកៈមក. លុះអ្នកបម្រើទៅនិមន្ត ឃើញភិក្ខុមីរដេរដាសពាសពេញវត្ត អង្គខ្លះធ្វើនេះ អង្គខ្លះធ្វើនោះ. សួរថា "លោកម្ចាស់អង្គណាឈ្មោះចូឡបន្ថកៈ?" ។ ភិក្ខុទាំងនោះឆ្លើយថា "អាត្មាឈ្មោះ ចូឡបន្ថកៈៗ" ទាំងអស់ ។ អ្នកបម្រើមិនដឹងជានិមន្តអង្គណា ក៏ទៅក្រាបទូលវិញតាមដំណើរនោះ ។ ព្រះអង្គមានព្រះបន្ទូលថា "ចូរទៅម្តងទៀត បើឮឈ្មោះថា ចូឡបន្ថកៈ គ្រប់រូបត្រូវចាប់ដៃ ១ រូបឱ្យជាប់ហើយនិមន្តមកចុះ បានហើយ" ។ លុះអ្នកបម្រើទៅនិមន្តម្តងទៀត ចាប់ដៃភិក្ខុ ១ រូបតាមព្រះពុទ្ធដីកា ភិក្ខុនិម្មិតទាំងប៉ុន្មាន ក៏បាត់អស់ នៅសល់តែព្រះចូឡបន្ថកៈមែនទែន ១ រូប ហើយអ្នកបម្រើនិមន្តលោកឆាន់ជាមួយភិក្ខុទាំងពួង ។

លុះសម្រេចភត្តកិច្ចហើយ ព្រះពុទ្ធជាម្ចាស់ត្រាស់ប្រើព្រះចូឡបន្ថកៈឱ្យសំដែងធម៌អនុមោទនាទាន ។ ព្រះចូឡបន្ថកៈ ក៏សំដែងធម៌អនុមោទនាយ៉ាងពិរោះអស្ចារ្យ ទាំឱ្យពុទ្ធបរិស័ទបានស្តាប់នៅពេលនោះ ស្ញើចសរសើរយ៉ាងក្រៃលែង ។

សេចក្តីអស្ចារ្យទាំងនេះ កើតមកពីការគិតពិចារណាដល់សេចក្តីមិនស្អាត

របស់រូបកាយ ហើយមានសេចក្ដីសង្វេគស្លុតចិត្តមួយស្របក់ ក្នុងជាតិមុន នោះឯង ។

ហេតុនេះ សាធុជនអ្នកបានឃើញសព បានជួយទំនុកបម្រុងបុណ្យសព បានជួយហែរសពវេលាណា គួរគិតពិចារណាឱ្យកើតត្រៃលក្ខណសញ្ញា អសុភសញ្ញា និងសង្វេគសញ្ញាវេលានោះ ទោះបីតិចក្ដីច្រើនក្ដី ក៏ឱ្យបានខ្លះកុំខាន. គ្រាន់បានជា ឧបនិស្ស័យ ដូចព្រះចូឡបន្ថកត្ថេរនោះចុះ ។

## ៣០_អានិសង្សបង្សុកូល

កិច្ចដែលភិក្ខុទាញយកសំពត់ ដោយគិតពិចារណា ឫសូត្រធម៌អនិច្ចា វត សង្ខារា ។ល។ ជាដើម ហៅថា បង្សុកូល ។

តាមវិនយបញ្ញត្តិ សំពត់ដែលភិក្ខុគួរបង្សុកូលយកនោះមាន ២យ៉ាងគឺ:

១-សំពត់សដែលគេចោលនៅគំនរសម្រាម ប្រឡាក់សៅហ្មងដោយអាចម៍ដី ដោយធូលី.

២-សំពត់ស្អប់ដែលគេរុំសាកសពចោលនៅព្រៃស្មសាន ។

បណ្ដាសំពត់ទាំង ២ យ៉ាងនោះ ភិក្ខុបានបង្សុកូលយកសំពត់ណាមួយ មកដេរប៉ះផ្សំគ្នា ធ្វើជាចីវរប្រើប្រាស់ ចីវរនោះហៅថា ចីវរបង្សុកូល គឺចីវរឥតម្ចាស់ ។

កាលព្រះពុទ្ធជាម្ចាស់ទើបនឹងបានត្រាស់ថ្មីៗ ទ្រង់ឱ្យភិក្ខុប្រើតែចីវរបង្សុកូលគ្រប់រូប សូម្បីតែតួព្រះអង្គក៏ទ្រង់ប្រើតែចីវរបង្សុកូលដែរ។ លុះ

ក្រោយមក គ្រូពេទ្យឈ្មោះ កោមារភត្យ ប្រគេនកោសេយ្យពស្ត្រ (សំពត់សូត្រ) ចំពោះព្រះអង្គ ទើបទ្រង់អនុញ្ញាតឱ្យភិក្ខុប្រើប្រាស់គហបតីចីវរ ចីវរមានម្ចាស់ឡើង ។

ព្រោះមានពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ដូចពោលមកនេះ ទើបភិក្ខុជាឧបជ្ឈាយ៍ឬគ្រូសូត្រ តែងបង្រៀនប្រដៅ ដែលហៅថា ផ្តាំនាគជាភាសាបាលីដល់ភិក្ខុបួសថ្មីថា:

បង្សុកូលចីវរំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ អតិរេកលាភោ ខោមំ កប្បាសិកំ កោសេយ្យំ សាណំ ភង្គំ ករណីយំ

ប្រែជាសេចក្តីថា: បព្វជិតត្រូវតែអាស្រ័យនូវបង្សុកូលចីវរ ហើយត្រូវឧស្សាហ៍ធ្វើករណីនេះ ដរាបដល់អស់ជីវិត. តែបើមានអតិរេកលាភគឺលាភច្រើន ភិក្ខុអាចប្រើចីវរដែលកើតពីសាច់សំពត់ ៥ យ៉ាងចុះ គឺខោមពស្ត្រ (សំពត់មកពីខោមប្រទេស) កប្បាសិកពស្ត្រ(សំពត់អំបោះ) កោសេយ្យពស្ត្រ (សំពត់សូត្រ) សាណពស្ត្រ (សំពត់ធ្វៃសម្បក) ភង្គពស្ត្រ (សំពត់មានសាច់លាយចម្រុះ) គឺថា បើគ្មានគហបតីប្រគេនសំពត់ណាមួយ ក្នុងបណ្តាសំពត់ ៥ យ៉ាងនោះទេ ភិក្ខុត្រូវតែប្រើសំពត់បង្សុកូលចីវរ ដរាបដល់អស់ជីវិត ។

បានជាព្រះសម្មាសម្ពុទ្ធទ្រង់ឱ្យភិក្ខុប្រើចីវរបង្សុកូលនោះ ព្រោះហេតុ ២ យ៉ាងគឺ :

១-ព្រោះនាំឱ្យភិក្ខុអ្នកប្រើកើតអប្បិច្ឆតាគុណ គឺសេចក្តីប្រាថ្នាតិច

www.elibraryofcambodia.org

សន្តុដ្ឋិតាគុណ គឺសេចក្តីសន្តោស.

២-ព្រោះពេលព្រះអង្គទើបបានត្រាស់ថ្មីៗ ពុំទាន់មានគហបតីប្រគេនចីវរ ។

# រឿងនាងបុណ្ណទាសី

សូម្បីតួព្រះអង្គក៏ទ្រង់ប្រើចីវរបង្សុកូលដែរ ដូចទ្រង់បង្សុកូលយកសំពត់ស្តប់រុំសពរបស់នាងបុណ្ណទាសី ជាខ្ញុំស្រីគហបតីម្នាក់ ដែលកាលរស់នៅឡើយ នាងខំសន្សំគហាបណៈទិញសំពត់ ១ ត្បូង វេលាទៀបស្លាប់នាងបានផ្តាំគហបតីថា "បើខ្ញុំស្លាប់កាលណា សូមលោកយកសំពត់នេះធ្វើជាស្តប់រុំសពខ្ញុំយកទៅចោលនៅព្រៃស្មសាន" ។ ដល់នាងស្លាប់ គហបតីធ្វើតាមបណ្តាំនោះ ។

ពេលដែលគេយកសពនាងនោះទៅចោលនៅព្រៃស្មសានហើយសពនោះរលួយរលេះ នៅតែរាងឆ្អឹង ព្រះពុទ្ធជាម្ចាស់ទ្រង់បង្សុកូលយកសំពត់ស្តប់នោះ ហើយទ្រង់រកទឹកខ្មែងបោកលាង ។

ខណៈនោះ ព្រះឥន្ទទ្រង់និម្មិតជាស្រះ ១ ថ្វាយព្រះអង្គៗ ទ្រង់បោកទឹកស្រះនោះ ហើយទ្រង់ហាលនៅទីសមគួរមួយ ។ ព្រះឥន្ទទ្រង់យកសំពត់នោះទៅឋានត្រៃត្រឹង្សឱ្យព្រះនាងសុជាតាព្រះមហេសីធ្វើជាចីវរ ហើយយកមកថ្វាយព្រះអង្គៗ ទ្រង់ប្រើចីវរនោះជំនួសចីវរចាស់រហូតមក ។

បណ្តាអង្គរបស់ធមិជាគ្រឿងកំចាត់បង់កិលេសហៅថា ធុតង្គមាន ១៣ ប្រការ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឱ្យភិក្ខុអ្នកត្រូវការប្រព្រឹត្តកំចាត់

www.elibraryofcambodia.org

បង់កិលេសព្យាយាមធ្វើ មានធុតង្គ ១ ឈ្មោះបង្សុកូលិកង្គធុតង្គ ជាធុតង្គរបស់ភិក្ខុអ្នកញ៉ាំស្វែងរកមគ្គផលនិព្វានៈតែងប្រព្រឹត្តដោយវិរិយភាព ។

នៅប្រទេសកម្ពុជាយើង សម័យបូរាណ ព្រះសង្ឃដែលបួលបរិវាសតែងដើរបង្សុកូលលើផ្នូរខ្មោចនៅព្រៃជិតៗ វត្ត ។ ពេលព្រះសង្ឃទៅបង្សុកូលនោះ មានឧបាសកខ្លះយកសំពត់សទៅគ្របលើផ្នូរអ្នកមានគុណឬគ្រួសាររបស់ខ្លួន ឱ្យលោកបង្សុកូលយកទៅធ្វើជាបរិក្ខាររប្រើប្រាស់ ។

ការប្រព្រឹត្តបែបនេះ មកពីលោកយកតាមបែបព្រះពុទ្ធជាម្ចាស់ដែលទ្រង់បង្សុកូលយកសំពត់ស្នប់រុំខ្មោច នាង បុណ្ណទាសី ដូចពោលមកខាងដើមនោះឯង ។

ចប់

# អារម្ភកថា

## ដោយលោក រ៉ាន់ សរ

តាងនាមគ្រួសារលោក **ចាប ពិន** អ្នកនិពន្ធសៀវភៅនេះ នឹងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងសេចក្ដីអំណរអរគុណដល់លោក វេជ្ជបណ្ឌិត **ខ្ញៅ សំរ៉ង** ដែលមានឧត្តមគតិដ៏ប្រសើរសុំយកសៀវភៅនេះទៅថតចំឡងដាក់ក្នុងបណ្ណាល័យអេឡិចត្រូនិច www.elibraryofcambodia.org ហើយយើងខ្ញុំមានចិត្តសោមនស្សរីករាយនឹងជូនសិទ្ធទៅលោកដើម្បីជាប្រយោជន៍សាធារណ។

ការរក្សាទុកសៀវភៅនេះក្នុងបណ្ណាល័យអេឡិចត្រូនិច ជាការធានាទុកស្នាដៃលោកអ្នកនិពន្ធ សៀវភៅនេះ ជាកេរ្ត៍ដំណែល មិនអោយបាត់បង់ អស់កាលជាអង្វែងតទៅ។

ម្យាងទៀតសាធារណជនទូទៅអាចចូលក្នុងបណ្ណាល័យអេឡិចត្រូនិច ដើម្បីអាននឹងរៀនសូត្រពីសៀវភៅនេះដោយសេរី នឹងតាមបំណង។

សូមជូនពរមហាបវរដល់អស់លោកអ្នកទាំងអស់ដែលជាអ្នកផលិត elibraryofcambodia នេះ សូមបានទទួលពុទ្ធពរទាំង ៤ ប្រការគឺអាយុ វណ្ណ សុខ ពល តរៀងទៅ។

យើងខ្ញុំក៏សូមឧទិសកុសលដែលកើតពីការចែកផ្សាយសៀវភៅនេះតាមរយះបណ្ណាល័យអេឡិចត្រូនិចជូនដល់វិញ្ញាណក្ខន្ធលោក **ចាប ពិន** អ្នកនិពន្ធសៀវភៅនេះ សូមលោកបានជួបប្រទះតែសេចក្ដីសុខជាអង្វែងតទៅទោះក្នុងជាតិណាក៏ដោយ៕

សូមសេរីស្វស្ដីកើតមានដល់លោកអ្នកអានទាំងឡាយ!

រ៉ាន់ សរ

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ស្កេន ជា eBook ដោយ **ប៉ៅ ភារម្យ**

មិថុនា ឆ្នាំ ២០១៥

សូមឧទិសកុសល់ជូនដល់វិញ្ញាណក្ខន្ធ **លោក ចាប ពិន**

សូមលោកបានជួបប្រទះតែសេចក្តីសុខទោះក្នុងជាតិណាក៏ដោយ

យើងខ្ញុំសូមថ្លែងអំណរអរគុណ យ៉ាងជ្រាលជ្រៅដល់

**លោក វ៉ាន់ សរ**

ដែលបានផ្ញើសៀវភៅនេះមកយើងខ្ញុំ

សម្រាប់ក្នុងការថែរក្សាទុកនិង ផ្សព្វផ្សាយជាទូទៅ

ដើម្បីបម្រើប្រយោជន៍សាធារណៈ ដោយមិនគិតយកកម្រៃ

សូមអរគុណ

ខ្ញៅ ឃុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org